សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# របបនៃការប្រកាសទោសនៅក្នុងរឿងក្តីព្រហ្មទណ្ឌ

ស្រាវជ្រាវពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣


ស្រាវជ្រាវដោយ៖
និស្សិតឈ្មោះ លោក **អ៊ន់ ប៉ូលិ**
លោក **ណាន សុខត្ថិ**

ណែនាំដោយ៖
លោក **ងីម ស៊ីនៀង**


ថ្នាក់បរិញ្ញាបត្រ ៖ **នីតិសាស្ត្រ**
ជំនាន់ទី២៣

ឆ្នាំចូលសិក្សា ២០១៩
ឆ្នាំសរសេរសារណា ២០២៣

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **អ៊ន់ ម៉ូលិ** និង **ណាន សុខន្តិ** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២៣ នៃ**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ឆ្នាំសិក្សា ២០១៩-២០២៣ ។

សូមលំឱនកាយការគោរពប្រណិបតន៍ និងសំដែងនូវកតញ្ញូតាធម៌ចំពោះ លោកអ្នកមានគុណ ដែលបានលះបង់នូវសាច់ស្រស់ឈាមស្រស់ ផ្តល់កំណើតឲ្យរូបកូន លោកបានលះបង់នូវកម្លាំងកាយកម្លាំងចិត្ត ពុះពារគ្រប់ឧបសគ្គ ត្រជាក់ ក្តៅ វងាយ៉ាងណាមិនរាថយ ខិតខំសព្វគ្រប់បែបយ៉ាង ដើម្បីចិញ្ចឹម បីបាច់ ថែរក្សា អប់រំទូន្មាន ណែនាំកូនឲ្យដើរផ្លូវល្អ ជៀសវាងអំពើអបាយមុខផ្សេងៗ ផ្គត់ផ្គង់ការរស់នៅ ហូបចុកស្លៀកពាក់ ថ្នាក់ថ្នម ចាប់តាំងពីរូបកូនចាប់កំណើតក្នុងផ្ទៃ រហូតដល់កូនធំដឹងក្តីនេះ ហើយលោកទាំងពីរបានប្រឹងប្រែងព្យាយាម ទោះបីនឿយហត់ ឧបត្ថម្ភកូនឲ្យបានសិក្សារៀនសូត្រក្រេបជញ្ជក់យកចំណេះដឹងមកអភិវឌ្ឍខ្លួន តាំងពីថ្នាក់បឋមសិក្សា រហូតដល់បញ្ចប់ថ្នាក់ឧត្តមសិក្សានេះប្រកបដោយមោទកភាពបំផុត។ គុណូបការៈគុណដ៏វិសាលក្រៃលែងរបស់លោកអ្នកមានគុណចំពោះយើងខ្ញុំជាកូនៗ ពិតជាធំធេងណាស់ ពុំមានអ្វីកាត់ថ្លៃបានឡើយ ធ្វើឲ្យកូនៗដឹងគុណ និងចងចាំពុំភ្លេចឡើយចំពោះអនេកប្បគុណរបស់លោកទាំងពីរ ។

យើងខ្ញុំសូមថ្លែងអំណរគុណដល់ឯកឧត្តមសាកលវិទ្យាធិការ **លុយ ចណ្ណា** សាកលវិទ្យាការរង សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក៏ដូចជាលោកគ្រូ អ្នកគ្រូដែលបានផ្តល់នូវចំណេះដឹងសម្រាប់បំភ្លឺផ្លូវឆ្ពោះទៅអនាគតរបស់យើងខ្ញុំទាំងពីរតាំងពីមតេយ្យសិក្សា ដល់ថ្នាក់ឧត្តមសិក្សានេះ ។

ពិសេសយើងខ្ញុំសូមថ្លែងអំណរគុណផងដែរដល់លោកគ្រូ **នឹម ស៊ីនៀង** ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ដឹកនាំ និងណែនាំ ក្នុងដំណើរការសរសេរសារណាបញ្ចប់ការសិក្សារបស់យើងខ្ញុំប្រកបដោយលទ្ធផលប្រសើរក្រៃលែង តាមរយៈការផ្តល់នូវអនុសាសន៍ល្អៗរបស់លោកគ្រូ បានធ្វើឲ្យសារណាមួយនេះមានភាពត្រឹមត្រូវ និងច្បាស់លាស់គួរជាទីពេញចិត្ត ព្រមទាំងបានចែករំលែកនូវបទពិសោធន៍ជាច្រើនដល់យើងខ្ញុំទាំងពីរសម្រាប់អភិវឌ្ឍខ្លួនផងដែរ ។

ជាចុងក្រោយយើងខ្ញុំទាំងពីរនាក់សូមលើកម្រាមដៃដប់គោរពជូនពរ និងបួងសួងទៅកាន់ ទេវតា អារុក្ខ អារក្សអ្នកតា និងវត្ថុស័ក្តិសិទ្ធទាំងឡាយ ជួយតាមថែរក្សាលោកអ្នកមានគុណ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាការរង លោក លោកស្រីសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូទាំងអស់ឲ្យជួបតែពុទ្ធពរទាំងប្រាំប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** និង**បដិភានៈ** កុំបីឃ្លៀងឃ្លាតឡើយ ។

# **អារម្ភកថា**

យើងខ្ញុំ **អ៊ន់ ម៉ូលិ** និង **ណាន សុខន្តិ** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២៣ នៃ **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** សូមក្រាបថ្វាយបង្គំព្រះថេរានុថេរគ្រប់ព្រះអង្គ សូមស្វាគមន៍ចំពោះប្រិយមិត្តអ្នកអាន មិត្តនិស្សិត លោក លោកស្រីសាស្ត្រាចារ្យ និងអ្នកសិក្សាស្រាវជ្រាវទាំងអស់ជាទីគោរពរាប់អាន ។

បន្ទាប់ពីបានសិក្សាទៅលើជំនាញនីតិសាស្ត្ររយៈពេលបួនឆ្នាំមកនេះ និងពិសេសក្រោយពីបានសិក្សាទៅលើមុខវិជ្ជានីតិព្រហ្មទណ្ឌរួចមកនោះ មានចម្ងល់ជាច្រើនបានកើតឡើងនាក្នុងអំឡុងពេលសិក្សារបស់ពួកយើង ។ ដោយសារតែហេតុនេះហើយបានជាយើងខ្ញុំទាំងពីរនាក់បានសម្រេចចិត្តជ្រើសយកប្រធានបទ **របបនៃការប្រកាសទោសនៅក្នុងរឿងក្ដីព្រហ្មទណ្ឌ** នេះឡើងក្នុងគោលបំណងដើម្បីធ្វើការសិក្សាស្រាវជ្រាវ និងស្វែងយល់ឲ្យកាន់តែស៊ីជម្រៅបន្ថែម និងជ្រើសយកជាប្រធានបទសម្រាប់ធ្វើជាអត្ថបទសារណាបញ្ចប់ការសិក្សាផងដែរ ព្រោះថាប្រធានបទនេះ គឺជាដំណាក់កាលមួយដ៏សំខាន់ក្នុងរឿងព្រហ្មទណ្ឌដែលសម្រេចពីជោគវាសនារបស់ពិរុទ្ធជនគ្រប់រូប ។

យើងខ្ញុំទាំងពីរនាក់សូមអភ័យទោស ក៏ដូចជាទទួលយកដោយរីករាយនូវរាល់មតិរិះគន់ទាំងឡាយ ពីសំណាក់ប្រិយមិត្តអ្នកអាន មិត្តនិស្សិត លោក លោកស្រីសាស្ត្រាចារ្យ និងអ្នកសិក្សាស្រាវជ្រាវគ្រប់រូប នូវរាល់កំហុសឆ្គងដោយអចេតនាត្រង់ពាក្យពេចន៍ វេយ្យាករណ៍ វគ្គ ឃ្លា អក្ខរាវិរុទ្ធ ជាពិសេសចំពោះភាពខ្វះចន្លោះនៃអត្ថន័យត្រង់ផ្នែកណាមួយនៃសារណានេះ ដើម្បីជួយកែលម្អ និងបំពេញភាពខ្វះខាតរបស់ពួកយើងឲ្យកាន់តែប្រសើរ និងមានអត្ថន័យគ្រប់គ្រាន់ច្បាស់លាស់នៅពេលក្រោយ ។

ជាចុងក្រោយរូបខ្ញុំទាំងពីរសូមជូនពរដល់ ប្រិយមិត្តអ្នកអាន អ្នកសិក្សាស្រាវជ្រាវ លោក លោកស្រីសាស្ត្រាចារ្យ និងមិត្តនិស្សិតទាំងអស់ឲ្យទទួលបាននូវពុទ្ធពរទាំងបួនប្រការ **សម្បត្តិបី អរិយទ្រព្យប្រាំពីរ** ឲ្យទទួលជោគជ័យក្នុងការសិក្សា និងសម្រេចបំណងប្រាថ្នាគ្រប់ៗគ្នា សូមអរគុណ ។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........ ១

**ជំពូកទី១**

**របបទូទៅនៃការប្រកាសទោស**

**ផ្នែកទី១ គោលការណ៍រួមនៃការប្រកាសទោស** ........ ៣

១. គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ........ ៣

២. គោលការណ៍ឯកត្តកម្មនៃទោស ........ ៤

២.១ ឆន្ទៈខាងក្នុងនៃបុគ្គល ........ ៤

២.២ ឆន្ទៈខាងក្រៅនៃបុគ្គល ........ ៥

**ផ្នែកទី២ ប្រភេទទោសដែលត្រូវប្រកាស** ........ ៦

១ ការប្រកាសមូលទោស ........ ៦

១.១ មូលទោសដែលប្រកាសចំពោះនីតិជន ........ ៧

១.២. ទោសដែលប្រកាសចំពោះអនីតិជន ........ ៨

១.២.១ អនីតិជនដែលមានអាយុក្រោម១៤ឆ្នាំ ........ ៩

១.២.២ អនីតិជនដែលមានអាយុចាប់ពី១៤ឆ្នាំ ដល់ក្រោម១៨ឆ្នាំ ........ ១០

១.៣ វិធានការអនុវត្តចំពោះអនីតិជន ........ ១២

១.៤ ទោសដែលប្រកាសចំពោះនីតិបុគ្គល ........ ១២

២. ការប្រកាសទោសបន្ថែម ........ ១៣

២.១ ទោសបន្ថែមដែលប្រកាសទៅលើនីតិជន ........ ១៤

២.២ ទោសបន្ថែមដែលប្រកាសចំពោះអនីតិជន ........ ១៧

២.៣ ទោសបន្ថែមដែលប្រកាសចំពោះនីតិបុគ្គល ........ ១៨

៣. ការប្រកាសទោសជំនួស ........ ១៩

៣.១ ទោសការងារសហគមន៍ ........ ១៩

៣.១.១ ទោសការងារសហគមន៍សម្រាប់នីតិជន ........ ២០

៣.១.២ ទោសការងារសហគមន៍សម្រាប់អនីតិជន ..............................................២១
៣.៣ ទោសស្ដីបន្ទោស..........................................................................................២១

## ជំពូកទី២
## របបនៃការព្យួរទោស

**ផ្នែកទី១ ការព្យួរទោសធម្មតា** ........................................................................................ ២២
១. លក្ខខណ្ឌនៃការព្យួរទោសធម្មតា ........................................................................ ២២
១.១ លក្ខខណ្ឌទាក់ទងនឹងការផ្ដន្ទាទោសពីមុន .......................................................... ២៣
១.១.១ ចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិម........................................................................ ២៣
១.១.២ ចំពោះបទលហុ.................................................................................................. ២៣
១.២ លក្ខខណ្ឌទាក់ទងនឹងការផ្ដន្ទាទោសនាពេលបច្ចុប្បន្ន............................................. ២៤
១.២.១ ចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិម ...................................................................... ២៤
១.២.២ ចំពោះបទលហុ ................................................................................................. ២៥
២. អានុភាពនៃការព្យួរទោស...................................................................................... ២៥
៣. ការដកហូត និងការមិនដកហូតការព្យួរទោសធម្មតា .............................................. ២៦
៣.១ ចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិម.............................................................................. ២៦
៣.២ ចំពោះបទលហុ...................................................................................................... ២៧
**ផ្នែកទី២ ការព្យួរទោសសាកល្បង**....................................................................................... ២៨
១. លក្ខខណ្ឌ និងអានុភាពនៃការព្យួរទោសសាកល្បង................................................... ២៨
១.១ លក្ខខណ្ឌដែលនាំឲ្យមានការព្យួរទោសសាលល្បង ................................................ ២៨
១.២ អានុភាពនៃការព្យួរទោសសាកល្បង........................................................................ ២៨
២. វិធានការត្រួតពិនិត្យ និងកាតព្វកិច្ចដោយឡែក ........................................................ ២៩
២.១ វិធានការត្រួតពិនិត្យ .............................................................................................. ២៩
២.២ កាតព្វកិច្ចដោយឡែករបស់ទណ្ឌិតជានីតិជន ........................................................ ៣០
២.៣ កាតព្វកិច្ចដោយឡែករបស់ទណ្ឌិតជាអនីតិជន........................................................ ៣១
៣. ការកែប្រែកាតព្វកិច្ចដោយឡែកដោយយុត្តាធិការ.................................................... ៣២
៤ ការដកហូតការព្យួរទោសសាកល្បង.......................................................................... ៣២

## ជំពូកទី៣

## របបនៃការប្រកាសទោសដោយផ្អែកលើគោលការណ៍មនុស្សធម៌


**ផ្នែកទី១ របបនៃការផ្អាកការប្រកាសទោស**.......................................................៣៤

១. លក្ខខណ្ឌនៃការផ្អាកការប្រកាសទោស.......................................................៣៤

១.១ លក្ខខណ្ឌនៃបទល្មើសដែលត្រូវចោទប្រកាន់.......................................................៣៤

១.១.១ ភាពច្របូកច្របល់នៃសណ្តាប់ធ្នាប់សាធារណៈដែលបង្កឡើងដោយបទល្មើសត្រូវបានបញ្ចប់.......................................................៣៥

១.១.២ ជនជាប់ចោទបានបង្ហាញការធានាក្នុងការចូលទៅរួមរស់នៅក្នុងសង្គមវិញ .....៣៥

១.១.៣ ជនជាប់ចោទសុំរយៈពេលដើម្បីជួសជុលការខូចខាត .......................................................៣៥

១.២ វត្តមានជនជាប់ចោទនាពេលសវនាការ .......................................................៣៥

២. សវនាការនៃការផ្អាកការប្រកាសទោស .......................................................៣៦

២.១ កិច្ចពិភាក្សាដេញដោលក្នុងពេលសវនាការ .......................................................៣៦

២.២ សវនាការពិនិត្យរឿងដែលបង្អង់.......................................................៣៦

**ផ្នែកទី២ របបនៃការប្រកាសទោសពាក់កណ្តាលសេរីភាព** .......................................................៣៧

១.លក្ខខណ្ឌនៃរបបពាក់កណ្តាលសេរីភាព.......................................................៣៨

២. បែបបទនៃការអនុវត្ត.......................................................៣៨

៣. ការរៀបចំ និងការលុបចោលរបបពាក់កណ្តាលសេរីភាព.......................................................៣៩

៤.ការចាប់ខ្លួន និងការឃុំខ្លួនទណ្ឌិត.......................................................៤០

**ផ្នែកទី៣ របបនៃការបែងចែកទោសជាប្រភាគ**.......................................................៤១

១ លក្ខខណ្ឌនៃការបែងចែកទោសជាប្រភាគ.......................................................៤១

២.បែបបទនៃការអនុវត្ត.......................................................៤១

៣. ការកែប្រែ ឬការលុបចោលរបបនៃការបែងចែកទោសជាប្រភាគ.......................................................៤២

៤. ការចាប់ខ្លួន និងការឃុំខ្លួនទណ្ឌិត.......................................................៤៣

**សេចក្តីសន្និដ្ឋាន** .......................................................៤៤

**អនុសាសន៍** .......................................................៤៦

**ឯកសារយោង**

# បញ្ជីឧបសម្ព័ន្ធ

# សេចក្តីផ្តើម

# សេចក្ដីផ្ដើម

## ១. បុព្វហេតុនៃការស្រាវជ្រាវ

ព្រះរាជាណាចក្រកម្ពុជា គឺជាប្រទេសដែលធ្លាប់ឆ្លងកាត់នូវនឹមត្រួតត្រារបស់អាណានិគមបារាំងអស់ជិតមួយសតវត្ស ហើយក្រោយពីទទួលបានឯករាជ្យមក កម្ពុជាក៏ក្លាយជាប្រទេសមួយដែលធ្លាប់មានការអភិវឌ្ឍរីកចម្រើនស្ទើរតែគ្រប់វិស័យរហូតទទួលបានរហ័សនាមជា« **គុជនៅអាស៊ី** » កាលពីសម័យសង្គមរាស្ត្រនិយមផងដែរ ។ ប៉ុន្តែភាពដ៏ល្អស្រស់ត្រកាលនេះ ពិតមិនស្ថិតស្ថេរនោះឡើយ ពោលគឺត្រូវបានផ្លាស់ប្តូររបបដឹកនាំរដ្ឋជាច្រើនដំណាក់កាល និងភាពជូរចត់នៃសង្គ្រាមរ៉ាំរ៉ៃជាច្រើនឆ្នាំ ពិសេសពិភពដ៏ខ្មៅងងឹតនៃរបបកម្ពុជាប្រជាធិបតេយ្យដែលបានបំផ្លាញហេដ្ឋារចនាសម្ព័ន្ធ ផ្លូវថ្នល់ សំណង់អគារ ប្រព័ន្ធយុត្តិធម៌ និងបាត់បង់ធនធានមនុស្សស្ទើរតែទាំងស្រុង ។

ជាភ័ព្វសំណាងដោយស្ថិតក្រោមការដឹកនាំរបស់ **សម្តេចតេជោ** កម្ពុជាបានប្រែនូវមុខមាត់ថ្មីពីប្រទេសដែលធ្លាប់តែគ្មានសន្តិភាព ស្ថេរភាពនយោបាយ គ្មានគមនាគមន៍ផ្លូវថ្នល់ សំណង់អគារ ការអភិវឌ្ឍសេដ្ឋកិច្ចធនធានមនុស្ស ប្រព័ន្ធយុត្តិធម៌ជាដើម មកជាប្រទេសដែលមានរបបដឹកនាំមួយច្បាស់លាស់ ផ្លូវថ្នល់ខ្វាត់ខ្វែងធនធានមនុស្ស ការអភិវឌ្ឍគ្រប់វិស័យ និងជាពិសេសគឺ ប្រព័ន្ធច្បាប់ ។ មកដល់បច្ចុប្បន្នយើងសង្កេតឃើញថាមានច្បាប់ជាច្រើនត្រូវបានបង្កើតឡើងសម្រាប់ប្រើដើម្បីគ្រប់គ្រង និងថែរក្សាសណ្តាប់ធ្នាប់របស់សង្គមជាតិជាអាទិ៍រួមមានរដ្ឋធម្មនុញ្ញ១៩៩៣ ក្រមរដ្ឋប្បវេណី ច្បាប់ស្តីពីការងារ ក្រមនីតិវិធីព្រហ្មទណ្ឌ ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក និងកាន់តែពិសេសនោះគឺ ក្រមព្រហ្មទណ្ឌ ។

ក្រមព្រហ្មទណ្ឌ គឺជាអត្ថបទច្បាប់ដែលបង្កើតឡើងដោយការប្រមូលផ្តុំនូវវិធានជាច្រើនបញ្ចូលគ្នាក្នុងគោលបំណងដើម្បីកំណត់បទល្មើស ចង្អុលបង្ហាញពីបុគ្គលដែលត្រូវទទួលខុសត្រូវ កំណត់អំពីទោស បែបបទនៃការប្រកាស និងការអនុវត្តទោសចំពោះទណ្ឌិត ។ មិនតែប៉ុណ្ណោះច្បាប់នេះជាច្បាប់ដែលមានចរិតលក្ខណៈចាប់បង្ខំ និងមានគោលការណ៍ជាច្រើនបានចែងកំណត់យ៉ាងជាក់លាក់ ពិសេសគឺ របបនៃការប្រកាសទោសដែលមានអានុភាពគ្រប់ដណ្តប់ចំពោះគ្រប់បទល្មើសដែលត្រូវដាក់ទណ្ឌកម្ម និងជាដំណាក់កាលដ៏សំខាន់សម្រាប់កំណត់អំពីអនាគតរបស់បុគ្គលដែលប្រព្រឹត្តបទល្មើស ព្រមទាំងអាចឲ្យបុគ្គលជាទណ្ឌិតទាំងនោះអាចកសាងខ្លួនឡើងវិញបាន ។

## ២. ចំណោទបញ្ហានៃការដោះស្រាយ

ដោយសារតែយល់ឃើញថាការប្រកាសទោសនេះមានសារៈសំខាន់ និងប្រយោជន៍ជាច្រើនសម្រាប់បុគ្គល ពិសេសទណ្ឌិតនៃការចោទប្រកាន់ចំពោះបទល្មើសព្រហ្មទណ្ឌ និងឈានដល់ការសម្រេចអំពីទណ្ឌកម្មណាមួយ ប៉ុន្តែការយល់ដឹងនៅក្នុងផ្នែកនេះហាក់នៅមានកម្រិតនៅឡើយ ។ ដើម្បីជាមូលដ្ឋានសម្រាប់នាំផ្លូវក្នុង

ការសិក្សាស្វែងយល់ចំពោះរបបនៃការប្រកាសទោស យើងគួរគប្បីដឹងអំពី អ្វីទៅជាការប្រកាសទោស? មុននឹងឈានដល់ការប្រកាសទោស តើចៅក្រមត្រូវពិចារណាទៅលើអ្វីខ្លះ? ហើយតើមានវិធានការអ្វីខ្លះដែលមានសារៈប្រយោជន៍សម្រាប់ទណ្ឌិត?

## ៣. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

រាប់ចាប់ពីពេលដែលសម្រេចជ្រើសយកប្រធានបទនេះរហូតដល់លទ្ធផលនៃការសរសេរមានលេចជារូបរាងឡើង គឺក្នុងគោលដៅធ្វើការបកស្រាយ និងស្រាវជ្រាវឲ្យកាន់តែលំអិតជាងមុនទៅលើប្រធានបទមួយនេះ។ ការសរសេរនូវអត្ថបទសារណានេះ បានពឹងផ្អែកទៅលើមូលដ្ឋានគ្រឹះដ៏រឹងមាំគឺ ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ សេចក្ដីសម្រេចរបស់តុលាការ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗជាច្រើនទៀតដែលកំពុងស្ថិតនៅជាធរមានក្នុងប្រទេស។ ក្នុងនោះការសរសេរសារណានេះក៏ទទួលបានការចូលរួមពីសំណាក់លោកសាស្ត្រាចារ្យ ពិសេសលោកគ្រូដែលដឹកនាំ អ្នកវិជ្ជាជីវៈច្បាប់ និងសិស្សច្បងក្នុងវិស័យច្បាប់ជាច្រើនជួយជ្រោមជ្រែង ផ្ដល់ជាមតិយោបល់ល្អៗ រហូតធ្វើឲ្យផ្នត់គំនិតនៃការសរសេរ និងការស្រាវជ្រាវមានភាពទូលំទូលាយស្របតាមទិសដៅដែលចង់បាន។

## ៤. សារៈសំខាន់នៃការស្រាវជ្រាវ

ជាធម្មតាយើងសង្កេតឃើញថាមានសៀវភៅមួយចំនួនបានសរសេរបកស្រាយពីគោលការណ៍ជាច្រើនដូចជា ការទទួលខុសត្រូវព្រហ្មទណ្ឌ ទោសព្រហ្មទណ្ឌជាអាទិ៍ ប៉ុន្តែចំពោះបែបបទ និងវិធានការទាក់ទងនឹងរបបនៃការប្រកាសទោសព្រហ្មទណ្ឌ ហាក់មិនទាន់ទូលំទូលាយនៅឡើយ។ ហេតុនេះហើយបានជាក្រុមយើងខ្ញុំជ្រើសយកប្រធានបទ **របបនៃការប្រកាសទោសក្នុងរឿងក្ដីព្រហ្មទណ្ឌ** នេះឡើងមកធ្វើការបកស្រាយឲ្យបានលំអិតជាងមុន ដើម្បីទុកជាឯកសារសម្រាប់ជំនួយស្មារតី ក៏ដូចជាជំនួយដល់ការសិក្សារបស់អ្នកសិក្សាស្រាវជ្រាវច្បាប់ អ្នកចង់ស្វែងយល់អំពីច្បាប់ ជាពិសេសសម្រាប់ជាមូលដ្ឋានមួយរបស់សិស្សប្អូននិស្សិតជំនាន់ក្រោយដែលចង់សិក្សាស្វែងយល់ទៅលើប្រធានបទមួយនេះ ។

## ៥. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សៀវភៅសារណានេះត្រូវបានសិក្សា និងផ្ដោតសំខាន់ទៅលើ **៣ជំពូក** គឺៈ

**ជំពូកទី១. របបទូទៅនៃការប្រកាសទោស**

**ជំពូកទី២. របបនៃការព្យួរទោស**

**ជំពូកទី៣. របបនៃការប្រកាសទោសដោយផ្អែកលើគោលការណ៍មនុស្សធម៌**

# ជំពូកទី១
# របបទូទៅនៃការប្រកាសទោស

# ជំពូកទី១

# របបទូទៅនៃការប្រកាសទោស

យើងបានដឹងរួចហើយថា ការប្រកាសទោសគឺជាដំណាក់កាលដ៏សំខាន់ដែលត្រូវតម្រូវឲ្យចៅក្រមធ្វើការពិចារណាយ៉ាងល្អិតល្អន់ មុននឹងធ្វើការប្រកាសដាក់ទណ្ឌកម្មទៅលើបុគ្គល ដើម្បីធ្វើឲ្យសមស្របទៅនឹងទង្វើក៏ដូចជាស្ថានភាពនៃបទល្មើសដែលបានកើតឡើង។ ទោសនេះទៀតសោធអាចអនុវត្តបានលុះត្រាទោសនោះត្រូវបានប្រកាសដោយចៅក្រម[1] ដែលនេះជាសមត្ថកិច្ចផ្តាច់មុខដែលបានផ្តល់ទៅឲ្យយុត្តាធិការក្នុងការសម្រេចអំពីទោស។ ហេតុនេះហើយនៅក្នុងក្រមព្រហ្មទណ្ឌបានចែងអំពីគោលការណ៍ធំៗចំនួនពីរ ដែលត្រូវបានចាត់ទុកថាជាគោលការណ៍គ្រឹះដែលតុលាការត្រូវយកមកធ្វើជាមូលដ្ឋានមុននឹងវិនិច្ឆ័យទោសនោះគឺ គោលការណ៍ឯកត្តកម្មនៃការទទួលលខុសត្រូវព្រហ្មទណ្ឌ និង គោលការណ៍ឯកត្តកម្មនៃទោស។

## ផ្នែកទី១ គោលការណ៍រួមនៃការប្រកាសទោស

អំពីគោលការណ៍រួមនៃការប្រកាសទោសនេះ ពោលនៅក្នុងក្រមព្រហ្មទណ្ឌបើនិយាយអំពីការប្រកាសទោសគឺត្រូវគោរពតាមគោលការណ៍គ្រឹះសំខាន់ៗរួមមាន គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ដែលមានចែងក្នុងមាត្រា ២៤ នៃក្រមព្រហ្មទណ្ឌ និង គោលការណ៍ឯកត្តកម្មនៃទោស ដែលមានចែងក្នុងមាត្រា ៩៦ នៃក្រមព្រហ្មទណ្ឌ។ លើសពីនេះទៀតយើងគួរគប្បីយល់ដឹងលើគោលការណ៍សំខាន់ៗទាំងនេះជាមុនសិន គឺ គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ(១) និង គោលការណ៍ឯកត្តកម្មនៃទោស(២)។

### ១. គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ

គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ គឺជាគោលការណ៍គ្រឹះដែលត្រូវបានច្បាប់ចែងកំណត់យ៉ាងច្បាស់លាស់សម្រាប់អនុវត្តនៅក្នុងនីតិព្រហ្មទណ្ឌកម្ពុជា។ គោលការណ៍នេះចង់សំដៅលើ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់បុគ្គលម្នាក់ៗចំពោះអំពើផ្ទាល់ខ្លួន[2] មានន័យថាកាលណាបុគ្គលណាមួយបានប្រព្រឹត្តអំពើដែលច្បាប់បានកំណត់ថាវាជាបទល្មើសនោះ បុគ្គលនោះត្រូវទទួលខុសត្រូវដោយខ្លួនឯងចំពោះ ទង្វើនោះ ដោយមិនអនុញ្ញាឲ្យបុគ្គលដទៃក្រៅពីខ្លួនឯងមកទទួលជំនួសឡើយ បើទោះបីជាមូលហេតុណាមួយ ឬ សាច់ញាតិ ជាសហព័ទ្ធ ជាមិត្តភក្តិ ជាអ្នកតំណាងតាមផ្លូវច្បាប់ជាអាទិ៍ក៏ដោយ ព្រោះថាប្រសិនបើអនុញ្ញាតឲ្យមានការទទួលខុសត្រូវជំនួសនោះ នឹងធ្វើឲ្យមានការកើតឡើងនូវបទល្មើសពេលក្រោយជាច្រើន និងធ្វើឲ្យមានភាពចលាចល ភាពអសន្តិសុខ ឬ ភាពរញ៉េរញ៉ៃហើយជនល្មើសគ្មានភាពខ្លាចរអាចំពោះច្បាប់ឡើយ។ ដោយឡែកការកំណត់នេះវាមានភាពផ្ទុយស្រឡះអំពីរឿងក្តីរដ្ឋប្បវេណីដែលអនុញ្ញាតឲ្យបុគ្គលមិនមែនសាមីខ្លួនអាច

---

[1] មាត្រា ៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[2] មាត្រា ២៤ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

ទទួលរ៉ាប់រងជំនួសបាននូវរាល់សំណងការខូចខាតទាំងអស់ មានន័យថាបុគ្គលដែលជាញាតិ ជាសហព័ទ្ធ ឬ អ្នកតំណាង អាចទទួលខុសត្រូវជំនួសជនដែលបង្កបាន។

## ២. គោលការណ៍ឯកត្តកម្មនៃទោស

បន្ទាប់ពីគោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌដែលជាមូលដ្ឋាននៃការកំណត់បុគ្គលឲ្យទទួលខុសត្រូវព្រហ្មទណ្ឌខាងលើ នីតិនិពន្ធបានកំណត់នូវគោលការណ៍ធំមួយទៀតនៅក្នុងក្រមព្រហ្មទណ្ឌដែលសម្រាប់ទុកជាមូលដ្ឋានពិចារណាអំពីទោសផងដែរ នោះគឺគោលការណ៍ឯកត្តកម្មនៃទោស។ គោលការណ៍ឯកត្តកម្មនៃទោស ជាគ្រឹះដ៏រឹងមាំដែលចៅក្រមតែងតែយកជាមូលដ្ឋាននៃការវិនិច្ឆ័យមុននឹងសម្រេចអំពីទោសទៅលើបុគ្គលណាមួយ ដោយបានកំណត់យ៉ាងច្បាស់ថា *តុលាការប្រកាសទោសដោយផ្អែកទៅលើស្ថានទម្ងន់ និងកាលៈទេសៈនៃបទល្មើស ទៅលើបុគ្គលិកលក្ខណៈនៃជនជាប់ចោទ ទៅលើសភាពផ្លូវចិត្ត ទៅលើធនធាននិងបន្ទុក ទៅលើមូលហេតុ ព្រមទាំងទៅលើកិរិយាមារយាទរបស់ជនល្មើស ក្រោយពេលប្រព្រឹត្តបទល្មើល ជាអាទិ៍ចំពោះជនរងគ្រោះ* [3]។ ពិតណាស់មុននឹងធ្វើការសម្រេចផ្តន្ទាទោសលើបទល្មើសនីមួយៗ តុលាការចាំបាច់សិក្សាពីមូលហេតុ និងកត្តាជំរុញដែលនាំឱ្យមានបទល្មើស និងកិរិយាមារយាទក្រោយពេលប្រព្រឹត្តបទល្មើសដោយគោរពនឹងភាពមិនរើសអើង និងស្មើភាពគ្នា ភាពសមាមាត្រនៃទោស និងគោលការណ៍ដោយឡែកដោយផ្អែកលើស្ថានភាពប្រែប្រួលរបស់ជនល្មើសនីមួយៗ។ ផ្ទុយទៅវិញ បើការប្រកាសទោសពុំបានឆ្លងកាត់ការវិនិច្ឆ័យដោយគោរពតាមគោលការណ៍ឯកត្តកម្មនៃទោសទេ ការជំនុំជម្រះលើទោស នឹងនាំឱ្យមានភាពលម្អៀង និងអយុត្តិធម៌។ មិនតែប៉ុណ្ណោះគោលការណ៍នេះប្រគល់ជូនដល់ចៅក្រមនូវអំណាចយ៉ាងទូលំទូលាយ ប៉ុន្តែទោះជាលក្ខណៈណាក៏ដោយក៏អំណាចនេះពុំមែនជាអំណាចផ្តាច់ការដែរ ផ្ទុយទៅវិញវាជាការដែលផ្តល់ឲ្យចៅក្រមនូវហេតុផលតាម រយៈអត្ថបទច្បាប់ ដោយឆ្លងតាមរយៈការកំណត់ខាងលើនេះយើងអាចមើលឃើញនូវស្ថានភាពចំនួនពីរគឺ ឆន្ទៈខាងក្នុងនៃបុគ្គល និងឆន្ទៈខាងក្រៅនៃបុគ្គល។

### ២.១ ឆន្ទៈខាងក្នុងនៃបុគ្គល

ឆន្ទៈខាងក្នុងនៃបុគ្គល ចង់សំដៅដល់ចេតនាផ្ទាល់របស់ចារី ឬ ជាការអត្តនោម័តរបស់ចារីដែលប្រព្រឹត្តបទល្មើសចេញពីចិត្តគំនិត ឬ ការគុំគួន ឬជននោះជាជនដែលមានសតិអារម្មណ៍ស្រើបស្រាល ខ្វះការប្រុងប្រយ័ត្នមានភាពធ្វេសប្រហែស ដែលវាស្តែងចេញដោយភាពកាចសាហាវ ព្រៃផ្សៃ បង្កឲ្យមានការតក់ស្លត់ខ្លាំងដល់សង្គម ឬ ការដឹងកំហុស សោកស្តាយចំពោះអ្វីដែលខ្លួនបានប្រព្រឹត្តជាដើម។ ថ្វីត្បិតតែគ្មានច្បាប់ បទដ្ឋានគតិយុត្ត ឬ អត្ថបទស្រាវជ្រាវណាមួយបានចែងអំពីបញ្ហានេះក៏ដោយ ប៉ុន្តែយើងអាចពិចារណាដោយយោងទៅតាមលក្ខខណ្ឌមួយចំនួនដែលបានកំណត់នៅក្នុងមាត្រា៩៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ហើយស្ថានភាពដែលកើត

[3] មាត្រា៩៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

ឡើងពីលក្ខខណ្ឌខាងលើអាចកើតឡើងដោយសារស្ថានភាពផ្លូវចិត្តរបស់ជនជាប់ចោទមិនប្រក្រតីមិនអាចវិនិច្ឆ័យខុសត្រូវបាន ជាហេតុនាំឱ្យគាត់ប្រព្រឹត្តបទល្មើស ឬ ក្រោយពេលប្រព្រឹត្តបទល្មើសជាអាទិ៍ ដោយគាត់បានបង្ហាញការស្តាយក្រោយ ឬ ព្រមទទួលសារភាពរាល់ទោសកំហុស និងទទួលទោសចំពោះមុខច្បាប់។ ម្យ៉ាងទៀត ប្រសិនបើយើងពុំបានពិចារណាឲ្យបានហ្មត់ចត់ទៅលើចំណុចនេះទេ ការវិនិច្ឆ័យអំពីទោសអាចនឹងមានភាពអយុតិធម៌ចំពោះជនល្មើសផងក៏ថាបាន។ **ឧទាហរណ៍៖** លោក **ក** បានរាយខ្សែភ្លើងពីផ្ទះកាត់តាមដើមស្វាយរបស់ខ្លួនទៅក្រោយផ្ទះដើម្បីតភ្លើងបំភ្លឺស្រះចិញ្ចឹមត្រី ប៉ុន្តែជួនជាពេលមួយមានក្មេងបានមកលួចបេះផ្លែស្វាយរបស់ខ្លួនមិនប្រយ័ត្នប៉ះត្រូវខ្សែភ្លើងបណ្តាលឲ្យឆក់ស្លាប់។ ក្នុងករណីនេះឃើញថាបានធ្វើឲ្យមានមនុស្សស្លាប់ តែបើមើលតាមស្ថានភាពនេះប្រសិនបើជាមិនបានពិចារណាសល្អិតល្អន់ទេអាចភ័ន្តច្រឡំថាគាត់មានបំណងដាក់ខ្សែភ្លើងលើដើមស្វាយដើម្បីឲ្យឆក់ក្មេងដែលមកបេះផ្លែស្វាយនោះ ប៉ុន្តែបើយើងមើលពិនិត្យឲ្យស៊ីជម្រៅទៅគឺគាត់ពុំមានចេតនាសម្លាប់មនុស្សនោះទេ ពោលគោលបំណងធំបំផុតរបស់គាត់គ្រាន់តែ តខ្សែភ្លើងទៅបំភ្លឺស្រះចិញ្ចឹមត្រីប៉ុណ្ណោះ យោងតាមករណីនេះពុំអាចផ្តន្ទាទោសពីបទឧក្រិដ្ឋឃាតកម្ម តាមមាត្រា១៩៩ នោះឡើយ ពោលគឺត្រឹមតែទោសមជ្ឈិមមនុស្សឃាតដោយអចេតនា មាត្រា២០៧ វិញទេ ព្រោះខ្វះធាតុសំខាន់ដែលកំណត់ថាការប្រព្រឹត្តបទល្មើសកើតឡើងដោយចេតនាផ្ទាល់របស់លោក **ក**។

### ២.២ ឆន្ទៈខាងក្រៅនៃបុគ្គល

ឆន្ទៈខាងក្រៅនៃបុគ្គល គឺជាសកម្មភាពណាមួយរបស់ជនល្មើសដែលកំពុងតែបង្ហាញចេញមកខាងក្រៅបន្ទាប់ពីប្រព្រឹត្តបទល្មើស ទៅលើជនរងគ្រោះ ឬ ការប្រព្រឹត្តបទល្មើសដោយចេញពីព្រឹត្តិការណ៍ក្រៅឆន្ទៈណាមួយដែលរុញច្រាន ឬ ដោយសារកត្តាសង្គម សេដ្ឋកិច្ច កត្តាគ្រួសារ និងកម្រិតវប្បធម៌របស់ជនល្មើសជាអាទិ៍។ យ៉ាងណាមិញវាក៏ពុំត្រូវបានរកឃើញនៅក្នុងអត្ថបទច្បាប់ណាមួយចែងជាក់លាក់នោះឡើយ ប៉ុន្តែបើយោងទៅតាមមាត្រា៩៦ ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ដដែលឃើញថា ស្ថានភាពមួយចំនួនអាចនាំឲ្យមានការពិចារណាអំពីឆន្ទៈខាងក្រៅផងដែរ ដូចជាស្ថានទម្ងន់ និងកាលៈទេសៈ ធនធាននិងបន្ទុកជាអាទិ៍ ។ ទាំងនេះគឺសុទ្ធតែជាមូលដ្ឋានសំខាន់ដែលចៅក្រមយកមកពិចារណាមុននឹងធ្វើការសម្រេចយ៉ាងណាផ្តន្ទាទោសឲ្យសមស្របតាម ទង្វើ ឬ សកម្មភាពរបស់ចារី ។ ក្នុងករណីមួយចំនួនការប្រព្រឹត្តបទល្មើសគឺដោយសារតែភាពទាល់ច្រក ឬការប្រព្រឹត្តដើម្បីការពារខ្លួន ការពារទ្រព្យសម្បត្តិ ឬការពារអ្នកដទៃពីការឈ្លានពានណាមួយក្នុងគោលបំណងមិនល្អ ការប្រព្រឹត្តដោយសារស្ថានភាពសង្គមរុញច្រាន ឬ បទល្មើសនោះទៀតសោធមិនមានភាពធ្ងន់ធ្ងរធ្វើឲ្យភ្ញាក់ផ្អើលខ្លាំងដល់សង្គមជាដើម។ **ឧទាហរណ៍១៖** បុគ្គលម្នាក់ដោយសារតែមានបន្ទុកមើលថែម្តាយចាស់ជរា និងមានជំងឺប្រចាំកាយ ដោយចាំបាច់ប្រើប្រាស់ថ្នាំជាប្រចាំ ដោយហេតុថាគ្រួសារមានជីវភាពក្រលំបាកខ្វះលទ្ធភាពទិញថ្នាំដើម្បីព្យាបាលជំងឺម្តាយ ក៏សម្រេចចិត្តចូលលួចថ្នាំពេទ្យទាំងដឹងថាអំពើនេះជាបទល្មើសដែលត្រូវផ្តន្ទាទោស

ដោយច្បាប់។ ក្នុងករណីនេះចៅក្រមអាចយកសកម្មភាពដែលជាមូលហេតុនៃការប្រព្រឹត្តបទល្មើសរបស់ជនល្មើសខាងលើមកពិចារណា ដើម្បីសម្រេចលើកលែងទោស ឬ អាចបន្ធូរបន្ថយនូវផ្នែកណាមួយនៃទោស ឬ ដាក់ទោសក្នុងរបបណាមួយដែលច្បាប់បានអនុញ្ញាតជាអាទិ៍។

## ផ្នែកទី២ ប្រភេទទោសដែលត្រូវប្រកាស

ទោស គឺជាទណ្ឌកម្មដែលត្រូវប្រកាសផ្ដន្ទាដោយអំណាចសាធារណៈ តាមរយៈអង្គការតុលាការ ទៅលើគ្រប់បុគ្គលដែលប្រព្រឹត្តបទល្មើស។ នៅក្នុងក្របខណ្ឌច្បាប់ទោសពុំអាចធ្វើការប្រកាសដោយផ្អែកតាមមនោសញ្ចេតនា ភាពគុំគួនខឹងសម្បារ ឬ ការទាមទារតាមអំពើចិត្តណាមួយឡើយ ពោលត្រូវប្រកាសដោយគោរពតាមគោលការណ៍ដែលច្បាប់បានកំណត់ គឺគោលការណ៍ឯកត្តកម្មនៃបទល្មើស និងនៃទោស មានន័យថា ទាល់តែបទល្មើសដែលប្រព្រឹត្តនោះបានកើតក្នុងអំឡុងពេល ឬ ក្រោយពេលដែលច្បាប់នោះកំពុងនៅជាធរមាន ហើយលុះត្រាបទល្មើស និងទោសនោះផងដែរមានចែងជាក់លាក់ក្នុងច្បាប់ទើបចៅក្រមអាចប្រកាសបាន[4] ហើយគោលការណ៍នេះក៏ត្រូវបានច្បាប់អន្តរជាតិកំណត់បែបនេះដូចគ្នាដែរជាអាទិ៍ សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស មាត្រា១១ និងកតិកាសញ្ញាអន្តរជាតិស្ដីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ យ៉ាងណាមិញបើក្រឡេកមកមើលទោសវិញ ក្រមព្រហ្មទណ្ឌកម្ពុជាបានបានបែងចែកជាបីប្រភេទគឺ មូលទោស ទោសបន្ថែម និងទោសជំនួស ដែលការប្រកាសទោសទាំងបីនេះវាអាស្រ័យលើបម្រែបម្រួលបុគ្គលផ្ទាល់ ពោលគឺ បុគ្គលជារូបវន្តបុគ្គលដែលការទទួលខុសត្រូវគឺអាស្រ័យលើនីតិភាពនៃការទទួលខុសត្រូវ និងបុគ្គលជានីតិបុគ្គល ហើយការប្រកាសនោះទៀតសោធផងដែរត្រូវគោរពទៅតាមលក្ខខណ្ឌដែលចែងដោយច្បាប់។

### ១ ការប្រកាសមូលទោស

មូលទោស សំដៅដល់ទោសចម្បងដែលច្បាប់បានបញ្ញត្តិជាលក្ខណៈសារវន្តសម្រាប់បទល្មើសនីមួយៗដើម្បីប្រកាសដាក់ទៅលើបុគ្គលជាទណ្ឌិតអនុវត្ត។ ហើយសម្រាប់ការប្រកាសមូលទោសនេះ គេអាចយកទៅប្រកាសដាច់តែឯងក៏បាន ឬ បញ្ចូលទោសបន្ថែមត្រួតជាមួយក៏បាន។ មូលទោសរួមមានទោសដាក់ពន្ធនាគារ ( ទោសគុក ) និង ទោសពិន័យជាប្រាក់ ហើយទោសពិន័យជាប្រាក់នេះទៀតសោធត្រូវគិតជាប្រាក់រៀល[5] ពោលគឺជារូបិយវត្ថុព្រះរាជាណាចក្រកម្ពុជា។ ទោសពន្ធនាគារ ឬ ទោសជាប់គុកនេះ ជាទោសដែលទណ្ឌិតត្រូវបានអំណាចសាធារណៈដកហូតសេរីភាព ដោយត្រូវអនុវត្តឃុំក្នុងពន្ធនាគារក្នុងពេលកំណត់មួយ រីឯទោសពិន័យជាប្រាក់ ជាទោសដែលតម្រូវឲ្យទណ្ឌិតបង់ប្រាក់ពិន័យតាមចំនួនកំណត់មួយ។ ប្រាក់ពិន័យនោះត្រូវបង់ចូលជា

[4] មាត្រា៣ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[5] មាត្រា ៤៣ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

ថវិការរដ្ឋ[6] ។ នៅពេលបទល្មើសមួយត្រូវប្រកាសផ្តន្ទាទោសឱ្យជាប់ពន្ធនាគារ ឬ បង់ប្រាក់ពិន័យ ទោសទាំងពីរនេះត្រូវបានច្បាប់កំណត់ជាអតិបរមា និងអប្បបរមានៃទោសដែលត្រូវទទួលរងនោះ[7] ពោលគឺទោសដែលនាំឲ្យវិនាសសេរីភាព មានអត្តិភាពនៅក្នុងបទល្មើសព្រហ្មទណ្ឌដែលក្នុងការកម្រិតជាអតិបរមា ឬ អប្បបរមានេះជាសេរីភាពផ្ទាល់ខ្លួនរបស់ចៅក្រមក្នុងការធ្វើមូលវិចារណ៍ ។ ម៉្យាងទៀតកម្រិតអតិបរមា និងអប្បបរមានៃទោសនេះអាចត្រូវបានបានបន្ថែមទម្ងន់ ឬ សម្រាលទោសដោយថាហេតុ ស្របតាម បុគ្គលិកលក្ខណៈជនល្មើស កាលៈទេសៈនៃបទល្មើស និងលក្ខខណ្ឌដែលច្បាប់បានកំណត់[8] ។

យ៉ាងណាមិញកាលណាបទល្មើសមួយត្រូវបានផ្តន្ទាទោសក្នុងឋានៈជាមូលទោសនោះត្រូវបានគេចែកទោសនោះជាបីកម្រិត គឺទោសឧក្រិដ្ឋ ទោសមជ្ឈិម និងទោសលហុ។ ទោសឧក្រិដ្ឋ គឺជាទោសដែលធ្ងន់ជាងគេហើយកាលណាបទល្មើសមួយត្រូវបានផ្តន្ទាទោសដោយទោសនេះ អតិបរមានៃទោសមានរយៈពេលលើសពី ៥ ( ប្រាំ ) ឆ្នាំ និងក្រោម ឬស្មើនឹង ៣០ ( សាមសិប )ឆ្នាំ ឬ ជាយថាហេតុមួយជីវិត និងអាចបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ[9] ដែលការជាប់ពន្ធនាគារមួយជីវិតនេះគឺ ជាទោសដែលធ្ងន់ធ្ងរជាងគេហើយបន្ទាប់ពីទោសប្រហារជីវិតត្រូវបានលុបចោល[10] ដោយរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ។ បន្ទាប់មកគឺទោសមជ្ឈិម ពោលគឺក្នុងករណីដែលចារីត្រូវបានដាក់ទោសពីបទមជ្ឈិម អតិបរមានៃទោសមានរយៈពេលលើសពី៦ ( ប្រាំមួយ )ថ្ងៃ ដល់ក្រោម ឬស្មើ ៥ ( ប្រាំ ) ឆ្នាំ រួមទាំងអាចបន្ថែមមកជាមួយនឹងទោសពិន័យជាប្រាក់[11] ។ រីឯទោសចុងក្រោយគឺទោសលហុ ដែលអតិបរមានៃទោសនេះមានថិរវេលាស្មើ ឬក្រោម៦ ( ប្រាំមួយ )ថ្ងៃ រួមជាមួយទោសពិន័យជាប្រាក់ ឬ អាចត្រឹមតែជាទោសពិន័យប៉ុណ្ណោះ[12] ។ គួររំលឹកផងដែរថាមូលទោស គឺជាទោសដែលតុលាកាត្រូវប្រកាសដោយស្របតាមបម្រែបម្រួលនៃបុគ្គល និងប្រភេទបុគ្គលក្នុងឋានៈជារូបវន្តបុគ្គល( នីតិជន និងអនីតិជន ) និងក្នុងឋានៈជានិតិបុគ្គល ។

### ១.១ មូលទោសដែលប្រកាសចំពោះនីតិជន

យោងតាមមាត្រា ៣៨ ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ កំណត់ថា នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានកំណត់អាយុចាប់ពី១៨ ( ដប់ប្រាំបី ) ឆ្នាំឡើងទៅ នោះមានន័យថាគ្រប់បុគ្គលជារូបវន្តបុគ្គលទាំងអស់ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌមានលក្ខណៈពេញលេញ ហើយទោសគ្រប់ប្រភេទត្រូវយកមកអនុវត្ត កាលណាជន

---

[6] មាត្រ ៥២ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩
[7] មាត្រា ៤៤ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩
[8] មាត្រា ៤៥ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩
[9] មាត្រា ៤៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩
[10] មាត្រា ៣២ កថាខណ្ឌទី២ នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣
[11] មាត្រា ៤៧ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩
[12] មាត្រា ៤៨ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

នោះមានអាយុតាមការកំណត់នៃមាត្រាខាងលើនេះ។ យ៉ាងណាមិញការប្រកាសទោសត្រូវប្រកាសដោយយោងតាមមាត្រា៩៧ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ដែលបានចែងយ៉ាងជាក់លាក់អំពីរបៀបនៃការប្រកាសមូលទោសចំពោះពិរុទ្ធជនថា ***នៅក្នុងគ្រប់ករណីដែលបទល្មើសត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារផង និង ពិន័យជាប្រាក់ផង តុលាការអាចប្រកាស ដាក់ទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់ជាមួយគ្នា ឬ ទោសពិន័យជាប្រាក់តែមួយមុខប៉ុណ្ណោះ ឬ ទោសពន្ធនាគារតែមួយមុខប៉ុណ្ណោះ***។

- **ជម្រើសទី១** ៖ តុលាការប្រកាសមូលទោស ដាក់ពន្ធនាគារផង និងទោសពិន័យផងរួមជាមួយគ្នា មានន័យថាជនជាប់ចោទត្រូវអនុវត្តទោសក្នុងពន្ធនាគារផង និងទទួលទោសសងជាប្រាក់ផងដែរ ។ **ឧទាហរណ៍៖ បទឆបោក** ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ៣ (បី) ឆ្នាំ និង ពិន័យជាប្រាក់ពី ១.000.000 (មួយលាន) រៀល ទៅ ៦.000.000 (ប្រាំមួយលាន) រៀល [13] ។
- **ជម្រើសទី២** ៖ តុលាការប្រកាសមូលទោស ដាក់ពន្ធនាគារតែមួយ មានន័យថា ជនជាប់ចោទគឺត្រូវទទួលអនុវត្តទោសដូចដែលតុលាការប្រកាស ពោលគឺទទួលអនុវត្តទោសតែជាប់ពន្ធនាគារ។ **ឧទាហរណ៍៖ បទរំលោភសេពសន្ថវៈ** ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ[14]។
- **ជម្រើសទី៣** ៖ តុលាការប្រកាសទោស ពិន័យជាប្រាក់តែមួយមុខ មានន័យថាជនជាប់ចោទគឺត្រូវទទួលអនុវត្តទោសដូចដែលតុលាការប្រកាស ពោលគឺទទួលអនុវត្តទោសពិន័យជាប្រាក់។ **ឧទាហរណ៍៖ បទបរិហាកេរ្តិ៍ជាសាធារណៈ** ត្រូវពិន័ជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល[15] ។

យោងតាមរយៈជម្រើសទាំងបីខាងលើនេះមានន័យថា វាបានផ្តល់លទ្ធភាពជូនចៅក្រមដើម្បីសម្រេចជ្រើសរើសក្នុងក្របខណ្ឌច្បាប់នូវមូលទោសមួយ ឬ ច្រើនដែលមានលក្ខណៈសមរម្យបំផុតដើម្បីប្រកាសដាក់ឲ្យទណ្ឌិតអនុវត្ត ពោលគឺតុលាការអាចប្រកាសទោសគុកដោយត្រួតគ្នាជាមួយនឹងទោសពិន័យក៏បាន ឬ ចៅក្រមប្រើនូវជម្រើសផ្សេងដោយប្រកាសទោសពន្ធនាគារដាច់ដោយឡែកតែមួយមុខ ឬ ប្រកាសទោសពិន័យនោះដាច់ដោយតែមួយមុខក៏បាន ប៉ុន្តែត្រូវធ្វើយ៉ាងណាស្របតាមការពិចារណានៃគោលការណ៍ឯកត្តកម្មនៃទោស ដើម្បីធានាថាការសម្រេចនេះស្របតាមការគ្រោងទុករបស់ច្បាប់ និងប្រកបដោយភាពត្រឹមត្រូវ និងយុត្តិធម៌ផងដែរ ។

### ១.២. ទោសដែលប្រកាសចំពោះអនីតិជន

ក្នុងរឿងព្រហ្មទណ្ឌអនីតិជន សំដៅដល់ជនដែលមានអាយុតិចជាង ១៨ (ដប់ប្រាំបី) ឆ្នាំ នៅពេលប្រព្រឹត្តបទល្មើស[16] ដោយឡែកក្នុងរឿងរដ្ឋប្បវេណីបានឲ្យអត្ថន័យថា អនីតិជន គឺជាជនដែលមិនទាន់គ្រប់អាយុតាម

---

[13] មាត្រា ៣៨៧ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[14] មាត្រា ២៣៩ កថាខណ្ឌ២ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[15] មាត្រា ៣០៥ កថាខណ្ឌ២ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[16] មាត្រា ៤ ចំណុចទី៣ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជនឆ្នាំ២០១៦

ច្បាប់កំណត់ ឬ ជនដែលមានអាយុក្រោម១៨ (ដប់ប្រាំបី) ឆ្នាំ[17] ។ ពិតណាស់អនីតិជនត្រូវបានច្បាប់កំណត់មិនឲ្យទទួលខុសត្រូវព្រហ្មទណ្ឌ ឬ ក៏អាចប្រកាសឱ្យទទួលខុសត្រូវត្រឹមកម្រិតណាមួយរបស់ច្បាប់ដោយអាស្រ័យលើជននោះផ្ទាល់។ នៅទីនេះយើងនឹងធ្វើការពិភាក្សាអំពីរូបវន្តបុគ្គលប្រភេទនេះដោយបែងចែកជាពីរប្រភេទគឺ អនីតិជនដែលមានអាយុក្រោម១៤ឆ្នាំ(១.២.១) និងអនីតិជនដែលមានអាយុចាប់ពី១៤ឆ្នាំ ដល់ក្រោម១៨ឆ្នាំ (១.២.២)។

### ១.២.១ អនីតិជនដែលមានអាយុក្រោម១៤ឆ្នាំ

ជាទូទៅនៅក្នុងច្បាប់ព្រហ្មទណ្ឌកម្ពុជា សម្រាប់អនីតិជនដែលមានអាយុក្រោម១៤ (ដប់បួន)ឆ្នាំ ត្រូវបានលើកលែងឱ្យរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ ហើយគ្មានទោសណាមួយត្រូវបានប្រកាសចំពោះជននេះឡើយ ទោះជាជននោះបានប្រព្រឹត្តបទល្មើសក៏ដោយ។ ប៉ុន្តែយ៉ាងណាមិញយើងពុំឃើញមានអត្ថបទច្បាប់ណាមួយបានកំណត់ជាក់លាក់អំពីបញ្ហានេះទេ តែក្រឡេកមកមើលច្បាប់ស្តីពី យុត្តិធម៌អនីតិជនវិញបានកំណត់ថា អនីតិជនដែលមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំដែលជាប់សង្ស័យថាបានប្រព្រឹត្តបទល្មើស ពុំអាចត្រូវបានគេឃាត់ខ្លួនឡើយ ហើយមន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រគល់អនីតិជននោះឲ្យទៅអ្នកតំណាងច្បាប់បានកំណត់វិញ[18] ។ ក្រមនីតិវិធីព្រហ្មទណ្ឌមាត្រា៩៦ ក៏បានកំណត់មិនឲ្យឃាត់ខ្លួនអនីតិជនដែលមានអាយុក្រោម១៤ (ដប់បួន) ឆ្នាំដែរ។ ដោយឡែកមាត្រា២៧ កថាខណ្ឌទី១ នៃច្បាប់ស្តីពី យុត្តិធម៌អនីតិជនបានចែងថា ក្នុងករណីអនីតិជនដែលមានអាយុក្រោម១៤ (ដប់បួន) ឆ្នាំ គិតត្រឹមថ្ងៃសង្ស័យថាបានចូលរួមប្រព្រឹត្តបទល្មើស នោះព្រះរាជអាជ្ញាត្រូវសម្រេចតម្កល់រឿងទុកឥតចាត់ការ និងត្រូវប្រគល់អនីតិជនទៅឲ្យអ្នកតំណាងដែលច្បាប់កំណត់វិញភ្លាម ។ បន្ថែមលើនេះ ច្បាប់ដដែលនេះបានកំណត់ផងដែរថាអនីជនអាយុក្រោម១៤ (ដប់បួន) ឆ្នាំមិនត្រូវឃុំខ្លួនបណ្តោះអាសន្នឡើយ ។ ក្នុងករណីដែលអនីតិជនដែលកំពុងជាប់ឃុំត្រូវបានរកឃើញថាមានអាយុក្រោម១៤ (ដប់បួន)ឆ្នាំ ចៅក្រមស៊ើបសួរត្រូវចេញដីកាដំណោះស្រាយលើកលែងការចោទប្រកាន់ និងបង្គាប់ឱ្យដោះលែងអនីតិជននោះជាបន្ទាន់ទោះបីមានបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាក៏ដោយ ហើយប្រគល់អនីតិជននោះឱ្យទៅអ្នកតំណាងដែលច្បាប់កំណត់វិញ[19] ។ ម្យ៉ាងទៀតមាត្រា ២១២ ក្រមនីតិវិធីព្រហ្មទណ្ឌក៏បានចែងស្រដៀងនេះដែរ។ អាយុអនីតិជននោះ ត្រូវកំណត់នៅពេលអនីតិជនប្រព្រឹត្តបទល្មើស ហើយភស្តុតាងនៃអាយុរបស់អនីតិជនត្រូវបានបញ្ជាក់ដោយសំបុត្រកំណើត ឬ ឯកសារផ្សេងទៀតដែលអាចបញ្ជាក់បានអំពីកំណើត ប៉ុន្តែបើមិនមានឯកសារ ឬ មានការសង្ស័យ ឬ មិនមានភាពច្បាស់លាស់ទាក់ទងនឹងឯកសារនោះ ភស្តុតាងរបស់អនីតិជនត្រូវ

---

[17] សន្ធនានុក្រមរដ្ឋប្បវេណីលេខ ១៨៧

[18] មាត្រា ១៤ កថាខណ្ឌទី១ នៃច្បាប់ស្តីពិយុត្តិធម៌អនីតិជនឆ្នាំ២០១៦

[19] មាត្រា ៣៩ កថាខណ្ឌទី៣ ច្បាប់ស្តីពីយុត្តិធម៌អនីតិជនឆ្នាំ២០១៦

ផ្តល់តាមមធ្យោបាយផ្សេងទៀតដែលតុលាការអាចជឿទុកចិត្តបាន[20] ។ ហេតុនេះបើទោះបីជាពុំមានអត្ថបទច្បាប់ណាមួយចង្អុលបង្ហាញជាក់លាក់ថាជនដែលមានអាយុក្រោម១៤ (ដប់បួន)ឆ្នាំ មិនទទួលរងទណ្ឌកម្មព្រហ្មទណ្ឌក្តី តែដោយយោងទៅតាមការកំណត់ខាងលើ អាចនាំឲ្យសន្និត់បានថាអនីតិជននេះមិនទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ហើយក៏គ្មានទោសណាមួយអាចប្រកាសមកលើជននេះដែរ ។

យ៉ាងណាមិញថ្វីបើអនីតិជនអាយុក្រោម១៤ (ដប់បួន) ឆ្នាំ សច្ចៈធារណ៍មិនអាចប្រកែកបាននៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌដែលរារាំងមិនឲ្យប្រកាសទោស ប៉ុន្តែមិនរារាំងការចូលខ្លួនមកកាន់តុលាការ និងការប្រកាសសេចក្តីសម្រេចអំពីការស្តីបន្ទោស ឬវិធានការអប់រំទេ ព្រោះថាអនីតិជនដែលប្រព្រឹត្តបទល្មើសគឺជាកម្មវត្ថុនៃវិធានការអប់រំ វិធានការការពារ វិធានការតាមដាន និងវិធានការតាមឧបត្ថម្ភដូចដែលបានកំណត់ក្នុងមាត្រា ៣៩ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ។

### ១.២.២ អនីតិជនដែលមានអាយុចាប់ពី១៤ឆ្នាំ ដល់ក្រោម១៨ឆ្នាំ

អនុលោមតាមក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ចែងថា ***អនីតិជនដែលប្រព្រឹត្តបទល្មើសជាកម្មវត្ថុនៃវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ ។ ប៉ុន្តែតុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី១៤ (ដប់បួន)ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី)ឆ្នាំ ឡើងទៅប្រសិនបើកាលៈទេសៈនៃបទល្មើស ឬ បុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ***[21] ។ ក្នុងករណីនេះមានន័យថា តុលាការអាចប្រកាសទោសព្រហ្មទណ្ឌទៅលើអនីតិជនកាលណាអនីតិជននោះមានអាយុមិនក្រោម១៤ (ដប់បួន)ឆ្នាំ និងមិនលើសពី១៨ (ដប់ប្រាំបី) ឆ្នាំ ប្រសិនបើកាលៈទេសៈនៃបទល្មើសមានលក្ខណៈធ្ងន់ធ្ងរធ្វើឲ្យសាធារណៈជនមានភាពខ្លាចរអា ឬ សភាពលក្ខណៈរបស់បុគ្គលនោះមានភាពកោងកាច សាហាវ ទាំងមុនពេល ក្នុងពេល និងក្រោយពេលប្រព្រឹត្តបទល្មើសជាអាទិ៍ តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជននោះបាន។

ម៉្យាងទៀតកាលណាតុលាការសម្រេចប្រកាសផ្តន្ទាទោសទៅលើអនីតិជនប្រភេទនេះហើយ មូលទោសចំពោះបទល្មើសដែលត្រូវចោទប្រកាន់ត្រូវបានបន្ថយដូចតទៅ អតិបរមានៃទោសដាក់ពន្ធនាគារត្រូវបន្ថយពាក់កណ្តាល ។ ប្រសិនបើអតិបរមានៃទោសនោះគឺជាទោសដាក់ពន្ធនាគារអស់មួយជីវិត អតិបរមាត្រូវបន្ថយមកដាក់ពន្ធនាគារត្រឹមរយៈពេល២០ (ម្ភៃ)ឆ្នាំវិញ ។ រីឯអប្បបរមានៃទោសដាក់ពន្ធនាគារត្រូវបន្ថយពាក់កណ្តាលផងដែរ កាលណាទោសនោះមានរយៈពេលលើសពី១ (មួយ)ថ្ងៃ ។ ហើយដោយឡែកចំពោះអតិបរមា និងអប្បបរមានៃទោសពិន័យជាប្រាក់វិញ ក៏ត្រូវបន្ថយពាក់កណ្តាលដែរ ។ គួររំលឹកផងដែរថា ក្នុងករណីទោសប្រកាសចំពោះបទឧក្រិដ្ឋដែលត្រូវចោទប្រកាន់ ប្រសិនបើបទប្បញ្ញត្តិនៃមាត្រានេះមានអានុភាព

---

[20] មាត្រា ៩ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជនឆ្នាំ២០១៦

[21] មាត្រា ៣៩ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

បន្ថយអតិបរមានៃទោសដាក់ពន្ធនាគារមកត្រឹមចិរវេលាមួយស្មើ ឬតិចជាង៥ (ប្រាំ)ឆ្នាំនោះ បទល្មើសដែលត្រូវចោទប្រកាន់នៅតែជាបទឧក្រិដ្ឋដដែល [22]។ អតិប្បបរមា និងអប្បបរមានៃទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់ដែលត្រូវបន្ថយនោះ គឺការបន្ថយដោយធៀបនឹងទោសរបស់នីតិជន ពោលគឺសន្មត់ថាបើនីតិជនត្រូវជាប់ពន្ធនាគារក្នុងពេលកំណត់១០ (ដប់) ឆ្នាំ និងទោសពិន័យជាប្រាក់២០,០០០,០០០ (ម្ភៃលាន)រៀល ចំពោះអនីតិជននឹងត្រូវទទួលរងទោសពន្ធនាគារ ៥ (ប្រាំ)ឆ្នាំ និងទោសពិន័យជាប្រាក់១០,០០០,០០០ (ដប់លាន) រៀល។ **ឧទាហរណ៍៖** ក្មេងស្រីម្នាក់អាយុ១៦ (ដប់ប្រាំមួយ)ឆ្នាំ បានប្រព្រឹត្តសកម្មភាពកាត់សោរទ្វាផ្ទះជនរងគ្រោះដើម្បីលួចយកសម្ភារៈ តែត្រូវបានជនរងគ្រោះភ្ញាក់ដឹងខ្លួនស្រែកឆោឡោ ហើយជនល្មើសក៏ត្រូវបានចាប់ខ្លួនប្រគល់ជូនសមត្ថកិច្ច។ ក្នុងករណីនេះជនល្មើសត្រូវបានចោទប្រកាន់ពី **បទល្មើសលួចមានស្ថានទម្ងន់ទោស។** ក្រោយពីឆ្លងកាន់កិច្ចពិភាក្សាដេញដោលរួចតុលាការសម្រេចផ្តន្ទាទោសជនល្មើសពី បទលួចមានស្ថានទម្ងន់ទោសតាមមាត្រា៣៥៣ ,៣៥៧ និង១៦០ នៃក្រមព្រហ្មទណ្ឌ ។ នេះសបញ្ជាក់ឲ្យឃើញយ៉ាងពិតប្រាកដថា កាលបើអនីតិជនបានប្រព្រឹតបទល្មើស ហើយតុលាការសម្រេចផ្តន្ទាទោសនោះ ទោសដែលគាត់ត្រូវទទួលគឺត្រូវអនុលោមតាមមាត្រា១៦០ នៃក្រមព្រហ្មទណ្ឌ។ គួរបញ្ជាក់ផងដែរថាសម្រាប់អនីតិជន បទប្បញ្ញត្តិស្តីពី ការមិនរាងចាលមិនត្រូវបានយកមកអនុវត្តឡើយ[23] ប៉ុន្តែក្រៅពីអត្ថប្រយោជន៍ដែលមានចែងក្នុងមាត្រា១៦០ និងការមិនអនុវត្តស្តីពី ការមិនរាងចាលតាមមាត្រា១៦៣ បទប្បញ្ញត្តិស្តីពី ស្ថានសម្រាលត្រូវយកមកអនុវត្តចំពោះអនីតិជនដូចមានកំណត់ក្នុងមាត្រា១៦៤ នៃក្រមព្រហ្មទណ្ឌដែលផ្តល់ឲ្យត្រួតគ្នាពីការបន្ថយទោសដោយស្វ័យប្រវត្តិដែលបណ្តាលមកពីនីតិភាព។

យ៉ាងណាមិញក្នុងករណីដែលតុលាការសម្រេចដាក់ទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជន អនីតិជនដែលជាប់ពន្ធនាគារត្រូវឃុំខ្លួននៅទីកន្លែងពិសេសខណ្ឌដាច់ពីនីតិជន។ អនីតិជននៅក្រោមរបបដោយឡែកជាឯកត្តបុគ្គលដែលជាទីកន្លែងសម្រាប់អប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ របបឃុំឃាំងត្រូវកំណត់ដោយប្រកាសរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ[24]។ ឆ្លងតាមរយៈការពន្យល់ខាងលើនេះ គឺគេគិតគូរដល់ អនីតិជនដែលជាយុវជនជំនាន់ក្រោយដោយទុកឱកាសឲ្យអនីតិជនទទួលបានការអប់រំ បណ្តុះបណ្តាល ការការពារដែលមានអត្ថប្រយោជន៍សម្រាប់អនាគតរបស់គាត់។ សូមរំលឹកផងដែរថានៅក្នុងករណីដែលកិច្ចពិភាក្សាដេញ

[22] មាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[23] មាត្រា ១៦៣ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[24] មាត្រា ១៦៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

ដោលក្នុងសវនាការទាក់ទងនឹងរឿងអនីតិជន តុលាការត្រូវលើកយករឿងក្តីរបស់អនីតិជនមកចាត់ការជាអាទិភាព ជាពិសេសរឿងក្តីអនីតិជនដែលជាប់ឃុំបណ្តោះអាសន្ន[25] និងត្រូវសម្រេចជាក្រុមដោយចៅក្រម៣ រូប[26] ។

### ១.៣ វិធានការអនុវត្តចំពោះអនីតិជន

ប៉ុន្តែការប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនដូចដែលពោលខាងលើ គឺជាជម្រើសចុងក្រោយរបស់តុលាការធ្វើការប្រកាសក្នុងករណីតែបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ ឬ កាលៈទេសៈនៃបទល្មើសតម្រូវតែប៉ុណ្ណោះ។ រីឯជម្រើសចម្បងដែលច្បាប់ប្រគល់ឱ្យតុលាការធ្វើការប្រកាស នោះគឺអនុលោមតាមមាត្រា ៣៩ កថាខណ្ឌទី១ ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ដែលចែងអំពីវិធានការអនុវត្តអនីតិជន ពោលគឺ***អនីតិជនដែលប្រព្រឹត្តបទល្មើស ជាកម្មវត្ថុនៃវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ***។ វិធានការតាមដាន គឺតុលាការអាចប្រគល់អនីតិជនឱ្យទៅឪពុកម្តាយ អាណាព្យាបាល បុគ្គលដែលថែរក្សាអនីតិជននោះ ឬ បុគ្គលណាផ្សេងទៀតដែលតុលាការអាចទុកចិត្តបាន។ ចំណែកវិធានការអប់រំ គឺតុលាការអាចប្រគល់អនីតិជនឱ្យទៅសេវាសាធារណៈដែលសម្រាប់ទទួលបន្ទុកអនីតិជន។ ដោយឡែកសម្រាប់វិធានការការពារ គឺតុលាការអាចប្រគល់អនីតិជនឱ្យទៅអង្គការឯកជនដែលមាននីតិសម្បទាក្នុងការទទួលអនីតិជន។ ហើយចំពោះវិធានការឧបត្ថម្ភវិញ គឺតុលាការអាចប្រគល់អនីតិជនឱ្យទៅមន្ទីរពេទ្យ ឬ ស្ថាប័នឯកទេស[27]។ ក្នុងករណីដែលតុលាការដាក់អនីតិជនស្ថិតក្រោមការការពាររបស់តុលាការនោះ តុលាការធ្វើការចាត់តាំងបុគ្គលមួយរូបដែលទទួលភារៈធ្វើការតាមដានអនីតិជន។ បុគ្គលនេះត្រូវធ្វើរបាយការណ៍ស្តីពី កិរិយាមារយាទរបស់អនីតិជនឱ្យបានទៀតទាត់ដល់ ស្ថាប័នអយ្យការ ហើយបុគ្គលដែលទទួលបន្ទុកភារៈនោះ ត្រូវផ្តល់ព័ត៌មានជូនព្រះរាជអាជ្ញាអំពីព្រឹត្តិការណ៍ទាំងអស់ ដែលនាំឱ្យមានការកែប្រែនូវវិធានការទាំងនេះ[28]។ ហេតុនេះវិធានការខាងលើនេះ តម្រូវឱ្យមានស្ថាប័នសង្គមកិច្ចពិសេស ឬ តតិយជនដែលត្រូវបានផ្តល់នីតិសម្បទាដោយច្បាប់សម្រាប់ជាជំនួយក្នុងការដាក់ឱ្យប្រើប្រាស់នូវវិធានការទាំងអស់នោះ។

### ១.៤ ទោសដែលប្រកាសចំពោះនីតិបុគ្គល

នីតិបុគ្គល សំដៅដល់ការប្រមូលផ្តុំគ្នាបង្កើតជាក្រុមមួយ ឬ មូលនិធិ ឬ ក្រុមហ៊ុនដោយរូបវន្តបុគ្គលច្រើនដែលមានទ្រព្យវិភាគទានរួមគ្នាក្នុងការងារមួយដែលមានគោលដៅរួមគ្នា។នៅក្នុងប្រវត្តិសាស្ត្រច្បាប់កម្ពុជាពីមុនគឺពុំឃើញមាត្រាណាមួយដែលចែងអំពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គលឡើយ ប៉ុន្តែបើយើងក្រឡេកមកមើលក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ វិញយើងបានឃើញកំណត់ឲ្យនីតិបុគ្គលទទួលខុសត្រូវព្រហ្មទណ្ឌផងដែរ

[25] មាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជនឆ្នាំ២០១៦

[26] មាត្រា ៤៤ កថាខណ្ឌទី២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជនឆ្នាំ២០១៦

[27] មាត្រា ៤០ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[28] មាត្រា ៤១ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

ដាក់ស្តែងមាត្រា៤២ បានកំណត់អំពីការទទួលខុសត្រូវព្រហ្មទណ្ឌយ៉ាងច្បាស់ថា *ក្នុងករណីដែលមានចែងដាក់លាក់ក្នុងច្បាប់ និងបទដ្ឋានគតិយុត្តផ្សេងទៀត នីតិបុគ្គលលើកលែងតែរដ្ឋចេញអាចត្រូវទទួលខុសត្រូវព្រហ្មទណ្ឌពីបទល្មើសដែលប្រព្រឹត្តដោយអង្គភាព ឬ អ្នកតំណាងរបស់ខ្លួនដើម្បីជាប្រយោជន៍របស់ នីតិបុគ្គលនោះ* [29] មានន័យថាការទទួលខុសខុសត្រូវរបស់នីតិបុគ្គលពុំមានលក្ខណៈទូទៅនោះទេ ពោលគឺកាលណានីតិបុគ្គលនោះត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើណាមួយនោះ លុះត្រាណាតែមានកំណត់ទុកជាមុនជាក់លាក់អំពីបញ្ហានោះនៅក្នុងអត្ថបទច្បាប់ដែលកំពុងស្ថិតនៅជាធរមាននៅកម្ពុជា។ ការកំណត់បែបនេះជារបៀបថ្មីមួយនៃការទទួលខុសត្រូវដែលពុំធ្លាប់មានសោះនៅក្នុងប្រព័ន្ធច្បាប់កម្ពុជាពីមុនមក ហើយការបញ្ញត្តិបែបនេះបានបំពេញនូវកង្វះខាតគតិយុត្តដ៏មានសារៈមួយផងដែរ ។ យ៉ាងណាមិញកាលណានីតិបុគ្គលមួយត្រូវទទួលខុសត្រូវព្រហ្មទណ្ឌត្រូវសម្រេចអំពីទោសនោះ ទោសដែលនីតិបុគ្គលនោះត្រូវទទួលរងនោះ គឺមូលទោសដែលត្រឹមតែជាការពិន័យជាប៉ុណ្ណោះ ពោលទោសពន្ធនាគារពុំត្រូវបានយកមកប្រើឡើយ ព្រោះប្រសិនបើយើងយកទោសពន្ធនាគារទៅអនុវត្តដាក់នីតិបុគ្គលនោះវាហាក់ដូចជាមិនសាកសមឡើយ។

បន្ថែមលើសនេះ សុំរំលឹកផងដែរថាបញ្ញត្តិ ក៏ដូចជាទោសទាំងឡាយដែលត្រូវអនុវត្តក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល គឺសម្រាប់តែនីតិបុគ្គលឯកជនប៉ុណ្ណោះ ដោយឡែកនីតិបុគ្គលសាធារណៈដែលជាចំណុះរបស់រដ្ឋ ក្រសួងស្ថាប័ន អង្គភាព ឬ ការិយាល័យរដ្ឋណាមួយជាអាទិ៍ ដែលបង្កើតដោយអំណាចសាធារណៈក្នុងនាមប្រយោជន៍សាធារណៈជនពុំទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ។ មួយវិញទៀតការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល មិនលើកលែងការទទួលខុសត្រូវរបស់រូបវន្តបុគ្គលក្នុងអំពើដដែលនោះទេ[30] មានន័យថាទោះជានីតិបុគ្គលឯកជនត្រូវបានតុលាការសម្រេចទោសហើយក៏ដោយ តែពុំបានន័យថារូបវន្តបុគ្គលដែលពាក់ព័ន្ធក្នុងនោះរួចខ្លួនដែរ គឺត្រូវទទួលខុសត្រូវដូចគ្នាដែរ ។ ប៉ុន្តែនីតិបុគ្គលនោះនឹងមិនទទួលខុសត្រូវទណ្ឌកម្មព្រហ្មទណ្ឌឡើយ ប្រសិនបើអំពើដែលបានប្រព្រឹត្តក្នុងពេលបំពេញមុខងាររបស់អ្នកដឹកនាំ ឬ និយោជិត ឬ និយោជកដែលបានធ្វើសកម្មភាពក្នុងនាមផលប្រយោជន៍ផ្ទាល់ខ្លួន រីឯនីតិបុគ្គលសាធារណៈវិញក៏ដូចគ្នាទោះជាច្បាប់ឲ្យរួចពីការទទួលខុសត្រូវក៏ដោយ តែជនដែលបានប្រព្រឹត្តបទល្មើសច្បាប់ពុំឲ្យរួចផុតឡើយ។

### ២. ការប្រកាសទោសបន្ថែម

ទោសបន្ថែម ជាទោសបន្ទាប់បន្សំ ឬ អនុទោសដែលចៅក្រមមិនអាចយកទៅសម្រេចដាច់តែឯងបាន គឺថាតុលាការអាចសម្រេចប្រកាសបានលុះត្រាតែមានមូលទោសមួយត្រូវបានប្រកាសជាមុនសិន ។ ព្រោះថាកាលណាបទល្មើសមួយត្រូវផ្តន្ទាទោសដោយមានទោសបន្ថែមមួយ ឬ ច្រើនត្រួតលើគ្នា ហើយទោសនេះគឺគេប្រើ

[29] មាត្រា ៤២ កថាខណ្ឌទី១ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[30] មាត្រា ៤២ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

សម្រាប់ប្រកាសបន្ថែមទៅលើមូលទោស[31] ។ ទោសបន្ថែម អាចប្រកាសទៅបានលុះត្រាតែទោសនេះត្រូវបានចែងយ៉ាងជាក់លាក់ចំពោះបទឧក្រិដ្ឋ ឬ បទមជ្ឈិម ឬ បទលហុដែលត្រូវចោទប្រកាន់។ ទោសបន្ថែមអាចប្រកាសក៏បាន មិនប្រកាសក៏បាន ប៉ុន្តែទោសបន្ថែមនេះត្រូវប្រកាសជាកាតព្វកិច្ច ប្រសិនបើច្បាប់បានចែងយ៉ាងជាក់លាក់[32] ។ ពិតណាស់នៅក្នុងគោលការណ៍នៃការប្រកាសទោសបន្ថែមប្រសិនបើគ្មានចែងជាក់លាក់នៅក្នុងច្បាប់ទេ តុលាការមិនអាចយកទៅប្រកាសតាមតែការនឹកឃើញបាននោះទេ ហើយកាលណាបទល្មើសមួយនោះមានចែងអំពីទោសបន្ថែមក្រៅពីមូលទោសនោះ ចៅក្រមមានសេរីភាពក្នុងការសម្រេចចិត្តថាគួរតែប្រកាសទោសនេះ ឬ មិនប្រកាស ប៉ុន្តែលើកលែងតែច្បាប់កំណត់ជាកាតព្វកិច្ចត្រូវតែប្រកាសដាច់ខាតប៉ុណ្ណោះ ។ យ៉ាងណាមិញបើពិនិត្យមើលក្នុងក្រមព្រហ្មទណ្ឌបច្ចុប្បន្ន ទោះបីជាច្បាប់បានផ្តល់លទ្ធភាពឲ្យចៅក្រមជាអ្នកមានសិទ្ធិសម្រេចសេចក្តីអំពីទោសបន្ថែមក៏ដោយ ក៏ទោសបន្ថែមមួយ ឬ ច្រើននោះប្រកាសបាន លុះត្រាតែមានកំណត់ដោយច្បាប់ទើបចៅក្រមអាចប្រកាសបាន ព្រោះពុំមែនចេះតែសម្រេចដាក់តាមតែការនឹកឃើញនោះឡើយ។

### ២.១ ទោសបន្ថែមដែលប្រកាសទៅលើនីតិជន

សំណុំរឿងព្រហ្មទណ្ឌបែបបទនៃការប្រកាសទោសបន្ថែមត្រូវអនុលោមតាមមាត្រា៥៤ ហើយក្នុងនោះការប្រកាសទោសបន្ថែមត្រូវបានកម្រិតអាស្រ័យទៅតាមប្រភេទនៃបុគ្គលដែលទទួលរង ។ នៅទីនេះយើងនឹងធ្វើការបកស្រាយអំពីទោសបន្ថែមដែលតុលាការត្រូវប្រកាសចំពោះនីតិជន នោះគឺអនុលោមទៅតាមមាត្រា ៥៣ ដែលតាមរយៈមាត្រានេះទោសបន្ថែមមានសរុបចំនួន១៩ ចំណុច ដែលចៅក្រមអាចសម្រេចប្រកាសត្រួតជាមួយមូលទោស ពោលគឺ *ទោសបន្ថែមរួមមាន៖*

*១ ការដកសិទ្ធិខ្លះជាពលរដ្ឋ។*

*២ ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈណា ដែលបទល្មើសនោះបានប្រព្រឹត្តនៅក្នុងពេលដែលកំពុងប្រកបវិជ្ជាជីវៈនេះ។*

*៣ ការហាមឃាត់ចំពោះការបើកបរយានយន្តគ្រប់ប្រភេទ។*

*៤ ការព្យួរលិខិតបើកបរ។*

*៥ ការហាមឃាត់ចំពោះការស្នាក់នៅ។*

*៦ ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា។*

*៧ ការហាមឃាត់ចំពោះការចូល និងការស្នាក់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ចំពោះ ទណ្ឌិតដែលជាជនបរទេស។*

[31] មាត្រា ៩៩ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[32] មាត្រា ៥៤ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

*៨ ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុដែលប្រើប្រាស់ក្នុងពេលប្រព្រឹត្តបទល្មើស ឬ ដែលទុកសម្រាប់ប្រព្រឹត្តបទល្មើស។*

*៩ ការរឹបអូសវត្ថុ ឬ មូលនិធិ ដែលជាកម្មវត្ថុនៃបទល្មើស។*

*១០ ការរឹបអូសផលទុន ឬ ទ្រព្យសម្បត្តិ ដែលជាផលកើតចេញពីបទល្មើស។*

*១១ ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬ ចលនវត្ថុ ដែលលំអទីកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្ត។*

*១២ ការរឹបអូសយានជំនិះដែលជារបស់ទណ្ឌិត។*

*១៣ ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ។*

*១៤ ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ។*

*១៥ ការបិទគ្រឹះស្ថានដែលប្រើប្រាស់ ដើម្បីត្រៀម ឬប្រព្រឹត្តបទល្មើស។*

*១៦ ការហាមឃាត់ចំពោះការធ្វើអាជីវកម្មនៅក្នុងគ្រឹះស្ថាន ដែលបើកចំហសម្រាប់សាធារណៈជន ឬ ដែលប្រើប្រាស់ដោយសាធារណៈជន។*

*១៧ ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស។*

*១៨ ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន។*

*១៩ ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍។*

*បទប្បញ្ញត្តិដោយឡែក អាចបង្កើតទោសបន្ថែមផ្សេងៗទៀត។*

គួរបញ្ជាក់ផងដែរថា ក្នុងចំណោមទោសទាំង១៩ ចំណុច តុលាការជ្រើសរើសយកមួយ ឬ ច្រើនចំណុចស្របតាមបទល្មើសដែលមានកំណត់មកប្រកាសបន្ថែមលើមូលទោស ។ ម៉្យាងទៀតដោយសារទោសនេះត្រូវប្រកាសបន្ថែមទៅលើមូលទោស និងអាចប្រកាសត្រួតគ្នាបាននោះតម្រូវឲ្យមានការកំណត់ជាក់លាក់ទៅតាមប្រភេទបទល្មើសនីមួយៗ ទើបតុលាការអាចយកមកប្រកាសបាន។ **ឧទាហរណ៍៖** នៅក្នុង **បទល្មើសប្រទូសកេរខ្មាស** មាត្រា ២៤៦ ច្បាប់បានកំណត់អំពីមូលទោសដែលត្រូវកំណត់ឲ្យជាប់ពន្ធនាគារពី១ (មួយ )ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ចន្លោះពី២,០០០,០០០ (ពីរលាន )រៀល ទៅ ៦,០០០,០០០ (ប្រាំមួយលាន )រៀល មិនតែប៉ុណ្ណោះមាត្រា២៥២ បានចែងអំពីទោសបន្ថែមនៅក្នុងបទល្មើសនេះចំនួន៨ ចំណុច រួមមានជាអាទិ៍ ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល៥ ឆ្នាំយ៉ាងច្រើន ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល៥ ឆ្នាំ ឬការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។ បន្ថែមលើនេះ យើងឃើញថាបទល្មើសមួយចំនួន មិនបានចែងអំពីទោសបន្ថែមទេ ក្នុងករណីនេះចៅក្រមមានសេរីភាពអាចយកទោសបន្ថែមក្នុងមាត្រា៥៣ មកប្រកាសបាន នោះគឺទោសបន្ថែមមានលក្ខណៈជាចាំបាច់តាមស្ថានភាពសង្គមតម្រូវ និងសមស្រប

ជាមួយបទល្មើសដែលកើតឡើងនោះ។ **ឧទាហរណ៍៖** លោក ខ ជាជនបរទេស បានរក្សាទុកនូសារធាតុញៀន និងបាននាំចូលមកព្រះរាជាណាចក្រកម្ពុជា សមត្ថកិច្ចបានចាប់ខ្លួនរួចបញ្ជូនទៅតុលាការ តុលាការសម្រេចធ្វើការផ្តន្ទាទោសពី **បទជួញដូរខុសច្បាប់នូវសារធាតុញៀន** ស្របតាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលផ្តន្ទាទោសដាក់ពន្ធនាគារចំនួន ២ឆ្នាំ ជា(មូលទោស) និង ហាមឃាត់ចំពោះការចូល និងការស្នាក់នូវលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលជា(ទោសបន្ថែម)។

ហេតុដូច្នេះប្រសិនបើច្បាប់ពុំបានចែងសោះថា ចំពោះបទល្មើសណាមួយត្រូវប្រកាសទោសបន្ថែមមួយ ឬច្រើនឱ្យជាក់លាក់ទេ តុលាការក៏មិនអាចប្រកាសនូវទោសបន្ថែមមួយ ឬ ច្រើនបានឡើយ។ **ឧទាហរណ៍៖** សម្រាប់ **បទបង្វេរវត្ថុរឹបអូស ឬ វត្ថុដាក់ធានា** ដូចមានចែងនៅមាត្រា ៣៩៧ នៃក្រមព្រហ្មទណ្ឌ គឺពុំមានបទប្បញ្ញត្តិណាមួយដែលបញ្ជាក់អំពីទោសបន្ថែមដែលអាចប្រកាសបានសម្រាប់បទល្មើសនោះទេ។ ហេតុដូច្នេះតុលាការមិនអាចប្រកាសទោសបន្ថែមណាមួយ ចំពោះបុគ្គលដែលបានប្រព្រឹត្តបទល្មើសឡើយ ។

ទោះបីជាយ៉ាងនេះក្តី បើយោងតាមមាត្រា៩៩ ក្រមព្រហ្មទណ្ឌ បានបញ្ញត្តិអំពីរបៀបប្រកាសទោសបន្ថែមលើមូលទោសថា ***កាលណាបទល្មើសមួយត្រូវផ្តន្ទាទោសដោយទោសបន្ថែមមួយ ឬ ច្រើន ទោសនេះត្រូវបន្ថែមទៅលើមូលទោស លើកលែងតែបញ្ញត្តិនៃមាត្រា១០០ (ការជំនួសមូលទោសដោយទោសបន្ថែម ) នៃក្រមនេះចេញ***។ ការជំនួសមូលទោសដោយទោសបន្ថែម តុលាការអាចសម្រេចជំនួសមូលទោសដោយទោសបន្ថែមមួយ ឬ ច្រើន នៅក្នុងករណីដែល ជនជាប់ចោទទទួលទោសពិន័យក្នុងឋានៈជាមូលទោសតែមួយគត់ និងកាលណាជនជាប់ចោទទទួលទោសដាក់ពន្ធនាគារដែលអតិបរមាស្មើ ឬតិចជាង៣ (បី)ឆ្នាំ ហើយកាលណាតុលាការសម្រេចជំនួសមូលទោសដោយទោសបន្ថែមមួយ ឬ ច្រើន តុលាការមិនអាចប្រកាសទោសដាក់ពន្ធនាគារ ឬទោសពិន័យជាប្រាក់បានទេ[33] ។ ពិតណាស់ជាគោលការណ៍ទោសបន្ថែមអាចប្រកាសបានលុះត្រាតែមានមូលទោសបានប្រកាសក្តី ប៉ុន្តែក្រមព្រហ្មទណ្ឌក៏បានផ្តល់លទ្ធភាពជូនចៅក្រមដោយអាចយកទោសបន្ថែមមកប្រកាសជំនួសមូលទោសតែម្តងដោយគោរពតាមលក្ខខណ្ឌយ៉ាងជាក់លាក់ណាមួយក្នុងចំណោមលក្ខខណ្ឌទាំងពីរ ពោលក្នុងករណីជនជាប់ចោទទទួលទោសក្នុងឋានៈជាមូលទោសនោះតែមួយ មានន័យថាជនជាប់ចោទទទួលតែទោសពន្ធនាគារ ដែលទោសនោះមានរយៈពេលមិនលើសពី៣ (បី) ឆ្នាំ ឬ ទទួលតែទោសពិន័យជាប្រាក់តែមួយគត់ ប៉ុន្តែទោសពិន័យនោះពុំមានកំណត់ចំនួនជាក់លាក់នោះទេ។ ម្យ៉ាងវិញទៀតបើតុលាការបានសម្រេចយកទោសបន្ថែមមកប្រកាសជំនួសឲ្យមូលទោសហើយនោះ ទោសដកហូតសេរីភាពក្នុងឋានៈជាមូលទោស និងទោសពិន័យជាប្រាក់ពុំអាចយកមកប្រកាសបានទៀតទេ ។

[33] មាត្រា ១០០ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

## ២.២ ទោសបន្ថែមដែលប្រកាសចំពោះអនីតិជន

ដូចដែលបានពោលពីខាងដើមរួចមកហើយថា ការប្រកាសទោសបន្ថែមគឺអាស្រ័យលើបម្រែបម្រួលនៃបុគ្គលផ្ទាល់ ហើយទោសបន្ថែមដែលមានចែងនៅក្នុងមាត្រា៥៣ ទាំង១៩ ចំណុច ជាបញ្ញត្តិទូទៅ ឬ អាចនិយាយបានថាសម្រាប់ដាក់លើនីតិជន ដោយឡែកអនីតិជនវិញមានបញ្ញត្តិដោយឡែកសម្រាប់ពួកគេផងដែរ គឺមានចែងនៅក្នុងមាត្រាផ្សេងពីនេះ។

នៅទីនេះយើងនឹងធ្វើការពិភាក្សាអំពីទោសបន្ថែមសម្រាប់អនីតិជន ប៉ុន្តែនោះគឺអនីតិជនដែលមានអាយុចាប់ពី១៤ (ដប់បួន) ឆ្នាំដល់ក្រោម១៨ (ដប់ប្រាំបី) ឆ្នាំ ប៉ុណ្ណោះ ដោយសារតែនៅក្នុងច្បាប់កម្ពុជាពុំតម្រូវឲ្យអនីតិជនដែលមានអាយុក្រោម១៤ (ដប់បួន) ឆ្នាំ ទទួលខុសត្រូវព្រហ្មទណ្ឌ ហេតុនេះក៏គ្មានទោសណាមួយត្រូវប្រកាសចំពោះជនបែបនេះដែររួមទាំងទោសបន្ថែមផងដែរ។

ជាគោលការណ៍ទោសបន្ថែម គឺជាទោសដែលគេត្រូវប្រកាសបន្ថែមឲ្យមូលទោស ហើយបើទោះបីជាច្បាប់អនុគ្រោះសម្រាប់អនីតិជនដែលមានអាយុក្រោម១៤ (ដប់បួន) ឆ្នាំ ពុំទទួលខុសត្រូវព្រហ្មទណ្ឌក៏ដោយ តែទោះជាយ៉ាងណាដើម្បីការពារសណ្តាប់ធ្នាប់សាធារណៈ និងសង្គមជាតិឲ្យមានរបៀបរៀបរយល្អ ច្បាប់មិនលើកលែងចំពោះអនីតិជនដែលមានអាយុចាប់ពី១៤ (ដប់បួន)ឆ្នាំ ដល់ក្រោម១៨ (ដប់ប្រាំបី)ឆ្នាំទេ គឺពួកគេនៅតែទទួលទណ្ឌកម្មពីច្បាប់ដដែល។ ក្នុងករណីដែលតុលាការជ្រើសរើសប្រកាសមូលទោសចំពោះអនីតិជនប្រភេទនេះ នោះមានតែទោសបន្ថែមចំនួន៥ប៉ុណ្ណោះ ដែលត្រូវយកទៅអនុវត្តចំពោះអនីតិជន ហើយក្នុងនោះទោសបន្ថែមទាំងនោះមាន៤ គឺជាទោសដែលជាវិធានការនៃការរឹបអូសយកទ្រព្យសម្បត្តិដែលមានទំនាក់ទំនងជាមួយបទល្មើសផ្ទាល់ និងទោសមួយគឺជាទោសដែលមានលក្ខណៈជាការហាមឃាត់ រីឯទោសដែលមានលក្ខណៈជាការបង្ខាំងទុក ការដកហូតសិទ្ធិពលរដ្ឋ ការហាមឃាត់មិនឲ្យស្នាក់អាស្រ័យ និងការផ្សព្វផ្សាយការផ្តន្ទាទោសជាអាទិ៍ មិនត្រូវយកមកអនុវត្តឡើយ ព្រោះវាជាទោសដែលអាចនាំឲ្យបាត់បង់សេចក្តីថ្លៃថ្នូរ និងនាំឲ្យខូចកិត្តិយសក៏ដូចជាអនាគតផងដែរ ។ អាស្រ័យហេតុនេះមាត្រា១៦១ បានបរិយាយយ៉ាងច្បាស់អំពីប្រភេទទោសបន្ថែមទាំងនោះ ដែលមាត្រានេះបានចែងថា ***មានតែទោសបន្ថែមដែលមានចែងដូចតទៅនេះប៉ុណ្ណោះ ដែលអាចអនុវត្តចំពោះអនីតិជនបាន***

***១ ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុអ្វីមួយដែលបានប្រើក្នុងការប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅប្រព្រឹត្តបទល្មើស។***

***២ ការរឹបអូសវត្ថុ ឬ មូលនិធិដែលជាកម្មវត្ថុនៃបទល្មើស។***

***៣ ការរឹបអូសផលទុន ឬ ទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស។***

***៤ ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬ ចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសបានប្រព្រឹត្ត។***

*៥ ការហាមឃាត់ចំពោះការកាន់កាប់ ឬ ការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ។*

### ២.៣ ទោសបន្ថែមដែលប្រកាសចំពោះនីតិបុគ្គល

នៅក្នុងលក្ខខណ្ឌនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល ទោះបីជាទណ្ឌកម្មក្នុងឋានៈជាមូលទោសដែលអំណាចសាធារណៈប្រកាសឲ្យទទួលរងត្រឹមតែជាទោសពិន័យជាប្រាក់គ្មានទោសពន្ធនាគារក៏ដោយ ប៉ុន្តែពុំមានន័យថាគ្មានទោសបន្ថែមដែលនីតិបុគ្គលត្រូវទទួលរងនោះឡើយ។ នីតិបុគ្គលអាចត្រូវតុលាការប្រកាសទោសបន្ថែមក្នុងករណីទោសបន្ថែមនោះមានចែងទុកក្នុងច្បាប់ មានន័យថាច្បាប់បានកំណត់ជាក់លាក់ជាមុនក្នុងបទល្មើសដែលត្រូវចោទប្រកាន់[34] ។ ជាការពិតណាស់ទោសបន្ថែមរបស់នីតិបុគ្គលនេះពុំមានលក្ខណៈជាទូទៅទេ ពោលគឺ លក្ខខណ្ឌចាំបាច់មួយដែលតម្រូវឲ្យតុលាការត្រូវតែប្រតិបត្តិតាមនោះគឺ លុះត្រាតែប្រភេទនៃទោសបន្ថែមនោះត្រូវបានរកឃើញនៅក្នុងបទល្មើសដែលត្រូវចោទប្រកាន់នោះ ។ ចំនួនទោសបន្ថែមដែលត្រូវអនុវត្តចំពោះនីតិបុគ្គលត្រូវបានកម្រិតក្នុងចំនួន១៤ចំណុច ដូចមានចែងក្នុងមាត្រា១៦៨ នៃក្រមព្រហ្មទណ្ឌ ដែលមានខ្លឹមសារថា *ទោសបន្ថែមដែលត្រូវអនុវត្តចំពោះនីតិបុគ្គលមានដូចតទៅ៖*

*១ ការរំលាយចោល។*

*២ ការដាក់ឲ្យនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ។*

*៣ ការហាមឃាត់ចំពោះការអនុវត្តចំពោះសកម្មភាពមួយ ឬ ច្រើន។*

*៤ ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ។*

*៥ ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈដល់ការសន្សំសំចៃ។*

*៦ ការហាមឃាត់ចំពោះការចេញឧបករណ៍អាចជួញដូរបាន ក្រៅពីឧបករណ៍អាចជួញដូរបាន ដែលកំណត់ដោយធនាគារ ។*

*៧ ការហាមឃាត់ចំពោះការប្រើបណ្ណទូទាត់។*

*៨ ការបិទគ្រឹះស្ថានដែលប្រើសម្រាប់ធ្វើការរៀបចំ ឬ ប្រព្រឹត្តបទល្មើស។*

*៩ ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថានដែលបើកចំហដល់សាធារណៈជន ឬ ដែលបានប្រើប្រាស់ដោយសាធារណៈជន។*

*១០ ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុណាមួយដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅសម្រាប់ប្រព្រឹត្តបទល្មើស។*

*១១ ការរបអូសវត្ថុ ឬ មូលនិធិដែលជាកម្មវត្ថុនៃបទល្មើស។*

*១២ ការរឹបអូសផលទុន ឬ ទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស។*

---
[34] មាត្រា ១៦៩ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

*១៣ ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬ ចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្ត។*

*១៤ ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬ ការផ្សាយតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍។*

*បទប្បញ្ញត្តិដោយឡែកអាចបង្កើតទោសបន្ថែមដទៃទៀត។*

### ៣. ការប្រកាសទោសជំនួស

ទោសជំនួស គឺជាទោសដែលត្រូវបានតុលាការយកមកប្រកាសជំនួសឲ្យមូលទោស។ ហើយកាលណាតុលាការបានប្រកាសទោសជំនួសទៅលើពិរុទ្ធជនរួចហើយតុលាការ ពុំអាចប្រកាសទោសក្នុងឋានៈជាមូលទោសឡើយ[35] ។ នេះគឺជាបែបផែនទោសថ្មីស្រឡាងមួយដែលត្រូវបានបញ្ចូលមកក្នុងប្រព័ន្ធនីតិកម្ពុជា ។ តាមរយៈការកំណត់ខាងលើនេះចៅក្រមនឹងត្រូវលះបង់លទ្ធភាពក្នុងការប្រកាសមូលទោស មានន័យថាពុំប្រកាសទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់ឡើយ ដោយផ្ទុយមកវិញគឺការប្រកាសទោសជំនួសនេះឯង[36] ។ យោងតាមក្រមព្រហ្មទណ្ឌឃើញថាទោសជំនួសមានពីរប្រភេទគឺ ទោសការងារសហគមន៍ និងការស្តីបន្ទោស ។ ទោសទាំងពីរនេះពុំអាចត្រូវបានតុលាការប្រកាសជាមួយគ្នាបានឡើយ[37] ។

#### ៣.១ ទោសការងារសហគមន៍

ទោសការងារសហគមន៍ ជាកាតព្វកិច្ចដែលតុលាការតម្រូវឲ្យទណ្ឌិតបំពេញដោយគ្មានកម្រៃ និងក្នុងនាមដើម្បីប្រយោជន៍របស់រដ្ឋ របស់សមូហភាពដែនដី របស់នីតិបុគ្គលតាមច្បាប់សាធារណៈ របស់សមាគមន៍ ឬអង្គការក្រៅរដ្ឋាភិបាល[38] ពោលគឺគ្រប់ករណីទាំងអស់ ទោសការងារសហគមន៍ត្រូវអនុវត្តសម្រាប់ប្រយោជន៍ទូទៅមិនចំពោះនរណាម្នាក់ ពោលគឺមិនមែនបំពេញជាប្រយោជន៍នៃរូបវន្តបុគ្គលណាមួយឡើយ[39] ។ ការងារសហគមន៍ ត្រូវតែស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ជាអាទិ៍ ការងារនៅពេលយប់ អនាម័យ សន្តិសុខ ហើយនិងការងាររបស់ស្ត្រី។ ការងារសហគមន៍ អាចត្រួតគ្នាបានជាមួយនឹងការអនុវត្តសកម្មភាពវិជ្ជាជីវៈបាន[40]។ ចំណែកឯសំណងការខូចខាតទៅលើអ្នកដទៃដែលបង្កដោយជនជាប់ចោទ រដ្ឋត្រូវតែចេញសោហ៊ុយជួសជុលការខូចខាតដែលបង្កដល់អ្នកដទៃដោយទណ្ឌិតនៅក្នុងពេលដែលកំពុងអនុវត្តការងារសហគមន៍។ រដ្ឋត្រូវធ្វើ

---

[35] មាត្រា ៩៨ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[36] សៀវភៅសហប្រតិបត្តិការបារាំងកម្រោងទ្រទ្រង់នីតិរដ្ឋ មេរៀននីតិព្រហ្មទណ្ឌ ទំព័រទី៨៣

[37] សៀវភៅសហប្រតិបត្តិការបារាំងកម្រោងទ្រទ្រង់នីតិរដ្ឋ មេរៀននីតិព្រហ្មទណ្ឌ ទំព័រទី៨៣

[38] មាត្រា ៧២ កថាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[39] មាត្រា ៧៣ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[40] មាត្រា ៧៤ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

ឧបាទេសកម្មដោយពេញច្បាប់ទៅក្នុងសិទ្ធិជនរងគ្រោះ[41] ។ មានន័យថា ករណីទណ្ឌិតអនុវត្តការងារសហគមន៍ រដ្ឋត្រូវចេញសងការខូចខាត ដែលទណ្ឌិតបានបង្កឡើងទៅឱ្យជនរងគ្រោះដោយពេញច្បាប់ ព្រោះតែទណ្ឌិតត្រូវតែអនុវត្តការងារដែលមានកម្មវត្ថុបម្រើឱ្យផលប្រយោជន៍សាធារណៈជំនួសវិញ។

## ៣.១.១ ទោសការងារសហគមន៍សម្រាប់នីតិជន

ដោយហេតុថាទោសការងារសហគមន៍ ជាប្រភេទទោសដែលបម្រើឲ្យផលប្រយោជន៍សាធារណៈ ហេតុនេះការប្រកាសត្រូវគោរពតាមលក្ខខណ្ឌតម្រូវដោយច្បាប់ មិនអាចប្រកាសទៅតាមអំពើចិត្តឡើយ ។ ទោសការងារសហគមន៍អាចប្រកាសបានកាលណាជនជាប់ចោទនឹងទទួលទោសដកហូតសេរីភាព (ទោសជាប់ពន្ធនាគារ) ដែលអតិបរមារបស់ទោសតិចជាង ឬ ស្មើនឹង៣ (បី)ឆ្នាំ [42] ។ ម្យ៉ាងទៀតដោយសារតែការងារសហគមន៍ជាទោសដែលផ្តល់ភាពវិជ្ជមានដល់សង្គម នោះគឺត្រូវគោរពតាមគោលការណ៍ស្ម័គ្រចិត្តរបស់ជនជាប់ចោទ ហេតុនេះតុលាការអាចប្រកាសបាន លុះត្រាណាតែជនជាប់ចោទមានវត្តមាននៅពេលសវនាការ ហើយយល់ព្រមធ្វើការងារនេះ។ ក្នុងនោះផងដែរនៅមុនពេលប្រកាសសាលក្រម ឬ សាលដីការត្រូវប្រាប់ជនជាប់ចោទថា សាមីខ្លួនមានសិទ្ធិបដិសេធមិនទទួលធ្វើការងារនេះបាន ហើយចម្លើយដែលគាត់បានផ្តល់មកវិញត្រូវតែមានចុះក្នុងសាលក្រម ឬ សាលដីការនោះ[43] ។ ដូច្នេះកាលណាតុលាការប្រកាសទោសការងារសហគមន៍ ហើយមានការយល់ព្រមពីជនជាប់ចោទនៅក្នុងសវនាការ នោះទណ្ឌិតត្រូវតែគោរពកាតព្វកិច្ចធ្វើការងារសហគមន៍ដែលតុលាការប្រកាសនោះ ។ ផ្ទុយទៅវិញបើទណ្ឌិតបានបំពានលើកាតព្វកិច្ចការងារសហគមន៍ ដោយអំពើបំពានដោយទណ្ឌិតលើកាតព្វកិច្ច ដែលជាលទ្ធផលនៃទោសការងារសហគមន៍ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគាពី ១ (មួយ)ឆ្នាំ ទៅ ២ (ពី)ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន)រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល[44] ។ យ៉ាងណាមិញទោសការងារសហគមន៍នេះ ទណ្ឌិតត្រូវបំពេញក្នុងចិរវេលាចន្លោះពី៣០ (សាមសិប) ម៉ោង ទៅ ២០០ (ពីររយ) ម៉ោង[45] ហើយត្រូវមានរយៈពេលអនុវត្តមិនលើសពី១ (មួយ)ឆ្នាំឡើយ[46] មានន័យថា វេលាដែលកំណត់ចន្លោះពី ៣០ (សាមសិប) ទៅ ២០០ (ពីររយ)ម៉ោងនោះ អនុវត្តយ៉ាងណាមិនឲ្យលើសពីរយៈពេល ១ (មួយ)ឆ្នាំ ឡើយ ដែលនេះគឺជារយៈពេលសម្រាប់រូបវន្តបុគ្គលជានីតិជន។

---

[41] មាត្រា ៧៥ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[42] មាត្រា៧២ កថាខណ្ឌទី១ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[43] មាត្រា ១០១ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[44] មាត្រា ៥៨៣ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[45] មាត្រា ៧២ កថាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[46] មាត្រា ១០២ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

### ៣.១.២ ទោសការងារសហគមន៍សម្រាប់អនីតិជន

ដោយឡែកសម្រាប់អនីតិជនវិញ ទោសការងារសហគមន៍នេះអាចប្រកាសបានចំពោះតែអនីតិជនណាដែលមានអាយុចាប់ពី១៦ (ដប់ប្រាំមួយ) ឆ្នាំ ពោលគឺអនីតិជនដែលមានចន្លោះអាយុចាប់ពីត្រឹម១៦ (ដប់ប្រាំមួយ) ឆ្នាំដល់ក្រោម១៨ (ដប់ប្រាំបី) ឆ្នាំ ហើយថិរវេលាអនុវត្តក៏ខុសពីនីតិជនផងដែរ គឺមានអតិបរមាមិនអាចលើសពី១០០ (មួយរយ) ម៉ោង បានឡើយ។ ម្យ៉ាងទៀតទោសនេះត្រូវតែសម្របសម្រួលទៅលើអនីតិជនមានលក្ខណៈជាការបណ្តុះបណ្តាល និងសម្រួលដល់ការបញ្ចូនខ្លួនទៅរស់នៅក្នុងសង្គមវិញ[47] បានន័យថាថិរវេលានៃទោសការងារសហគមន៍ចំពោះអនីតិជនដែលមានអាយុយ៉ាងតិច ១៦ ឆ្នាំឡើងទៅ គឺច្បាប់បានកំណត់ត្រឹមមកពាក់កណ្តាលនៃទោសនីតិជន ពោលចំពោះនីតិជន ២០០ ម៉ោង ដូច្នេះចំពោះអនីតិជន ១០០ ម៉ោង ដូចមានកំណត់។ សូមរំលឹកដែរថាទោសការងារសហគមន៍របស់អនីតិជន ត្រូវគិតគូរតែចំពោះការងារទាំងឡាយណាដែលមានលក្ខណៈជាការអប់រំបណ្តុះបណ្តាល ឬ ការងារណាដែលមានប្រយោជន៍ដល់ការលូតលាស់ទាំងផ្នែកបញ្ញា ស្មារតី រាងកាយ ពិសេសផ្តល់នូវចំណេះដឹងដល់អនីតិជននោះ ទើបអាចប្រកាសបាន។

គួរបញ្ជាក់ផងដែរថាបែបបទនៃការអនុវត្តទោសការងារសហគមន៍ ការចង្អុលប្រាប់ឈ្មោះនីតិបុគ្គលដែលត្រូវទទួលបានអត្ថប្រយោជន៍ពីការងារនេះ និងរួមទាំងសកម្មភាពអនុវត្តការងារនេះ របស់គ្រប់រូបបុគ្គលទាំងនីតិជន និងអនីតិជនត្រូវស្ថិតក្រោមសមត្ថកិច្ចរបស់ព្រះរាជអាជ្ញា[48] ពោលគឺព្រះរាជអាជ្ញាត្រូវណែនាំដល់ទណ្ឌិតអំពីការអនុវត្តការងារសហគមន៍ និងកាតព្វកិច្ចដែលត្រូវអនុវត្ត ក៏ដូចជាណែនាំដល់នីតិបុគ្គល និងត្រូវរៀបចំបែបបទ និងការអនុវត្តទោសនេះដល់នីតិបុគ្គលនោះជាអាទិ៍ផងដែរ[49]។

## ៣.៣ ទោសស្តីបន្ទោស

ការស្តីបន្ទោស ជាប្រភេទទោសជំនួសមួយក្នុងចំណោមនោះផងដែរ (ទោសការងារសហគមន៍ និងទោសស្តីបន្ទោស) ដែលតុលាការអាចយកវាទៅប្រកាសជួសឲ្យមូលទោសបាន ។ នេះជាទោសថ្មីមួយដែលនីតិនិពន្ធបានបញ្ចូលមកក្នុងប្រព័ន្ធច្បាប់កម្ពុជា ដែលលើកការពិចារណានូវការពិន័យចារី និងកម្រិតទោសនៅត្រឹមតែទម្រង់ធម្មតាមួយ ក្នុងករណីដែលបទល្មើសពុំមានភាពធ្ងន់ធ្ងរខ្លាំងហួសហេតុដល់សង្គម។ ការស្តីបន្ទោសអាចត្រូវបានតុលាការប្រកាសបាន ក្នុងករណីដែលជនជាប់ចោទរងទោសជាប់ទោសពន្ធនាគារ ដែលមានកម្រិតអតិបរមាតិចជាង ឬស្មើនឹង៣ (បី) ឆ្នាំ ហើយរួមផ្សំនឹងករណីដែលលក្ខខណ្ឌទាំង៣នេះ ត្រូវបានបំពេញគឺះ ភាពចលាចលដល់សណ្តាប់ធ្នាប់សាធារណៈ ដែលបណ្តាលមកពីបទល្មើសបានបញ្ចប់ ការខូចខាតត្រូវបានជួស

---

[47] មាត្រា ១៦២ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[48] មាត្រា ១០៣ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[49] សារាចរណ៍ ០៣ ក.យ.សរ/១៤ ស្តីពី ការអនុវត្តបទប្បញ្ញត្តិនៃការអនុវត្តទោសការងារសហគមន៍

ផុលរួចរាល់ហើយ និង ជនជាប់ចោទបានបង្ហាញការធានាក្នុងការចូលទៅរួមរស់នៅក្នុងសង្គមវិញ[50] ។ ជាការពិតណាស់ក្នុងករណីដែលលក្ខខណ្ឌទាំងបីបានបំពេញគ្រប់គ្នា ចៅក្រមអាចពិចារណាប្រកាសដាក់ទោសការស្តីបន្ទោសនេះ ហើយទោសនេះមានឧបនិស្ស័យអនុវត្តក្នុងករណីជនល្មើសក្មេងៗជាអនីតិជនប្រព្រឹត្តលើកដំបូងជាអាទិ៍ **បទហិង្សាស្រាល** ការបង្ករបួសស្នាមដោយអចេតនា ហើយជនល្មើសបានចូលខ្លួនបង្ហាញមុខចំពោះតុលាការរួមទាំងបានសំដែងនូវការព្យាយាមដ៏ចាំបាច់សម្រាប់ផ្តល់សោហ៊ុយជំងឺចិត្តដល់ជនរងគ្រោះស្វែងរកផ្លូវត្រឹមត្រូវត្រឡប់ទៅកាន់ជីវភាពធម្មតាវិញ ដូចជាការបណ្តុះបណ្តាលនៅសាលា ឬ វិជ្ជាជីវៈវិញជាដើម[51] ។ ផ្ទុយទៅវិញសម្រាប់បទល្មើស ដែលមានស្ថានភាពធ្ងន់ធ្ងរដូចជា **បទឧក្រិដ្ឋ បទមជ្ឈឹម** ដែលមានស្ថានទម្ងន់ទោសដទៃទៀត ដែលទណ្ឌិតត្រូវបានតុលាការផ្តន្ទាទោសពីបទល្មើសទាំងនេះ ទណ្ឌិតពុំអាចទទួលបានឱកាសក្នុងការអនុវត្តនូវទោសជំនួស ដែលមានការស្តីបន្ទោសបានឡើយ ។ ព្រោះតែរបបគតិយុត្តនៃទោសប្រភេទនេះ មិនអនុញ្ញាតឱ្យតុលាការប្រកាសបាន ចំពោះកម្រិតអតិបរមានៃទោសដាក់ពន្ធនាគារលើសពី ៣ ឆ្នាំ។

[50] មាត្រា ៧៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[51] សៀវភៅសហប្រតិបត្តិការបារាំងកម្រោងទ្រទ្រង់នីតិរដ្ឋ មេរៀននីតិព្រហ្មទណ្ឌ ទំព័រទី៥៨, ៥៩

# ជំពូកទី២
# របបនៃការព្យួរទោស

# ជំពូកទី២
# របបនៃការព្យួរទោស

ការព្យួរទោស គឺជាវិធានការណ៍នៃការអនុគ្រោះទោស ដែលអនុញ្ញាតឲ្យមានឯកត្តកម្មកាន់តែហ្មត់ចត់ថែមទៀតនៃទោស។ វិធានការនេះបានបង្កើតឡើង ពុំមែនជាសិទ្ធិរបស់ទណ្ឌិតឡើយ តែគឺជាសេរីភាពរបស់អង្គចៅក្រមទៅវិញទេ ក្នុងការសម្រេចអនុញ្ញាតឲ្យព្យួរទោស ឬ បដិសេធចោល នៅពេលដែលមានការស្នើសុំក្នុងការអនុវត្តការព្យួរទោស ។ ការព្យួរទោសនេះជាគោលការណ៍មួយនៅក្នុងរបបប្រកាសទោសដែលប្រតិបត្តិដោយតុលាការទៅលើពិរុទ្ធជនដោយបង្គាប់ឲ្យព្យួរការអនុវត្តទោសទាំងស្រុង ឬ មួយផ្នែកនៃមូលទោស (ទោសជាប់ពន្ធនាគារ និងទោសពិន័យជាប្រាក់)[52] ហើយការអនុវត្តការព្យួរទោសនេះទៀតសោធ ត្រូវគិតគូរតែអំពីការផ្តន្ទាទោសខាងបណ្តឹងអាជ្ញាចូលជាស្ថាពរតែប៉ុណ្ណោះ[53] គឺចង់មានន័យថាលុះត្រាតែទណ្ឌកម្មព្រហ្មទណ្ឌត្រូវបានប្រកាសចូលជាស្ថាពរប៉ុណ្ណោះ។ យ៉ាងណាមិញវិធានការនៃការព្យួរទោសនេះផងដែរ ថ្វីត្បិតតែមានលក្ខខណ្ឌអាចបង្អាក់ការអនុវត្តទោសសិនមែនពិត តែវាក៏អាចភ្ជាប់មកជាមួយដែរនូវកាតព្វកិច្ចដែលច្បាប់បានកំណត់ ។ របបនៃការព្យួរទោស ដោយផ្អែកតាមក្រមព្រហ្មទណ្ឌកម្ពុជាបច្ចុប្បន្នត្រូវបានបែងចែកជាពីរប្រភេទគឺ ការព្យួរទោសធម្មតា និងការព្យួរទោសសាកល្បង។

## ផ្នែកទី១ ការព្យួរទោសធម្មតា

ការព្យួរទោសធម្មតា គឺជាការព្យួរការអនុវត្តទោសដោយពុំមានដាក់ឲ្យទណ្ឌិតស្ថិតក្រោមវិធានការ ឬ ក្រោមកាតព្វកិច្ចណាមួយរបស់តុលាការឡើយ ។ ការព្យួរទោសធម្មតា អាចត្រូវបានតុលាការផ្តល់ឲ្យដល់គ្រប់ជនជារូបវន្តបុគ្គល ដែលប្រព្រឹត្តបទល្មើស ទាំងបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ កាលណាលក្ខខណ្ឌដែលច្បាប់តម្រូវបានបំពេញ ។

### ១. លក្ខខណ្ឌនៃការព្យួរទោសធម្មតា

ដូចដែលបានបរិយាយពីខាងដើមហើយថា ការព្យួរទោសធម្មតាពុំមែនត្រូវបានផ្តល់ឲ្យដោយទំនើងចិត្តនោះទេ ពោលគឺអាចផ្តល់ឲ្យបានលុះត្រាតែលក្ខខណ្ឌត្រូវបានបំពេញ ។ ក្នុងផ្នែកនេះយើងនឹងធ្វើការពិភាក្សាលម្អិតអំពី លក្ខខណ្ឌទាក់ទងនឹងការផ្តន្ទាទោសពីមុន (១.១) និងលក្ខខណ្ឌទាក់ទងនឹងការផ្តន្ទាទោសនាពេលបច្ចុប្បន្ន (១.២) ។

[52] មាត្រា ១០៤ ក្រមព្រហ្មទណ្ឌ២០០៩

[53] មាត្រា ១០៥ ក្រមព្រហ្មទណ្ឌ២០០៩

### ១.១ លក្ខខណ្ឌទាក់ទងនឹងការផ្តន្ទាទោសពីមុន

លក្ខខណ្ឌនៃការផ្តន្ទាទោសពីមុន ឬ ហៅម៉្យាងទៀតថាគោលការណ៍ស្អាតស្អំ គឺជាលក្ខខណ្ឌដែលបរិយាយអំពីអតីតភាពរបស់ជនម្នាក់ នូវមុនពេលដែលពួកគាត់បានទៅប្រព្រឹត្តបទល្មើស ។ ក្នុងលក្ខខណ្ឌនេះ យើងនឹងត្រូវធ្វើការសិក្សាលម្អិតអំពីបទល្មើសដែលច្បាប់បានកំណត់នោះបទល្មើសដែលត្រូវផ្តល់គឺ ចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិម (១.១.១) និងចំពោះបទលហុ (១.១.២)។

#### ១.១.១ ចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិម

ចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិម ការព្យួរទោសធម្មតាអាចត្រូវបានតុលាករប្រកាសទៅលើជនជាប់ចោទកាលណាប្រវត្តិរបស់ជននោះពុំធ្លាប់មានការផ្តន្ទាទោសជាស្ថាពរណាមួយក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំមុនអំពើល្មើស[54] មានន័យថាការព្យួរទោសធម្មតា តុលាការអាចប្រកាសបានលុះណាតែជននេះមានភាពស្អាតស្អំមិនធ្លាប់មានការផ្តន្ទាទោសជាស្ថាពរពីតុលាការចំពោះបទល្មើសដែលត្រូវចោទប្រកាន់ណាមួយ យ៉ាងហោចណាស់រយៈពេល៥ (ប្រាំ)ឆ្នាំ មុនពេលដែលជនជាប់ចោទទៅប្រព្រឹត្តបទល្មើស។ **ឧទាហរណ៍៖** នៅក្នុងថ្ងៃទី ១ ខែមករា ឆ្នាំ២០២០ បុគ្គល ក បានប្រព្រឹត្តបទល្មើស **លួច** តាមមាត្រា ៣៥៣ នៃក្រមព្រហ្មទណ្ឌ ប៉ុន្តែគិតពីពេលដែលបទល្មើសបានកើតឡើងត្រឡប់មកក្រោយក្នុងរយៈពេល៥ (ប្រាំ)ឆ្នាំ ពោលគឺ ថ្ងៃទី១ ខែមករា ឆ្នាំ២០១៥ បុគ្គល ក នោះមិនដែលមានការផ្តន្ទាទោសចំពោះបទល្មើសដែលត្រូវចោទប្រកាន់ណាមួយត្រូវបានប្រកាសស្ថាពរទេ នោះតុលាការអាចពិចារណាផ្តល់នូវការអនុគ្រោះទោសដោយការព្យួរទោសធម្មតានេះទៅជនជាប់ចោទបានតាមការស្នើរសុំ ។ សូមបញ្ជាក់ថា រយៈពេល ៥ឆ្នាំ នៃគោលការណ៍ស្អាតស្អំក្នុងឧទាហរណ៍ គឺរាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៥ ដល់ថ្ងៃទី១ ខែមករា ឆ្នាំ២០២០ ។

#### ១.១.២ ចំពោះបទលហុ

ដោយឡែកចំពោះបទលហុវិញ ក៏មានភាពស្រដៀងនឹងបទល្មើសទាំងពីរខាងលើដែរ គឺតុលាការធ្វើការពិចារណាទៅលើអតីតកាលរបស់ជនល្មើសមុនពេលដែលហេតុការណ៍ដែលគាត់ប្រព្រឹត្តបានកើតឡើង ។ ជនជាប់ចោទអាចត្រូវបានតុលាការប្រកាសឲ្យអនុវត្តការព្យួរទោសធម្មតា កាលបើក្នុងករណីមិនដែលត្រូវបានទទួលទោសព្រហ្មទណ្ឌស្ថាពរណាមួយក្នុងរយៈពេល១ (មួយ)ឆ្នាំ នៅមុនកាលដែលបទល្មើសបានប្រព្រឹត្ត[55] រយៈពេលមួយឆ្នាំនៅទីនេះគឺ គិតចាប់ពីថ្ងៃដែលគាត់បានប្រព្រឹត្តបទល្មើសដែលត្រូវចោទប្រកាន់នេះបកត្រឡប់មកក្រោយ ប្រសិនបើជនជាប់ចោទនោះ គាត់ពុំធ្លាប់បានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌនាំឲ្យមានទោសស្ថាពរណាមួយបានកើតនោះទេ ប្រាកដណាស់តុលាការអាចពិចារណាប្រកាសឲ្យព្យួរទោសរបស់គាត់តាមការស្នើរសុំ។

---

[54] មាត្រា ១០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[55] មាត្រា ១១២ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

**ឧទាហរណ៍:** ជនម្នាក់បានប្រព្រឹត្តបទល្មើស **បរិហារកេរ៍្តជាសាធារណៈ** ហើយត្រូវបានតុលាការសម្រេចចោទប្រកាន់ពីបទល្មើសនេះ តាមមាត្រា ៣០៥ នៃក្រមព្រហ្មទណ្ឌ។ ករណីនេះការព្យួរទោសអាចប្រព្រឹត្តទៅបាន កាលណាមុនរយៈពេល ១ ឆ្នាំ គិតត្រឹមថ្ងៃជននេះប្រព្រឹត្តបទល្មើសនេះ ជនជាប់ចោទមិនទាន់មានការផ្តន្ទាទោសស្ថាពរ ឱ្យជាប់ពន្ធនាគារទេនោះ ករណីនេះជនជាប់ចោទអាចនឹងទទួលបានការព្យួរទោស។

យ៉ាងណាមិញលក្ខខណ្ឌនៃការផ្តន្ទាទោសពីមុន ឬ គោលការណ៍ស្អាតស្អំនេះរវាងបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ គឺចៅក្រមធ្វើការថ្លឹងថ្លែងទៅលើប្រវត្តិរបស់ជនល្មើសដូចគ្នា ប៉ុន្តែអ្វីដែលខុសគ្នានោះគឺនៅត្រង់ថារយៈពេល ពោលគឺចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិមលុះត្រាតែគាត់មានភាពស្អាតស្អំរយៈពេល៥ (ប្រាំ)ឆ្នាំ មុនបទល្មើសទើបអាចផ្តល់បាន រីឯចំពោះបទលហុវិញតុលាការអាចប្រកាសការព្យួរទោសបែបនេះបាន ចំពោះជនជាប់ចោទដែលមិនធ្លាប់មានទោសស្ថាពរក្នុងរយៈពេល១ (មួយ)ឆ្នាំ។

## ១.២ លក្ខខណ្ឌទាក់ទងនឹងការផ្តន្ទាទោសនាពេលបច្ចុប្បន្ន

បន្ទាប់ពីបានដឹងអំពីលក្ខខណ្ឌទី១ ដែលសិក្សាទៅលើភាពស្អាតស្អំរបស់ទណ្ឌិតដូចបានពោលខាងលើនោះរួចមកហើយ នៅទីនេះយើងនឹងធ្វើការសិក្សាទៅលើលក្ខខណ្ឌទី២ ដែលនាំឲ្យមានការព្យួរទោសធម្មតាវិញម្តង គឺលក្ខខណ្ឌទាក់ទងនឹងការផ្តន្ទាទោសនាពេលបច្ចុប្បន្ន ដែលនៅក្នុងចំណុចនេះគឺត្រូវធ្វើការពិភាក្សាលម្អិតដោយបែងចែកចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិម (១.២.១) និងចំពោះបទលហុ (១.២.២) ដាច់ដោយឡែកពីគ្នា។

### ១.២.១ ចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិម

ចំពោះលក្ខខណ្ឌទោសនាពេលបច្ចុប្បន្ន ទៅលើបទឧក្រិដ្ឋ ឬបទមជ្ឈិម តុលាការអាចប្រកាសការព្យួរទោសធម្មតាបានកាលណាជនជាប់ចោទបានប្រព្រឹត្តបទល្មើសត្រូវទទួលរងទោសជាប់ពន្ធនាគារមានរយៈពេលតិចជាង ឬស្មើនឹង៥ (ប្រាំ)ឆ្នាំ ព្រមទាំងអាចប្រកាសឲ្យព្យួរទោសពិន័យជាប្រាក់ផងដែរ[56] ។ ក្នុងករណីនេះបើជនជាប់ចោទមានបំណងចង់ឲ្យតុលាការប្រកាសទោសមកលើខ្លួនដោយមានការព្យួរទោសនោះ យ៉ាងហោចណាស់លុះត្រាតែគាត់ត្រូវបានចៅក្រមប្រកាសទោសជាប់ពន្ធនាគារកំណត់រយៈពេល៥ (ប្រាំ)ឆ្នាំចុះក្រោម ទើបត្រូវតាមលក្ខខណ្ឌដែលច្បាប់បានកំណត់ រីឯទោសពិន័យជាប្រាក់វិញពុំមានកំណត់អតិបរមាប៉ុណ្ណាឡើយទើបប្រកាសព្យួរទោសធម្មតានេះបាន ។ ហេតុនេះប្រសិនបើតុលាការធ្វើការប្រកាសទោសដាក់ពន្ធនាគាររយៈពេលលើសពី៥ (ប្រាំ)ឆ្នាំ ដោយបានប្រព្រឹត្តក្នុងបទមជ្ឈិមណាមួយនោះ ទោសនេះមិនអនុញ្ញាតឱ្យតុលាការប្រកាសព្យួរទោសបានឡើយ។ ក៏ប៉ុន្តែផ្ទុយទៅវិញ ប្រសិនបើតុលាការធ្វើការប្រកាសទោសដាក់ពន្ធនាគាររយៈពេលកំណត់មិនលើសពី៥ (ប្រាំ)ឆ្នាំ ដែលបានប្រព្រឹត្តក្នុងបទឧក្រិដ្ឋណាមួយ ពោលទោសនេះតុលាការអាចធ្វើការប្រកាសព្យួរបាន ។

---

[56] មាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

### ១.២.២ ចំពោះបទលហុ

យ៉ាងណាមិញបើយើងក្រឡេកមកមើលករណីបទលហុវិញម្តង តុលាការអាចប្រកាសឲ្យជនជាប់ចោទទទួលការអនុវត្តការព្យួរទោសធម្មតាផងដែរ ដោយហេតុថាបើគិតពីកម្រិតនៃទោសមានលក្ខណៈស្រាល មានន័យថាបទលហុនេះពុំមានព្យសនកម្មធ្ងន់ធ្ងរណាមួយដល់អ្នកដទៃក៏ដូចជាមិនធ្វើឲ្យសង្គមមានការភ័យខ្លាចឡើយ ហើយវាពិតជាសមហេតុសមផលណាស់ដែលច្បាប់ផ្តល់លទ្ធភាពឲ្យចៅក្រមអាចប្រកាសវិធានអនុវត្តបែបនេះទៅលើទណ្ឌិតនោះ ។ ជាការពិតណាស់ ក្រមព្រហ្មទណ្ឌមិនបានបញ្ជាក់កំណត់អំពីថិរវេលាជាក់លាក់នៃទោសសម្រាប់ប្រកាសដែលជាលក្ខខណ្ឌអនុញ្ញាតឱ្យតុលាការប្រកាសការព្យួរទោសធម្មតាឡើយ ត្រង់ចំណុចនេះគឺមានន័យថា ទោសដែលត្រូវបានតុលាការប្រកាសផ្តន្ទាទោសចំពោះបទលហុទាំងអស់ អាចជាកម្មវត្ថុនៃការព្យួរទោសធម្មតាបាន ពោលគឺ មូលទោសចំពោះបទលហុ ទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់[57] ។

## ២. អានុភាពនៃការព្យួរទោស

របបនៃការព្យួរទោសធម្មតា មានអានុភាពនៃការអនុវត្តទៅលើមូលទោស ។ ចំពោះបទមជ្ឈិម ឬបទឧក្រិដ្ឋ តុលាការអាចសម្រេចថាការព្យួរទោសធម្មតានេះ នឹងត្រូវអនុវត្តចំពោះមួយផ្នែកនៃទោសជាប់ពន្ធនាគារ ឬមួយផ្នែកនៃប្រាក់ពិន័យដែលនេះត្រូវបានកំណត់ដោយតុលាការ[58] ។ នេះមានន័យថាការព្យួរទោសធម្មតាពុំមែនព្យួរការអនុវត្តមូលទោសទាំងស្រុងនោះទេ គឺអានុភាពរបស់វាអាចអនុវត្តព្យួរទាំងស្រុង ឬ មួយផ្នែកនៃទោសពន្ធនាគារ ឬ អនុវត្តព្យួរទាំងស្រុង ឬ មួយផ្នែកនៃទោសពិន័យជាប្រាក់ប៉ុណ្ណោះ ហើយចំពោះថិរវេលានៃទោសពន្ធនាគារ ឬ ចំនួនទឹកប្រាក់ដែលត្រូវព្យួរនោះ គឺតុលាការជាអ្នកកម្រិត។ យ៉ាងណាមិញចំពោះបទលហុវិញក៏មិនខុសពីបទឧក្រិដ្ឋ និងបទមជ្ឈិមដែរ គឺការព្យួរទោសធម្មតាត្រូវអនុវត្តទៅលើទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់ ហើយដូចដែលពោលពីខាងដើមមកហើយថា តុលាការ គឺជាអ្នកកំណត់អំពីរយៈពេល និងចំនួនទឹកប្រាក់ដែលត្រូវប្រកាសឲ្យព្យួរ[59] ។ នេះជាភារៈរបស់ចៅក្រមដែលត្រូវតែបង្ហាញភាពជាក់លាក់ក្នុងការតាក់តែងកំណត់នៅក្នុងសាលក្រម ឬ សាលដីកា ដើម្បីអនុញ្ញាតឲ្យជនជាប់ចោទត្រូវអនុវត្តផ្នែកណាមួយនៃទោសពន្ធនាគារ ឬផ្នែកណាមួយនៃទោសពិន័យ ។ **ឧទាហរណ៍ទី១៖** បុគ្គលម្នាក់ បានប្រព្រឹត្តបទល្មើសទទួលផលចោរកម្ម ដូចមានចែងក្នុងក្រមព្រហ្មទណ្ឌមាត្រា៣៩៩ និងមាត្រា៤០០ តែដោយហេតុគាត់ទើបប្រព្រឹត្តលើកទីមួយ តុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារតែទោសនោះត្រូវអនុវត្ត១ (មួយ)ឆ្នាំ ក្នុងពន្ធនាគារ ហើយទោសដែលនៅសល់ត្រូវអនុវត្តព្យួរទោសធម្មតា។ **ឧទាហរណ៍ទី២៖** បុរស៣នាក់ ត្រូវបានចោទប្រកាន់ពី **បទឆបោក**

---

[57] មាត្រា ១១៣ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[58] មាត្រា ១០៨ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[59] មាត្រា ១១៣ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

លុយអ្នកដទៃ ដែលបទល្មើសមានចែងក្នុងក្រមព្រហ្មទណ្ឌ ហើយត្រូវបានតុលាការសម្រេចផ្តន្ទាទោសឲ្យជាប់ពន្ធនាគារក្នុងម្នាក់ៗកំណត់ចំនួន១ (មួយ)ឆ្នាំ តែទោសនេះត្រូវបានតុលាការសម្រេចឲ្យព្យួរទាំងស្រុង តាមមាត្រា៣៧៧, ៣៧៨,១០៧ នៃក្រមប្រហ្មទណ្ឌ ។ តាមរយៈឧទាហរណ៍ទាំងពីខាងលើសបញ្ជាក់ពីការបញ្ញត្តិនៃក្រមព្រហ្មទណ្ឌដែលកំណត់ថាការព្យួរទោសធម្មតាគឺ មានអានុភាពព្យួរនូវផ្នែកមួយ ឬទាំងស្រុងនៃទោសពន្ធនាគារ ឬទោសពិន័យជាប្រាក់ ។

បន្ថែមលើនេះចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិម បើកាលណាក្នុងរយៈពេល៥ (ប្រាំ) ឆ្នាំ ក្រោយពីមានទោសស្ថាពរពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ដោយមានការព្យួរទោសធម្មតា ហើយទណ្ឌិតនោះគ្មានការផ្តន្ទាទោសស្ថាពរណាមួយពីបទឧក្រិដ្ឋ ឬបទមជ្ឈិមទេនោះ ការផ្តន្ទាទោសដោយមានការព្យួរទោសនេះត្រូវចាត់ទុកជាអាសារបង់។ ទោសក៏មិនយកមកអនុវត្តទៀតបានឡើយ ហើយប្រសិនបើការព្យួរទោសត្រូវបានប្រកាសទៅលើតែផ្នែកណាមួយនៃទោសពន្ធនាគារ ឬទោសពិន័យជាប្រាក់ ការផ្តន្ទាទោសត្រូវចាត់ទុកជាអាសារបង់ទាំងស្រុង[60] ។រីឯចំពោះការចោទប្រកាន់ពីបទលហុវិញ បើក្នុងរយៈពេលពេល១ (មួយ)ឆ្នាំ បន្ទាប់ពីការផ្តន្ទាទោសជាស្ថាពរពីបទលហុដែលមានការព្យួរទោសនោះ ហើយគ្មានទោសថ្មីដែលបានចូលជាស្ថាពរណាមួយកើតចេញពីឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ នោះការផ្តន្ទាទោសដែលព្យួរនោះ ត្រូវទុកជាអាសារបង់ ហើយទោសក៏មិនយកមកអនុវត្តទៀតដែរ[61]។ នេះសបញ្ជាក់ឲ្យឃើញថាបើក្នុងករណីដែលទណ្ឌិតត្រូវបានតុលាការប្រកាសឲ្យអនុវត្តបបនេះហើយ ក្នុងអំឡុងពេលអនុវត្តក្នុងរយៈពេលដែលបានពោលខាងលើ ជនជាប់ចោទមិនត្រូវបានតុលាការប្រកាសឲ្យទទួលទោសស្ថាពរណាមួយពីបទល្មើសថ្មីទេ នោះទោសនឹងត្រូវចាត់ទុកជាអាសារបង់ទាំងស្រុង បើទោះជាការព្យួរទោសនេះអាចត្រូវបានផ្តល់ឲ្យចំពោះតែទោសមួយផ្នែកក៏ដោយ ពោលវានឹងមានអានុភាពដូចជាមានការអនុញ្ញាតឲ្យរួចខ្លួនជាស្ថាពរពីទោសទណ្ឌ។

## ៣. ការដកហូត និងការមិនដកហូតការព្យួរទោសធម្មតា

### ៣.១ ចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិម

ការព្យួរទោសធម្មតា ដែលអាចនិយាយបានថាជាការអនុញ្ញាតឲ្យរួចពីទោសមួយផ្នែកនៃទោសពន្ធនាគារ ឬមួយផ្នែកនៃទោសពិន័យនោះ ឬទាំងស្រុងក្នុងទោសណាមួយនៃមូលទោស គឺតុលាការអាចធ្វើការដកហូតបាន ទោះជាការព្យួរទោសនោះជាទោសអ្វីក៏ដោយឲ្យតែទោសនោះត្រូវបានចៅក្រមផ្តល់ឲ្យទណ្ឌិតចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិម ប្រសិនបើមានលេចឡើងនូវការប្រកាសផ្តន្ទាទោសស្ថាពរថ្មី ។ ក្នុងរយៈពេល៥ (ប្រាំ)ឆ្នាំ បន្ទាប់ពីការផ្តន្ទាទោសជាស្ថាពរពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ការព្យួរទោសនេះត្រូវដកហូតចេញដោយពេញច្បាប់ដោយទោសទី

[60] មាត្រា ១១១ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[61] មាត្រា ១១៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

មួយត្រូវអនុវត្តដោយមិនអាចស្រូបចូលជាមួយទោសទីពីរបានឡើយ[62] ។ **ឧទាហរណ៍៖** លោក ក បានប្រព្រឹត្ត បទល្មើស ត្រូវបានតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារចំនួន ២ឆ្នាំ ដោយទោសនេះត្រូវបានតុលាការ សម្រេចឱ្យព្យួរទោសធម្មតា។ លុះពីរឆ្នាំក្រោយមក លោក ក ដដែលនេះបានប្រព្រឹត្តបទល្មើសថ្មីមួយទៀត ហើយ ត្រូវបានតុលាការសម្រេចផ្តន្ទាទោសឱ្យជាប់ពន្ធនាគារចំនួន ៣ឆ្នាំ ។ ប្រសិនបើការផ្តន្ទាទោសបានចូលជាស្ថាពរ រួចហើយនៅពេលនោះ ដូច្នេះ ទណ្ឌិតត្រូវតែអនុវត្តទោសដោយបូកបញ្ចូលគ្នាជាចាំបាច់ ពោលគឺ ៣ឆ្នាំ(ទោស ដែលត្រូវបានផ្តន្ទាទោសសម្រាប់បទល្មើសថ្មី) បូកនឹង ២ឆ្នាំ (ទោសដែលត្រូវបានព្យួរកាលពីលើកមុន និងត្រូវ បានដកហូត ដោយសារមានការប្រព្រឹត្តបទល្មើសថ្មីក្នុងអំឡុងពេលព្យួរទោសធម្មតា)។ ហេតុដូច្នេះ លោក ក ត្រូវ តែអនុវត្តទោសដាក់ក្នុងពន្ធនាគាររយៈពេលចំនួន ៥ឆ្នាំ។ ផ្ទុយទៅវិញ តុលាការក៏អាចសម្រេចថាទណ្ឌកម្មថ្មីមិន នាំឲ្យមានការដកហូតនូវការព្យួរទោសធម្មតាដែលបានសម្រេចពីមុនបានផងដែរ ប៉ុន្តែតុលាការគប្បីត្រូវសរសេរ សំអាងហេតុពិសេស នៅក្នុងសេចក្តីសម្រេច[63] ។

### ៣.២ ចំពោះបទលហុ

បើយើងក្រឡេកមកមើលករណីដែលការព្យួរទោសដែលតុលាការផ្តល់ឲ្យមានមូលដ្ឋានចេញពីបទលហុ វិញក៏មិនខុសគ្នាដែរពីការដកហូតការព្យួរទោសចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិម គឺគ្រាន់តែរយៈពេលសម្រាប់បទ ឧក្រិដ្ឋ ឬបទមជ្ឈិម មានរយៈពេលវែងជាងបទលហុប៉ុណ្ណោះ ប៉ុន្តែចំពោះមូលហេតុវិញគឺដូចគ្នាពោលការដកហូត ការព្យួរទោសវិញ ដោយសារតែមានទោសថ្មីបានប្រកាសជាស្ថាពរ ។ ក្នុងនោះច្បាប់បានកំណត់ថា ប្រសិនបើក្នុង រយៈពេល១ (មួយ )ឆ្នាំ ក្រោយការផ្តន្ទាទោសជាស្ថាពរពីបទលហុ ដោយមានការព្យួរទោសធម្មតាផង ហើយកើត មានការផ្តន្ទាទោសស្ថាពរថ្មីមួយទៀតពីបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ការព្យួរទោសធម្មតានេះត្រូវបានដក ហូតចេញ ហើយទោសទីមួយត្រូវអនុវត្តដោយគ្មានការស្រូបចូលជាមួយទោសទីពីរឡើយ[64] ពោលគឺរយៈពេលនៃ ទោសទីមួយត្រូវអនុវត្តដោយបូលបញ្ចូលជាមួយទោសទីពីរដែលបានចូលជាស្ថាពរក្រោយនេះ ។ ផ្ទុយមកវិញ តុលាការអាចសម្រេចមិនដកហូតការព្យួរទោសមកវិញបានបើទោះបីជាមានការផ្តន្ទាទោសស្ថាពរថ្មីមួយទៀតក៏ ដោយត្រូវសរសេរសំអាងហេតុពិសេសនៅក្នុងសេចក្តីសម្រេចរបស់ខ្លួន[65]។

[62] មាត្រា ១០៩ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[63] មាត្រា ១១០ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[64] មាត្រា ១១៤ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[65] មាត្រា ១១៥ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

## ផ្នែកទី២ ការព្យួរទោសសាកល្បង

ការព្យួរទោសសាកល្បង ផ្ទុយពីការព្យួរទោសធម្មតា គឺមានន័យថាជាការអនុគ្រោះទោសមួយដែលចៅក្រមប្រកាសព្យួរដោយមានដាក់ឲ្យទណ្ឌិតស្ថិតក្រោមវិធានការត្រួតពិនិត្យ និងត្រូវគោរពនូវកាតព្វកិច្ចមួយចំនួនផងដែរ។

### ១. លក្ខខណ្ឌ និងអានុភាពនៃការព្យួរទោសសាកល្បង

ដើម្បីឲ្យកាន់តែមានភាពងាយស្រួលក្នុងការស្វែងយល់ យើងសូមធ្វើការបែងចែកចំណុចខាងលើជាពីរគឺលក្ខខណ្ឌដែលនាំឲ្យមានការព្យួរទោសសាកល្បង (១.១) និងអានុភាពនៃការព្យួរទោសសាកល្បង (១.២)។

#### ១.១ លក្ខខណ្ឌដែលនាំឲ្យមានការព្យួរទោសសាលល្បង

បើធ្វើការប្រៀបធៀបការព្យួរទោសសាកល្បងនេះ ជាមួយនឹងការព្យួរទោសធម្មតាឃើញថាការព្យួរទោសសាកល្បងមានលក្ខណៈទូលំទូលាយជាងព្រោះថា លក្ខខណ្ឌនៃការព្យួរទោសសាកល្បងហាក់មានភាពស្រាលជាង ពោលគឺគ្មានការគិតគូរពីការផ្តន្ទាទោសពីមុនដូចការព្យួរទោសធម្មតាឡើយ គឺគិតគូរតែពីការផ្តន្ទាទោសនាពេលបច្ចុប្បន្នប៉ុណ្ណោះ។ ចៅក្រមអាចសម្រេចឲ្យជនល្មើសទទួលរងទោសដោយអនុវត្តការព្យួរទោសសាកល្បងបាន កាលណាទោសជាប់ពន្ធនាគារមានរយៈពេលពី៦ (ប្រាំមួយ)ខែ ទៅ៥ (ប្រាំ)ឆ្នាំ ហើយរបបនេះអាចដាក់ឲ្យទណ្ឌិតក្នុងពេលសាកល្បងនោះ ស្ថិតក្រោមវិធានការត្រួតពិនិត្យ និងគោរពនូវកាតព្វកិច្ចដោយឡែកមួយ ឬច្រើនផងដែរ[66]។ ដូចដែលបានពោលពីខាងលើហើយថា របបនេះមានលក្ខខណ្ឌទូលំទូលាយជាងរបបនៃការព្យួរទោសធម្មតា តែផ្ទុយទៅវិញបែរជាការព្យួរទោសសាកល្បងនេះមានភាពចង្អៀតចង្អល់ជាងការព្យួរទោសធម្មតាទៅវិញ ពោលគឺតុលាការអាចប្រកាសព្យួរបានតែចំពោះទោសស្ថាពរខាងពន្ធនាគារប៉ុណ្ណោះ។

#### ១.២ អានុភាពនៃការព្យួរទោសសាកល្បង

របបព្យួរទោសសាកល្បង មានឧបនិស្ស័យអនុវត្តចំពោះតែរូបវន្តបុគ្គលប៉ុណ្ណោះ គឺមិនអនុវត្តចំពោះនីតិបុគ្គលឡើយ។ ចំណុចនេះដូចគ្នាទៅនឹងការអនុវត្តនៃការព្យួរទោសធម្មតាដែរ។ ក្នុងករណីចៅក្រមប្រកាសការព្យួរទោសសាកល្បងឲ្យអនុវត្ត ចៅក្រមត្រូវកំណត់រយៈពេលនោះពុំអាចតិចជាង១ (មួយ)ឆ្នាំ និងមិនអាចលើសពី៣ (បី) ឆ្នាំ ឡើយ[67] ។ ដូចនេះមានន័យថារបបនៃការព្យួរទោសសាកល្បង នេះតុលាការចាំបាច់ត្រូវតែកំណត់រយៈពេលនៃការអនុវត្តឲ្យច្បាស់ថា តើគេ ( ជនល្មើស ) ត្រូវអនុវត្តការព្យួរទោសសាកល្បងនេះមានរយៈពេលប៉ុន្មានហើយ ត្រូវគោរពវិធានការ និងកាតព្វកិច្ចដោយឡែកនៃរបបនេះនូវចំណុចណាខ្លះ។

---

[66] មាត្រា ១១៧ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[67] មាត្រា ១១៨ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

បន្ថែមលើនេះតុលាការ ( ចៅក្រម ) ត្រូវចេញសម្រង់សាលក្រមចំនួនបីច្បាប់ ដែលពីរច្បាប់សម្រាប់ជូនព្រះរាជអាជ្ញា និងមួយច្បាប់ទៀតសម្រាប់ឲ្យទណ្ឌិតដើម្បីអនុវត្ត។ រីឯព្រះរាជអាជ្ញាជាអ្នកដែលមានភារកិច្ចត្រូវដឹកនាំ សម្របសម្រួលការអនុវត្តសេចក្ដីសម្រេចការព្យួរទោសដែលតុលាការសម្រេច និងចាត់តាំងមន្ត្រីរាជការសាធារណៈដើម្បីធ្វើការតាមដានសកម្មភាពនៃការអនុវត្តរបស់ទណ្ឌិត[68]។

យ៉ាងណាមិញប្រសិនបើមុនពេលផុតរយៈពេលសាកល្បងគ្មានពាក្យសុំដកហូតដែលនាំឲ្យមានសេចក្ដីសម្រេចដកហូតពីតុលាការទេ ការផ្ដន្ទាទោសនឹងត្រូវចាត់ទុកជាអាសារបង់[69] ។ មានន័យថាបើការសាកល្បងបានប្រព្រឹត្តទៅដោយរលូនគ្មានឧប្បត្តិហេតុណាមួយកើតឡើង ហើយពេលវេលាដែលតុលាការបានកំណត់ទណ្ឌិតពុំត្រូវបានទទួលរងការដកហូតទេ បានន័យថាការផ្ដន្ទាទោសឲ្យជាប់ពន្ធនាគារដែលបានប្រកាសរួចហើយនោះ នឹងមិនត្រូវយកមកអនុវត្តទៀតឡើយ ពោលគឺគាត់ត្រូវរួចខ្លួនពីឥទ្ធិពលនៃទោសព្រហ្មទណ្ឌទាំងស្រុង។ **ឧទាហរណ៍៖** តុលាការធ្វើការប្រកាសផ្ដន្ទាទោសដាក់ពន្ធនាគារចំនួន ១ឆ្នាំ ចំពោះលោក **ក** ។ ក៏ប៉ុន្តែទោសនេះត្រូវបានតុលាការអនុញ្ញាតឱ្យព្យួរទោសសាកល្បង ដោយតុលាការបានកំណត់អំពីវិធានការត្រួតពិនិត្យ ឬកាតព្វកិច្ចដោយឡែកសម្រាប់អនុវត្ត និងរយៈពេលសាកល្បង **១០ខែ** នៅក្នុងសេចក្ដីសម្រេចរបស់តុលាការ។ ដូច្នេះហើយប្រសិនបើជាផុតរយៈពេល ១០ខែ ថែមទាំងលោក **ក** បានគោរពវិធានការត្រួតពិនិត្យ ឬ បំពេញកាតព្វកិច្ចដោយឡែកបានចប់សព្វគ្រប់ហើយ ពោលទោសដែលត្រូវបានតុលាការប្រកាសផ្ដន្ទាទោសដាក់ពន្ធនាគារចំនួន ១ឆ្នាំ គឺមិនអាចយកអនុវត្តបានទៀតទេ។

### ២. វិធានការត្រួតពិនិត្យ និងកាតព្វកិច្ចដោយឡែក

ដូចដែលធ្លាប់បានពោលពីខាងដើមរួចមកហើយថាការព្យួរទោសសាកល្បងក្នុងករណីដែលចៅក្រមសម្រេចផ្ដល់ឲ្យហើយបុគ្គលដែលទទួលបានការព្យួរសាកល្បងនេះ តុលាការនឹងត្រូវតម្រូវឲ្យទណ្ឌិតគោរពនូវវិធានការត្រួតពិនិត្យរបស់តុលាការ ឬ កាតព្វកិច្ចដោយឡែកផងដែរ។ នៅទីនេះយើងនឹងធ្វើការសិក្សាផងដែរអំពីវិធានការនោះ ពោលគឺវិធានការត្រួតពិនិត្យ និងកាតព្វកិច្ចដែលត្រូវគោរពនោះ។

#### ២.១ វិធានការត្រួតពិនិត្យ

យោងតាមបញ្ញត្តិនៃក្រមព្រហ្មទណ្ឌមាត្រា ១១៩ វិធានការដែលត្រូវប្រកាសឲ្យទណ្ឌិតអនុវត្តក្នុងឱកាសព្យួរទោសសាកល្បងនោះមានចំនួនប្រាំមួយចំណុច។ ***វិធានការ ត្រួតពិនិត្យដែលតម្រូវទៅទណ្ឌិត មានដូចតទៅ:***

***១ ទណ្ឌិតត្រូវតែគោរពតាមដីកាកោះរបស់ព្រះរាជអាជ្ញា ឬរបស់បុគ្គលដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឲ្យ ។***

[68] សារាចរលេខ ០២ កយ.សរ/១៤ស្ដីពីការអនុវត្តបទប្បញ្ញត្តិនៃការព្យួរទោសសាកល្បង ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៤

[69] មាត្រា១២៣ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

*២ ទណ្ឌិតត្រូវមកទទួលនូវការមើលពិនិត្យមើលរបស់បុគ្គលដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឲ្យ។*

*៣ ទណ្ឌិតត្រូវប្រគល់ដល់ព្រះរាជអាជ្ញាឬដល់បុគ្គលដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឲ្យ នូវគ្រប់ឯកសារសម្រាប់ធ្វើការផ្ទៀងផ្ទាត់លើការបញ្ចូលឲ្យទៅរស់នៅក្នុងសង្គមវិញ។*

*៤ ទណ្ឌិតត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា អំពីការផ្លាស់ប្តូរអាសយដ្ឋានរបស់ខ្លួន។*

*៥ ទណ្ឌិតត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញាអំពីការផ្លាស់ប្តូរមុខរបររបស់ខ្លួន។*

*៦ ទណ្ឌិតត្រូវតែមានការអនុញ្ញាតពីព្រះរាជអាជ្ញា មុនពេលធ្វើដំណើរទៅបរទេស។*

គួររំឭកបន្ថែមផងដែរថាវិធានការត្រួតពិនិត្យទាំង៦ ( ប្រាំមួយ )ចំណុចដែលបានលើកឡើងខាងលើនេះ ចៅក្រមអាចដាក់កំហិតឲ្យទណ្ឌិតដោយពិចារណាជ្រើសយកនូវមួយចំណុច ឬ ច្រើនចំណុចក្នុងចំណោមវិធានការនោះ នោះមានន័យថាវិធានការនេះពុំចាំបាច់ ដាក់ទាំងស្រុងក៏បានប៉ុន្តែទណ្ឌិតដាច់ខាតត្រូវតែអនុវត្តតាមបើពុំដូច្នោះទេនឹងក្លាយជាមូលហេតុដែលបណ្តាលឲ្យការព្យួរទោសសាកល្បងនេះត្រូវបានដកហូត។

### ២.២ កាតព្វកិច្ចដោយឡែករបស់ទណ្ឌិតជានីតិជន

បើក្រឡេកមកមើលកាតព្វកិច្ចដោយឡែកទាំង១៣ (ដប់បី) ចំណុចដែលមានបញ្ញត្តិក្នុងមាត្រា១២០ ក្រមព្រហ្មទណ្ឌវិញ មានអានុភាពអនុវត្តទៅលើគ្រប់បុគ្គលទាំងអស់ ពោលចៅក្រមអាចរើសយកមួយចំណុច ឬ ច្រើនតាមការយល់ឃើញយ៉ាងណាដែលខ្លួនគិតថាសមរម្យមកដាក់ឲ្យទណ្ឌិតអនុវត្ត។ យោងតាមមាត្រានេះ *កាតព្វកិច្ចដោយឡែកដែលអាចតម្រូវទៅលើទណ្ឌិតមានដូចតទៅៈ*

*១ បំពេញសកម្មភាពខាងវិជ្ជាជីវៈ។*

*២ ទទួលការបង្ហាត់បង្រៀន ឬទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈ។*

*៣ រស់នៅក្នុងទីកន្លែងណាមួយជាកំណត់។*

*៤ ទទួលឲ្យពេទ្យធ្វើការពិនិត្យ ឬការព្យាបាល។*

*៥ បញ្ជាក់ថាខ្លួនចូលរួមចំណែកក្នុងការចិញ្ចឹមបីបាច់គ្រួសារ។*

*៦ ធ្វើការជួសជុលការខូចខាតដែលបណ្តាលមកពីបទល្មើស តាមលទ្ធភាពនៃធនធានរបស់ខ្លួន។*

*៧ បញ្ជាក់ថាខ្លួនបានបង់ប្រាក់ជូនរដ្ឋបន្ទាប់ពីការផ្តន្ទាទោសតាមលទ្ធភាពធនធានរបស់ខ្លួន។*

*៨ មិនត្រូវធ្វើសកម្មភាពខាងវិជ្ជាជីវៈឬសង្គមដែលអនុញ្ញាត ឬ សម្រួលដល់ការប្រព្រឹត្តបទល្មើស។ ក្នុងករណីនេះតុលាការបញ្ជាក់អំពីសកម្មភាពដែលហាមឃាត់។*

*៩ មិនត្រូវមានមុខនៅទីកន្លែងខ្លះ។ ក្នុងករណីនេះតុលាការបញ្ជាក់អំពីទីកន្លែងដែលហាមឃាត់។*

*១០ មិនត្រូវសេពគប់បនល្បែង ។*

*១១ មិនត្រូវសេពគប់គ្រឿងភេសជ្ជៈស្រវឹង។*

*១២ មិនត្រូវសេពគប់ជាមួយបុគ្គលខ្លះពិសេសចារីសហចារី អ្នកផ្តើមគំនិត អ្នកសមគំនិត ឬ ជនរងគ្រោះនៃបទល្មើស។ ក្នុងករណីនេះតុលាការបញ្ជាក់អំពីបុគ្គលដែលមិនត្រូវសេពគប់ជាមួយ។*

*១៣ មិនត្រូវកាន់កាប់ ឬយកតាមខ្លួននូវអាវុធគ្រឿងផ្ទុះនិងគ្រាប់រំសេវគ្រប់ប្រភេទ។*

*នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនតុលាការត្រូវចែងអំពីកាតព្វកិច្ចដោយឡែកដែលតម្រូវទៅលើទណ្ឌិត ។* ដូចគ្នាទៅនឹងការអនុវត្តវិធានការត្រួតពិនិត្យផងដែរ ទណ្ឌិតត្រូវគោរពតាមសេចក្តីសម្រេចរបស់តុលាការចំពោះកាតព្វកិច្ចទាំងនោះ បើក្នុងករណីមិនប្រតិបត្តិតាមនោះ តុលាការអាចដកហូតការព្យួរទោសនោះបាន។

### ២.៣ កាតព្វកិច្ចដោយឡែករបស់ទណ្ឌិតជាអនីតិជន

ចំពោះអនីតិជនវិញក្នុងករណីគេបានប្រព្រឹត្តបទល្មើស ហើយតុលាការសម្រេចឲ្យអនុវត្តការព្យួរទោសសាកល្បងនោះកាតព្វកិច្ចដោយឡែកដែលពួកគេត្រូវគោរពគឺដាច់ដោយឡែកពីនីតិជនដែលចែងកំណត់ក្នុងមាត្រា ១២០ នោះ។ ពោលកាលណាត្រូវបានតុលាការប្រកាសឲ្យអនុវត្តទោសដោយមានការព្យួរទោសសាកល្បងនោះកាតព្វកិច្ចដោយឡែកនេះត្រូវកម្រិតមកត្រឹមតែ៩ ( ប្រាំបួន )ចំណុចប៉ុណ្ណោះ ដែលកាតព្វកិច្ចទាំងនោះសុទ្ធសឹងតែមានបំណងជាបឋមដើម្បីការពារ ជួយ និងអប់រំដល់ជនល្មើសជាអនីតិជននោះ។ តាមបញ្ញត្តិនៃមាត្រា១៦៥ នៃក្រមព្រហ្មទណ្ឌ ចែងថា*ក្នុងករណីនៃការព្យួរទោសសាកល្បងមានតែកាតព្វកិច្ចដោយឡែកដូចតទៅនេះប៉ុណ្ណោះដែលអាចអនុវត្តទៅលើអនីតិជន*

*១ ទទួលការបង្ហាត់បង្រៀន ឬការបណ្តុះបណ្តាលវិជ្ជាជីវៈ។*

*២ ស្ថិតនៅទីកន្លែងមួយជាកំណត់។*

*៣ ដាក់ខ្លួនឲ្យពេទ្យពិនិត្យ ឬ ព្យាបាល។*

*៤ ជួសជុលព្យសនកម្មដែលបណ្តាលមកពីបទល្មើសទៅតាមធនធានរបស់ខ្លួន។*

*៥ បង្ហាញភស្តុតាងបញ្ជាក់ថាខ្លួនបង់ទឹកប្រាក់ដែលជំពាក់ជូនរដ្ឋរួចហើយតាមលទ្ធភាពនៃធនធានរបស់ខ្លួនបន្ទាប់ពីការផ្តន្ទាទោស។*

*៦ មិនត្រូវបង្ហាញមុខនៅទីកន្លែងខ្លះ។*

*៧ មិនត្រូវសេពគប់ទីកន្លែងលក់ភេសជ្ជៈស្រវឹង។*

*៨ មិនត្រូវសេពគប់ជាមួយបុគ្គលខ្លះ ដោយឡែកជាមួយសហចារី អ្នកផ្តើមគំនិត អ្នកសមគំនិត ឬជនរងគ្រោះនៃបទល្មើស។*

*៩ មិនត្រូវកាន់កាប់ ឬ យកតាមខ្លួននូវអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ។*

### ៣. ការកែប្រែកាតព្វកិច្ចដោយឡែកដោយយុត្តាធិការ

ការកែប្រែកាតព្វកិច្ចត្រូវបានផ្តល់ភារៈជូនស្ថាប័នអាចធ្វើការកែប្រែនូវកាតព្វកិច្ចដោយឡែកដែលបានដាក់ឲ្យអ្នកដែលទទួលការព្យួរទោសនោះ ដោយមានមូលហេតុចេញពីកាលៈទេសៈនៃអង្គហេតុ ឬបុគ្គលិកលក្ខណៈរបស់ជនជាប់ចោទជាអាទិ៍។ យ៉ាងណាមិញនៅគ្រប់ពេលវេលា តុលាការអាចសម្រេចកែប្រែកាតព្វកិច្ចដោយឡែកដែលប្រកាសលើទណ្ឌិតបាន។ តាមមាត្រា១២១ ក្រមព្រហ្មទណ្ឌ តុលាការត្រូវបានទទួលបណ្តឹងនៅក្នុងលក្ខខណ្ឌដែលបានចែងដោយក្រមនីតិវិធីព្រហ្មទណ្ឌ។ ការទទួលបណ្តឹងរបស់តុលាការនោះ គឺអាចបណ្តាលមកពីការលំបាកក្នុងការអនុវត្តទោស ពោលគឺបណ្តាលមកពីទណ្ឌិតមិនគោរពកាតព្វកិច្ចដោយឡែក ឬកាលៈទេសៈសង្គមមិនអំណោយផលក្នុងការអនុវត្តជាអាទិ៍។ ហេតុនេះក្នុងករណីដែលជួបការលំបាកក្នុងការអនុវត្ត ត្រូវលើកជូនតុលាការជាន់ដំបូង ឬ បញ្ជូនទៅតុលាការជាន់ខ្ពស់ដែលជាអ្នកសម្រេចផ្តន្ទាទោសនោះធ្វើការដោះស្រាយ។ ការណ៍នេះតុលាការត្រូវទទួលបណ្តឹងតាមពាក្យបណ្តឹងរបស់ស្ថាប័នអយ្យការ ឬ ភាគីពាក់ព័ន្ធ ហើយតុលាការត្រូវសម្រេចក្នុងពេលកិច្ចពិភាក្សាដេញដោលជាសវនាការសាធារណៈបន្ទាប់ពីបានស្តាប់សេចក្តីថ្លែងការណ៍របស់អយ្យការ ភាគីពាក់ព័ន្ធឬ មេធាវីរបស់ភាគី[70]។ ការអនុវត្តទោសអាចត្រូវបានសាកសួរដោយតុលាការ។

### ៤ ការដកហូតការព្យួរទោសសាកល្បង

ការដកហូតការព្យួរសាកល្បងអាចត្រូវបានប្រកាសនៅក្នុងករណីចំនួនពីរដោយតុលាការគឺ

១ ក្នុងករណីដែលទណ្ឌិតមិនគោរពនូវវិធានការត្រួតពិនិត្យ ឬកាតព្វកិច្ចដោយឡែកដែលត្រូវបានដាក់ឲ្យទណ្ឌិតប្រតិបត្តិនិង។

២ ក្នុងករណីដែលទណ្ឌិតត្រូវបានតុលាការផ្តន្ទាទោសពីបទល្មើសឧក្រិដ្ឋ ឬ មជ្ឈិមថ្មីផ្សេងទៀតដែលបទល្មើសនោះត្រូវបានកើតឡើងក្នុងរយៈពេលសាកល្បងនេះ។

ការដកហូតការព្យួរទោសនោះតុលាការអាចសម្រេចដកហូតវិញទាំងស្រុង ឬ ដកហូតតែមួយផ្នែកស្តីពីការសាកល្បង ហើយប្រសិនបើដូច្នោះ នោះទោសនឹងត្រូវយកមកអនុវត្តទាំងមូល ឬ មួយផ្នែកតាមការដកហូតនេះផងដែរ។ ការដកហូតនេះតុលាការត្រូវបានទទួលបណ្តឹងស្របតាមលក្ខខណ្ឌដែលកំណត់ដោយក្រមនីតិវិធីព្រហ្មទណ្ឌ[71] មានន័យថាបណ្តឹងសុំដកហូតការព្យួរទោសត្រូវបានធ្វើឡើងដោយព្រះរាជអាជ្ញា កាលណាទណ្ឌិតនោះបានគេចវេចមិនប្រតិបត្តិ តាមកាតព្វកិច្ច ឬ វិធានការដែលចៅក្រមដាក់ឲ្យនោះ ព្រោះថាស្ថាប័នអយ្យការ គឺជាស្ថាប័នដែលជាអ្នកធានាក្នុងការអនុវត្តសេចក្តីសម្រេចខាងព្រហ្មទណ្ឌ និងម្យ៉ាងទៀតរាល់ទោសទាំងអស់គឺ

---

[70] មាត្រា ៥០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[71] មាត្រា ១២២ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

អយ្យការធ្វើការធានាក្នុងការអនុវត្តកាលណាសេចក្តីសម្រេចអំពីទោសនោះត្រូវបានចូលជាស្ថាពរ[72]។ ករណីមួយទៀត ប្រសិននៅក្នុងរយៈពេលសាកល្បងនេះ ទណ្ឌិតត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាថ្មីទៀតដែលទណ្ឌិតបានប្រព្រឹត្តនៅក្នុងរយៈពេលសាកល្បងនោះ ចំណុចនេះក៏ជាកម្មវត្ថុនៃការហូតការព្យួរទោសសាកល្បងបានដែរ។ តុលាការអាចធ្វើការដកហូតការព្យួរទោសសាកល្បងទាំងមូល ឬ មួយផ្នែក រីឯការអនុវត្តទោសវិញក៏ដូចគ្នាដែរ ទោសត្រូវយកអនុវត្តទាំងមូល ឬ មួយផ្នែកដូចគ្នា។

[72] មាត្រា ៤៩៧ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

# ជំពូកទី៣
# របបនៃការប្រកាសទោសដោយ
# ផ្អែកលើគោលការណ៍មនុស្សធម៌

# ជំពូកទី៣

# របបនៃការប្រកាសទោសដោយផ្អែកលើគោលការណ៍មនុស្សធម៌

នេះគឺជាយន្តការថ្មីដែលនីតិនិពន្ធបានដាក់បញ្ចូលមកក្នុងច្បាប់ព្រហ្មទណ្ឌខ្មែរនាពេលបច្ចុប្បន្ននេះ។ យន្តការទាំងនេះ គឺច្បាប់បានផ្តល់ឲ្យដោយផ្អែកលើគោលការណ៍មនុស្សធម៌ មានន័យថាការសម្រេចសេចក្តី គឺសម្រេចដោយសេចក្តីសម្បុរស ការយោគយល់ក្នុងពេលមានទុក្ខលំបាក ក្នុងគ្រាអាសន្នអន់ក្រ ឬភាពចាំបាច់ទាំងឡាយណាដែលជាភាពចាំបាច់សម្រាប់ជីវិត។ នៅទីនេះយើងនឹងធ្វើការពិភាក្សាលម្អិតទៅលើរបបបីដែលចៅក្រមសម្រេចផ្អែកលើគោលការណ៍មនុស្សធម៌នោះ គឺរបបនៃការផ្អាកការប្រកាសទោស ( ផ្នែកទី១ ) របបពាក់កណ្តាលសេរីភាព ( ផ្នែកទី២ ) និង របបនៃការបែងចែកជាប្រភាគ ( ផ្នែកទី៣ )។

## ផ្នែកទី១ របបនៃការផ្អាកការប្រកាសទោស

ការផ្អាកការប្រកាសទោស សំដៅដល់ការផ្អាកជាបណ្តោះអាសន្នក្នុងរយៈពេលណាមួយ បន្ទាប់ពីតុលាការបើកកិច្ចពិភាក្សាដេញដោលក្នុងពេលសវនាការ និងកំណត់ការប្រកាសម្តងទៀតជាថ្មី ប៉ុន្តែពុំបើកសវនាការជំនុំជម្រះម្តងទៀតនោះទេ។

### ១. លក្ខខណ្ឌនៃការផ្អាកការប្រកាសទោស

ការផ្អាកការប្រកាសទោសអាចប្រកាសចំពោះទណ្ឌិតបាន កាលណាចំណុចទាំងពីរត្រូវបានបំពេញគឺលក្ខខណ្ឌនៃបទល្មើសដែលត្រូវចោទប្រកាន់ ( ១.១ ) និងវត្តមានជនជាប់ចោទនាពេលសវនាការ ( ១.២ )។

#### ១.១ លក្ខខណ្ឌនៃបទល្មើសដែលត្រូវចោទប្រកាន់[73]

នៅក្នុងរបបមួយនេះ តុលាការអាចធ្វើការអនុវត្តបានចំពោះតែក្នុងករណីដែលបទល្មើសដែលជនល្មើសបានប្រព្រឹត្តនោះជាបទមជ្ឈិមប៉ុណ្ណោះ ដែលវាជាស្ថានភាពមួយក្នុងអំឡុងពេលសវនាការជនត្រូវចោទត្រូវបានតុលាការចោទប្រកាន់អំពីបទមជ្ឈិម និងឈានដល់ការប្រកាសអំពីពិរុទ្ធភាពដោយតុលាការ។ ប៉ុន្តែក្នុងករណីនេះតុលាការអាចសម្រេចប្រើយន្តការមួយនេះ ពោលគឺអាចធ្វើការផ្អាកសម្រេចអំពីទោស មិនទាន់ជាស្ថាពរភ្លាមៗនោះទេ ពោលដោយកំណត់កាលបរិច្ឆេទផ្សេងមួយទៀត សម្រាប់ការប្រកាសទោសនាពេលក្រោយ ហើយផ្អាកប្រកាសទោសអំពីពិរុទ្ធភាពដែលទើបតែរកឃើញនោះ។ បន្ថែមលើនេះដើម្បីអាចប្រកាសប្រើរបបនេះបាន ក៏ត្រូវបំពេញផងដែរចំពោះស្ថានភាពបីគឺ ភាពច្របូកច្របល់នៃសណ្តាប់ធ្នាប់សាធារណៈដែលបង្កឡើងដោយបទល្មើសត្រូវបានបញ្ចប់ (១.១.១) ជនជាប់ចោទបានបង្ហាញការធានាក្នុងការចូលទៅរួមរស់ក្នុងសង្គមវិញ( ១.១.២) និងជនជាប់ចោទសុំរយៈពេលដើម្បីជួសជុលការខូចខាត ( ១.១.៣ )។

[73] មាត្រា ១២៤ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

### ១.១.១ ភាពច្របូកច្របល់នៃសណ្តាប់ធ្នាប់សាធារណៈដែលបង្កឡើងដោយបទល្មើសត្រូវបានបញ្ចប់

បទល្មើសដែលបង្កឱ្យមានភាពភ្ញាក់ផ្អើលដល់សង្គមកាលពីបទល្មើសបានប្រព្រឹត្តបានស្ងប់ស្ងាត់ទៅវិញ ឬ អាចនិយាយម៉្យាងទៀតថាលែងមានអ្នកនឹកឃើញក៏ដូចជាពុំមានអ្នកចងចាំអំពីហេតុការណ៍ដែលកើតឡើងនោះទៀតហើយ។ នេះសបញ្ជាក់ថាគេចង់ផ្តោតទៅលើបទល្មើសដែលមានលក្ខណៈស្រាលៗ ពោលគឺជាគិតគូរតែចំពោះបទមជ្ឈិមស្រាលប៉ុណ្ណោះ ហើយម៉្យាងទៀតបទល្មើសនោះពុំមានបង្កឲ្យវិនាសដល់សាធារណៈជនធ្ងន់ធ្ងរ និងបទល្មើសនោះហាក់បីដូចជាមិនធ្វើឲ្យដក់ជាប់ក្នុងចិត្តរបស់នរណាម្នាក់ឡើយ។

### ១.១.២ ជនជាប់ចោទបានបង្ហាញការធានាក្នុងការចូលទៅរួមរស់នៅក្នុងសង្គមវិញ

ក្រោយពីប្រព្រឹត្តបទល្មើសជនជាប់ចោទបានស្តាយក្រោយ និងដឹងនូវកំហុសរបស់ខ្លួនយល់ព្រមកែប្រែខ្លួន និងបង្ហាញនូវអាកប្បកិរិយាវិជ្ជាមានឡើងវិញ ហើយធ្វើការសន្យាថាខ្លួនខិតខំប៉ះប៉ូវដើម្បីកសាងខ្លួនឲ្យក្លាយជាពលរដ្ឋល្អ ឈប់ប្រព្រឹត្តអំពើទាំងឡាយដែលនាំឲ្យវិនាសដល់អ្នកដទៃ ឬ ធ្វើឲ្យខូចខាតប្រយោជន៍សង្គមជាតិ បន្ទាប់ពីបានចូលខ្លួនទៅជាផ្នែកមួយនៃសង្គមវិញ។

### ១.១.៣ ជនជាប់ចោទសុំរយៈពេលដើម្បីជួសជុលការខូចខាត

នៅក្នុងអំឡុងពេលដែលតុលាការសម្រេចផ្តន្ទាទោស ហើយបង្គាប់ឲ្យបង់ប្រាក់ពិន័យ និងសងសំណងនៃការខូចខាតចំពោះព្យសនកម្មនៃអំពើរបស់ខ្លួន ប៉ុន្តែដោយសារកត្តាជីវភាពខ្លួនពុំទាន់មានលទ្ធភាពក្នុងការបង់ ពោលគឺខ្លួនត្រូវចាំបាច់ត្រូវការចេញទៅប្រកបការងារដើម្បីរកកម្រៃជាមុននោះ ជនជាប់អាចលើកយកមូលហេតុមួយនេះស្នើសុំទៅតុលាការឲ្យផ្តល់ឱកាសនេះមកឲ្យខ្លួនបាន។

## ១.២ វត្តមានជនជាប់ចោទនាពេលសវនាការ

ដោយយោងតាមក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ការផ្អាកការប្រកាសទោសគឺតម្រូវឲ្យទណ្ឌិតត្រូវមានវត្តមាននៅក្នុងកិច្ចសវនាការ។ ក្នុងនោះតុលាការត្រូវកំណត់នៅក្នុងសាលក្រម ឬ សាលដីកាផងដែរអំពីកាលបរិច្ឆេទដែលត្រូវសម្រេចអំពីទោស ហើយសេចក្តីសម្រេចអំពីទោសត្រូវតែធ្វើឡើងយ៉ាងច្រើនបំផុតមួយឆ្នាំក្រោយការផ្អាក[74]។ នេះបានន័យថាលក្ខខណ្ឌចាំបាច់ដែលជាហេតុនៃការពិចារណាក្នុងការផ្អាកប្រកាសទោស គឺវត្តមានជនជាប់ចោទនាពេលសវនាការ ហើយការផ្អាកពិរុទ្ធភាពដែលធ្វើឡើងដោយចៅក្រមពុំមែនជាការផ្អាកទោសមិនអនុវត្តហូតនោះទេ ពោលគឺបន្ទាប់ពីកិច្ចពិភាក្សាចប់សព្វគ្រប់ចៅក្រមគ្រាន់តែបញ្ជាក់ថាជននោះជាពិរុទ្ធជនប៉ុណ្ណោះ រីឯទោសដែលត្រូវទទួលរងនៅពុំទាន់ត្រូវបានប្រកាសឡើយ។ យ៉ាងណាមិញការផ្អាកនោះពុំមែនមាន

[74] មាត្រា ១២៥ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

ន័យថាជនជាប់ចោទត្រូវបានលើកលែងឲ្យរួចខ្លួនឡើយ គឺចៅក្រមនឹងធ្វើការកំណត់អំពីកាលបរិច្ឆេទថ្មីដោយបញ្ជាក់អំពី រយៈពេល ថ្ងៃ ខែ ឆ្នាំ ម៉ោង និងសាលសវនាការដែលត្រូវបើក ដើម្បីធ្វើការប្រកាសទោស ហើយកាលបរិច្ឆេទដែលត្រូវកំណត់ទោសនោះទៀតសោតត្រូវធ្វើយ៉ាងណាមិនឲ្យលើសពីរយៈពេលមួយឆ្នាំបន្ទាប់ពីសេចក្តីសម្រេចផ្អាកសវនាការលើកមុន។

## ២. សវនាការនៃការផ្អាកការប្រកាសទោស

នៅក្នុងចំណុចទី២នេះយើងនឹងធ្វើការសិក្សាលម្អិតទៅលើ កិច្ចពិភាក្សាដេញដោលក្នុងពេលសវនាការ ( ២.១) និងសវនាការពិនិត្យរឿងដែលបង្អង់ (២.២)។

### ២.១ កិច្ចពិភាក្សាដេញដោលក្នុងពេលសវនាការ

ជាដំណើការសវនាការដំបូងនៃការជំនុំជម្រះក្តីដែលតុលាការបានចាប់ផ្តើមនៅពេលដែលជនណាម្នាក់បានប្រព្រឹត្តបទល្មើស ហើយដំណើរការនៃរឿងក្តីបានឈានដល់ការជំនុំជម្រះ។ ការបើកកិច្ចសវនាការតុលាការដែលមានសមត្ថកិច្ចធ្វើការពិចារណាលើរឿងក្តីអំពីអង្គហេតុ និងអង្គច្បាប់ ថាតើពិរុទ្ធភាពនៃជននោះបានសម្រេចចំពោះបទល្មើសអ្វី ហើយតើទោសក្នុងទំហំប៉ុណ្ណាសាកសមនឹងតម្លៃដែលបទល្មើសនោះបង្ក ពោលដើម្បីស្វែងរកអំពីពិរុទ្ធភាពរបស់ជនត្រូវចោទក្នុងបទល្មើសមួយដែលកំពុងត្រូវចោទប្រកាន់នេះ។ ប្រសិនបើតុលាការពិនិត្យបន្ទាប់ពីកិច្ចសវនាការនោះ ឃើញថាជនជាប់ចោទពិតជាមានពិរុទ្ធពិតប្រាកដ និងជាបទមជ្ឈិមស្រាលនោះដូចលក្ខខណ្ឌតម្រូវ ហើយលក្ខខណ្ឌទាំងបីដែលជាហេតុដែលអាចនាំឲ្យផ្អាកការប្រកាសទោសដែលមានចែងក្នុងមាត្រា១២៤ ក្រមព្រហ្មទណ្ឌត្រូវបានបំពេញ នោះចៅក្រមអាចនឹងប្រើប្រាស់នូវយន្តការមួយនេះបាន ។ យ៉ាងណាមិញការផ្អាកនេះទៀតសោត គឺគ្រាន់តែជាការបញ្ឈប់ក្នុងរយៈពេលកំណត់ណាមួយដោយមិនទាន់ប្រកាសអំពីទណ្ឌកម្មដែលត្រូវអនុវត្តប៉ុណ្ណោះ ពោលគឺគ្រាន់តែជារយៈពេលមួយដែលចៅក្រមផ្តល់ឲ្យជនជាប់ចោទក្នុងស្ថានភាពលំបាកមួយពេលនោះទេ ហើយដោយត្រូវរង់ចាំកាលបរិច្ឆេទនៃការកំណត់ មកដល់នឹងធ្វើការសម្រេចអំពីទោស។

### ២.២ សវនាការពិនិត្យរឿងដែលបង្អង់

សវនាការនេះ គឺជាសវនាការដែលតុលាការបើកជាថ្មីបន្ទាប់ពីសវនាការដែលមានសេចក្តីសម្រេចផ្អាកនាពេលលើកមុន។ សវនាការនេះបើកឡើងតាមកាលបរិច្ឆេទដែលចៅក្រមបានកំណត់ទុករួចមកហើយតាំងពីពេលដែលការប្រកាសទោសត្រូវបានផ្អាកមកនោះ ស្របតាមលក្ខខណ្ឌដែលចែងដោយមាត្រា១២៤ និងមាត្រា១២៥ ក្រមព្រហ្មទណ្ឌ។ ការបើកនេះក្នុងគោលបំណងតែមួយគត់ គឺដើម្បីសម្រេចអំពីទោស ឬ អាចហៅម្យ៉ាងទៀត

ថាសវនាការប្រកាសទោស[75] មានន័យថាវាកើតឡើងក្រោយពីសេចក្តីសម្រេចលើការផ្អាកទោសក្នុងពេលសវនាការលើកមុនដែលកំណត់១ ( មួយ )ឆ្នាំយ៉ាងយូរក្រោយការសម្រេចផ្អាក ហើយសវនាការនេះទៀតសោធ គឺពុំធ្វើការពិភាក្សាដេញដោល ឬ ជំនុំជម្រះលើរឿងដដែលនោះទៀតឡើយ ព្រោះពិរុទ្ធភាពត្រូវបានរកឃើញតាំងតែពីកិច្ចពិភាក្សាក្នុងសវនាការលើកដំបូងមកម្ល៉េះ ហេតុនេះសវនាការដែលបើកក្រោយតាមកាលបរិច្ឆេទនៃសេចក្តីសម្រេចលើកមុនគឺជាការសម្រេចអំពីទោសដែលទណ្ឌិតត្រូវអនុវត្ត។

បន្ថែមលើនេះនៅក្នុងអំឡុងពេលដែលចៅក្រមប្រគល់ការផ្អាកទោស នេះមានន័យថាក្នុងចន្លោះរយៈពេលចាប់ពីសវនាការលើកទីមួយមកដែលសម្រេចមិនទាន់ប្រកាសទណ្ឌកម្មនោះ តុលាការនឹងពិនិត្យទៅលើកិច្ចខិតខំប្រឹងប្រែងរបស់ជនជាប់ចោទ ហើយប្រសិនបើក្នុងពេលនោះជនជាប់ចោទបានជួសជុលការខូចខាតបានទាំងស្រុង ហើយគាត់មានអាកប្បកិរិយាវិជ្ជមានផងនោះចៅក្រមអាចសម្រេចឲ្យជនជាប់ចោទរួចពីទោសដោយយោងតាមការពិចារណាលើចំណុចទាំងនេះបាន ប៉ុន្តែផ្ទុយទៅវិញប្រសិនបើជនជាប់ចោទពុំបានខិតខំប្រឹងប្រែងក្នុងអំឡុងពេលផ្អាកនោះ ឬ មានសកម្មភាពអវិជ្ជមានណាមួយបានកើតឡើង ចៅក្រមអាចប្រើនូវអំណះអំណាងទាំងនោះដើម្បីបន្ថែមទោសឲ្យកាន់តែធ្ងន់នៅពេលកាលបរិច្ឆេទប្រកាសទោសបាន[76]។ **ឧទាហរណ៍៖** លោក **ក** បានប្រព្រឹត្តអំពើលួចទូរស័ព្ទរបស់អ្នកដទៃដោយយកទៅលក់បានប្រាក់ ចាយវាយអស់។ សកម្មប្រព្រឹត្តអំពើលួចនេះ យោងតាមមាត្រា **៣៥៦** នៃក្រមព្រហ្មទណ្ឌ ទោសនេះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ)ខែ ទៅ ៣ (បី)ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន)រៀល។ ក្នុងករណី លោក **ក** បានទទួលស្គាល់កំហុសក៏ដូចជាបានសារភាពអំពីកំហុសដែលបានប្រព្រឹត្ត ហើយស្នើសុំតុលាការយៈពេល **៤ខែ** សម្រាប់រកថវិការដើម្បីជួសជុលការខូចខាតដល់ជនរងគ្រោះវិញ ដោយការស្នើសុំនេះគឺ លោក **ក** មានវត្តមានក្នុងសវនាការ។ ចំណុចនេះតុលាការអាចសម្រេចផ្អាកការប្រកាសទោសពីបទ **លួច** ដោយទុករយៈពេល **៤ខែ** ពោលតុលាការនឹងធ្វើការពន្យារកាលបរិច្ឆេទនៃការប្រកាសទោសដែលត្រូវផ្តន្ទាទោសចំពោះលោក **ក** ។ លុះដល់កាលបរិច្ឆេទដែលតុលាការត្រូវប្រកាសទោសសម្រាប់ផ្តន្ទទោស គឺរយៈពេល **៤ខែ** បានកន្លងផុតទៅ ករណីរយៈពេលពន្យារការប្រកាសទោសរបស់តុលាការ បើសិនលោក **ក** មិនបានសងថ្លៃទូរស័ព្ទវិញទៅជនរងគ្រោះទេ តុលាការនឹងធ្វើការប្រកាសទោស ដែលស្របជាមួយនឹងបទល្មើសនោះដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ។

## ផ្នែកទី២ របបនៃការប្រកាសទោសពាក់កណ្តាលសេរីភាព

របបពាក់កណ្តាលសេរីភាព គឺជារបបមួយដែលចៅក្រមផ្តល់លទ្ធភាពឲ្យទណ្ឌិតដោយអនុញ្ញាតឲ្យចេញទៅក្រៅពន្ធនាគារក្នុងរយៈពេលកំណត់មួយ ដើម្បីបំពេញសកម្មភាពវិជ្ជាជីវៈ ទទួលការសិក្សា ឬឧបត្ថម្ភដល់

[75] មាត្រា ១២៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩
[76] សៀវភៅសហប្រតិបត្តិការបារាំងកម្រោងទ្រទ្រង់នីតិរដ្ឋ មេរៀននីតិព្រហ្មទណ្ឌ ទំព័រទី៩៣

សេចក្ដីត្រូវការក្នុងគ្រួសារជាអាទិ៍ ហើយត្រូវត្រឡប់មកពន្ធនាគារវិញដើម្បីអនុវត្តទោស។ នេះគឺជាវិធានការឯកត្តកម្មថ្មីមួយដែលផ្ដល់ឲ្យទណ្ឌិតដែលពុំធ្លាប់មានទាល់តែសោះនៅក្នុងនីតិព្រហ្មទណ្ឌខ្មែរបុរាណដែលនីតិនិពន្ធបានបញ្ជូលមក។ ក្នុងនេះផងដែរ ផ្នែកនេះយើងនឹងធ្វើការសិក្សាទៅលើវិធានមួយនេះទាំងមូលអំពី លក្ខខណ្ឌនៃរបបពាក់កណ្ដាលសេរីភាព(១) បែបបទនៃការអនុវត្ត(២) ការរៀបចំ និងការលុបចោលរបបពាក់កណ្ដាលសេរីភាព(៣) ការចាប់ខ្លួន និងការឃុំខ្លួនទណ្ឌិត(៤)។

**១.លក្ខខណ្ឌនៃរបបពាក់កណ្ដាលសេរីភាព**

ចៅក្រមប្រកាសឲ្យទណ្ឌិតអនុវត្តនូវរបបពាក់កណ្ដាលសេរីភាពបានក្នុងករណីដែលទោសពន្ធនាគារដែលប្រកាសតិចជាង ឬ ស្មើនឹង៦ ( ប្រាំមួយ )ខែដើម្បីអនុញ្ញាតឲ្យទណ្ឌិតនេះអាចបំពេញសកម្មភាពវិជ្ជាជីវៈ បានទទួលការសិក្សា ឬ ការបណ្ដុះបណ្ដាល ឬ ការពិនិត្យព្យាបាលជំងឺ ឬជួយឧបត្ថម្ភដល់សេចក្ដីត្រូវការក្នុងគ្រួសារ[77] មានន័យថា យន្តការមួយនេះអនុញ្ញាតឲ្យទណ្ឌិតបានចាកចេញពីពន្ធនាគារដើម្បីទៅបំពេញកិច្ចការវិជ្ជាជីវៈរបស់ខ្លួន បន្តបង្រៀន ឬ សិក្សារៀនសូត្រ ការព្យាបាលខាងវិទ្យាសាស្ត្រ ហើយកាន់តែសំខាន់នោះគឺ ការរក្សាទំនាក់ទំនង និងផ្គត់ផ្គង់ជីវភាពគ្រួសារ។ វិធានការដកហូតសេរីភាពមួយនេះ អាចផ្ដល់ឲ្យចំពោះទោសពាក់ព័ន្ធត្រឹមតែទោសពន្ធនាគារដែលមានរយៈពេលខ្លីប៉ុណ្ណោះ ពោលគឺទោសដែលមានរយៈពេលតិចជាង ឬស្មើនឹង ៦ (ប្រាំមួយ) ខែ រីឯទោសដែលមានរយៈពេលលើសពីនេះពុំអាចត្រូវយកយន្តការនេះមកអនុវត្តឡើយ។

**២. បែបបទនៃការអនុវត្ត**

កាលណាទណ្ឌិតត្រូវបានដាក់ឲ្យស្ថិតនៅក្រោមរបបពាក់កណ្ដាលសេរីភាព គាត់នឹងត្រូវបានតុលាការអនុញ្ញាតឲ្យចាកចេញពីពន្ធនាគារនៅក្នុងរយៈពេលកំណត់មួយ ហើយនៅក្នុងសេចក្ដីសម្រេចរបស់ខ្លួន តុលាការចាំបាច់ត្រូវកំណត់ឲ្យបានជាក់លាក់អំពីម៉ោង អំពីថ្ងៃដែលត្រូវឲ្យទណ្ឌិតមានវត្តមាននៅក្នុងពន្ធនាគារ[78] មានន័យថានៅពេលមានទណ្ឌិតណាម្នាក់ត្រូវបានប្រកាសឲ្យអនុវត្តនូវយន្តការមួយនេះ គាត់ត្រូវបានតុលាការអនុញ្ញាតឲ្យមានសេរីភាពក្នុងមួយរយៈពេលដែលបានកំណត់ក្នុងសេចក្ដីសម្រេច ដើម្បីបំពេញសកម្មភាពការងារ ឬ ទៅបន្តការសិក្សា ឬអាជីព ឬដើម្បីព្យាបាលជំងឺប្រចាំកាយរបស់ខ្លួន ឬ ដើម្បីរកកម្រៃផ្គត់ផ្គង់គ្រួសារជាអាទិ៍។ ប៉ុន្តែការចាកចេញទៅបំពេញសកម្មភាពទាំងនេះពុំមែនធ្វើតាមតែការនឹកឃើញនោះឡើយពោល គឺចាំបាច់ត្រូវអនុវត្តតាមការកំណត់របស់តុលាការដែលបានសរសេរនៅក្នុងសាលក្រម អំពីរយៈពេល ម៉ោង ឬ ថ្ងៃ ដែលកំណត់នោះ។ ម្យ៉ាងទៀតរយៈពេលពាក់កណ្ដាលសេរីភាពត្រូវគិតបញ្ចូលទៅក្នុងរយៈពេលនៃទោសដែលកំពុងអនុវត្ត[79] បាន

[77] មាត្រា ១២៧ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[78] មាត្រា ១២៨ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[79] មាត្រា ១២៩ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

ន័យថារយៈពេលដែលគាត់អនុវត្តទោសនៅក្នុងគ្រឹះស្ថានពន្ធនាគារត្រូវគណនាឲ្យគ្រប់វិញតាមចំនួនទោសដែលតុលាការប្រកាស រីឯរបៀបនៃការគណនាទោសត្រូវគិតតាមការកំណត់នៃមាត្រា៤៩ ក្រមព្រហ្មទណ្ឌ។ **ឧទាហរណ៍៖** និស្សិតម្នាក់ត្រូវបានតុលាការផ្តន្ទាទោសពីបទបន្លំដែលមានចែងក្នុងមាត្រា ៣៨៤ ក្រមព្រហ្មទណ្ឌ ហើយត្រូវបានសម្រេចអំពីពិរុទ្ធភាពនោះ បន្ទាប់មកក៏ត្រូវបានតុលាការសម្រេចទោសឲ្យជាប់ពន្ធនាគាររយៈពេល ២ (ពីរ) ខែ តែទោសនេះត្រូវអនុវត្តក្រោមរបបពាក់កណ្តាលសេរីភាព ដោយសារទណ្ឌិតជានិស្សិតដែលត្រូវប្រឡងបញ្ចប់ថ្នាក់បរិញ្ញាបត្រ។ ដូច្នេះតុលាការបង្គាប់ឲ្យគាត់ចាកចេញពីពន្ធនាគារនៅពេលដែលត្រូវទៅបំពេញសកម្មភាពនោះចាប់ពីម៉ោង៦ (ប្រាំមួយ) ព្រឹកដល់ម៉ោង១៧ (ដប់ប្រាំពីរ)ល្ងាចហើយចាប់ពីម៉ោង១៨ (ដប់ប្រាំបី)ល្ងាចតទៅគាត់ត្រូវអនុវត្តទោសក្នុងពន្ធនាគារ រីឯរយៈពេលអនុវត្តក្នុងពន្ធនាគារត្រូវគណនាយ៉ាងណាបញ្ចូលឲ្យគ្រប់ចំនួនទោសពន្ធនាគារដែលបានប្រកាស។ **ឧទាហរណ៍៖** តុលាការបានសម្រេចអនុញ្ញាតឱ្យទណ្ឌិតឈ្មោះ **ឃ** ទទួលបានការអនុវត្តរបបពាក់កណ្តាលសេរីភាព ដោយព្រមអនុញ្ញាតឱ្យទណ្ឌិតចេញទៅនៅក្រៅពន្ធនាគារសម្រាប់រៀនសូត្រដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រ តុលាការកំណត់ចាប់ពីថ្ងៃច័ន្ទ ដល់ថ្ងៃសៅរ៍ ដោយចាប់ផ្តើមពីម៉ោង ៦ព្រឹក រហូតដល់ម៉ោង ៦ល្ងាច ក្រៅពីនេះទណ្ឌិតត្រូវតែអនុវត្តនៅក្នុងពន្ធនាគារឱ្យបានទៀងទាត់ដូចដែលតុលាការបានកំណត់។ ថ្វីត្បិតតែទណ្ឌិតចេញទៅនៅក្រៅពន្ធនាគារ ចាប់ពីថ្ងៃច័ន្ទ ដល់ថ្ងៃសៅរ៍ ដោយចាប់ផ្តើមពីម៉ោង ៦ព្រឹក រហូតដល់ម៉ោង ៦ល្ងាច ពិតមែន តែរយៈពេលនៃការនៅក្នុងពន្ធនាគារនេះ ត្រូវរាប់បញ្ចូលទៅក្នុងការអនុវត្តទោសយ៉ាងណាឲ្យគ្រប់ចំនួនទោសដែលតុលាការបានប្រកាស ស្របតាមការកំណត់នៃមាត្រា ១២៩ នៃក្រមព្រហ្មទណ្ឌ។ ដូច្នេះហើយ ករណីឧទាហរណ៍ខាងលើនេះ បើសិនទណ្ឌិតត្រូវបានតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារចំនួន ៦ខែ ហើយទោសនេះគឺអនុវត្តរបបពាក់កណ្តាលសេរីភាព គឺក្រោយរយៈពេល ៦ខែ ទណ្ឌិតពិតជាបានអនុវត្តទោសរបស់ខ្លួនបានចប់សព្វគ្រប់ ទោះបីជាមិនបាននៅក្នុងពន្ធនាគារទាំងស្រុងក៏ដោយក៏ត្រូវចាត់ទុកថាទណ្ឌិតបានអនុវត្តទោសដែលតុលាការបានកំណត់រួចរាល់ដែរ។

### ៣. ការរៀបចំ និងការលុបចោលរបបពាក់កណ្តាលសេរីភាព

ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ មាត្រា១៣០ បានបញ្ញត្តិថា ***នៅគ្រប់ពេលវេលាតុលាការអាចរៀបចំរយៈពេលនៃពាក់កណ្តាលសេរីភាព ឬ ក៏លុបចោលនូវរបបពាក់កណ្តាលសេរីភាពតាមបណ្តឹងរបស់ព្រះរាជអាជ្ញា។ តុលាការត្រូវបានទទួលដំណឹង នៅក្នុងលក្ខខណ្ឌដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ***។ មាត្រានេះបានលើកឡើងពីការផ្តល់ឲ្យទណ្ឌិតនូវការអនុវត្តរបបពាក់កណ្តាលសេរីភាព ដែលចៅក្រមអាចដកហូតបាននៅគ្រប់ពេលវេលាក្នុងករណីទណ្ឌិតមិនអនុវត្តកាតព្វកិច្ចដែលបានដាក់កំហិត ឬ ចំពោះចរិតលក្ខណៈ ឬ ឥរិយាបថមិនល្អទាំងឡាយរបស់ទណ្ឌិត ។ យោងតាមមាត្រានេះជាការពិតមិនអាចប្រកែកបានថាតុលាការមានសេរីភាពដោយអាចធ្វើការរៀបចំរយៈពេលរបបពាក់កណ្តាលសេរីភាព ឬ សម្រេចលុបចោលរបបនេះបានតាមបណ្តឹង

ដែលអយ្យការបានដាក់មក បានសេចក្តីថាតុលាការអាចបន្ថែមរយៈនៃការអនុវត្តពាក់កណ្តាលសេរីភាព ឬ អាចរៀបចំរយៈពេលនោះយ៉ាងណាស្របតាមកាលៈទេសៈ ឬ ស្រមតាមតម្រូវការសកម្មភាពដែលទណ្ឌិតត្រូវចេញទៅបំពេញ ឬម៉្យាងតុលាការអាចសម្រេចលុបចោលរបបនេះបាននូវគ្រប់ពេលវេលាទាំងអស់។ ក្នុងការអនុវត្តនៃតាមការបញ្ជាក់ខាងលើនេះ អាចធ្វើទៅបានតាមការស្នើសុំរបស់ព្រះរាជអាជ្ញានៅក្នុងករណីដែលមាន ការលំបាកក្នុងការអនុវត្តទោស[80] ដោយសារតែទណ្ឌិតមិនគោរពតាមការកំណត់របស់តុលាការ ឬ ក្នុងករណីដូចបានពោលខាងលើ ឬ ប្រសិនបើការអនុវត្តទោសមានវិវាទបានកើតឡើង[81]។

## ៤.ការចាប់ខ្លួន និងការឃុំខ្លួនទណ្ឌិត

ក្នុងករណីដែលទណ្ឌិតមិនអនុវត្តតាមសេចក្តីសម្រេច ដោយមិនគោរពតាមកាតព្វកិច្ចរបស់តុលាការតម្រូវឲ្យត្រឡប់មកពន្ធនាគារវិញ ព្រះរាជអាជ្ញាអាចបង្គាប់ឲ្យចាប់ខ្លួន និងឃុំខ្លួនទណ្ឌិតដែលមិនអនុវត្តកាតព្វកិច្ចនោះនៅពេលដែលរយៈពេលនៃពាក់កណ្តាលសេរីភាពបានកន្លងផុត [82]មានន័យថាបើរយៈពេលដែលតុលាការបានផ្តល់ឲ្យទណ្ឌិតមានសេរីភាពខាងក្រៅ ដើម្បីការសិក្សារៀនសូត្រ ដើម្បីទទួលការព្យាបាល ការបណ្តុះបណ្តាល ឬ ការផ្គត់ផ្គង់ជីវភាពគ្រួសារជាអាទិ៍នោះ បានដល់ពេលកំណត់ត្រូវវិលចូលទៅអនុវត្តទោសក្នុងពន្ធនាគារវិញ តែទណ្ឌិតបានគេចវេសមិនព្រមត្រឡប់តាមការកំណត់នោះ ដោយគ្មានមូលហេតុសមស្របដែលអាចឲ្យតុលាការជឿបាន ព្រះរាជអាជ្ញាអាចបង្គាប់ឲ្យចាប់ខ្លួន និងឃុំខ្លួនភ្លាមៗនូវទណ្ឌិតដែលមិនគោរពតាមសេចក្តីសម្រេចនោះឲ្យមកអនុវត្តទោសក្នុងពន្ធនាគារវិញ។

នេះជាសមត្ថកិច្ចផ្តាច់មុខរបស់ព្រះរាជអាជ្ញាក្នុងការតាមដានការអនុវត្តរបស់ទណ្ឌិត ព្រោះអង្គការអយ្យការជាអង្គការដែលធានាការអនុវត្តទោស ហើយនៅក្នុងការអនុវត្តយន្តការមួយនេះ ឬក្នុងករណីហេតុការណ៍ដែលបានពោលខាងលើបានកើតឡើង ព្រះរាជអាជ្ញាមានលទ្ធភាពអាចកេណ្ឌកងកម្លាំងសាធារណៈដោយផ្ទាល់ដើម្បីជាជំនួយក្នុងការអនុវត្តរបបពាក់កណ្តាលសេរីភាព ឬធ្វើការចាប់ខ្លួន និងបង្គាប់ឲ្យឃុំខ្លួនទណ្ឌិតដែលមិនអនុវត្តកាតព្វកិច្ចនោះ[83] ក្នុងពន្ធនាគារវិញ។

ជារួមមក របបពាក់កណ្តាលសេរីភាពដែលនីតិនិពន្ធបានបញ្ចូលក្នុងច្បាប់ព្រហ្មទណ្ឌនាពេលបច្ចុប្បន្ន ពិតជារបបមួយដែលបានផ្តល់អត្ថប្រយោជន៍ជាច្រើនដល់ទណ្ឌិត ព្រោះថាតាមរយៈរបបមួយនេះទណ្ឌិតមានលទ្ធភាពអាចចាកចេញទៅខាងក្រៅដើម្បីធ្វើការសិក្សារៀនសូត្រ ឬ ចេញទៅបំពេញសកម្មភាពមុខរបររបស់ខ្លួន ប៉ុន្តែ

---

[80] មាត្រា ៥០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[81] មាត្រា ៥៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[82] មាត្រា ១៣១ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[83] មាត្រា ២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

គ្រាន់តែលក្ខខណ្ឌនៃការប្រកាសហាក់មានភាពចង្អៀត និងទាមទារឲ្យទណ្ឌិតត្រូវគោរពចិរវេលាដាច់ខាតត្រូវត្រឡប់មកពន្ធនាគារវិញ។

## ផ្នែកទី៣ របបនៃការបែងចែកទោសជាប្រភាគ

ការបែងចែកទោសជាប្រភាគ បានដល់របៀបនៃការបែងចែកទោសទៅជាផ្នែកៗមួយចំនួនក្នុងរយៈពេលកំណត់មួយដែលទណ្ឌិតត្រូវ អនុវត្តនៅក្នុងពន្ធនាគារខ្លះ និងចេញក្រៅពន្ធនាគារខ្លះ ដោយមូលហេតុភាពធ្ងន់ធ្ងរដែលមកពីលក្ខណៈជាគ្រួសារ ជាវិជ្ជាជីវៈ ឬជាវេជ្ជសាស្ត្រជាអាទិ៍។ របបនេះក៏ជាយន្តការឯកត្តកម្មយុត្តាធិការទំនើបថ្មីមួយដែលនីតិនិពន្ធបានសម្រេចបញ្ចូលមកក្នុងប្រព័ន្ធនីតិខ្មែរ។ នៅក្នុងផ្នែកនេះយើងនឹងធ្វើការពិភាក្សាទៅលើលក្ខខណ្ឌនៃការបែងចែកទោសជាប្រភាគ ( ១ ) បែបបទនៃការអនុវត្ត ( ២ ) ការប្រែប្រួល ឬការលុបចោលរបបនៃការបែងចែកទោះជាប្រភាគ ( ៣ ) និងការចាប់ខ្លួន និងការឃុំខ្លួនទណ្ឌិត ( ៤ )។

### ១ លក្ខខណ្ឌនៃការបែងចែកទោសជាប្រភាគ

របបពាក់នៃការបែងចែកទោសប្រភាគទណ្ឌិតអាចត្រូវបានតុលាការសម្រេចប្រកាសកាលណាបើក្នុងករណីដែលតុលាការបានប្រកាសដាក់ទោសឲ្យជាប់ពន្ធនាគាររយៈពេលកំណត់តិចជាង ឬស្មើនឹង១ (មួយ)ឆ្នាំដោយសំអាងថាមានហេតុធ្ងន់ធ្ងរដែលមានលក្ខណៈជាគ្រួសារ ជាវេជ្ជសាស្ត្រ ឬ ជាវិជ្ជាជីវៈជាអាទិ៍[84]។ មានន័យថាចៅក្រមអាចផ្តល់ឲ្យទណ្ឌិតណាដែលត្រូវបានសម្រេចទោសពន្ធនាគារកំណត់រយៈពេលមិនលើសពី១ (មួយ)ឆ្នាំ ដោយត្រូវអនុវត្តជារបបពាកកណ្តាលសេរីភាពតាមការស្នើសុំរបស់សាមីខ្លួន ឬមេធាវី ដោយសារហេតុផលមានភាពចាំបាច់ត្រូវបំពេញសកម្មភាពប៉ុណ្ណោះ។ លក្ខខណ្ឌដែលទទួលបាននូវរបបមួយនេះបើធៀបនឹងរបបពាក់កណ្តាលសេរីភាពឃើញថាមានភាពធូរស្រាលជាងព្រោះលក្ខខណ្ឌនៃទោសពន្ធនាគារដែលប្រកាសមានរយៈពេល១ (មួយ)ឆ្នាំ រីឯរបបពាក់កណ្តាលសេរីភាពវិញមានត្រឹមតែទោសជាប់ពន្ធនាគារ៦ (ប្រាំមួយ)ខែប៉ុណ្ណោះ។

### ២.បែបបទនៃការអនុវត្ត

ទាក់ទងនឹងបែបបទនៃការអនុវត្តរបបនៃការបែងចែកទោសជាប្រភាគ ដោយអនុលោមតាមការកំណត់មាត្រា១៣៣ ក្រមព្រហ្មទណ្ឌ២០០៩ ប្រភាគនៃទោសនីមួយៗមិនត្រូវតិចជាងមួយខែទេ។ ចិរៈវេលាសរុបនៃការអនុវត្តទោសមិនអាចលើសពី២ (ពីរ)ឆ្នាំទេដោយរាប់បញ្ចូលទាំងការផ្អាកការអនុវត្តទោស។ តុលាការកំណត់ក្នុងសេចក្តីសម្រេចរបស់ខ្លួនអំពីបែបបទនៃការបែងចែកទោសជាប្រភាគ។ មាត្រានេះបញ្ញត្តិដោយចង់សំដៅថាក្នុងករណីដែលតុលាការសម្រេចដាក់ឲ្យទណ្ឌិតអនុវត្តយន្តការមួយនេះទោសដែលត្រូវគិតជាប្រភាគនេះមិនអាច

[84] មាត្រា ១៣២ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

អនុវត្តតិចជាងរយៈពេល១ (មួយ)ខែ ឡើយនៅក្នុងប្រភាគនីមួយៗ ឬអាចនិយាយបានថារបបនេះការអនុវត្តត្រូវគិតជាខែៗ ។ ម៉្យាងទៀតការកំណត់ប្រភេទនៃទោសធ្វើយ៉ាងណាមិនអាចអូសបន្លាយរហូតហួសរយៈពេល ២ (ពីរ)ឆ្នាំ បូករួមទាំងការផ្អាកការអនុវត្តទោសឡើយ ពោលរាល់ការអនុវត្តទាំងឡាយរបស់ទណ្ឌិតចៅក្រមមានភារៈចារនៅក្នុងសាលក្រមនាពេលប្រកាសទោសនោះ។ របបនេះមានគោលដៅសម្រួលការលំបាករបស់ទណ្ឌិតមួយចំនួនដែលមានភាពធ្ងន់ធ្ងរ និងចាំបាច់ដែលត្រូវធ្វើខាងតែបាន នាពេលត្រូវអនុវត្តទោសដកហូតសេរីភាពទាំងស្រុង។ ការបែងចែកទោសជាប្រភាគអនុញ្ញាតឲ្យទណ្ឌិតទទួលបានលទ្ធភាពរក្សាការងារ ទទួលបាននូវការព្យាបាលជំងឺ ឬដើម្បីទ្រទ្រង់ជីវភាពរស់នៅរបស់គ្រួសារជាអាទិ៍។ ការគិតរយៈពេលប្រភាគ ក្នុងរបបនេះត្រូវអនុលោមតាមមាត្រា៤៩ក្រមព្រហ្មទណ្ឌ។ **ឧទាហរណ៍៖** ជនម្នាក់ត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារចំនួន ៨ខែ ។ ដោយមូលហេតុជនជាប់ចោទមានជម្ងឺប្រចាំកាយ ត្រូវទទួលការព្យាបាលសម្រាកនៅមន្ទីពេទ្យជារៀងរាល់ខែ ដោយត្រូវសម្រាកពី ៣ថ្ងៃ ទៅ ៤ថ្ងៃ ជាចាំបាច់។ ករណីនេះតុលាការមានសិទ្ធិសម្រេចឱ្យមានការអនុវត្តនូវរបបបែងទោសជាប្រភាគ មានន័យថាជនជាប់ចោទជាប់ពន្ធនាគាររយៈពេល ៨ខែ ក៏ប៉ុន្តែទោសត្រូវយកមកអនុវត្តជាប្រភាគ ដោយឱ្យជាប់ពន្ធនាគាររយៈពេល ១ខែ ហើយអនុញ្ញាតឱ្យនៅក្រៅពន្ធនាគារ ១ខែ រហូតដល់គ្រប់ចំនួន ៨ខែ នៃការអនុវត្តទោសក្នុងពន្ធនាគារ។ ដូច្នេះហើយករណីខាងលើនេះ ចិរវេលាសរុបនៃការអនុវត្តទោស ដោយត្រូវរាប់បញ្ចូលទាំងការផ្អាកការអនុវត្តទោសផងនោះ មានរយៈពេល ១ឆ្នាំ និង៦ខែ ស្របតាមមាត្រា ១៣៣ នៃក្រមព្រហ្មទណ្ឌ។

### ៣. ការកែប្រែ ឬការលុបចោលរបបនៃការបែងចែកទោសជាប្រភាគ

ជាការពិតការកែប្រែ ឬ ការលុបចោលរបបនៃការបែងចែកទោសជាប្រភាគ និង របបពាក់កណ្តាលសេរីភាពហាក់ដូចជាមានភាពស្រដៀងគ្នា ពោលគឺនៅគ្រប់ពេលវេលាតុលាការអាចរៀបចំបែបបទ នៃការបែងចែកទោសជាប្រភាគ ឬ អាចលុបចោលនៃការបែងចែកទោសប្រភាគតាមបណ្តឹងរបស់ព្រះរាជអាជ្ញា។ តុលាការត្រូវបានទទួលបណ្តឹងនៅក្នុងលក្ខខណ្ឌដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ[85]។ ពោលកាលណាបើក្នុងករណីមាន បណ្តឹងសុំពីព្រះរាជអាជ្ញាតុលាការអាចទទួលបណ្តឹងនៅគ្រប់ពេលវេលាទាំងអស់ដើម្បីធ្វើការកែប្រែរបបពាក់កណ្តាលសេរីភាព ឬ ដកហូតរបបនេះចោលបានភ្លាមភ្លាមតែម្តង។ យ៉ាងណាមិញយើងបានពោលខាងលើថារបបនៃការបែងចែកទោសជាប្រភាគនិងរបបពាក់កណ្តាលសេរីភាពហាក់មានភាពដូចគ្នានោះគឺ ត្រង់ថាការរៀបចំជាថ្មី ការកែប្រែរបប ឬ ការដកហូតត្រឡប់វិញពីការអនុវត្តរបស់ទណ្ឌិតគឺកើតឡើងតាមរយៈបណ្តឹងសុំរបស់អយ្យការ និងលក្ខខណ្ឌដែលមានកំណត់ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។

---

[85] មាត្រា ១៣៤ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

### ៤. ការចាប់ខ្លួន និងការឃុំខ្លួនទណ្ឌិត

ព្រះរាជអាជ្ញាអាចបង្គាប់ឲ្យចាប់ខ្លួន និងឃុំខ្លួនទណ្ឌិតក្នុងពន្ធនាគារវិញបានកាលណាទណ្ឌិតដែលកំពុងស្ថិតក្រោមវិធានការអនុវត្តរបបនៃការបែងចែកទោសជាប្រភាគពុំគោរពតាមសេចក្ដីសម្រេចរបស់ចៅក្រម[86] ពេលនេះពុំមាន គិតត្រឹមថាបើទណ្ឌិតមិនគោរពរយៈពេលដែលតុលាការកំណត់ឲ្យមកអនុវត្តទោសក្នុងពន្ធនាគារវិញនោះទេគឺ ពិចារណារួមទាំងឥរិយាបថ ឬ សកម្មភាពរបស់ទណ្ឌិតជាអាទិ៍ផងដែរ ក៏អាចក្លាយជាមូលហេតុនៃការប្ដឹងសុំរបស់ព្រះរាជអាជ្ញាទៅកាន់តុលាការឲ្យធ្វើការកែប្រែរបបនៃការបែងចែកទោសជាប្រភាគ ឬលុបចោលរបបនេះពីការអនុវត្តតែម្ដង ដើម្បីបញ្ចៀសហានិភ័យនៅក្នុងសង្គម។ គួរបញ្ជាក់ដែរថានៅក្នុងអំឡុងពេលអនុវត្តទោស ការចាប់ខ្លួនទណ្ឌិតដែលល្មើសនឹងសេចក្ដីសម្រេចរបស់ចៅក្រម ព្រះរាជអាជ្ញាមានសិទ្ធិអំណាចពេញលេញក្នុងការកេណ្ឌកងកម្លាំងប្រដាប់អាវុធ ឬ កងកម្លាំងមន្ត្រីរាជការសាធារណៈទាំងឡាយដើម្បីជួយដល់ភារកិច្ចមួយនេះដូចដែលបានកំណត់ក្នុងមាត្រា២៧ និងមាត្រា៤៩៩ក្រមនីតិវិធីព្រហ្មទណ្ឌ។

សរុបសេចក្ដីមក របបនៃការបែងចែកទោសជាប្រភាគហាក់បីមានការបើកទូលាយដល់ទណ្ឌិតអាចធ្វើការស្នើអនុវត្តក្នុងករណីដែលខ្លួនកំពុងតែជួបប្រទះនូវស្ថានភាពចាំបាច់ដែលត្រូវបំពេញ ព្រោះថារយៈពេលដែលដែលជាលក្ខខណ្ឌចម្បងកំណត់រហូតដល់ទៅរយៈពេលមួយឆ្នាំ ហើយចំណែកឯរយៈពេលក្នុងការចេញទៅបំពេញសកម្មភាពរបស់ខ្លួន នឹងការត្រឡប់មកអនុវត្តទោសវិញត្រូវបានផ្ដល់ឲ្យជាខែថែមទៀត។

[86] មាត្រា ១៣៥ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

# សេចក្តីសន្និដ្ឋាន

# សេចក្ដីសន្និដ្ឋាន

រាប់ចាប់តាំងពីពេលចាប់ផ្ដើមរហូតមកដល់ទីបញ្ចប់នៃការសិក្សាស្រាវជ្រាវទៅលើប្រធានបទរបបនៃការប្រកាសទោសនៅក្នុងរឿងក្ដីព្រហ្មទណ្ឌមួយនេះ យើងសង្កេតឃើញថារបបនៃការប្រកាសទោសនេះពិតជាផ្ដល់ផលប្រយោជន៍ជាច្រើនដល់ការប្រកាសទោសរបស់ចៅក្រមឲ្យមានភាពងាយស្រួល និងមានមូលដ្ឋានក្នុងការសម្រេចសេចក្ដីបានច្បាស់លាស់ និងមានភាពហ្មត់ចត់គ្រប់ជ្រុងជ្រោយ។ របបនេះបានផ្ដល់លទ្ធភាពពិចារណា និងជម្រើសជាច្រើនជូនចៅក្នុងការសម្រេចសេចក្ដីថាគួរប្រើវិធានការណាមួយនៃការប្រកាសទោសមកប្រកាសដាក់ចំពោះទណ្ឌិតឲ្យអនុវត្ត។ ប៉ុន្តែបើទោះបីជាយើងនិយាយថារបបនេះមានសារៈប្រយោជន៍ច្រើន ក៏ពុំមែនមានន័យថាមានភាពទន់ខ្សោយនោះដែរ ពោលគឺទោសនឹងត្រូវសម្រេចអាស្រ័យទៅលើបទល្មើស ព្រមទាំងអាស្រ័យលើបុគ្គលផ្ទាល់ ពិសេសដូចបានកំណត់ក្នុងគោលការណ៍ឯកត្តកម្មនៃទោសជាដើម។ ក្នុងការប្រកាសទោសនេះទៀតសោធ គឺដាក់ទោសដោយស្មើគ្នាចំពោះមុខច្បាប់នូវរាល់បុគ្គល ទាំងនីតិបុគ្គល និងរូបវន្តបុគ្គលដោយពុំមានការរើសអើង ពុំមានការលម្អៀង ពោលតុលាការធ្វើការសម្រេចទៅតាមការកំណត់ក្នុងលក្ខខណ្ឌដែលច្បាប់របស់កម្ពុជាបានកំណត់។ ជាពិសេសគឺតាមរយៈគោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌដែលបរិយាយអីអំពីលក្ខខណ្ឌដែលអ្នកប្រព្រឹត្តបទល្មើសត្រូវទទួលរងទណ្ឌកម្ម និងគោលការណ៍ឯកត្តកម្មនៃទោសដែលជាគ្រឹះដ៏រឹងមាំដែលតុលាការយកមកធ្វើជាមូលដ្ឋានក្នុងការពិចារណាមុនពេលសម្រេចទោសហើយក៏ត្រូវគោរពតាមផងដែរចំពោះគោលការណ៍នីត្យានុកូល នៃបទល្មើសនិងនៃទោសព្រោះមានតែបទល្មើស និងទោសដែលបានកំណត់ជាក់លាក់ក្នុងច្បាប់ប៉ុណ្ណោះទើបអាចប្រកាសផ្ដន្ទាទោសបាន។

ជាចុងក្រោយយើងអាចធ្វើការសន្និដ្ឋានបានថារបបនៃការប្រកាសទោសដែលបញ្ញត្តិក្នុងក្រមព្រហ្មទណ្ឌ ២០០៩ មានយន្តការជាច្រើនដែលប្រព័ន្ធច្បាប់ខ្មែរកាលពីបុរាណពុំដែលធ្លាប់មាន ដែលនេះអាចបង្ហាញឲ្យឃើញថាប្រព័ន្ធនីតិព្រហ្មទណ្ឌខ្មែរមានការរីកចម្រើនគួរឲ្យកត់សម្គាល់។ របបនីមួយៗដែលមានក្នុងដំណាក់កាលនៃការប្រកាសទោសនោះពុំមែនបង្កត្រឹមតែភាពងាយស្រួលដល់ចៅក្រមក្នុងកាជ្រើសរើសយកមកប្រកាសនោះទេ គឺវាក៏បានផ្ដល់នូវលទ្ធភាព និងប្រយោជន៍ជាច្រើនដល់សង្គមផងដែរ អ្វីដែលកាន់តែពិសេសនោះគឺផ្ដល់ការអនុគ្រោះច្រើនដល់ទណ្ឌិត ក្នុងនោះផងដែរ ផលប្រយោជន៍ដែលទទួលបានយើងអាចឃើញក្នុងយន្តការការថ្មីៗដែលនីតិព្រហ្មទណ្ឌខ្មែរពីមុនពុំធ្លាប់មានដូចជា របបពាក់កណ្ដាលសេរីភាព ឬ ការបែងចែកទោសជាប្រភាគជាអាទិ៍។ របបទាំងនេះបានផ្ដល់លទ្ធភាពឲ្យទណ្ឌិតអាចថែរក្សា ក៏ដូចជាបន្តនូវសកម្មភាពរបស់ខ្លួន មិនឲ្យបាត់បង់ ឬ ខូតខាតឡើយ ពោលគឺគេគិតគូរពីប្រយោជន៍របស់ទណ្ឌិតផងដែរ។ មិនតែប៉ុណ្ណោះក្នុងរបបនៃការប្រកាសទោសនេះទៀតសោធក៏ផ្ដល់នូវអត្ថប្រយោជន៍ជាច្រើនដល់សង្គមជាតិផងដែរដូចជា នៅក្នុងរបបនៃការប្រកាសទោសទូទៅ ក្នុងលក្ខខណ្ឌនៃទោសជំនួសទោសការងារសហគមន៍ត្រូវបាន បង្គាប់ឲ្យទណ្ឌិតដែលបានសម្រេច

ពិរុទ្ធហើយឲ្យធ្វើការងារសង្គមដើម្បីជាប្រយោជន៍ដល់សាធារណជនជំនួសឲ្យការប្រកាសទោសដកហូតសេរីភាព។ ម៉្យាងទៀតថ្វីត្បិតតែមានរបបខ្លះផ្តល់នូវប្រយោជន៍ដល់ទណ្ឌិតមែនពិតតែក្នុងស្ថានភាពទូទៅ ជនល្មើសពុំអាចគេចផុតបានអំពីការប្រកាសទោសដកហូតសេរីភាពក្នុងក្របខណ្ឌនៃការប្រកាសទោសទូទៅ ព្រោះច្បាប់គិតគូរជាខ្លាំងដល់សុវត្ថិភាពភាពក្នុងសង្គម។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវទៅលើប្រធានបទ " **របបនៃការប្រកាសទោសនៅក្នុងរឿងក្តីព្រហ្មទណ្ឌ** " រួចបើទោះជាច្បាប់ព្រហ្មទណ្ឌបានផ្តល់នូវលទ្ធភាព ប្រយោជន៍ និងនវានុវត្តន៍នៃបរិបទទោសមានការរីកវឌ្ឍជាច្រើនពីប្រព័ន្ធច្បាប់កាលពីបុរាណដែលនៅកម្ពុជាយើងធ្លាប់មានពីមុនមកមែនពិត ប៉ុន្តែផ្នែកខ្លះនៃរបបនេះហាក់មានភាពកកស្ទះពុំទាន់អាចអនុវត្តបាននៅឡើយ ហើយផ្នែកខ្លះក៏អនុវត្តបានបន្តិចបន្តួចផងដែរនោះបើផ្អែកតាមការអនុវត្ត ជាក់ស្តែងនៅកម្ពុជា។ ជាក់ស្តែងដូចជាទោសការងារសហគមន៍ របបនៃការព្យួរទោសដូចជាការព្យួរទោសធម្មតាហាក់មានការអនុវត្តពុំទាន់មានភាពទូលំទូលាយនៅឡើយ រីឯការព្យួរសាកល្បងក៏ពុំមានការអនុវត្តណាមួយគួរឲ្យកត់សម្គាល់ផងដែរគិតមកដល់ពេលបច្ចុប្បន្ន។ ដោយឡែករបបនៃការផ្អាកការប្រកាស របបពាក់កណ្តាលសេរីភាព និងការបែងចែកទោសជាប្រភាគដែលជាយន្តការថ្មី ដែលនីតិនិពន្ធបានបញ្ចូលក្នុងក្រមព្រហ្មទណ្ឌនោះពុំមានរំលេចរូបរាងនៃការអនុវត្តទាល់តែសោះ ដែលនេះមើលទៅហាក់បីដូចជាយន្តការទាំងបីនេះគ្មានប្រយោជន៍សោះនៅក្នុងប្រព័ន្ធយុត្តាធិការកម្ពុជា។ យ៉ាងណាមិញច្បាប់បានកំណត់ផ្លូវសម្រាប់អនុវត្តរួចទៅហើយ ប៉ុន្តែការអនុវត្តនូវពុំទាន់អាចធ្វើទៅបានតាមកាលកំណត់នោះ គឺដោយសារកង្វះខាតខាងធនធានថវិកា បច្ចេកវិទ្យានៅពុំទាន់មានភាពទូលំទូលាយ ស្ថានភាពសង្គមពលរដ្ឋខ្វះការយល់ដឹងអំពីបញ្ហាច្បាប់ ពិសេសនោះធនធានមនុស្សដែលជាអ្នកមានសមត្ថភាពអនុវត្ត ក៏ដូចជាអ្នកជំនួយនៅពេលអនុវត្តគោលការណ៍ច្បាប់ នៅពុំទាន់មានគ្រប់គ្រាន់នៅឡើយ ហើយក៏អាចនិយាយបានថាដោយសារតែភាគច្រើនជារបបថ្មីហេតុនេះសេចក្តីណែនាំ ឬ បទដ្ឋានគតិយុត្តដែលពាក់ព័ន្ធទៅនឹងការអនុវត្តពុំទាន់មាន ដែលជាហេតុធ្វើឲ្យចៅក្រមមិនអាចប្រើយុទ្ធសាស្ត្រនេះក្នុងការអនុវត្តជាក់ស្តែងបាន។

ដូច្នេះជាចុងក្រោយដើម្បីឲ្យរបបនៃការប្រកាសទោសនោះអាចអនុវត្តពេញលេញ យើងខ្ញុំដែលជានិស្សិតដែលជាអ្នកសិក្សាស្រាវជ្រាវយល់ថាក្រសួងដែលពាក់ព័ន្ធនៅកម្ពុជាជាពិសេសក្រសួងយុត្តិធម៌គួរតែ៖

១. បង្កើនការបញ្ជ្រាបការផ្សព្វផ្សាយច្បាប់ទៅក្នុងសង្គមដើម្បីឲ្យពលរដ្ឋយល់ដឹងអំពីយន្តការច្បាប់តាមគ្រប់វិធីឲ្យបានច្រើនៗ

២. បង្កើនការយល់ដឹង និងជំនាញពិតប្រាកដទៅលើផ្នែកបច្ចេកវិទ្យាដែលអាចជាជំនួយក្នុងការអនុវត្តទោសតាមបរិបទសង្គមឲ្យបានជឿនលឿន និង

៣. ធ្វើការបណ្តុះបណ្តាលមន្ត្រីជំនាញដែលមានសមត្ថភាពឲ្យជួយដល់ការអនុវត្តទាក់ទងនឹងរបបនៃការប្រកាសទោស ឬ ជាជំនួយក្នុងការអនុវត្តគោលការណ៍ច្បាប់ឲ្យបានគ្រប់គ្រាន់ និង

៤. ពិសេសនោះគឺបង្កើតនូវយុទ្ធសាស្ត្រជា សេចក្តីណែនាំ ឬលិខិតបទដ្ឋានគតិយុត្តដទៃទៀតដែលកំណត់អំពីវិធីអនុវត្ត ដើម្បីចៅក្រមអាចយកវាមកធ្វើជាមូលដ្ឋាននាពេលធ្វើការប្រើវិធានការដែលរាំងស្ទះទាំង៣ខាងលើនោះ។

# ឯកសារយោង

# ឯកសារយោង

## ១. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩
- ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧
- ច្បាប់ស្តីពី យុត្តិធម៌អនីតិជន ឆ្នាំ២០១៦
- ច្បាប់ស្តីពី ត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១២
- សារាចរលេខ ០២កយ.សរ/១៤ ស្តីពីការអនុវត្តបទប្បញ្ញត្តិ នៃការព្យួរទោសសាកល្បង ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៤
- សារាចរលេខ ០៣ កយ.សរ/១៤ ស្តីពីការអនុវត្តបទប្បញ្ញត្តិនៃ ការអនុវត្តទោសការងារសហគមន៍ ចុះថ្ងៃទី២២ មករា ២០១៤

## ២. សៀវភៅមេរៀនច្បាប់

- មេរៀននីតិព្រហ្មទណ្ឌ របស់សហប្រតិបត្តិការបារាំងគម្រោងទ្រទ្រង់នីតិរដ្ឋ ឆ្នាំ២០០៨

# **បញ្ជីឧបសម្ព័ន្ធ**

- **ឧបសម្ព័ន្ធទី១** ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩
- **ឧបសម្ព័ន្ធទី២** ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦
- **ឧបសម្ព័ន្ធទី៣** សារាចរលេខ ០២ កយ.សរ/១៤ ស្តីពីការអនុវត្តបទប្បញ្ញត្តិ នៃការព្យួរទោសសាកល្បង ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៤
- **ឧបសម្ព័ន្ធទី៤** សារាចរលេខ ០៣ កយ.សរ/១៤ ស្តីពីការអនុវត្តបទប្បញ្ញត្តិនៃ ការអនុវត្តទោសការងារសហគមន៍ ចុះថ្ងៃទី២២ មករា ២០១៤
- **ឧបសម្ព័ន្ធទី៥** សាលក្រមព្រហទណ្ឌ សម្រេចអំពីមូលទោស (ដាក់ពន្ធនាគារផង និងពិន័យជាប្រាក់ផង)
- **ឧបសម្ព័ន្ធទី៦** សាលក្រមព្រហទណ្ឌ សម្រេចអំពីមូលទោស (ដាក់ពន្ធនាគារ)
- **ឧបសម្ព័ន្ធទី៧** សាលក្រមព្រហទណ្ឌ សម្រេចអំពីមូលទោស (អនីតិជន)
- **ឧបសម្ព័ន្ធទី៨** សាលក្រមព្រហទណ្ឌ សម្រេចអំពីទោសបន្ថែម
- **ឧបសម្ព័ន្ធទី៩** សាលក្រមព្រហទណ្ឌ សម្រេចអំពីការព្យួរទោសធម្មតា (មួយផ្នែកចំពោះទោសពន្ធនាគារ)
- **ឧបសម្ព័ន្ធទី១០** សាលក្រមព្រហទណ្ឌ សម្រេចអំពីការព្យួរទោសធម្មតា (ទាំងស្រុងចំពោះទោសពន្ធនាគារ)
- **ឧបសម្ព័ន្ធទី១១** សាលក្រមព្រហទណ្ឌ សម្រេចអំពីការព្យួរទោសសាកល្បង (មានកាតព្វកិច្ច)
- **ឧបសម្ព័ន្ធទី១២** សាលក្រមព្រហទណ្ឌ សម្រេចអំពីការព្យួរទោសសាកល្បង (មានវិធានការ និងកាតព្វកិច្ច)

# ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី ២

រដ្ឋសភា
ចូល
លេខ
ថ្ងៃទី ឆ្នាំ ម៉ោង
បញ្ជូនទៅ

# ច្បាប់
# ស្តីពី
# យុត្តិធម៌អនីតិជន

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ព្រះរាជក្រម

នស/រកម/០៧១៦/០០៩

## យើង

### ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
### សមានតូមិជាតិសាសនា រក្ខតខត្តិយា ខេមរជាតិរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
### ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
### ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៦ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៦ នាសម័យប្រជុំសាមញ្ញ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

# ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

### មាត្រា ១.- គោលបំណង

ច្បាប់នេះមានគោលបំណង៖

- ធានាការពារសិទ្ធិ និងឧត្តមប្រយោជន៍របស់អនីតិជនដែលប្រព្រឹត្តបទល្មើស
- គាំទ្រដល់ការស្តារនីតិសម្បទា និងការធ្វើសមាហរណកម្មអនីតិជនទៅក្នុងសង្គម និង សហគមន៍
- ធានាការពារផលប្រយោជន៍សង្គមនិងសហគមន៍ ។

### មាត្រា ២.- គោលដៅ

ច្បាប់នេះមានគោលដៅកំណត់អំពីវិធាន និងនីតិវិធីទាំងឡាយដែលត្រូវគោរព និងប្រព្រឹត្តតាមដោយហ្មត់ចត់ ដើម្បីកំណត់ឲ្យបានច្បាស់នូវអត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌណាមួយដែលប្រព្រឹត្តដោយអនិតិជន ។

បទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមព្រហ្មទណ្ឌ និងច្បាប់ដោយឡែកផ្សេងទៀត ត្រូវយកមកអនុវត្ត លើកលែងតែក្នុងករណីដែលមានចែងនៅក្នុងច្បាប់នេះ ។

### មាត្រា ៣.- វិសាលភាព

ច្បាប់នេះមានវិសាលភាពអនុវត្តលើករណីអនីតិជនប្រព្រឹត្តបទល្មើស ។

### មាត្រា ៤.- និយមន័យ

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះ មាននិយមន័យដូចតទៅ៖

១- យុត្តិធម៌អនីតិជន សំដៅដល់ការការពារសិទ្ធិអនីតិជនតាមរយៈយន្តការ វិធាន និងនីតិវិធីទាំងឡាយដែលត្រូវគោរព និងអនុវត្តដោយហ្មត់ចត់ ព្រមទាំងវិធាននៃការកំណត់ទោសក្នុងករណីអនីតិជនប្រព្រឹត្តបទល្មើស ។

២- អាជ្ញាធរមានសមត្ថកិច្ច សំដៅដល់បុគ្គល ឬស្ថាប័នដែលអនុវត្តដោយស្របច្បាប់នូវមុខងាររបស់ខ្លួនដែលពាក់ព័ន្ធនឹងរឿងក្តីអនីតិជន ។

៣- អនីតិជន សំដៅដល់ជនដែលមានអាយុតិចជាង ១៨ (ដប់ប្រាំបី) ឆ្នាំ នៅពេលប្រព្រឹត្តបទល្មើស ។

## មាត្រា ៦.- សិទ្ធិជាមូលដ្ឋានក្នុងនីតិវិធី

អនីតិជនគ្រប់រូបដែលជាប់សង្ស័យ ឬត្រូវចោទ ឬជាប់ចោទថាបានប្រព្រឹត្តបទល្មើសត្រូវទទួលបាននូវសិទ្ធិជាមូលដ្ឋានក្នុងនីតិវិធីដូចតទៅ ៖

- សិទ្ធិមិនផ្តល់ចម្លើយនៅពេលដែលមាន ឬគ្មានវត្តមានមេធាវី
- សិទ្ធិមិនទទួលការបង្ខិតបង្ខំឲ្យឆ្លើយដាក់បន្ទុកលើខ្លួនឯង
- សិទ្ធិរក្សាការសម្ងាត់នៃជីវិតឯកជន
- សិទ្ធិទទួលបានការពិនិត្យសុខភាព និងការព្យាបាល
- សិទ្ធិទទួលបានការឲ្យដំណឹងអំពីបទចោទប្រកាន់
- សិទ្ធិក្នុងការជូនដំណឹងអំពីការចាប់ខ្លួនទៅដល់អ្នកតំណាងដែលច្បាប់បានកំណត់
- សិទ្ធិទទួលបានជំនួយពីមេធាវីដោយការជ្រើសរើស ឬដោយការចាត់តាំងដោយមិនយកកម្រៃ ស្របតាមលក្ខខណ្ឌដែលចែងដោយច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ចាប់តាំងពីដំណាក់កាលដំបូងបំផុតនៃនីតិវិធី
- សិទ្ធិឲ្យមានការចូលរួមពីអ្នកតំណាងដែលច្បាប់បានកំណត់នៅគ្រប់ដំណើរការរឿងក្តី ប្រសិនបើការចូលរួមនេះមិនផ្ទុយនឹងឧត្តមប្រយោជន៍របស់អនីតិជន
- សិទ្ធិទទួលបានជំនួយពីអ្នកបកប្រែភាសាដោយមិនយកកម្រៃ កាលបើមានការចាំបាច់
- សិទ្ធិបង្ហាញភស្តុតាង
- សិទ្ធិស្នើសុំឲ្យកោះហៅសាក្សី និងសួរសាក្សី
- សិទ្ធិស្នើសុំអនុញ្ញាតនៅក្រៅឃុំ
- សិទ្ធិស្នើសុំឲ្យកែប្រែដីកានការត្រួតពិនិត្យតាមផ្លូវតុលាការ
- សិទ្ធិទំនាក់ទំនងជាមួយស្ថានទូត ស្ថានកុងស៊ុល ក្នុងករណីអនីតិជនជាជនបរទេស
- សិទ្ធិផ្សេងៗទៀតដែលមានចែងនៅក្នុងបទដ្ឋានគតិយុត្តជាធរមាន ។

# ជំពូកទី ៣

# ការទទួលខុសត្រូវព្រហ្មទណ្ឌ និងវិធានការរបស់អនីតិជន

## មាត្រា ៧.- ការទទួលខុសត្រូវព្រហ្មទណ្ឌ

នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានកំណត់ចាប់ពីអាយុ ១៨ (ដប់ប្រាំបី) ឆ្នាំ ឡើងទៅ ។ ប៉ុន្តែ តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជននោះតម្រូវ លើកលែងតែក្នុងករណីមានចែងពិសេសនៅក្នុងច្បាប់ផ្សេងទៀត ។

## មាត្រា ៨.- ការទទួលខុសត្រូវរដ្ឋប្បវេណី

បទប្បញ្ញត្តិនៃ កថាខណ្ឌទី ១ មាត្រា ៧៤៥ (អសមត្ថភាពក្នុងការទទួលខុសត្រូវ) និងមាត្រា ៧៤៦ (ការទទួលខុសត្រូវរបស់អ្នកមានករណីយកិច្ចត្រួតពិនិត្យ) នៃជំពូកទី ១៦ (អំពើអនីត្យានុកូល) ក្នុងគន្ថីទី ៥ (កិច្ចសន្យាសំខាន់ៗ និងអំពើអនីត្យានុកូល)នៃក្រមរដ្ឋប្បវេណី ត្រូវយកមកអនុវត្តចំពោះការទទួលខុសត្រូវរដ្ឋប្បវេណីរបស់អនីតិជន ។

## មាត្រា ៩.- ការកំណត់អាយុ

អាយុនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន ត្រូវកំណត់យកអាយុនៅពេលដែលអនីតិជននោះប្រព្រឹត្តបទល្មើស ។

ភស្តុតាងនៃអាយុរបស់អនីតិជន ត្រូវបានបញ្ជាក់ដោយសំបុត្រកំណើត ឬឯកសារផ្សេងទៀតដែលអាចបញ្ជាក់បានអំពីកំណើត ។ ក្នុងករណីពុំមានឯកសារ ឬមានការសង្ស័យ ឬមិនមានភាពច្បាស់លាស់ទាក់ទងនឹងយថាភូតនៃឯកសារនោះ ភស្តុតាងនៃអាយុរបស់អនីតិជនអាចផ្តល់តាមគ្រប់មធ្យោបាយផ្សេងទៀតដែលអាជ្ញាធរតុលាការអាចជឿទុកចិត្តបាន ។

អាជ្ញាធរមានសមត្ថកិច្ចត្រូវស្វះស្វែងរកភស្តុតាង ដើម្បីកំណត់អាយុរបស់អនីតិជនឲ្យបានឆាប់រហ័សបំផុតដែលអាចធ្វើទៅបាន ។

ក្នុងករណីមានការសង្ស័យអំពីអាយុរបស់អនីតិជន វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់អនីតិជននោះ ។

# ជំពូកទី ៤
# ជំនួយផ្នែកសេវាសង្គមកិច្ច

## មាត្រា ១០.- ការតែងតាំង និងការទទួលស្គាល់ភ្នាក់ងារសង្គមកិច្ច

ការតែងតាំង ការទទួលស្គាល់ និងការគ្រប់គ្រងភ្នាក់ងារសង្គមកិច្ចជាសមត្ថកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

បែបបទនៃការតែងតាំង និងការទទួលស្គាល់ភ្នាក់ងារសង្គមកិច្ច ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យសង្គមកិច្ច។

## មាត្រា ១១.- ភ្នាក់ងារសង្គមកិច្ច

ភ្នាក់ងារសង្គមកិច្ចមានភារកិច្ចជាអាទិ៍ ៖

- ជួបអនីតិជននៅគ្រប់ដំណាក់កាលនៃនីតិវិធី ជាពិសេស នៅដំណាក់កាលដំបូងនៃនីតិវិធីរបស់មន្ត្រីនគរបាលយុត្តិធម៌ និងនៅក្នុងពន្ធនាគារ ដើម្បីប្រមូលព័ត៌មានវាយតម្លៃ និងផ្តល់សេវាបន្ទាន់ដល់អនីតិជន

ក្នុងករណីដែលអនីតិជនត្រូវការកិច្ចការពារនិងថែទាំ មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនអនីតិជន នោះទៅមន្ទីរ ឬការិយាល័យទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីចាត់វិធានការ សមស្របទៅតាមសុខុមាលភាពនិងស្ថានភាពសង្គមរបស់អនីតិជន ។ មន្ទីរឬការិយាល័យទទួលបន្ទុក វិស័យសង្គមកិច្ចរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើរបាយការណ៍អំពីការទទួលអនីតិជនពីនគរបាល យុត្តិធម៌ ជូនទៅព្រះរាជអាជ្ញា ។

ក្នុងករណីយល់ឃើញថាអនីតិជនត្រូវការកិច្ចការពារនិងថែទាំ នោះមន្ទីរ ឬការិយាល័យត្រូវចាត់ វិធានការស្នើសុំព្យួរ ឬសុំដកហូតអំណាចមេបា ឬបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នក អាណាព្យាបាលទូទៅ ក្នុងករណីដែលអនីតិជនមានអ្នកតំណាងដែលច្បាប់បានកំណត់ ដើម្បីតុលាការ សម្រេចអំពីការព្យួរ ឬការដកហូត ឬការបញ្ឈប់អ្នកតំណាងដែលច្បាប់បានកំណត់ និងសិទ្ធិអាណា ព្យាបាលលើអនីតិជននោះ ។ ក្នុងករណីដែលអនីតិជនគ្មានអ្នក តំណាងដែលច្បាប់បានកំណត់ មន្ទីរ ឬការិយាល័យត្រូវសុំទៅតុលាការ ដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

## មាត្រា ១៤.- នីតិវិធីចាត់ចែងនឹងអនីតិជនអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ

អនីតិជនមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ ដែលជាប់សង្ស័យថាបានប្រព្រឹត្តបទល្មើស ពុំ អាចត្រូវបានគេឃាត់ខ្លួនឡើយ ហើយមន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រគល់អនីតិជននោះទៅឲ្យអ្នកតំណាង ដែលច្បាប់បានកំណត់ ។

ក្នុងករណីដែលអនីតិជនត្រូវការកិច្ចការពារ និងថែទាំ មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនអនីតិជន នោះទៅមន្ទីរ ឬការិយាល័យទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីចាត់ វិធានការសមស្របទៅតាមសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន ។ មន្ទីរ ឬការិយាល័យ ទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើរបាយការណ៍អំពីការទទួល អនីតិជនពីមន្ត្រីនគរបាលយុត្តិធម៌ ជូនទៅព្រះរាជអាជ្ញា ។

ក្នុងករណីយល់ឃើញថាអនីតិជនត្រូវការកិច្ចការពារនិងថែទាំ នោះមន្ទីរ ឬការិយាល័យត្រូវ ចាត់វិធានការស្នើសុំព្យួរ ឬសុំដកហូតអំណាចមេបា ឬបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ ក្នុងករណីដែលអនីតិជនមានអ្នកតំណាងដែលច្បាប់បានកំណត់ ដើម្បី តុលាការសម្រេចអំពីការព្យួរ ឬការដកហូត ឬការបញ្ឈប់អ្នកតំណាងដែលច្បាប់បានកំណត់ និងសិទ្ធិ អាណាព្យាបាលលើអនីតិជននោះ ។ ក្នុងករណីដែលអនីតិជនគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ មន្ទីរ ឬការិយាល័យ ត្រូវសុំទៅតុលាការដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

គ្រប់អំពើដែលជាបទល្មើសទាំងអស់ដែលប្រព្រឹត្តដោយអនីតិជនអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា ។

ROYAUME DU CAMBODGE · LE MINISTERE DU PALAIS ROYAL

## មាត្រា ៣៧.- ការព្យួរការសិក្សា និងការងារសម្រាប់អនីតិជន

ចៅក្រមស៊ើបសួរអាចបង្គាប់ទៅគ្រឹះស្ថានសិក្សា ឬនិយោជក មិនឲ្យព្យួរការសិក្សា ឬព្យួរការងារ របស់អនីតិជន ប្រសិនបើអនីតិជនមិនត្រូវបានឃុំខ្លួនបណ្តោះអាសន្នទេ ។

ក្នុងករណីអនីតិជនត្រូវបានឃុំខ្លួនបណ្តោះអាសន្ន ឬត្រូវអនុវត្តផែនការបង្វែរ គ្រឹះស្ថាន ឬនិយោជក អាចព្យួរការសិក្សា ឬព្យួរការងាររហូតដល់មានសេចក្តីសម្រេចរបស់តុលាការជាស្ថាពរ ។ ក្នុងករណី តុលាការសម្រេចសេចក្តីថាគ្មានទោសទេ នោះគ្រឹះស្ថានសិក្សា ឬនិយោជកត្រូវអនុញ្ញាតឲ្យអនីតិជនចូល សិក្សា ឬធ្វើការជាធម្មតាឡើងវិញ ។

## មាត្រា ៣៨.- អំណាចរបស់ចៅក្រមស៊ើបសួរក្នុងការបង្វែរ

ចៅក្រមស៊ើបសួរត្រូវពិចារណាជាបឋមទៅលើការបង្វែរ ដូចមានចែងក្នុងជំពូកទី ១០ (ការបង្វែរ) នៃច្បាប់នេះ ចំពោះអនីតិជនដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តបទមជ្ឈិម ។ បទមជ្ឈិមដែល មានស្ថានទម្ងន់ទោស អាចត្រូវបានយកមកពិចារណាអំពីការបង្វែរផងដែរ ។ ករណីចៅក្រមស៊ើបសួរ សម្រេចបង្វែរ បទប្បញ្ញត្តិក្នុងជំពូកទី ១០ (ការបង្វែរ) នៃច្បាប់នេះ ត្រូវយកមកអនុវត្ត ។ ក្នុងករណីនេះ ចៅក្រមស៊ើបសួរត្រូវផ្អាកនីតិវិធីនៃការស៊ើបសួរដោយដីកាសម្រេច និងបង្គាប់ឲ្យដោះលែងអនីតិជន ដែលត្រូវបានឃុំខ្លួន ប្រសិនបើអនីតិជននោះត្រូវបានឃុំខ្លួនបណ្តោះអាសន្ន ។ ចៅក្រមស៊ើបសួរអាច បង្គាប់ឲ្យប្រគល់អនីតិជនទៅអ្នកតំណាងដែលច្បាប់បានកំណត់ ឬមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ច រាជធានី ខេត្ត ដើម្បីទទួលបានការគ្រប់គ្រងនិងថែទាំ ដើម្បីរង់ចាំអនុវត្តផែនការបង្វែរ ទោះបីផែនការ បង្វែរត្រូវការពេលវេលារៀបចំក៏ដោយ ។

ចៅក្រមស៊ើបសួរត្រូវជូនដំណឹងដល់ជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះ ក្នុង ករណីជនរងគ្រោះជាអនីតិជន និងមេធាវីរបស់អនីតិជន អំពីការសម្រេចផ្អាកនីតិវិធីនៃការស៊ើបសួរ ។ ជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះ អាចប្តឹងទាមទារសំណងទៅតុលាការរដ្ឋប្បវេណី ។

ចៅក្រមស៊ើបសួរត្រូវចេញដីកាដំណោះស្រាយលើកលែងចោទប្រកាន់ ក្នុងករណីដែលការអនុវត្ត ផែនការបង្វែរទទួលបានជោគជ័យ ដោយផ្អែកលើលទ្ធផលរបាយការណ៍ដែលបញ្ជាក់រួមគ្នាពីភ្នាក់ងារ សង្គមកិច្ច និងអ្នកទទួលបន្ទុកអនុវត្តផែនការបង្វែរ ។

ក្នុងករណីដែលអនីតិជនអនុវត្តផែនការបង្វែរមិនបានជោគជ័យ ចៅក្រមស៊ើបសួរអាចចេញដីកា សម្រេចបង្វែរជាថ្មីដោយពិចារណាទៅលើមូលហេតុដែលនាំឲ្យបរាជ័យក្នុងការអនុវត្តផែនការបង្វែរ ទស្សនៈរបស់អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ និងការពិគ្រោះយោបល់ជាមួយភ្នាក់ងារ សង្គមកិច្ច ឬចាត់វិធានការតាមនីតិវិធី ។

## មាត្រា ៣៩.- ការឃុំខ្លួនបណ្តោះអាសន្ន

ការឃុំខ្លួនអនីតិជនបណ្តោះអាសន្ន ជាវិធានការចុងក្រោយ ។

បន្ថែមលើបទប្បញ្ញត្តិស្ដីពីលក្ខខណ្ឌ មូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្នដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ចៅក្រមស៊ើបសួរមុននឹងសម្រេចអំពីការឃុំខ្លួនបណ្ដោះអាសន្ន ត្រូវពិចារណាលើរបាយការណ៍ប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជនផងដែរ ប្រសិនបើមាន ។

អនីតិជនអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ មិនត្រូវបានឃុំខ្លួនបណ្ដោះអាសន្នឡើយ ។ ក្នុងករណីអនីតិជនដែលកំពុងជាប់ឃុំត្រូវបានរកឃើញថាមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ ចៅក្រមស៊ើបសួរត្រូវចេញដីកាដំណោះស្រាយលើកលែងចោទប្រកាន់ និងបង្គាប់ឲ្យដោះលែងអនីតិជននោះជាបន្ទាន់ ទោះបីមានបណ្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាក៏ដោយ ហើយប្រគល់អនីតិជននោះទៅឲ្យអ្នកតំណាងដែលច្បាប់បានកំណត់ ។

ក្នុងករណីដែលអនីតិជនត្រូវការកិច្ចការពារ និងថែទាំ ចៅក្រមស៊ើបសួរត្រូវបញ្ជូនអនីតិជននោះទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីចាត់វិធានការសមស្របទៅតាមសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន ។

ក្នុងករណីយល់ឃើញថាអនីតិជនត្រូវការកិច្ចការពារ និងថែទាំ នោះមន្ទីរ ឬការិយាល័យត្រូវចាត់វិធានការស្នើសុំព្យួរ ឬសុំដកហូតអំណាចមេបា ឬបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ ក្នុងករណីដែលអនីតិជនមានអ្នកតំណាងដែលច្បាប់បានកំណត់ ដើម្បីតុលាការសម្រេចអំពីការព្យួរ ឬការដកហូត ឬការបញ្ឈប់អ្នកតំណាងដែលច្បាប់បានកំណត់ និងសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

ក្នុងករណីដែលអនីតិជនគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ មន្ទីរ ឬការិយាល័យ ត្រូវសុំទៅតុលាការដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

ជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់ អាចដាក់ពាក្យប្ដឹងទាមទារសំណងទៅតុលាការរដ្ឋប្បវេណីបាន ។

## មាត្រា ៤០.- ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

ចៅក្រមស៊ើបសួរអាចដាក់អនីតិជនត្រូវចោទឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលាជំនួសឲ្យការឃុំខ្លួនបណ្ដោះអាសន្ន ប្រសិនបើអនីតិជនត្រូវចោទនោះ ត្រូវបានចោទប្រកាន់អំពីបទល្មើសដែលត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារ ។ បន្ថែមលើបទប្បញ្ញត្តិស្ដីពីការត្រួតពិនិត្យតាមផ្លូវតុលាការនៃក្រមនីតិវិធីព្រហ្មទណ្ឌ ចៅក្រមស៊ើបសួរអាចបង្គាប់អនីតិជនដែលនៅក្រៅឃុំឲ្យគោរពកាតព្វកិច្ចមួយ ឬច្រើនដូចតទៅ ៖

- ឲ្យស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់ពីឪពុកម្ដាយ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ ឬអ្នកទំនុកបម្រុងរបស់អនីតិជន ឬក្រុមគ្រួសារណាមួយសមស្រប

ស្តីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជនមិនទាន់មានលក្ខណៈគ្រប់គ្រាន់ ចៅក្រមស៊ើបសួរត្រូវបង្គាប់ឲ្យភ្នាក់ងារសង្គមកិច្ចផ្តល់របាយការណ៍បន្ថែមក្នុងរយៈពេលឆាប់បំផុតដែលអាចធ្វើទៅបាន ដោយមិនឲ្យលើសរយៈពេល ១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការ ។

ដីកាដំណោះស្រាយលើកលែងចោទប្រកាន់មានអានុភាពនាំឲ្យដោះលែងអនីតិជនដែលជាប់ឃុំ ទោះបីមានបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាក៏ដោយ ។

ចៅក្រមស៊ើបសួរត្រូវបង្គាប់ឲ្យប្រគល់អនីតិជនទៅអ្នកតំណាងដែលច្បាប់បានកំណត់ ។

ក្នុងករណីអនីតិជនត្រូវការកិច្ចការពារនិងថែទាំ ចៅក្រមស៊ើបសួរត្រូវបញ្ជូនអនីតិជននោះទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីចាត់វិធានការសមស្របទៅតាមសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន ។

ក្នុងករណីយល់ឃើញថាអនីតិជនត្រូវការកិច្ចការពារនិងថែទាំ នោះមន្ទីរ ឬការិយាល័យត្រូវចាត់វិធានការស្នើសុំព្យួរ ឬសុំដកហូតអំណាចមេបា ឬបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ ក្នុងករណីអនីតិជនមានអ្នកតំណាងដែលច្បាប់បានកំណត់ ដើម្បីតុលាការសម្រេចអំពីការព្យួរ ឬការដកហូត ឬការបញ្ឈប់អ្នកតំណាងដែលច្បាប់បានកំណត់ និងសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

ក្នុងករណីអនីតិជនគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ មន្ទីរ ឬការិយាល័យ ត្រូវសុំទៅតុលាការដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

### មាត្រា ៤៣.- ការប្តឹងទៅសភាស៊ើបសួរនៃសាលាឧទ្ធរណ៍

មុននឹងសម្រេចប្តឹងទៅសភាស៊ើបសួរនៃសាលាឧទ្ធរណ៍ចំពោះដីកាលើកលែងចោទប្រកាន់ ដីកាសម្រេចឃុំខ្លួន ដីកាសម្រេចមិនឃុំខ្លួន ដីកាដោះលែងឲ្យនៅក្រៅឃុំ និងដីកាបង្វែររបស់ចៅក្រមស៊ើបសួរ ព្រះរាជអាជ្ញាត្រូវពិចារណាជាចម្បងអំពីឧត្តមប្រយោជន៍របស់អនីតិជន ។

## ជំពូកទី ៨
## សមត្ថកិច្ចរបស់សាលាដំបូង

### មាត្រា ៤៤.- សមត្ថកិច្ចនៃការជំនុំជម្រះ

សាលាដំបូងដែលមានសមត្ថកិច្ចជំនាញទាក់ទងនឹងអនីតិជន ជំនុំជម្រះបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុដែលមានជនជាប់ចោទជាអនីតិជន ។

សាលាដំបូងសម្រេចជាក្រុមសមូហភាពដោយមានចៅក្រម ៣ (បី) រូប ចំពោះបទឧក្រិដ្ឋ ព្រមទាំងបទមជ្ឈិម និងបទលហុដែលជាប់ទាក់ទងនឹងបទឧក្រិដ្ឋ និងបទមជ្ឈិម ។

សាលាដំបូងសម្រេចជាចៅក្រមទោលចំពោះបទលហុ ។

## មាត្រា ៤៥.- អាទិភាពលើរឿងក្តីអនីតិជន

តុលាការត្រូវលើកយករឿងក្តីរបស់អនីតិជនមកចាត់ការជាអាទិភាព ជាពិសេសរឿងក្តីអនីតិជនដែលជាប់ឃុំខ្លួនបណ្តោះអាសន្ន ។

ដើម្បីជាឧត្តមប្រយោជន៍របស់អនីតិជនក្នុងពេលរង់ចាំការជំនុំជម្រះ តុលាការត្រូវពិចារណាដោះលែងអនីតិជនដែលជាប់ឃុំបណ្តោះអាសន្នឲ្យមានសេរីភាព ។ ករណីដែលរឿងក្តីត្រូវបានលើកពេលជំនុំជម្រះ តុលាការត្រូវពិចារណាផងដែរអំពីការដោះលែងអនីតិជនដែលជាប់ឃុំបណ្តោះអាសន្នឲ្យមានសេរីភាព ។

## មាត្រា ៤៦.- នីតិវិធីមុនពេលសវនាការ

មុនពេលសវនាការ តុលាការត្រូវពិនិត្យរបាយការណ៍ និងយោបល់ស្តីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន ដែលផ្តល់ដោយភ្នាក់ងារសង្គមកិច្ច ។

ក្នុងករណីដែលរបាយការណ៍ និងយោបល់ស្តីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជនមិនទាន់បានរៀបចំ ហើយតុលាការត្រូវការព័ត៌មានបន្ថែម តុលាការត្រូវបង្គាប់ឲ្យភ្នាក់ងារសង្គមកិច្ចរៀបចំ និងបំពេញបន្ថែមនូវរបាយការណ៍ និងយោបល់នោះ តាមតម្រូវការ ។

## មាត្រា ៤៧.- សវនាការជាអសាធារណៈ

ការពិភាក្សាដេញដោល និងការប្រកាសសាលក្រមរឿងក្តីអនីតិជន ត្រូវធ្វើឡើងក្នុងសវនាការជាអសាធារណៈ ។

មានតែបុគ្គលដែលមានសិទ្ធិ ភារកិច្ច ឬផលប្រយោជន៍ដែលពាក់ព័ន្ធនឹងរឿងក្តីប៉ុណ្ណោះដែលមានសិទ្ធិចូលរួមក្នុងសវនាការ ។

អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងរបស់អនីតិជនត្រូវចូលរួមក្នុងសវនាការ លើកលែងតែមានសំណូមពរពីអនីតិជនផ្ទុយពីនេះ ឬតុលាការយល់ឃើញថាការចូលរួមរបស់បុគ្គលទាំងនោះមិនបម្រើឧត្តមប្រយោជន៍របស់អនីតិជន ។

## មាត្រា ៤៨.- សវនាការ

នៅពេលសវនាការ តុលាការត្រូវប្រើប្រាស់នីតិវិធីកុមារមេត្រី ។

ក្នុងកាលៈទេសៈពិសេស មេធាវីរបស់អនីតិជន ភ្នាក់ងារសង្គមកិច្ច ឬព្រះរាជអាជ្ញា អាចស្នើសុំឲ្យតុលាការប្រើប្រាស់វាំងក្នុងពេលសវនាការ ឬប្រើប្រាស់វិធីសមស្របណាមួយក្នុងការស្តាប់ចម្លើយ ។

## មាត្រា ៤៩.- ការឲ្យរួចផុតពីបទចោទ

ក្នុងករណីតុលាការរកឃើញថា អនីតិជនជាប់ចោទមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ នៅពេលប្រព្រឹត្តបទល្មើស តុលាការត្រូវសម្រេចឲ្យអនីតិជនរួចផុតពីបទចោទប្រកាន់ ហើយបង្គាប់ឲ្យដោះលែងអនីតិជនដែលជាប់ឃុំជាបន្ទាន់ ទោះបីមានបណ្តឹងឧទ្ធរណ៍ពីព្រះរាជអាជ្ញាក៏ដោយ ហើយប្រគល់អនីតិជននោះឲ្យទៅអ្នកតំណាងដែលច្បាប់បានកំណត់ ។

ក្នុងករណីតុលាការរកឃើញថាអនីតិជនខាងលើពិតជាបានប្រព្រឹត្តបទល្មើស តុលាការត្រូវសម្រេចអំពីសំណងរដ្ឋប្បវេណី ប្រសិនបើមានបណ្តឹងរដ្ឋប្បវេណី ។

ប្រសិនបើតុលាការរកឃើញថា អំពើដែលចោទប្រកាន់មកលើអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ មិនមែនជាបទល្មើស ឬអនីតិជនជាប់ចោទគ្មានកំហុសទេ តុលាការត្រូវសម្រេចឲ្យរួចខ្លួនពីបទចោទ និងបង្គាប់ឲ្យដោះលែងអនីតិជននោះភ្លាម ទោះបីមានបណ្តឹងឧទ្ធរណ៍ពីព្រះរាជអាជ្ញាក៏ដោយ ហើយប្រគល់អនីតិជននោះឲ្យទៅអ្នកតំណាងដែលច្បាប់បានកំណត់ ប្រសិនបើអនីតិជននោះមិនត្រូវបានជាប់ឃុំពីបទល្មើសផ្សេងទៀតទេ ។

ក្នុងករណីដែលអនីតិជនត្រូវការកិច្ចការពារនិងថែទាំ តុលាការត្រូវបញ្ជូនអនីតិជននោះទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីចាត់វិធានការសមស្របទៅតាមសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន ។

ក្នុងករណីយល់ឃើញថាអនីតិជនត្រូវការកិច្ចការពារ និងថែទាំ នោះមន្ទីរឬការិយាល័យត្រូវចាត់វិធានការស្នើសុំព្យួរ ឬសុំដកហូតអំណាចមេបា ឬបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ ក្នុងករណីដែលអនីតិជនមានអ្នកតំណាងដែលច្បាប់បានកំណត់ ដើម្បីតុលាការសម្រេចអំពីការព្យួរ ឬការដកហូត ឬការបញ្ឈប់អ្នកតំណាងដែលច្បាប់បានកំណត់ និងសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

ក្នុងករណីដែលអនីតិជនគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ មន្ទីរ ឬការិយាល័យត្រូវសុំទៅតុលាការដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

## មាត្រា ៥០.- ជំនួយរបស់មេធាវី

ជំនួយរបស់មេធាវីត្រូវតែមានជាចំាបាច់នៅក្នុងសវនាការ ។ បើគ្មានការជ្រើសរើសដោយអនីតិជន មេធាវីត្រូវបានចាត់តាំងដោយមិនយកកម្រៃតាមគំនិតផ្តើមរបស់ប្រធានតុលាការ នៅក្នុងលក្ខខណ្ឌដែលមានចែងនៅក្នុងច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ។ សោហ៊ុយសម្រាប់ធ្វើការ ចម្លងសំណុំរឿងជាបន្ទុករបស់រដ្ឋ ។

តុលាការត្រូវផ្តល់ពេលវេលាសមស្រប និងលិខិតចម្លងសំណុំរឿង ទៅឲ្យមេធាវីសម្រាប់រៀបចំការពារក្តី ។ សោហ៊ុយសម្រាប់ធ្វើការចម្លងសំណុំរឿងជាបន្ទុករបស់មេធាវីដែលត្រូវបានជ្រើសរើសដោយអនីតិជន ។

**ឧបសម្ព័ន្ធទី ៣**

# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងយុត្តិធម៌**

លេខ :០៧.កយ.សរ/១៦

## សារាចរ
## ស្តីពី
## ការអនុវត្តបទប្បញ្ញត្តិ នៃការព្យួរទោសសាកល្បង

ក្រសួងយុត្តិធម៌បានកត់សម្គាល់ឃើញថា បទប្បញ្ញត្តិ និងគោលការណ៍ស្តីពីការអនុវត្តរបបនៃការព្យួរទោសសាកល្បង ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌចាប់ពីមាត្រា ១១៧ ដល់ មាត្រា ១២៣ និងមាត្រា ១៦៥ មិនទាន់អនុវត្តឲ្យបានគ្រប់ជ្រុងជ្រោយនៅឡើយ ដែលជាហេតុធ្វើឲ្យការអនុវត្តនៃការព្យួរទោសសាកល្បង មិនទាន់បានល្អប្រសើរ។

ដើម្បីអនុវត្តបទប្បញ្ញត្តិ និងគោលការណ៍ទាំងនេះឲ្យមានប្រសិទ្ធភាព ក្រសួងយុត្តិធម៌សូមធ្វើការណែនាំដូចខាងក្រោម ៖

### ក-ចៅក្រមជំនុំជម្រះ

១-យោងតាមមាត្រា ១១៧ នៃក្រមព្រហ្មទណ្ឌ ចៅក្រមគប្បីត្រូវពិចារណាសម្រេចព្យួរសាកល្បងនៃទោស ឲ្យបានជាអតិបរិមានូវទោស ដែលបានសម្រេចដាក់ពន្ធនាគារ ក្នុងបទល្មើសមជ្ឈិម។

២-តុលាការត្រូវចេញសម្រង់សាលក្រមស្ថារពរចំនួនបីច្បាប់។ ចំនួនពីរច្បាប់ប្រគល់ជូនព្រះរាជអាជ្ញា និងមួយច្បាប់ទៀតប្រគល់ឲ្យទៅទណ្ឌិតដើម្បីអនុវត្ត។

### ខ-ព្រះរាជអាជ្ញា

១-ត្រូវដឹកនាំសម្របសម្រួល ការអនុវត្តសេចក្តីសម្រេចព្យួរទោសសាកល្បងរបស់តុលាការគ្រប់ជាន់ថ្នាក់ ឲ្យមានប្រសិទ្ធភាព។

២-ត្រូវចាត់តាំងបុគ្គលនៅក្នុងមូលដ្ឋានដែលទណ្ឌិតរស់នៅ ឬ បំពេញកាតព្វកិច្ច ឲ្យតាមដានសកម្មភាពរបស់ទណ្ឌិត។ បុគ្គលដែលគប្បីចាត់តាំង ដូចជានគរបាលប៉ុស្តិ៍រដ្ឋបាល សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ មន្ត្រីទទួលបន្ទុកអប់រំ និងស្ថាបនីតិសម្បទា...។

៣-ត្រូវបង្គាប់ណែនាំដល់ទណ្ឌិត ឲ្យទៅបង្ហាញខ្លួននៅចំពោះមុខបុគ្គលដែលត្រូវបានចាត់តាំងឲ្យតាមដាន។

៤-ត្រូវប្រគល់សម្រង់សាលក្រម ឬ សម្រង់សាលដីកាស្ថាពរដល់បុគ្គលដែលត្រូវបានចាត់តាំងឲ្យតាមដានទណ្ឌិត និងធ្វើការដឹកនាំសម្របសម្រួលការអនុវត្ត។

៥-ក្នុងករណីចាំបាច់ ត្រូវបង្គាប់ទៅអង្គភាពនគរបាលយុត្តិធម៌ ឲ្យចាត់វិធានការជួយតាមដានរាល់សកម្មភាពរបស់ទណ្ឌិត និងត្រូវធ្វើរបាយការណ៍តាមការកំណត់ ពីការកត់សម្គាល់ឃើញរបស់ខ្លួនចំពោះសកម្មភាពរបស់ទណ្ឌិតជូនទៅព្រះរាជអាជ្ញា ដើម្បីស្នើសុំយោបល់ ឬ ចាត់វិធានការ។

សូមលោក លោកស្រី ជាចៅក្រម ព្រះរាជអាជ្ញា គ្រប់ស្ថាប័នតុលាការ និងអយ្យការ ត្រូវអនុវត្តសារាចរនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី..២២..ខែមករា.. ឆ្នាំ២០១៤..

**រដ្ឋមន្ត្រី**

អង្គ វង្សវឌ្ឍនា

<u>ចម្លងជូន ៖</u>
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
-ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-តុលាការ និងមហាអយ្យការអមតុលាការកំពូល
-សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍
-សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត
-ឯកសារ-កាលប្បវត្តិ

**ឧបសម្ព័ន្ធទី ៤**

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

លេខ : ០៧ គយក សរ/១៤

## សារាចរ
## ស្តីពី
## ការអនុវត្តបទប្បញ្ញត្តិនៃ ការអនុវត្តទោសការងារសហគមន៍

ក្រសួងយុត្តិធម៌បានកត់សម្គាល់ឃើញថា បទប្បញ្ញត្តិ និងគោលការណ៍ស្តីពីការអនុវត្តទោសការងារសហគមន៍ ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌចាប់ពីមាត្រា ៧២ ដល់មាត្រា ៧៥ មាត្រា ៩៨ មាត្រា ១០១ ដល់ ១០៣ និងមាត្រា ១៦២ មិនទាន់អនុវត្តបានគ្រប់ជ្រុងជ្រោយនៅឡើយ ដែលជាហេតុធ្វើឲ្យការអនុវត្តទោសការងារសហគមន៍ មិនទាន់មានប្រសិទ្ធិភាព និងមិនទាន់មានភាពរលូន។

ដើម្បីធានាការអនុវត្តបទប្បញ្ញត្តិ និងគោលការណ៍ទាំងនេះឲ្យមានប្រសិទ្ធភាព ក្រសួងយុត្តិធម៌សូមធ្វើការណែនាំដូចខាងក្រោម ៖

**ក-ចៅក្រមជំនុំជម្រះ**

១-គប្បីធានាឲ្យបាននូវការអនុវត្តតាមបទប្បញ្ញត្តិ និងគោលការណ៍ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌស្តីពីទោសការងារសហគមន៍ ចំពោះទណ្ឌិតណាដែលតុលាការប្រកាសទោសដាក់ពន្ធនាគារតិចជាង ឬស្មើ ៣ (បី) ឆ្នាំ ។

២-តុលាការត្រូវប្រគល់សម្រង់សាលក្រម ជូនព្រះរាជអាជ្ញាមួយច្បាប់ និងប្រគល់ឲ្យទៅទណ្ឌិតមួយច្បាប់។

**ខ-ព្រះរាជអាជ្ញា**

១-ត្រូវសហការជាមួយអង្គការរដ្ឋ សមាគមន៍ ឬអង្គការមិនមែនរដ្ឋាភិបាល ដើម្បីកសាង និងធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះនីតិបុគ្គល និងប្រភេទការងារ ដែលមានតម្រូវការផ្តល់ការងារឲ្យទណ្ឌិតធ្វើ។ បញ្ជីនេះត្រូវដាក់បង្ហាញជូនតុលាការដើម្បីជ្រើសរើសការងារ ឲ្យទណ្ឌិតដែលយល់ព្រមទទួលយក។

២-ការផ្តល់ការងារសហគមន៍ដល់អនីតិជន ត្រូវពិភាក្សាបន្ថែមជាមួយមន្ត្រីសង្គមកិច្ចអំពីការងារដែលមានលក្ខណៈជាការងារបណ្តុះបណ្តាល និងសម្រួលដល់ការបញ្ចូលខ្លួនទៅរស់នៅក្នុងសង្គមវិញ។

៣-ត្រូវរៀបចំបែបបទនៃការអនុវត្តទោសការងារសហគមន៍ សម្រាប់នីតិបុគ្គលដែលទទួលទណ្ឌិតឲ្យធ្វើការងារ ដោយឲ្យនីតិបុគ្គលនោះ បំពេញនូវកាតព្វកិច្ចដូចតទៅ ៖

-ណែនាំដល់ទណ្ឌិតអំពីការបំពេញកាតព្វកិច្ច និងអប់រំទណ្ឌិតឲ្យយកចិត្តទុកដាក់ក្នុងការកសាងខ្លួនចូលក្នុងសង្គមវិញ

-គ្រប់គ្រងតាមដានសកម្មភាពរបស់ទណ្ឌិត ក្នុងពេលបំពេញកាតព្វកិច្ច

-ធ្វើរបាយការណ៍អំពីសកម្មភាពរបស់ទណ្ឌិតជូនដល់ព្រះរាជអាជ្ញា

-ត្រូវចុះហត្ថលេខាលើកំណត់ហេតុទទួលស្គាល់ អំពីការអនុវត្តការងាររបស់ទណ្ឌិត

៤-ត្រូវយកចិត្តទុកដាក់តាមដានត្រួតពិនិត្យការអនុវត្តការងាររបស់ទណ្ឌិតដែលមានដូចខាងក្រោម ៖

-គ្រប់គ្រង តាមដាន រក្សាទុករបាយការណ៍ កំណត់ហេតុអំពីការអនុវត្តការងារសហគមន៍

-តាមដានការអនុវត្តរបស់ទណ្ឌិតទៅតាមលក្ខខណ្ឌរបស់សាលក្រម

-ណែនាំទណ្ឌិតអំពីការអនុវត្តការងារសហគមន៍ និងកាតព្វកិច្ចដែលត្រូវអនុវត្ត

-ណែនាំដល់នីតិបុគ្គលដែលទទួលទណ្ឌិត អំពីបែបបទអនុវត្តការងារគ្រប់គ្រង

-ចេញដីកាសម្រេចបញ្ចប់ការអនុវត្តទោសរបស់ទណ្ឌិត ដែលបានអនុវត្តទោសការងារសហគមន៍ដោយជោគជ័យ។

សូមលោក លោកស្រី ជាចៅក្រម ព្រះរាជអាជ្ញា គ្រប់ស្ថាប័នតុលាការ និងអយ្យការ ត្រូវអនុវត្តសារាចរនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី..២២..ខែ[illegible].. ឆ្នាំ..២០១៤

**រដ្ឋមន្ត្រី**

អង្គ.វង្សវឌ្ឍនា

ចម្លងជូន ៖
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
-ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-តុលាការ និងមហាអយ្យការអមតុលាការកំពូល
-សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍
-សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត
-ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធទី ៥



## ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ

លេខ ៤៥៣១

ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៧

ដំនុំជម្រះលេខ ៣៦២៥

ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៧

សាលក្រមព្រហ្មទណ្ឌ

លេខ ៧៤០ ក្រ៩ "អ"

ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០១៧

## តាមនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងរាជធានីភ្នំពេញ នាថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៧ ដោយមានសមាសភាពដូចខាងក្រោម ÷

### ក្រុមប្រឹក្សាជំនុំជម្រះ

| | | |
|---|---|---|
| លោក | **ឃុិន សារឿន** | ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ<br>ជាប្រធានក្រុមប្រឹក្សា |
| លោក | **សាន សុផាត** | ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ<br>ជាចៅក្រមប្រឹក្សា |
| លោក | **ប៊ុន ធី** | ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ<br>ជាចៅក្រមប្រឹក្សា |

### តំណាងអយ្យការ

| | | |
|---|---|---|
| លោក | **ហ៊ុង ប៊ុនថន** | ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ |

### ក្រឡាបញ្ជីសវនាការ

| | | |
|---|---|---|
| លោក | **ជោគ ច័ាន់ចាន់** | ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ |

### ដើម្បីជំនុំជម្រះ

លើសំណុំរឿងព្រហ្មទណ្ឌលេខៈ ៤៥៣១ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៧ ដែលមានជនជាប់ចោទ ÷ -

-ឈ្មោះ សារិត ឧត្តម ភេទប្រុស អាយុ២៣ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ ចុងភៅ ទីកន្លែងកំណើតភូមិត្រពាំងជ្រៃ សង្កាត់កាកាប ខណ្ឌដង្កោ រាជធានីភ្នំពេញ ទីលំនៅបច្ចុប្បន្នបន្ទប់ជួល ផ្លូវលំ ភូមិស្លែងរលើង សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប្រពន្ធឈ្មោះ ព្រេីន សុភី "រ" មានកូន០១នាក់ ឪពុកឈ្មោះ ម៉ី រដ្ឋា "ស" ម្ដាយឈ្មោះ មិន សុវណ្ណនី "រ" ជានីតិជន ទោសពីមុនគ្មាន ។

ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៥៨៩០"ល" ដ.ឃ.ដ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៧ ។ មានលោក ហេង ឃាង ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។

ជាប់ចោទពីបទ ÷ លួចមានស្ថានទម្ងន់ទោស (ឆ្កិះសោរបន្ទប់ជួលយកទូរស័ព្ទដៃ) និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅក្នុងបន្ទប់ជួល ភូមិស្លែងរលើង សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ម៉ុ សាវុទ្ធិ ភេទប្រុស អាយុ៣០ឆ្នាំ ជាតិខ្មែរ អាសយដ្ឋានបន្ទប់ជួល ផ្លូវបេតុង ភូមិស្លែងរលើង សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

-បានឃើញ របាយការណ៍សំយោគលេខ ៣៦០/១៧ របក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៧ របស់អធិការដ្ឋាននគរបាលខណ្ឌសែនសុខ ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៣៣២៩ អ.យ.ម ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៧ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះលេខ ៤១៩១ "ហ" ជ.ជ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៧ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៧ វេលាម៉ោងប្រហែល០៨:៣០នាទី ឈ្មោះ ម៉ុ សាវុទ្ធិ ដាក់ទូរស័ព្ទដៃមួយគ្រឿងម៉ាកសាំងសុង ពណ៌ស បញ្ចូលថ្មក្នុងបន្ទប់ជួល ស្ថិតនៅភូមិស្លែងរលើង សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ រួចក៏បានបិទទ្វារបន្ទប់ ហើយចេញទៅធ្វើការ ។ ពេលនោះជនជាប់ចោទឈ្មោះ សាវីត ឧត្តម ដែលស្នាក់នៅបន្ទប់ក្បែរនោះ បានដើរចេញពីបន្ទប់របស់ខ្លួនប្រហែល២០០ម៉ែត្រ ឃើញបន្ទប់ជួលខាងលើបិទទ្វារចាក់សោពីក្រៅ ជនជាប់ចោទបានយកដែកឆ្កិះសោទ្វារបន្ទប់ លួចយកទូរស័ព្ទដែលជនរងគ្រោះដាក់បញ្ចូលថ្មនៅលើតុដាក់ចូលក្នុងហោប៉ៅខោខាងស្តាំ ហើយចេញក្រៅដើរបានប្រហែលជា១០០ម៉ែត្រ ត្រូវបានអ្នកជិតខាងបានស្រែកថាចោរៗ ហើយឃាត់ខ្លួនប្រគល់ឱ្យសមត្ថកិច្ចតែម្តង ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ សាវីត ឧត្តម បានឆ្លើយថា ÷ នៅថ្ងៃកើតហេតុខ្លួនបានយកប្រដាប់ឆ្កិះសោ ដែលខ្លួនរើសបានពីថ្ងៃមុនយកទៅឆ្កិះសោបន្ទប់ជួល ស្ថិតនៅភូមិស្លែងរលើង សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។ នៅពេលឆ្កិះសោទ្វារបានហើយ ខ្លួនបាន ដើរចូលក្នុងបន្ទប់ជួល ក៏ឃើញមានទូរស័ព្ទដៃមួយគ្រឿងម៉ាក សាំងសុង ពណ៌ស ដែលម្ចាស់គេបានដាក់បញ្ចូលថ្មនៅលើតុ រួចខ្លួនក៏បានយកទូរស័ព្ទដៃនោះដាក់ចូលក្នុងហោប៉ៅខោខាងស្តាំ ដើរចេញមកក្រៅបានប្រហែល ១០០ម៉ែត្រ ក៏ត្រូវបានអ្នកជិតខាងស្រែកថាចោរៗ ហើយឃាត់ខ្លួនប្រគល់ឱ្យសមត្ថកិច្ចតែម្តង ។ ខ្លួនសុំ/

ជម្រាបថាខ្លួនពិតជាបានប្រើប្រាស់សារធាតុញៀន ដូចការចោទប្រកាន់ដែរ ។

-ក្រឡាបញ្ជីអានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ម៉ី សាវុទ្ធី នៅសមត្ថកិច្ចថា ÷ កាលពីថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៧ វេលាម៉ោងប្រហែល០៧:៣០នាទី ខ្លួនបានយកទូរស័ព្ទម៉ាកសាំងស៊ុងដាក់សាកថ្មនៅលើតុក្នុងបន្ទប់ជួលរបស់ខ្លួន ហើយក៏បានបិទទ្វាចាក់សោពីខាងក្រៅ រួចចេញទៅធ្វើការ ។ មួយសន្ទុះក្រោយមកម្ចាស់ផ្ទះបានទូរស័ព្ទប្រាប់ខ្លួនថាចាប់បានមនុស្សប្រុសម្នាក់ដែលបានធ្វើសកម្មភាពគាស់សោបន្ទប់របស់ខ្លួន ចូលទៅយកទូរស័ព្ទដៃ ហើយមនុស្សប្រុសម្នាក់នោះត្រូវម្ចាស់ផ្ទះយកទៅប្រគល់ឱ្យសមត្ថកិច្ចប៉ុស្តិ៍នគរបាលទឹកថ្លា ពេលនោះខ្លួនបានទៅប៉ុស្តិ៍នគរបាលដាក់ពាក្យបណ្តឹងតែម្តង ។

-ក្រឡាបញ្ជីអានចម្លើយសាក្សីឈ្មោះ គីម សុម៉ាលី នៅសមត្ថកិច្ចថា ÷ កាលពីថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៧ វេលាម៉ោងប្រហែល០៧:៣០នាទី ខ្លួនបានពរកូនទៅទិញនំ នៅកន្លែងលក់នំមានចម្ងាយពីផ្ទះប្រហែល៥០ម៉ែត្រ នៅពេលទិញឱ្យកូនរួចក៏ត្រឡប់មកផ្ទះវិញ ស្រាប់តែឃើញមនុស្សប្រុសម្នាក់ដើរចេញពីបន្ទប់ជួល ដែលខ្លួនជួលឱ្យគេស្នាក់នៅ ពេលនោះខ្លួនបានស្រែកថាចោរៗ ធ្វើលដល់អ្នកជិតខាង ក៏ចេញមកជួយចាប់ឃាត់ខ្លួននាំមកប្រគល់ឱ្យសមត្ថកិច្ច ហើយខ្លួនបានទូរស័ព្ទប្រាប់ម្ចាស់បន្ទប់ឱ្យមកប៉ុស្តិ៍នគរបាលរដ្ឋបាលទឹកថ្លា ។ នៅពេលសមត្ថកិច្ចឆែកឆេរលើខ្លួនរបស់មនុស្សប្រុសនោះឃើញមានទូរស័ព្ទរបស់ម្ចាស់បន្ទប់នៅក្នុងហោប៉ៅខោ ហើយម្ចាស់បន្ទប់បានដាក់ពាក្យបណ្តឹងប្តឹងតែម្តង ។

<u>សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ</u>

-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា ÷ ក្រោយពីបានស្តាប់ចម្លើយចោលនាពេលសវនាការជនជាប់ចោទបានសារភាពថាខ្លួនពិតជាបានធ្វើសកម្មភាពគាស់សោលួចយកទូរស័ព្ទដៃ ប្រាកដមែន ហេតុនេះតំណាងអយ្យការសុំតម្កល់ការចោទប្រកាន់ដដែល និងសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះសម្រេចតាមច្បាប់ ។

<u>សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ</u> ÷

-លោក ហេង ឃាង ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ សាវិត ឧត្តម បានធ្វើសេចក្តីសន្និដ្ឋានការពារថាៈ ក្រោយពីការសាកសួរពេលនេះឃើញថាៈ កូនក្តីរបស់ខ្លួនបានឆ្លើយសារភាពហើយព្យសនកម្មមានលក្ខណៈតូចតាច ម្យ៉ាងទៀតកូនក្តីខ្លួនមានម្តាយចាស់ជរា និងមានកូនតូចៗនៅឡើយ ហេតុនេះសូមក្រុមប្រឹក្សាមេត្តាបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនផង ។

<u>សំដីចុងក្រោយរបស់ជនជាប់ចោទ</u>

-ជនជាប់ចោទឈ្មោះ សាវិត ឧត្តម បាននិយាយសំដីចុងក្រោយថាៈ សុំឱ្យតុលាការមេត្តាបន្ធូរបន្ថយទោសដល់ខ្លួនផង ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់អំណានចម្លើយសាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារ ភស្តុតាងនានា

-ក្រោយពីបានពិនិត្យពិចារណា និងពិភាក្សា ត្រឹមត្រូវតាមច្បាប់ហើយ

**សំអាងហេតុ**

១-កាលពីថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៧ វេលាម៉ោង០៩:៣០ នាទី មានករណី ÷លួចមានស្ថានទម្ងន់ទោស (ឆ្កឹះសោបន្ទប់ជួលយកទូរស័ព្ទដៃ)នៅចំណុចក្នុងបន្ទប់ជួល ភូមិស្លែងរលើង សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ សារិត ឧត្តម បានធ្វើសកម្មភាពឆ្កឹះសោចូលក្នុងបន្ទប់ជួលយកទូរស័ព្ទដៃម៉ាកសាំងស៊ុង ដែលជនរងគ្រោះដាក់បញ្ចូលថ្ម ។

២-តាមរបាយការណ៍សំយោគលេខ ៣៦០/១៧ របក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៧ របស់អធិការដ្ឋាននគរបាលខណ្ឌសែនសុខ បញ្ជាក់ថា: មានករណី ÷ លួច (ឆ្កឹះសោបន្ទប់ជួលយកទូរស័ព្ទដៃ) កាលពីថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៧ វេលាម៉ោង០៩:៣០នាទី នៅចំណុចក្នុងបន្ទប់ជួល ភូមិស្លែងរលើង សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

៣-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ សារិត ឧត្តម បានឆ្លើយសារភាពថាខ្លួនពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន មានភាពស៊ីសង្វាក់ជាមួយនឹងចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងចម្លើយរបស់សាក្សី ។

៤-អំពើរបស់ជនជាប់ចោទឈ្មោះ សារិត ឧត្តម ជាអំពើដកហូតដោយទុច្ចរិតនូវទ្រព្យសម្បត្តិរបស់អ្នកដទៃក្នុងគោលបំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន ដោយការគាស់ទម្លុះទម្លាយ អំពើនេះដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៥-តាមកំណត់ហេតុធ្វើតេស្តស្វែងរកសារធាតុញៀន ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៧ របស់អធិការដ្ឋាននគរបាលខណ្ឌសែនសុខ បានបញ្ជាក់ថា: ជនជាប់ចោទមានសារធាតុញៀន ជាប្រភេទមេតំហ្វេតាមីន ។

៦-ជនជាប់ចោទឈ្មោះ សារិត ឧត្តម ភេទប្រុស អាយុ២៣ឆ្នាំ ជាកំណត់អាយុដែលអាចទទួលខុសត្រូវខាងព្រហ្មទណ្ឌ ចំពោះអំពើរបស់ខ្លួន ហើយពុំមានសញ្ញាណាមួយដែលនាំឱ្យមានការសង្ស័យអំពីបញ្ហាស្មារតីឡើយ ដូចនេះ ជននេះប្រាកដជាយល់ដឹងថា អំពើរបស់ខ្លួនពិតជាប៉ះពាល់ធ្ងន់ធ្ងរដល់របៀបរៀបរយសណ្តាប់ធ្នាប់ សាធារណៈ និងសន្តិសុខសង្គម ។

៧- មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ សារិត ឧត្តម ភេទប្រុស អាយុ២៣ឆ្នាំ ពីបទ ÷លួចមានស្ថានទម្ងន់ទោស (ឆ្លុះសោរបន្ទប់ជួលយកទូរស័ព្ទដៃ) និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅក្នុងបន្ទប់ជួល ភូមិស្លែងលើង សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**ហេតុដូច្នេះសម្រេច**

-ផ្តន្ទាទោស ÷ ឈ្មោះ សារិត ឧត្តម ភេទប្រុស អាយុ២៣ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៤០០,០០០៛ (សែសិបម៉ឺន) រៀល ដាក់ចូលថវិការដ្ឋ ។

ពីបទ ÷ លួចមានស្ថានទម្ងន់ទោស (ឆ្លុះសោរបន្ទប់ជួលយកទូរស័ព្ទដៃ) និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅក្នុងបន្ទប់ជួល ភូមិស្លែងលើង សង្កាត់ទឹកថ្លា ខណ្ឌ សែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៧ ចំពោះមុខជនជាប់ចោទឈ្មោះ សារិត ឧត្តម ,កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈ នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៧ បើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។/

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា និងត្រា |
| **ជោត ច័ន្ទចាន់** | **ម៉ុន ចិ** | **សាន សុជាត** | **យ៉ុន សារឿន** |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០១៧

**ក្រឡាបញ្ជី**

**ជោត_ច័ន្ទចាន់**

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

យ៉ុន សារឿន

# ឧបសម្ព័ន្ធទី ៦

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

សំណុំរឿងព្រហ្មទណ្ឌលេខ ១៦៩៥
ចុះថ្ងៃទី ១២ ខែមេសា ឆ្នាំ ២០១៦
សំណុំរឿងជំនុំជម្រះលេខ១៩១៣
ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៦
**សាលក្រមលេខ ៥៦៣ ក្រ២ "ក"**
ចុះថ្ងៃទី២១ ខែ ធ្នូ ឆ្នាំ ២០១៦

**តាមនាមប្រជាពលរដ្ឋខ្មែរ**
**សាលាដំបូងរាជធានីភ្នំពេញ**

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ ២០១៦ វេលាម៉ោង ៨ និង ៣០ នាទី ព្រឹក ដោយមានសមាសភាព ៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] អនុប្រធានសាលាដំបូងរាជធានីភ្នំពេញ ប្រធានក្រុមប្រឹក្សា

លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ១៦៩៥ ចុះថ្ងៃទី ១២ ខែមេសា ឆ្នាំ ២០១៦ ដែលមានជនជាប់ចោទ ៖

១. ឈ្មោះ [redacted] **ឆេងា** ហៅ ស្ពា ភេទប្រុស អាយុ ២៦ ឆ្នាំ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ កម្រិតវប្បធម៌រៀន ថ្នាក់ទី៩ មុខរបរនៅផ្ទះ ទីកន្លែងកំណើត សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក ក្រុងភ្នំពេញ មានទីលំនៅបច្ចុប្បន្នផ្ទះជួល [redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "រស់" ម្តាយឈ្មោះ [redacted] "រស់" ប្រពន្ធឈ្មោះ [redacted] មានកូន ១ នាក់ ទោសពីមុន គ្មាន ។

លោក [redacted] **ចិសាល** មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ
**ឃាត់ខ្លួនថ្ងៃទី ១១ ខែមេសា ឆ្នាំ ២០១៦**
**ឃុំខ្លួនថ្ងៃទី ១៣ ខែមេសា ឆ្នាំ ២០១៦**

២.ឈ្មោះ [redacted] **សុជាតិ** ភេទប្រុស អាយុ ៣២ឆ្នាំ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ កម្រិតវប្បធម៌រៀនថ្នាក់ទី៥ មុខរបររត់ម៉ូតូឌុប ទីកន្លែងកំណើតភូមិពោធិ៍ ឃុំតានី ស្រុកអង្គរជ័យ ខេត្តកំពត មានទីលំនៅបច្ចុប្បន្ន ផ្ទះជួល សង្កាត់ទឹក [redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "រស់" ម្តាយឈ្មោះ [redacted] "រស់" ប្រពន្ធឈ្មោះ [redacted] មានកូន ០១នាក់ ទោសពីមុនគ្មាន ។

លោក [redacted] **សាល** មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ
**ឃាត់ខ្លួនថ្ងៃទី ១១ ខែមេសា ឆ្នាំ ២០១៦**
**ឃុំខ្លួនថ្ងៃទី ១៣ ខែមេសា ឆ្នាំ ២០១៦**

៣.ឈ្មោះ [redacted]សុមុនី ហៅ គួក ភេទប្រុស អាយុ ១៨ឆ្នាំ សញ្ជាតិខ្មែរ សាសនា ព្រះពុទ្ធ កម្រិតវប្បធម៌រៀនថ្នាក់ទី៨ មុខរបរគ្មាន ទីកន្លែងកំណើតនៅ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ មានទីលំនៅបច្ចុប្បន្ន [redacted] ខណ្ឌទួលគោក រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] -ស្លាប់- ម្តាយឈ្មោះ [redacted] -រស់- នៅលីវ ទោសពីមុនគ្មាន។

លោក[redacted]**ចិសាល** មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

ឃាត់ខ្លួនថ្ងៃទី ១១ ខែមេសា ឆ្នាំ ២០១៦

ឃុំខ្លួនថ្ងៃទី ១៣ ខែមេសា ឆ្នាំ ២០១៦

ពីបទ **ប៉ុនប៉ងលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅចំណុច ផ្ទះលេខ១៣៦ ផ្លូវលំ ភូមិផ្សារទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ២៧ មាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

ជនរងគ្រោះឈ្មោះ [redacted] **សាព៌ត** ភេទប្រុស អាយុ ៥៩ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ មន្ត្រីគយ មានទីលំនៅផ្ទះលេខ១៣៦ ផ្លូវលំ ភូមិផ្សារទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ២៨៥០ អ.យ.ព ចុះថ្ងៃទី ១៤ ខែតុលា ឆ្នាំ ២០១៦ របស់ អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៣៧២៤ ច.ជ ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៦ ជនរងគ្រោះឈ្មោះ [redacted] សាព៌ត បានយកមេសោ ពណ៌ខ្មៅ ទៅចាក់ទ្វារជណ្តើរឡើងទៅលើផ្ទះជួល នៅចំណុចផ្ទះលេខ១៣៦ ផ្លូវលំ ភូមិផ្សារទឹកថ្លា សង្កាត់ ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ រួចក៏ចូលទៅដេកលង់លក់ជាមួយក្រុមគ្រួសារ។ លុះដល់ម៉ោង ប្រហែល ០៣ និង ៣០ នាទី រំលងអាធ្រាត ក៏មានជនជាប់ចោទចំនួនបីនាក់មានឈ្មោះ [redacted] សុមុនី ហៅ គួក ភេទ ប្រុស ឈ្មោះ [redacted] រតនា ហៅ ស្នា ភេទ ប្រុស និងឈ្មោះ [redacted] សុជាតិ ភេទ ប្រុស បាន ជិះម៉ូតូ មួយគ្រឿង មកឈប់មុខផ្ទះជនរងគ្រោះ។ ដោយឃើញសភាពស្ងាត់ឈ្មោះ គួក និងឈ្មោះ ស្នា បានដើរចូលទៅដោយបានយកម្ជុលខ្វាស់ទៅគ្លេះសោទ្វារឱ្យបើក បន្ទាប់មកជនសង្ស័យទាំងពីរ នាក់ បានដើរទៅជាន់ទីពីរ។ ពេលកំពុងតែដើរឡើងទៅ ស្រាប់តែមានអ្នកជិតខាងឃើញក៏ស្រែកថា ចោរៗ ភ្លាមនោះជនរងគ្រោះក៏បើកទ្វារផ្ទះចេញមកឃើញទ្វារជណ្តើរចំហរ ហើយមេសោរបូត ក៏ផ្អើលដល់ ប្រជាពលរដ្ឋ រួចចាប់ខ្លួនជនជាប់ចោទទាំងបីនាក់បាន ហើយប្រគល់ឱ្យសមត្ថកិច្ចប៉ុស្តិ៍នគរបាលទឹក ថ្លាតែម្តង។

## នាពេលសវនាការ

ជនជាប់ចោទឈ្មោះ [redacted]**រតនា** បានឆ្លើយថា : កាលពីយប់ថ្ងៃទី ១១ ខែមេសា ឆ្នាំ ២០១៦ វេលាម៉ោង១និង៣០នាទីរំលងអាធ្រាត្រ ខ្លួន និង ឈ្មោះ [redacted] សុមុនី នៅកន្លែងបាញ់ត្រីបានឲ្យឈ្មោះ [redacted] សុជាតិ ឌុបម៉ូតូជូនខ្លួនទៅទារលុយបងប្អូននៅជិតទឹកថ្លា ពេលជិះដល់ក្រោយវត្តទឹកថ្លា ស្រាប់តែ ឃើញផ្ទះមួយ មានទុកកង់ ខ្លួនបានដើរចូលទៅ ជាមួយឈ្មោះ [redacted] សុមុនី ក៏បានម្ជុលខ្វាស់គ្លេះ សោរ ទ្វារដើរចូលទៅក្នុងផ្ទះបំណងយកកង់តែមិនបានយកក៏ត្រូវបានម្ចាស់គេទាន់ស្រែកថាចោរៗសមត្ថកិច្ច

មកដល់ក៏ឃាត់ពួកខ្លួនតែម្តង ។ ចំណែកឈ្មោះ [redacted] សុជាតិ នៅឈរចាំម៉ូតូខាងក្រៅ ។

ជនជាប់ចោទឈ្មោះ [redacted] **សុជាតិ** បានឆ្លើយថា : ខ្លួនសុំបដិសេធ ដោយខ្លួនមិនបាន សមគំនិតក្នុងការចូលលួចទេ យប់នោះឈ្មោះ [redacted] រតនា និងឈ្មោះ [redacted] សុមុន្នី ហៅខ្លួនជាអ្នកជាក់ ម៉ូតូឌុបឲ្យខ្លួនឌុបទៅដោយឲ្យខ្លួនចំនួន១០០០០(មួយម៉ឺន)រៀល ដោយប្រាប់ខ្លួនថាទៅទារលុយប្អូន ដោយខ្លួនមិនបានឮពួកគេនិយាយថាទៅលួចទេ ពេលខ្លួនឌុបទៅដល់ខ្លួនបានឈប់ម៉ូតូពួកគេ ទាំង២នាក់បាន ចុះពីលើម៉ូតូដើរសំដៅផ្ទះមួយ ហើយខ្លួនបាននៅឈរចាំចម្ងាយ២០ម៉ែត្រពីពួកគេ ហើយខ្លួនឃើញឈ្មោះ [redacted] រតនា លូកដៃចូលក្នុងក្រង់ជាផ្តិះសោរឬអត់ខ្លួនអត់បានដឹងទេ ហើយខ្លួនឃើញឈ្មោះ [redacted] រតនា និងឈ្មោះ [redacted] សុមុន្នី ដើរចូលទៅ មួយសន្ទុះក៏ត្រូវសមត្ថកិច្ចចាប់ខ្លួនបាន ហើយខ្លួនក៏មិន ទាន់បានលុយពីពួកគេឡើយ។

ជនជាប់ចោទឈ្មោះ [redacted] **សុមុន្នី** បានឆ្លើយថា : កាលពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ វេលាម៉ោង ប្រហែល ២រំលងអាធ្រាត្រ ខ្លួនបានទៅលេងហ្គេមបាញ់ត្រីនៅសង្កាត់ទឹកល្អក់៣ ជួបជាមួយឈ្មោះ [redacted] រតនា ហៅស្វា ក៏បានបបួលខ្លួនទៅលួចគេនៅភូមិទឹកថ្លាហើយក៏បាននាំគ្នាជិះម៉ូតូឌុបរបស់ឈ្មោះ សុជាតិ ពេលដល់ភូមិក្រោយផ្សារទឹកថ្លាឈ្មោះ [redacted] រតនា ហៅស្វា បានឲ្យម៉ូតូឈប់ហើយឈ្មោះ [redacted] រតនា និង ខ្លួន បានដើរចូលទៅផ្ទះមួយទ្វារបិទជិត ឃើញមានកង់មួយបំណង លួចយកទៅលក់បានលុយចែកគ្នា ហើយឈ្មោះ [redacted] រតនា បានលូកដៃទៅក្នុងទ្វារផ្តិះសោរទ្វារបើក នាំគ្នាដើរចូលទៅ ក៏ត្រូវម្ចាស់ផ្ទះគេស្រែក ថា ចោរៗ ក៏ត្រូវ ចាប់ខ្លួនតែម្តង។ ចំណែកឈ្មោះ សុជាតិ គ្រាន់តែជាម៉ូតូឌុបឈរ ចាំម៉ូតូមិនបាន ចូលទៅ ជាមួយទេ។

តាមអំណាចចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] **សាខ៊ាត** បានឆ្លើយនៅចំពោះមុខចៅក្រមស៊ើបសួរថា កាលពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ប្រហែលម៉ោង៨ទៀបភ្លឺពេលនោះ ខ្លួនឮសំលេងស្រែកថាចោរៗ នៅល្វែងខាងលើផ្ទះដែលខ្លួនបានសង់ជាបន្ទប់ ជួលឲ្យគេខ្លួនក៏បានបើក ទ្វារខាងក្រោយផ្ទះ ហើយឃើញសមត្ថកិច្ចកំពង់ប្រតិបត្តិការដោយកំពុង ក្ងងជនសង្ស័យម្នាក់ដែលនៅពួនក្រោមជណ្តើរ ហើយសមត្ថកិច្ចក៏បានស្រែកឲ្យវាចេញមកហើយក៏ចាប់បានម្នាក់ ពេលនោះសមត្ថកិច្ចក៏បានឡើងទៅជាន់ខាងលើចាប់បានម្នាក់ទៀត ពេលនោះខ្លួនក៏បានតាមមើលសមត្ថកិច្ចបណ្តើរ ជនសង្ស័យទាំងពីរមកខាងក្រៅ ហើយក៏បានឃើញម្នាក់ទៀតដែលសមត្ថកិច្ច ឃាត់បានសរុបគឺមានជនល្មើស៣នាក់។ កន្លងមកអ្នកដែលនៅផ្ទះជួលជាន់លើ តែងតែបាត់បង់ទូរទស្សន៍ កុំព្យូទ័រ ម៉ូតូ គឺតែងតែគាស់សោរទ្វារបន្ទប់ចូលយកអីវ៉ាន់។ នៅថ្ងៃកើតហេតុនោះគឺជនសង្ស័យគាស់សោរទ្វារខាងមុខដើម្បីឡើងទៅជាន់ខាងលើ តែឡើងទៅជាន់ខាងលើមិនទាន់បានធ្វើអ្វីទេ សាក្សីបានឃើញហើយស្រែក ពក់នាំគ្នាចុះមកក្រោមតែត្រូវសមត្ថកិច្ចខ្ទប់ហើយធ្វើការឃាត់ខ្លួនតែម្តង ខ្លួនបានមើលឃើញសកម្មភាពនេះតាមកាមេរ៉ាសុវត្ថិភាព។ ខ្លួនសំណូមពរឲ្យផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ និងមិនទាមទារសំណងជម្ងឺចិត្តអ្វីទេ ។

តាមអំណាចចម្លើយរបស់សាក្សីឈ្មោះ [redacted] **មុនី** បានស្បថស្បែហើយ បានឆ្លើយថា កាលពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ វេលាម៉ោងជិត៨ ទៀបភ្លឺ ពេលនោះពេលនោះខ្លួនទើប ចេញពីធ្វើការ ហើយត្រឡប់មកផ្ទះជួលក៏ឡើងទៅលើជាន់ទី៣ អង្គុយលេងជាមួយមិត្តភក្តិ នៅជាន់នោះ ព្រោះបន្ទប់

ខ្លួននៅជាន់ទី២ភ្លេចយកសោរពុំមានអ្វីចូលក៏ត្រូវអង្គុយលេងចាំមិត្តភក្តិយកសោរមក ពេលនោះ ខ្លួនក៏បានឃើញមនុស្សប្រុសបីនាក់ ជិះម៉ូតូមកឈប់នៅមុខផ្ទះជួល ហើយហើយបានឃើញមនុស្ស ប្រុស២នាក់បានឡើងមកជាន់ទី២ ខ្លួនក៏សង្ស័យព្រោះថាអ្នកជួលផ្ទះនេះសុទ្ធតែជាអ្នកធ្វើការ និងសិស្ស តែ២នាក់នោះគឺមិនមែន ស្រាប់តែពេលនោះខ្លួនបានឃើញប៉ូលីសជិះល្បាតពីម៉ូតូខ្លួនក៏ស្រែកថា ចោរៗ សមត្ថកិច្ចក៏បានឡើងមកជាន់លើធ្វើការឃាត់ខ្លួនបានទាំង២នាក់ ដែលឡើងមកជាន់ទី២នោះ និងម្នាក់ទៀតដែលនៅចាំនៅក្រៅ សរុបបានបីនាក់ ។ ខ្លួនបានឃើញពីនាក់ដែលឡើងមកជាន់ទី២ នោះ ដិះសោរបន្ទប់គេ ដែលម្ចាស់បន្ទប់បានទៅស្រុកកំណើតចូលឆ្នាំអស់ ។ ពួកគេមិនទាន់ផ្តិះបានសម្រេចទេ ដោយពេលនោះខ្លួនឃើញប៉ូលីសល្បាតមកឈប់ ស្រាប់ម្នាក់ទៀតដែលនៅចាំខាង ក្រៅភ្លាមខ្លួនក៏ស្រែកភ្លាមតែម្តង ។

តាមអំណានកំណត់ហេតុទទួលវត្ថុតាប់យកលេខ៤២៨ វ.អ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៦ មាន៖ ១. មេសោរចិនចំនួន១

២. ទួរស័ក្តដៃចំនួន១ (ពណ៌ខ្មៅបែកអេក្រង់ចាស់)

៣. ម៉ូតូចំនួន១គ្រឿង ម៉ាកសង់សេ១០០ ពណ៌ខ្មៅសេរី៩៧ ពាក់ស្លាកលេខ ខ៣៣៥២ ក.ណ ១ (មិនប្រក្រតី) ។

តាមអំណានរបាយការណ៍សំយោគលេខ០៤៣/១៦ របក ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៦ របស់អធិការដ្ឋាននគរបាលខណ្ឌសែនសុខថា៖ ជនសង្ស័យចំនួន៣នាក់ ដែលឃាត់ខ្លួនបាន មាន ឈ្មោះ[redacted]សុមុន្នី, ឈ្មោះ[redacted]រតនា, ឈ្មោះ[redacted]សុជាតិ ពិតជាបានប្រព្រឹត្តអំពើប៉ុនប៉ងលួច កាលពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ វេលាម៉ោងប្រហែល ៣ និង៣០នាទី រំលងអាធ្រាត្រ នៅចំណុចផ្ទះលេខ១៣៦ ផ្លូវលំ ភូមិផ្សារទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប្រាកដមែន។

## សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

ក្រោយពីបានសួរដេញដោលជនជាប់ចោទទាំង៣ ឃើញថាជនជាប់ចោទ ឈ្មោះ[redacted]រតនា បានឆ្លើយសារភាពថាខ្លួនពិតជាបានប៉ុនប៉ងធ្វើ សកម្មភាពលួច ប្រព្រឹត្តនៅនៅចំណុចផ្ទះលេខ១៣៦ ផ្លូវលំ ភូមិផ្សារទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែន សុខ រាជធានីភ្នំពេញ ប្រាកដមែន ។ហើយឈ្មោះ[redacted] រតនា និងឈ្មោះ[redacted] សុមុន្នី បានពិភាក្សាគ្នាដើររកលុយ ចំណែកឈ្មោះ[redacted] សុជាតិ ជាអ្នកជិះម៉ូតូឌុបនាពេលសវនាការបានឆ្លើយបដិសេធថា ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ តែខ្លួនបានឌុបឈ្មោះ[redacted]រតនា និងឈ្មោះ[redacted] សុមុន្នី ដែលចម្លើយនេះស្របជាមួយកស្តុតាង ដែលឈ្មោះ[redacted] រតនា និងឈ្មោះ[redacted]សុមុន្នី ចូលធ្វើសកម្មភាព ឈ្មោះ[redacted]សុជាតិ បានឈប់ម៉ូតូចម្ងាយ២០ម៉ែត្រ រីឯឈ្មោះ[redacted]សុមុន្នី ក៏បានឆ្លើយសារភាពដូចឈ្មោះ[redacted]រតនា ដែរ ចម្លើយទាំងបី គឺមានភាពស៊ីចង្វាក់គ្នាជាមួយ ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងចម្លើយសាក្សី តែការធ្វើសកម្មភាពរបស់ជនទាំងបីគឺមិនបានសម្រេច ដូច្នេះតំណាងអយ្យការនៅតែតម្កល់ការចោទប្រកាន់ តាមដីកាសន្និដ្ឋានស្ថាពរលេខ ២៤៥០ អ.យ.ពចុះថ្ងៃទី ១៩ ខែតុលា ឆ្នាំ២០១៦ ទុកដដែល សុំឱ្យតុលាការ សម្រេច ទៅតាមច្បាប់ ។

**មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា** ក្នុងពេលសវនាការកូនក្តីខ្លួន ឈ្មោះ [redacted] រតនា និងឈ្មោះ [redacted] សុមុន្នី បានឆ្លើយសារភាពជូន តុលាការដោយបាន ដឹងពីកំហុសរបស់ខ្លួនហើយ ដូចនេះខ្លួនសុំឲ្យតុលាការជួយបន្ធូរបន្ថយទោសដល់កូនក្តីខ្លួន។ ចំពោះកូនក្តីខ្លួន ឈ្មោះ [redacted] សុជាតិ បានឆ្លើយថាខ្លួនមិនបានចូលរួមប្រព្រឹត្តទេ ហើយចម្លើយនេះដូចចម្លើយនៅ សមត្ថកិច្ច និងចម្លើយនៅចៅក្រមស៊ើបសួរ ថាខ្លួនគ្រាន់តែឌុបជូនឈ្មោះ [redacted] រតនា និងឈ្មោះ [redacted] សុមុន្នី ទៅយកលុយប្អូនដោយទទួលតម្លៃចំនួន១០០០០(មួយម៉ឺន)រៀល ហើយអ្នកទាំងពីរបាន ឲ្យខ្លួនឈប់ នៅរងចាំ ដោយមិនបានដឹងថាអ្នកទាំងពីរចូលធ្វើសកម្មភាព ផ្តិះសោរទ្វារបំណងចូលលួច សម្ភារៈ របស់គេទេ។ ដូច្នេះហើយខ្លួនសុំឲ្យតុលាការសម្រេចឲ្យឈ្មោះ [redacted] សុជាតិ បានរួចផុតពី បទចោទ ប្រកាន់ ។

## ជនជាប់ចោទឆ្លើយសម្តីចុងក្រោយ

ជនជាប់ចោទឈ្មោះ [redacted] **រតនា** បានឆ្លើយថា ៖ សុំឲ្យតុលាការមេត្តាជួយ សម្រាលទោស ដល់ខ្លួនផង ខ្លួនដឹងកំហុសហើយ ។

ជនជាប់ចោទឈ្មោះ [redacted] **សុមុន្នី** បាននិយាយសម្តីចុងក្រោយថា ៖ សុំឲ្យតុលាការសម្រាលទោសខ្លួនដឹងកំហុសហើយ ។

ជនជាប់ចោទឈ្មោះ [redacted] **សុជាតិ** បាននិយាយសម្តីចុងក្រោយថា ៖ សុំឲ្យតុលាការលើកលែងចោទ ប្រកាន់ ។

ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ
ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនរងគ្រោះ
ក្រោយពីបានស្តាប់អំណានចម្លើយរបស់សាក្សី
ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ
ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ
ក្រោយពីបានពិនិត្យកស្តុតាង
ក្រោយពីបានពិនិត្យ ពិភាក្សា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១. កាលពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ វេលាម៉ោងប្រហែល៣ និង៣០ នាទី រំលងអាធ្រាត្រ ជនជាប់ចោទឈ្មោះ [redacted] រតនា ហៅ ស្វា, ឈ្មោះ [redacted] សុមុន្នី ហៅ តូក និងឈ្មោះ [redacted] សុជាតិ ពិតជា បានផ្តើមធ្វើសកម្មភាពប៉ុនប៉ងលួចទ្រព្យសម្បត្តិ នៅផ្ទះលេខ១៣៦ ផ្លូវលំ ភូមិផ្សារទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប៉ុន្តែមានអ្នកជិតខាងឃើញក៏ស្រែកថាចោរភ្លាមនោះជនរងគ្រោះក៏ភ្ញាក់ពី ដំណេក ក៏បើកទ្វារចេញមកមើលឃើញ ទ្វារដេញ្ឈើរចំហរក៏ ស្រែកដល់ប្រជាពលរដ្ឋ នោឡោឡ ដល់ សមត្ថកិច្ច កំពុងដើរល្បាតមកដល់កន្លែងកើតហេតុក៏បានអន្តរាគមន៍ឡើងលើផ្ទះចាប់បានជនជាប់ចោទចំនួន២ នាក់ឈ្មោះ [redacted] រតនា និងឈ្មោះ [redacted] សុមុន្នី ចំណែកឈ្មោះ [redacted] សុជាតិ ចាប់ខ្លួនបាននៅខាង

ក្រោមកំពុងមើលម៉ូតូរងចាំអ្នកទាំងពីររួចបង្កសំណុំរឿងបញ្ជូនមកតុលាការតែម្តង ប្រាកដមែន ។

២. ជនជាប់ចោទឈ្មោះ [redacted] រតនា និងឈ្មោះ [redacted] សុមុន្នី បានឆ្លើយសារភាពថាពួកខ្លួនពិតជាបានប៉ុនប៉ងធ្វើសកម្មភាពលួចប្រាកដមែន ដែលចម្លើយសារភាពនេះ ស្របទៅនឹងចម្លើយរបស់ជនរងគ្រោះ និងសាក្សី បានឆ្លើយនៅគ្រប់ដំណាក់កាលនីតិវិធី ស្របទៅនឹងរបាយការណ៍ សំយោគរបស់មន្ត្រី នគរបាលយុត្តិធម៌ ហើយក៏ស្របទៅនឹងភស្តុតាង ជាឯកសារផ្សេងៗទៀតដែល មាននៅក្នុងសំណុំរឿង ផងដែរ ។

៣. ថ្វីត្បិតតែនាពេលសវនាការជនជាប់ចោទឈ្មោះ [redacted] សុជាតិ បានឆ្លើយបដិសេធថាខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេប៉ុន្តែចម្លើយនេះគ្រាន់តែជាការដោះសារប៉ុណ្ណោះព្រោះថាតាម ចម្លើយរបស់ជនរងគ្រោះ និងចម្លើយរបស់សាក្សីបានបញ្ជាក់ថាជនជាប់ចោទពិតជាបានប៉ុនប៉ងធ្វើសកម្មភាពលួចទ្រព្យរបស់អ្នកដទៃ នៅយប់ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៦ ដែលស្របទៅ និងរបាយការណ៍សំយោគ ប្រាកដមែន។

៤. ជនជាប់ចោទឈ្មោះ [redacted] រតនា, ឈ្មោះ [redacted] សុមុន្នី និងឈ្មោះ [redacted] សុជាតិ ជានីតិជនដែលពុំមានភស្តុតាង ណាមួយបញ្ជាក់ថា មានបញ្ហាខាងស្មារតីឡើយ ដូច្នេះជនជាប់ចោទពិតជាមានការយល់ដឹងពីផល វិបាក ដែលកើតចេញពីអំពើប្រព្រឹត្តរបស់ខ្លួន ។

៥. សកម្មភាពប្រព្រឹត្តរបស់ជនជាប់ចោទ បានបញ្ជាក់យ៉ាងច្បាស់ពីចេតនាទុច្ចរិតក្នុងការចាប់ផ្តើមប្រព្រឹត្តសកម្មភាពយកទ្រព្យសម្បត្តិរបស់អ្នកដទៃមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន ប៉ុន្តែត្រូវរអាក់ខានមិនបានសម្រេចដោយ សារតែកម្លាំងនគរបាលមកពាំងប្រាកដមែន។

៦.អំពើប្រព្រឹត្តរបស់ជនជាប់ចោទ បានធ្វើឱ្យប៉ះពាល់ដល់របៀបរៀបរយសណ្តាប់សាធារណៈ សន្តិសុខសង្គម និងទ្រព្យសម្បត្តិរបស់បុគ្គលឯកជនដែលច្បាប់ការពារ ។

៧. មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] រតនា, ឈ្មោះ [redacted] សុមុន្នី និងឈ្មោះ [redacted] សុជាតិ ពីបទ **ប៉ុនប៉ងលួចមានស្ថានទម្ងន់ទោសដោយការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅ ចំណុចផ្ទះលេខ១៣៦ ផ្លូវលំ ភូមិផ្សារទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី ១១ ខែមេសា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមាន ចែងឱ្យផ្តន្ទាទោសតាមមាត្រា ២៧ មាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៨.ជនជាប់ចោទជាជនក្រីក្រ និងមានកម្រិតវប្បធម៌ទាប ។

៩.វត្ថុចាប់យកតប្បីរឹបអូសមាន៖

ក. មេសោរចិនចំនួន១

ខ. ទូរស័ព្ទដៃចំនួន១ (ពណ៌ខ្មៅបែកអេក្រង់ចាស់)

គ. ម៉ូតូចំនួន១គ្រឿង ម៉ាកសង់សេ១០០ ពណ៌ខ្មៅស៊េរី៩៧ ពាក់ស្លាកលេខ ខ៣៣៥២ ក.ណ ១ (មិនប្រក្រតី)

១០. ជនជាប់ឈ្មោះ [redacted] រតនា ត្រូវបានឃុំខ្លួនថ្ងៃទី១៣ ខែមេសា ឆ្នាំ ២០១៦ ។

១១. ជនជាប់ចោទឈ្មោះ [redacted] សុមុន្នី ត្រូវបានឃុំខ្លួនថ្ងៃ១៣ ខែមេសា ឆ្នាំ ២០១៦ ។

១២. ជនជាប់ចោទឈ្មោះ [redacted] សុជាតិ ត្រូវបានឃុំខ្លួនថ្ងៃទ១៣ ខែមេសា ឆ្នាំ ២០១៦ ។

## <u>ហេតុដូច្នេះសម្រេច</u>

១. ផ្តន្ទាទោស ៖

ក. ឈ្មោះ [redacted] គេងា ហៅស្វា ភេទប្រុស អាយុ ២៦ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ៤ (បួន)ឆ្នាំ

ខ. ឈ្មោះ [redacted] សុមុន្នី ហៅតូក ភេទប្រុស អាយុ ១៨ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ៤ (បួន)ឆ្នាំ

គ. ឈ្មោះ [redacted] សុជាតិ ភេទប្រុស អាយុ ៣៧ឆ្នាំសញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់៤ (បួន)ឆ្នាំ

ពីបទ **ប៉ុនប៉ងលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅចំណុចផ្ទះលេខ១៣៦ ផ្លូវលំ ភូមិផ្សារទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី ១១ ខែមេសា ឆ្នាំ ២០១៦។

តាមមាត្រា ២៧ មាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

២. រក្សាចាប់យកក្រូវិបអូសតាមមាត្រា៦២, មាត្រា៦៣ នៃក្រមព្រហ្មទណ្ឌគឺ៖

ក. មេសោរចិនចំនួន១

ខ. ទូរស័ព្ទដៃចំនួន១ (ពណ៌ខ្មៅបែកអេក្រង់ចាស់)

គ. ម៉ូតូចំនួន១គ្រឿង ម៉ាកសង់សេ១០០ ពណ៌ខ្មៅសេរី៩៧ ពាក់ស្លាកលេខ ខ៣៣៥២ ក.ណ ១ (មិនប្រក្រតី)។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ២០១៦ ចំពោះមុខជនជាប់ចោទ ចំពោះមុខមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទនិងប្រកាសជាសាធារណៈនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៦។

បើកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

| ក្រឡាបញ្ជីសវនាការ | តំណាងអយ្យការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |
| [redacted] | [redacted] | [redacted] | [redacted] | [redacted] |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១៦

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

**ឧបសម្ព័ន្ធទី ៧**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ
លេខ ៣៨៩៥
ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៦

សំណុំរឿងជំនុំជម្រះ
លេខ ៩០៣០
ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៦

សាលក្រមព្រហ្មទណ្ឌ
លេខ ១១ "ក្រ៤ស"
ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៧

## តាមនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៧
វេលាម៉ោង ០៨ព្រឹក ដោយមានសមាសភាពៈ

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] អនុប្រធានសាលាដំបូងរាជធានីភ្នំពេញជាប្រធានក្រុមប្រឹក្សា
លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សា
លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារង អមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៣៨៩៥ ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ដែលមានជនជាប់ចោទ:

ឈ្មោះ [redacted] សុគន្ធា ភេទស្រី អាយុ ១៦ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ ស្ត្រីរកស៊ីផ្លូវភេទ ទីកន្លែងកំណើតនៅសង្កាត់បឹងព្រលិត ខណ្ឌ៧មករា ក្រុងភ្នំពេញ សាសនាព្រះពុទ្ធ កម្រិតវប្បធម៌ មិនចេះអក្សរ មានទីលំនៅមុនពេលចាប់ខ្លួ [redacted] ៣០០ សង្កាត់បឹងព្រលិត ខណ្ឌ៧មករា រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "រ" នៅរស់ ជាតិជន។

ឃាត់ខ្លួន នៅថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦។

ឃុំខ្លួន នៅថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១៦។

ដោយមានលោក [redacted] ទិសាល ជាមេធាវីការពារសិទ្ធិ។

ពីបទ **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចផ្ទះលេខ ១៨១E₀ ផ្លូវលេខ ១២៨ ភូមិ ០៨ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦ តាមមាត្រា ៣៥៣ , ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

ជនរងគ្រោះនិងជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ទិមុល ភេទប្រុស អាយុ ២៥ឆ្នាំ មានអាសយដ្ឋាននៅផ្ទះលេ [redacted] ភូមិ ០៨ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ។

## អង្គហេតុ

កាលពីថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦ វេលាម៉ោងប្រហែល ០៣:១០នាទី ទៀបភ្លឺ នៅចំណុច ផ្ទះលេខ ១៨១E₀ ផ្លូវលេខ ១២៨ ភូមិ ០៨ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ មានករណីលួចមានស្ថានទម្ងន់ទោស មួយបានកើតឡើង ដែលបង្កដោយជនជាប់ចោទឈ្មោះ [redacted] សុភក្រ្ត័ បានកាត់សោរទ្វាផ្ទះ លួចយកសម្ភារៈរបស់ជនរងគ្រោះឈ្មោះ [redacted] វិបុល ពេលកំពុងធ្វើសកម្មភាពនោះ ស្រាប់តែប្រពន្ធរបស់ជនរងគ្រោះភ្ញាក់ដឹងខ្លួនទាន់ ក៏ស្រែកឆោឡោ ហើយឈ្មោះ [redacted] សុភក្រ្ត័ រត់ចុះមកក្រោម ក៏ត្រូវប្រជាជនចាប់ខ្លួនប្រគល់ឲ្យសមត្ថកិច្ចតែម្តង។

បានឃើញ របាយការណ៍សំយោគលេខ ៨១/១៦ រ.ប.ក ចុះថ្ងៃទី ១៨ សីហា ឆ្នាំ ២០១៦ របស់អធិការដ្ឋានខណ្ឌ៧មករា នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ។

បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៣១៦៨ អ.យ.ច ចុះថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០១៦ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញ ដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ ៨១២០ "ឆ" ច.ជ ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៦ របស់ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ។

## [illegible]

ជនជាប់ចោទឈ្មោះ [redacted] សុភក្រ្ត័ បានឆ្លើយថា: កាលពីថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦ វេលាម៉ោងប្រហែល ០៣:១០នាទី ទៀបភ្លឺ ខ្លួនបានជិះម៉ូតូឌុបមកឈប់នៅមុខផ្ទះលេខ ១៨១E₀ ផ្លូវលេខ ១២៨ ភូមិ ០៨ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ហើយខ្លួនក៏ចូលទៅកាត់សោរទ្វាផ្ទះរបស់គេ លួចយកបានលេបថបចំនួន ០១គ្រឿង និងទូរស័ព្ទចំនួន ០២គ្រឿង ពេលកំពុងធ្វើសកម្មភាពនោះ ស្រាប់តែម្ចាស់គេភ្ញាក់ដឹងខ្លួនទាន់ ក៏ស្រែកឆោឡោ ហើយខ្លួនរត់ចុះមកក្រោម ក៏ត្រូវប្រជាជនចាប់ឃាត់ខ្លួនប្រគល់ឲ្យសមត្ថកិច្ចតែម្តង។ ខ្លួនប្រព្រឹត្តតែម្នាក់ឯងទេ គ្មានបក្ខពួកឡើយ។

តាមអំណានចម្លើយជនរងគ្រោះនិងជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] វិបុល នៅចំពោះមុខចៅក្រមស៊ើបសួរថា: កាលពីថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៦ ពេលយប់ ក្រុមគ្រួសារខ្លួនបានចាក់សោរផ្ទះចូលដេក លុះដល់ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦ វេលាម៉ោងប្រហែល ០៣:១០នាទី ទៀបភ្លឺ ស្រាប់តែប្រពន្ធខ្លួនបានស្រែកឆោឡោថាមានចោរចូលលួចយកសម្ភារៈក្នុងផ្ទះ ពេលនោះជនសង្ស័យក៏រត់ចុះមកក្រោម ហើយត្រូវប្រជាជនឃាត់ខ្លួនប្រគល់ឲ្យសមត្ថកិច្ចតែម្តង។ ចំពោះសម្ភារៈដែលមានចោរលួចមានទូរសព្ទដៃ ០២គ្រឿង ម៉ាកសាំសុង ចំនួន ០១គ្រឿង និងអាហ្វូនចំនួន ០១គ្រឿង , ឡេបថបចំនួន ០១គ្រឿង និងខ្សែកធ្លាកទិនចំនួន ០១ខ្សែ តម្លៃចំនួន ១៨០ (មួយរយប៉ែតសិប)ដុល្លារអាមេរិក ហើយខ្លួនទទួលបានទូរសព្ទដៃ និងឡេបថប មកប្រើប្រាស់វិញហើយ តែខ្សែករកមិនឃើញ។ សំណូមពរសុំឲ្យតុលាការផ្តន្ទាទោសជនល្មើសតាមច្បាប់ និងសុំទាមទារថ្លៃខ្សែកដែលបាត់បង់ចំនួន ១៨០ (មួយរយប៉ែតសិប)ដុល្លារអាមេរិក។

តាមអំណានចម្លើយសាក្សីឈ្មោះ [redacted] ស្រីភា នៅចំពោះមុខចៅក្រមស៊ើបសួរថា: កាលពីថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៦ ពេលយប់ ក្រុមគ្រួសារខ្លួនបានចាក់សោរផ្ទះចូលដេក លុះដល់ថ្ងៃទី ១៣

ខែ សីហា ឆ្នាំ ២០១៦ វេលាម៉ោងប្រហែល ០៣:១០នាទី ទៀបភ្លឺ ស្រាប់តែខ្លួនឃើញមានចោរចូលលួចយកសម្ភារៈក្នុងផ្ទះ ខ្លួនក៏ស្រែកឆោឡោថាមានចោរចូលលួចយកសម្ភារៈក្នុងផ្ទះ ពេលនោះជនសង្ស័យក៏រត់ចុះមកក្រោម ក៏ត្រូវប្រជាជនឃាត់ខ្លួនប្រគល់ឲ្យសមត្ថកិច្ចតែម្តង។

តាមអំណានចម្លើយសាក្សីឈ្មោះ [redacted]រតនាវង្ស នៅចំពោះមុខចៅក្រមស៊ើបសួរថា: កាលពីថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦ វេលាម៉ោងប្រហែល ០៣:១០នាទី ទៀបភ្លឺ ពេលខ្លួនកំពុងដេក ស្រាប់តែឮសម្លេងស្រែកឆោឡោថាមានចោរគាស់ផ្ទះលួចយកសម្ភារៈ ខ្លួនក៏ក្រោកឡើងឃើញមានមនុស្សស្រីម្នាក់កំពុងកាន់ទូរសព្ទដៃរបស់ប្អូនស្រីខ្លួន ហើយឃើញគៀបលេបផបជាប់ភ្លៀក ខ្លួនស្ទុះទៅចាប់ជននោះ តែជនសង្ស័យក៏រត់ចុះមកក្រោម ក៏ត្រូវប្រជាជនឃាត់ខ្លួនប្រគល់ឲ្យសមត្ថកិច្ចតែម្តង។

តាមអំណានកំណត់ហេតុចាប់យកវត្ថុតាង ចុះថ្ងៃទី ១៣ សីហា ឆ្នាំ ២០១៦ របស់អធិការដ្ឋានខណ្ឌ៧មករា បានបញ្ជាក់ថា: បានដំណើរការធ្វើកំណត់ហេតុចាប់យកវត្ថុតាងពីឈ្មោះ[redacted]សុភក្រ្តី ភេទស្រី អាយុ ១៦ឆ្នាំ រួមមានកន្ត្រៃសម្រាប់កាត់ដែកចំនួន ០១ដើម មានដងពណ៌បៃតង និងស្លាប់ដៃជ័រ ពណ៌ខ្មៅ , ផ្លែរណាសម្រាប់អាដែកចំនួន ០១ដើម , កូនកន្ត្រៃដងជ័រ ពណ៌ខៀវ ចំនួន ០១ , កូនកន្ត្រៃដែកចំនួន ០១ , មេសោរម៉ាកស្មុឡេច ពណ៌មាស កាត់ដាច់ ចំនួន ០១ , ទូរសព្ទដៃម៉ាក ខេមហ្វូន ចំនួន ០១គ្រឿង , ទូរសព្ទដៃ ០២គ្រឿង សាំសុង ចំនួន ០១គ្រឿង និងអាយហ្វូនចំនួន ០១គ្រឿង និងឡេបថបចំនួន ០១គ្រឿង។

តាមអំណានរបាយការណ៍សំយោគលេខ ៨១/១៦ រ.ប.ក ចុះថ្ងៃទី ១៤ សីហា ឆ្នាំ ២០១៦ របស់អធិការដ្ឋានខណ្ឌ៧មករា បានបញ្ជាក់ថា: យោងតាមរបាយការណ៍លេខ ០៧/២០១៦ រ.ប.ក ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦ , ពាក្យបណ្តឹង ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦ , កំណត់ហេតុបណ្តឹង ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦ របស់ឈ្មោះ [redacted]វិបុល , កំណត់ហេតុស្តាប់ការបំភ្លឺរបស់កសិណសាក្សី ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦ របស់សាក្សីឈ្មោះ [redacted]ស្រីកា និងឈ្មោះ [redacted] រតនាវង្ស , កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦ របស់ឈ្មោះ [redacted] សុភក្រ្តី , កំណត់ហេតុប្រគល់ និងទទួលជនសង្ស័យ ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦ , កំណត់ហេតុចាប់យកវត្ថុតាង ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦ , កំណត់ហេតុឃាត់ខ្លួនពីបទល្មើសជាក់ស្តែង ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦ , កំណត់ហេតុសរុបនៃការឃាត់ខ្លួនជនសង្ស័យ ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦ , ពាក្យស្នើសុំសម្ភារៈ ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦ , កំណត់ហេតុប្រគល់សម្ភារៈ ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦ , រូបថតប្រគល់សម្ភារៈឲ្យជនរងគ្រោះ និងរូបថតជនសង្ស័យ សន្និដ្ឋានថា ជនសង្ស័យឈ្មោះ [redacted]សុភក្រ្តី ពិតជាបានប្រព្រឹត្តអំពើ លួចមានស្ថានទម្ងន់ទោស (គាស់ទម្លុះទម្លាយ) យកសម្ភារៈរបស់ជនរងគ្រោះ នៅចំណុចផ្ទះលេខ ១៩១E₀ ផ្លូវលេខ ១២៨ ភូមិ ០៨ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦ វេលាម៉ោង ០៣:១០នាទី ទៀបភ្លឺ ប្រាកដមែន។

## សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថាសូមតម្កល់ការចោទប្រកាន់ទុកជាបានការដដែល និងប្តឹងសុំឲ្យតុលាការផ្តន្ទាទោសជនជាប់ចោទទៅតាមច្បាប់។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា សុំឲ្យតុលាការសម្រេចបន្ធូរបន្ថយទោសដល់កូនក្តីខ្លួន។

## សម្តីចុងក្រោយរបស់ជនជាប់ចោទ

ជនជាប់ចោទឈ្មោះ [redacted] សុអក្ត្រ័ បាននិយាយសម្តីចុងក្រោយថា: សុំឲ្យតុលាការបន្ធូរបន្ថយទោសដល់ខ្លួន។

ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

ក្រោយពីបានស្តាប់អំណានចម្លើយរបស់សាក្សី

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទ

ក្រោយពីបានពិនិត្យភស្តុតាងនានា

ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១.កាលពីថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦ វេលាម៉ោងប្រហែល ០៣:១០នាទី ទៀបភ្លឺ នៅចំណុចផ្ទះលេខ ១៨១E₀ ផ្លូវលេខ ១២៨ ភូមិ ០៨ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ មានករណីលួចមានស្ថានទម្ងន់ទោស មួយបានកើតឡើង ដែលបង្កដោយជនជាប់ចោទឈ្មោះ [redacted] សុភក្រ្ត័ បានកាត់សោរទ្វាផ្ទះ លួចយកសម្ភារៈរបស់ជនរងគ្រោះឈ្មោះ [redacted]វិបុល ពេលកំពុងធ្វើសកម្មភាពនោះ ស្រាប់តែប្រពន្ធរបស់ជនរងគ្រោះភ្ញាក់ដឹងខ្លួនទាន់ ក៏ស្រែកចោរឡោ ហើយឈ្មោះ [redacted] សុភក្រ្ត័ រត់ចុះមកក្រោម ក៏ត្រូវប្រជាជនចាប់ខ្លួនប្រគល់ឲ្យសមត្ថកិច្ច ប្រាកដមែន។

២.នាពេលចុះប្រតិបត្តិការឃាត់ខ្លួនជនជាប់ចោទ សមត្ថកិច្ចដកហូតបានកន្រ្តៃសម្រាប់កាត់ដែកចំនួន ០១ដើម មានដងពណ៌បៃតង និងស្នាប់ដៃជ័រ ពណ៌ខ្មៅ , ផ្លែរណាសម្រាប់អាដែកចំនួន ០១ដើម , កូនកន្រ្តៃដងជ័រ ពណ៌ខៀវ ចំនួន ០១ , កូនកន្រ្តៃដែកចំនួន ០១ , មេសោម៉ាកស្វៀឡេចពណ៌មាស កាត់ដាច់ ចំនួន ០១ , ទូរស័ព្ទដៃម៉ាក ខេមហ្វូន ចំនួន ០១គ្រឿង , ទូរស័ព្ទដៃ ០២គ្រឿង សាំស៊ុង ចំនួន ០១គ្រឿង , អាយហ្វូនចំនួន ០១គ្រឿង និងឡេបថបចំនួន ០១គ្រឿង មានដូចក្នុងកំណត់ហេតុចាប់យកវត្ថុតាង ចុះថ្ងៃទី ១៣ សីហា ឆ្នាំ ២០១៦ របស់អធិការដ្ឋានខណ្ឌ៧មករា។

៣.តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] សុភក្រ្ត័ មានភាពស៊ីង្វាក់ទាំងស្រុងជាមួយ:

ក.ពាក្យបណ្តឹង ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦

ខ.កំណត់ហេតុបណ្តឹង ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦

គ.កំណត់ហេតុស្តាប់ការបំភ្លឺរបស់កសិណសាក្សី ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦

ឃ.កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦

ង.កំណត់ហេតុប្រគល់ និងទទួលជនសង្ស័យ ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦

ច.កំណត់ហេតុចាប់យកវត្ថុតាង ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦

ឆ.កំណត់ហេតុឃាត់ខ្លួនពីបទល្មើសជាក់ស្តែង ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦

ជ.កំណត់ហេតុសរុបនៃការឃាត់ខ្លួនជនសង្ស័យ ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦

ឈ.របាយការណ៍លេខ ០៧/២០១៦ រ.ប.ក ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦

៣.របាយការណ៍សំយោគលេខ ៨១/១៦ រ.ប.ក ចុះថ្ងៃទី ១៤ សីហា ឆ្នាំ ២០១៦ របស់មន្ត្រីនគរបាលយុត្តិធម៌ ដែលអាចឲ្យជឿបានថាជនជាប់ចោទឈ្មោះ [redacted] សុភក្ត្រ័ ពិតជាបានប្រព្រឹត្តអំពើ លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចផ្ទះលេខ ១៨១E₀ ផ្លូវលេខ ១២៨ ភូមិ ០៨ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦ ប្រាកដមែន។

៤.ជនជាប់ចោទឈ្មោះ [redacted] សុភក្ត្រ័ ភេទស្រី អាយុ ១៦ឆ្នាំ ជាអនីតិជន ដែលពុំមានភស្តុតាងណាមួយបញ្ជាក់ថា មានបញ្ហាខាងស្មារតីឡើយ ដូច្នេះជនជាប់ចោទពិតជាមានស្មារតីយល់ដឹងពីផលវិបាក ដែលកើតចេញពីអំពើប្រព្រឹត្តរបស់ខ្លួន ដោយដឹងយ៉ាងច្បាស់ថាពុំមានសិទ្ធិណាមួយតាមច្បាប់ក្នុងការប្រព្រឹត្តអំពើទុច្ចរិត ប៉ុន្តែនៅតែប្រព្រឹត្តដោយចេតនាទុច្ចរិត ដែលច្បាប់បានកំណត់ថាជាបទល្មើសព្រហ្មទណ្ឌនិងត្រូវផ្តន្ទាទោស តែដោយជនជាប់ចោទជាអនិតិជន គប្បីពិចារណាទៅលើមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ។

៥.សកម្មភាពប្រព្រឹត្តរបស់ជនជាប់ចោទបានបញ្ជាក់យ៉ាងច្បាស់ពីចេតនាទុច្ចរិតក្នុងការលួចយកទ្រព្យសម្បត្តិអ្នកដទៃ មកធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួនប្រាកដមែន។

៦.អំពើប្រព្រឹត្តរបស់ជនជាប់ចោទ បានធ្វើឲ្យប៉ះពាល់ដល់របៀបរៀបរយសាធារណៈ សន្តិសុខសង្គម និងទ្រព្យសម្បត្តិរបស់បុគ្គលឯកជន ដែលច្បាប់បានហាមឃាត់។

៧.សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ មានមូលដ្ឋានគ្រប់គ្រាន់ ដើម្បីបញ្ជាក់អំពីតម្រុយពិរុទ្ធភាពរបស់ជនជាប់ចោទ ដែលតុលាការគប្បីពិចារណា និងសម្រេច។

៨.សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ សុំឲ្យតុលាការបន្ធូរបន្ថយទោសដល់កូនក្តីនោះ គប្បីតុលាការពិចារណា។

៩.មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] សុភក្ត្រ័ ភេទស្រី អាយុ ១៦ឆ្នាំ ពីបទ **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចផ្ទះលេខ ១៨១E₀ ផ្លូវលេខ ១២៨ ភូមិ ០៨ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦ តាមមាត្រា ៣៥៣ , ៣៥៧ , ១៦០ នៃក្រមព្រហ្មទណ្ឌ។

១០.វត្ថុចាប់យក មានដូចក្នុងកំណត់ហេតុទទួលវត្ថុចាប់យកលេខ ១០៣៧ វ.ត ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១៦ របស់ទៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ គឺទូរសព្ទដៃចំនួន ០១គ្រឿងម៉ាកខេមហ្វូន ពណ៌ទឹកប្រាក់ (ចាស់ , ខូច) , កន្ត្រៃសម្រាប់កាត់ដែកចំនួន ០១ដើម , ថ្លៃណោចំនួន ០១ , កូនន្ត្រៃចំនួន ០២ និងមេសោរស្ទឡិចកាត់ដាច់ចំនួន ០១ គប្បីសម្រេចរឹបអូស តាមមាត្រា ៦២ , ៦៣ នៃក្រមព្រហ្មទណ្ឌ។

១១.ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]បុល បានទទួលទូរសព្ទដៃ ០២គ្រឿង ម៉ាកសាំសុង ចំនួន ០១គ្រឿង និងអាហ្វូនចំនួន ០១គ្រឿង , ឡេបថបចំនួន ០១គ្រឿង វិញហើយ តាមកំណត់ហេតុប្រគល់ ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦ របស់ប៉ុស្តិ៍នគរបាលរដ្ឋបាលមិត្តភាព គប្បីតុលាការពុំលើកមកពិចារណា។

១២.ដើមបណ្តឹងរដ្ឋប្បវេណីបានប្តឹងទាមទារថ្លៃខ្សែកដែលបាត់បង់ចំនួន ១៨០ (មួយរយប៉ែតសិប)ដុល្លាអាមេរិក គប្បីតុលាការសម្រេចតាមការជាក់ស្តែង។

១៣.សំដីចុងក្រោយរបស់ជនជាប់ចោទ បានសុំឲ្យតុលាការបន្ធូរបន្ថយទោស គប្បីតុលាការពិចារណា។

## <u>ហេតុដូច្នេះសម្រេច</u>

១-ផ្តន្ទាទោសឈ្មោះ [redacted] សុគន្ធា ភេទស្រី អាយុ ១៦ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០២ (ពីរ)ឆ្នាំ

ពីបទ **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចផ្ទះលេខ ១៨១E₀ ផ្លូវលេខ ១២៨ ភូមិ០៨ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦ តាមមាត្រា ៣៥៣ , ៣៥៧ , ១៦០ នៃក្រមព្រហ្មទណ្ឌ។

២-បង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted] សុគន្ធា រួមទាំងអាណាព្យាបាលសងសំណងការខូចខាតចំនួន ១៧០ (មួយរយចិតសិប)ដុល្លាអាមេរិក ទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]។

៣-វត្ថុចាប់យក ដែលត្រូវរឹបអូស តាមមាត្រា ៦២ , ៦៣ នៃក្រមព្រហ្មទណ្ឌ គឺទូរសព្ទដៃចំនួន ០១គ្រឿង ម៉ាកខេមហ្វូន ពណ៌ទឹកប្រាក់ (ចាស់ , ខូច) , កន្ត្រៃសម្រាប់កាត់ដែកចំនួន ០១ដើម , ផ្លែរណាចំនួន ០១ , កូនកន្ត្រៃចំនួន ០២ និងមេសោរស្ទូឡិចកាត់ដាច់ចំនួន ០១។

សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ នៅថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១៧ ចំពោះមុខជនជាប់ចោទ , មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ , កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី។

បើកសិទ្ធិប្តឹងទាស់ ឬប្តឹងឧទ្ធរណ៍ តាមកំណត់ច្បាប់។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
| --- | --- | --- | --- |
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |
| [redacted] | [redacted] | [redacted] | [redacted] |

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១៧

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

**ក្រឡាបញ្ជី**

[redacted]

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមព្រហ្មទណ្ឌ**

លេខ ៥៥៣ "សក្រ៦"

ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២២

-សំណុំរឿងព្រហ្មទណ្ឌលេខ ៣៧៨១

ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២១

-សំណុំរឿងស៊ើបសួរលេខ ២៨៤៤

ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១

-សំណុំរឿងជំនុំជម្រះលេខ ៨២៦

ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២

## នាមនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២២ វេលាម៉ោង ០៩ និង០០ នាទីព្រឹក នៅសាលសវនាការទី១ ជាន់ទី១ នៃសាលាដំបូងរាជធានីភ្នំពេញ ដោយមានសមាសភាពជំនុំជម្រះ ដូចខាងក្រោម ៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក **សុខ ប៊ុណ្ណារិទ្ធិ** ប្រធានក្រុមប្រឹក្សាជំនុំជម្រះនៃសាលាដំបូងរាជធានីភ្នំពេញ

លោកស្រី **ឈុន ដាវី**ចៅក្រមប្រឹក្សាជំនុំជម្រះនៃសាលាដំបូងរាជធានីភ្នំពេញ

លោក **ឆាម ច័ន្ទពិសិដ្ឋ** ចៅក្រមប្រឹក្សាជំនុំជម្រះនៃសាលាដំបូងរាជធានីភ្នំពេញ

**តំណាងអយ្យការ**

លោក **គី មុនិន្ទ** ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

លោក **សុខ ចន្ទណ្ណារ៉ា** ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៣៧៨១ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានជនជាប់ចោទ ៖

១-ឈ្មោះ KENT WIJAYA ភេទប្រុស អាយុ៤៤ឆ្នាំ ជនជាតិឥណ្ឌូនេស៊ី កាន់លិខិតឆ្លងដែនលេខ X៧៣៣៦៥៤ មុខរបរ អ្នកជំនួញ ទីកន្លែងកំណើតប្រទេសឥណ្ឌូនេស៊ី ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅអាផាតមិន បឹងទន្លេសាប ស្ថិតនៅផ្ទះលេខ១៣ ផ្លូវ៧០ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឪពុកឈ្មោះ HOK WIJAYA "រស់" ម្តាយឈ្មោះ LIE YINGYING "រស់" ប្រពន្ធឈ្មោះ WENA មានកូន ០២នាក់ ជានីតិជន ។

ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន។ (ក្នុងឃុំ)

បច្ចុប្បន្នកំពុងឃុំខ្លួននៅមណ្ឌលអប់រំកែប្រែទី១ (ម១) តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៦៥៤៧ "ដ១" ដ.ឃ.ដ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

២-ឈ្មោះ RUDI SUPARNO ភេទប្រុស អាយុ៤២ឆ្នាំ ជនជាតិឥណ្ឌូនេស៊ី មុខរបរ គណនេយ្យករ កាន់លិខិតឆ្លងដែនលេខ C១៥២០៧៥៤ ទីកន្លែងកំណើតMEDAN ប្រទេសឥណ្ឌូនេស៊ី ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅផ្ទះលេខ៣៤ ផ្លូវលេខ១៥ ភូមិបឹងឈូក សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោះ YUAN CANG XI "រស់" ម្តាយឈ្មោះ DEN QIAN JU "រស់" ប្រពន្ធឈ្មោះ HARUMI COSASI មានកូន ០២នាក់ ជានីតិជន។

ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន។ (ក្នុងឃុំ)

បច្ចុប្បន្នកំពុងឃុំខ្លួននៅមណ្ឌលអប់រំកែប្រែទី១ (ម១) តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៦៥៤៣ "ដ១" ដ.ឃ.ដ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

២៥. ការអនុវត្តទោសបន្ថែម ផ្អែកតាមបញ្ញត្តិមាត្រា ២៥៥ ចំណុចទី៤ នៃក្រមព្រហ្មទណ្ឌ បានចែងអំពី "ការហាមឃាត់ដល់ទណ្ឌិតបរទេសចំពោះការចូល ឬស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ឆ្នាំយ៉ាងច្រើន"។ តុលាការការយល់ឃើញថា តាមបញ្ញត្តិមាត្រាខាងលើនេះ គឺស្របទៅនឹងលិខិតលេខ ២៣៥៥ ល.ស ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២១ របស់អគ្គស្នងការ នៃស្នងការដ្ឋាននគរបាលជាតិ ដែលសំណើសុំគោលការណ៍បញ្ជូនជនជាតិឥណ្ឌូនេស៊ីចំនួន ០៥ នាក់ មាន ៖ ១-ឈ្មោះ KENT WIJAYA ភេទប្រុស ជនជាតិឥណ្ឌូនេស៊ី ២-ឈ្មោះ RUDI SUPARNO ភេទប្រុស ជនជាតិឥណ្ឌូនេស៊ី ៣-ឈ្មោះ HENDRA CAHYADI ភេទប្រុស ជនជាតិឥណ្ឌូនេស៊ី ៤-ឈ្មោះ RUDY GUNAWAN ភេទប្រុស ជនជាតិឥណ្ឌូនេស៊ី៥-ឈ្មោះ RODIH CANDIAWAN ភេទប្រុស ជនជាតិឥណ្ឌូនេស៊ី ទៅអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ដើម្បីធ្វើការបណ្តេញចេញពីព្រះរាជាណាចក្រកម្ពុជា ក្រោយពីអនុវត្តទោសរួចរាល់។ គប្បីតុលាការពិចារណា និងសម្រេចតាមនីតិវិធីច្បាប់។

២៦. ជនរងគ្រោះទាំងពីរ ពុំបានចូលតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខតុលាការ ដើម្បីទាមទារសំណងរដ្ឋប្បវេណី ឬសំណងជម្ងឺចិត្តពីជនជាប់ចោទទេ ។ ហេតុនេះ តុលាការមិនពិចារណាសម្រេចអំពីសំណងរដ្ឋប្បវេណី ឬសំណងជម្ងឺចិត្តនោះទេ។

២៧. គ្រឿងញៀនដែលមានក្នុងកំណត់ហេតុចុះបញ្ជីវត្ថុតាងចាប់យក(២) លេខ ១៦០៩ ក.ក.ត ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២១ របស់សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ត្រូវបានតុលាការសម្រេចរឹបអូស និងប្រគល់ជូនគណៈកម្មការបំផ្លាញគ្រឿងញៀន នៅសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមនីតិវិធីរួចហើយ តាមរយៈសាលក្រមព្រហ្មទណ្ឌមុនអង្គសេចក្តីលេខ ៣៧ "ណព្រ៦" ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ។ ហេតុនេះតុលាការមិនលើកយកមកសម្រេចម្តងទៀតទេ។

## ហេតុដូច្នេះ សម្រេច

១/-កែប្រែបទចោទប្រកាន់លើជនជាប់ចោទ ៖

១.១-ឈ្មោះ KENT WIJAYA ភេទប្រុស អាយុ៤៤ឆ្នាំ ជនជាតិឥណ្ឌូនេស៊ី

១.២-ឈ្មោះ RUDI SUPARNO ភេទប្រុស អាយុ៤២ឆ្នាំ ជនជាតិឥណ្ឌូនេស៊ី

១.៣-ឈ្មោះ HENDRA CAHYADI ភេទប្រុស អាយុ៣១ឆ្នាំ ជនជាតិឥណ្ឌូនេស៊ី

១.៤-ឈ្មោះ RUDY GUNAWAN ភេទប្រុស អាយុ៣៣ឆ្នាំ ជនជាតិឥណ្ឌូនេស៊ី

១.៥-ឈ្មោះ RODIH CANDIAWAN ភេទប្រុស អាយុ៣៦ឆ្នាំ ជនជាតិឥណ្ឌូនេស៊ី

ដែលមានអត្តសញ្ញាណដូចខាងលើ ពីបទ ៖ បង្ខាំងមនុស្សដោយខុសច្បាប់ធ្វើទារុណកម្ម ដើម្បីជំរិតទារប្រាក់ ប្រព្រឹត្តនៅចំណុច អាផាតមិន បឹងទន្លេសាប ស្ថិតនៅផ្ទះលេខ១៣ ផ្លូវ៧០ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ និងចំណុច SKY TREE APARTMENT ស្ថិតនៅផ្លូវលេខ១០៥ សង្កាត់ទួលសង្កែ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៨ និងថ្ងៃទី៣០ ខែសីហា និងថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៥៤ នៃក្រមព្រហ្មទណ្ឌ មកបទ ចាប់ឃុំឃាំង និងបង្ខាំងដោយខុសច្បាប់ តាមបញ្ញត្តិមាត្រា ២៥៣ នៃក្រមព្រហ្មទណ្ឌ វិញ។

១.៦-កែប្រែបទចោទប្រកាន់លើជនជាប់ចោទឈ្មោះ PENG HUA ភេទប្រុស អាយុ៣៣ឆ្នាំ ជនជាតិឥណ្ឌូនេស៊ី ដែលមានអត្តសញ្ញាណដូចខាងលើ ពីបទ៖ បង្ខាំងមនុស្សដោយខុសច្បាប់ធ្វើទារុណកម្មដើម្បីជំរិតទារប្រាក់ ប្រព្រឹត្តនៅចំណុចសណ្ឋាគារផាលស ស្ថិតនៅបណ្តោយផ្លូវព្រះស៊ីសុវត្ថិ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៨ និងថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៥៤ នៃក្រមព្រហ្មទណ្ឌ មកបទ ចាប់ឃុំឃាំង និងបង្ខាំងដោយខុសច្បាប់ តាមបញ្ញត្តិមាត្រា ២៥៣ នៃក្រមព្រហ្មទណ្ឌ វិញ។

១.៧-កែប្រែបទចោទប្រកាន់លើជនជាប់ចោទឈ្មោះ គង់ រស្មី ភេទប្រុស អាយុ ២៧ឆ្នាំ ជនជាតិខ្មែរ ដែលមានអត្តសញ្ញាណដូចខាងលើ ពីបទ ៖ សមគំនិតក្នុងអំពើបង្ខាំងមនុស្សដោយខុសច្បាប់ធ្វើទារុណកម្មដើម្បីជំរិតទារប្រាក់ ប្រព្រឹត្តនៅចំណុច SKY TREE APARTMENT ស្ថិតនៅផ្លូវលេខ១០៥ សង្កាត់ទួលសង្កែ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៨ និងថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៩ និងមាត្រា ២៥៤ នៃក្រមព្រហ្មទណ្ឌ មកបទ សមគំនិតក្នុងអំពើចាប់ឃុំឃាំង និងបង្ខាំងដោយខុសច្បាប់ តាមបញ្ញត្តិមាត្រា ២៩ និងមាត្រា ២៥៣ នៃក្រមព្រហ្មទណ្ឌ វិញ។

**២./-ឲ្យជនជាប់ចោទ ៖**

២.១-ឈ្មោះ KENT WIJAYA ភេទប្រុស អាយុ៤៤ឆ្នាំ ជនជាតិឥណ្ឌូនេស៊ី

២.២-ឈ្មោះ RUDI SUPARNO ភេទប្រុស អាយុ៤២ឆ្នាំ ជនជាតិឥណ្ឌូនេស៊ី

រួចខ្លួនពីបទចោទប្រកាន់ ពីបទ ៖ រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុច អាផាតមិនបឹងទន្លេសាប ស្ថិតនៅផ្ទះលេខ១៣ ផ្លូវលេខ៧០ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៨ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**៣./-ផ្តន្ទាទោសជនជាប់ចោទ ៖**

៣.១-ឈ្មោះ KENT WIJAYA ភេទប្រុស អាយុ៤៤ឆ្នាំ ជនជាតិឥណ្ឌូនេស៊ី មានអត្តសញ្ញាណដូចខាងលើ

៣.២-ឈ្មោះ RUDI SUPARNO ភេទប្រុស អាយុ៤២ឆ្នាំ ជនជាតិឥណ្ឌូនេស៊ី មានអត្តសញ្ញាណដូចខាងលើ

ដាក់ពន្ធនាគារក្នុងម្នាក់ៗ កំណត់ ០១ ឆ្នាំ ០២ ខែ (**មួយឆ្នាំ ពីរខែ**)

ពីបទ ៖ ចាប់ឃុំឃាំង និងបង្ខាំងដោយខុសច្បាប់ ប្រព្រឹត្តនៅចំណុច អាផាតមិន បឹងទន្លេសាប ស្ថិតនៅផ្ទះលេខ ១៣ ផ្លូវ៧០ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ និងចំណុច SKY TREE APARTMENT ស្ថិតនៅផ្លូវលេខ១០៥ សង្កាត់ទួលសង្កែ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៨ និងថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៥៣ នៃក្រមព្រហ្មទណ្ឌ។

៣.៣-ឈ្មោះ PENG HUA ភេទប្រុស អាយុ៣៣ឆ្នាំ ជនជាតិចិន មានអត្តសញ្ញាណដូចខាងលើ

ដាក់ពន្ធនាគារ កំណត់ ២ ឆ្នាំ (**ពីរឆ្នាំ**)

ពីបទ ៖ ចាប់ឃុំឃាំង និងបង្ខាំងដោយខុសច្បាប់ ប្រព្រឹត្តនៅចំណុច សណ្ឋាគារតាជាលេស ស្ថិតនៅបណ្តោយផ្លូវព្រះស៊ីសុវត្ថិ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៨ និងថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៥៣ នៃក្រមព្រហ្មទណ្ឌ។

៣.៤-ឈ្មោះ HENDRA CAHYADI ភេទប្រុស អាយុ៣១ឆ្នាំ ជនជាតិឥណ្ឌូនេស៊ី មានអត្តសញ្ញាណដូចខាងលើ

៣.៥-ឈ្មោះ RUDY GUNAWAN ភេទប្រុស អាយុ៣៣ឆ្នាំ ជនជាតិឥណ្ឌូនេស៊ី មានអត្តសញ្ញាណដូចខាងលើ

៣.៦-ឈ្មោះ RODIH CANDIAWAN ភេទប្រុស អាយុ៣៦ឆ្នាំ ជនជាតិឥណ្ឌូនេស៊ី មានអត្តសញ្ញាណដូចខាងលើ

ដាក់ពន្ធនាគារក្នុងម្នាក់ៗ កំណត់ ២ឆ្នាំ ០៦ខែ (**ពីរឆ្នាំ ប្រាំមួយខែ**)

ពីបទ ៖ ចាប់ឃុំឃាំង និងបង្ខាំងដោយខុសច្បាប់ និងបទ រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុច អាផាតមិន បឹងទន្លេសាប ស្ថិតនៅផ្ទះលេខ១៣ ផ្លូវ៧០ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ និងចំណុច SKY TREE APARTMENT ស្ថិតនៅផ្លូវលេខ១០៥ សង្កាត់ទួលសង្កែ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៨ និងថ្ងៃទី៣០ ខែសីហា និងថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៥៣ នៃក្រមព្រហ្មទណ្ឌ និងតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៨ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៣.៧-ឈ្មោះ គង់ រស្មី ភេទប្រុស អាយុ ២៧ឆ្នាំ ជនជាតិខ្មែរ មានអត្តសញ្ញាណដូចខាងលើ

ដាក់ពន្ធនាគារ កំណត់ ០១ ឆ្នាំ (មួយឆ្នាំ) តែទោសនេះអនុវត្តក្នុងពន្ធនាគាររយៈពេល ២ ខែ ១៤ ថ្ងៃ (ពីរខែដប់បួនថ្ងៃ) ទោសសល់ពីនេះត្រូវព្យួរធម្មតា

ពីបទ ៖ សមគំនិតក្នុងអំពើចាប់ឃុំឃាំង និងបង្ខាំងដោយខុសច្បាប់ ប្រព្រឹត្តនៅចំណុច SKY TREE APARTMENT ស្ថិតនៅផ្លូវលេខ១០៥ សង្កាត់ទួលសង្កែ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៨ និងថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៩ និងមាត្រា ២៥៣ នៃក្រមព្រហ្មទណ្ឌ។

៣.៨-ឈ្មោះ ZHENG YINGFEI ភេទប្រុស អាយុ៣៧ឆ្នាំ ជនជាតិចិន កាន់លិខិតឆ្លងដែនលេខ E៣២៥១៤៣១៨។ (គេចខ្លួន)

ដាក់ពន្ធនាគារកំណត់ ២៧ឆ្នាំ(ម្ភៃប្រាំពីរឆ្នាំ) និងទោសពិន័យជាប្រាក់ចំនួន ៨០,០០០,០០០៛ (ប៉ែតសិបលានរៀល)

ពីបទ ៖ រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុច អាផាតមិន បឹងទំព្នេសាប ស្ថិតនៅផ្ទះលេខ ១៣ ផ្លូវលេខ៧០ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៨ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៤./ រឹបអូសវត្ថុចាប់យក ដែលជាមធ្យោបាយសម្រាប់ការប្រព្រឹត្តបទល្មើស តាមបញ្ញត្តិមាត្រា ៦២ និងបញ្ញត្តិមាត្រា ៦៣ នៃក្រមព្រហ្មទណ្ឌ នូវ ៖

៤.១-ទូរស័ព្ទម៉ាក IPHONE ពណ៌ស (បែកអេក្រង់) ចំនួន ០១ គ្រឿង (មិនដំណើរការ)។

៤.២-ទូរស័ព្ទម៉ាក VIVO ពណ៌ខៀវ ចំនួន ០១ គ្រឿង (មិនដំណើរការ)

៤.៣-ទូរស័ព្ទម៉ាក IPHONE ពណ៌ទឹកមាស ចំនួន ០១ គ្រឿង (មិនដំណើរការ)

៤.៤-ទូរស័ព្ទម៉ាក IPHONE ពណ៌ខ្មៅ ចំនួន ០១ គ្រឿង (មិនដំណើរការ)។

៤.៥-ទូរស័ព្ទដៃម៉ាក HUAWEI ពណ៌ទឹកប្រាក់ ចំនួន ០១ គ្រឿង (មិនដំណើរការ)

៤.៦-ទូរស័ព្ទម៉ាក OPPO ពណ៌ខ្មៅ ចំនួន ០១ គ្រឿង (មិនដំណើរការ)

៤.៧-ទូរស័ព្ទម៉ាក IPHONE ពណ៌ខ្មៅ ចំនួន ០១ គ្រឿង (មិនដំណើរការ)

៤.៨-ទូរស័ព្ទម៉ាក REDMI ពណ៌ស ចំនួន ០១ គ្រឿង (មិនដំណើរការ)

៤.៩-ឧបករណ៍ប្រើប្រាស់សារធាតុញៀនមួយ ចំនួន

៤.១០-ជញ្ជីងថ្លឹងម៉ាក PERFECT ចំនួន ០១ គ្រឿង

៤.១១-ស្លាប់ព្រៃ ចំនួន ០១

៤.១២-ឧបករណ៍ប្រើប្រាស់សារធាតុញៀន មួយចំនួន

៤.១៣-ឡោះចង្រ្កាក់ ចំនួន ០១

៤.១៤-ម៉ាស៊ីន ម៉ូនីទ័រ ចំនួន ០១។

៤.១៥-ទូរស័ព្ទម៉ាក IPHONE 12 PRO MAX ពណ៌ប្រផេះ ចំនួន ០១ គ្រឿង

៤.១៦-ទូរស័ព្ទម៉ាក IPHONE 12 PRO MAX ពណ៌ខៀវ ចំនួន ០១ គ្រឿង

៤.១៧-កុំព្យូទ័រលើតុ ចំនួន ០២ គ្រឿង

៤.១៨-កុំព្យូទ័រយួរដៃ ចំនួន ០១ គ្រឿង

៥./ ប្រគល់វត្ថុចាប់យកឲ្យទៅម្ចាស់ដើមវិញ តាមបញ្ញត្តិមាត្រា ៣៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នូវ ៖

**-វត្ថុតាងដែលដកហូត ពីឈ្មោះ គង់ ស្មើ មាន ៖**

៥.១-ទូរស័ព្ទម៉ាក REALME ពណ៌ខៀវ ចំនួន ០១ គ្រឿង (មិនដំណើរការ)។

**-វត្ថុតាងដែលដកហូត ពីឈ្មោះ RODIH CANDIAWAN រួមមាន ៖**

៥.២-លិខិតឆ្លងដែនឥណ្ឌូនេស៊ី លេខ A4810187 ចំនួន ០១

៥.៣-បណ្ណចាក់វ៉ាក់សាំងកូវីដ ១៩ ចំនួន ០១
៥.៤-កាបូបដៃពណ៌ខ្មៅ ចំនួន ០១
៥.៥-អត្តសញ្ញាណបណ្ណឥណ្ឌូនេស៊ី ចំនួន ០១
៥.៦-បណ្ណបើកបរឥណ្ឌូនេស៊ី ចំនួន ០២
៥.៧-កាតផ្សេងៗ ចំនួន ០២
៥.៨-ប្រាក់ឥណ្ឌូនេស៊ីចំនួន ១០០០ (មួយពាន់)
៥.៩-ប្រាក់ដុល្លារអាមេរិច ១ (មួយ) ដុល្លារ។
-ចក្ខុតាងដែលដកហូតពីឈ្មោះ HENDRA CAHYADI រួមមាន ៖
៥.១០-សៀវភៅការងារជនបរទេស ចំនួន ០១
៥.១១-អត្តសញ្ញាណបណ្ណឥណ្ឌូនេស៊ី ចំនួន ០១
៥.១២-បណ្ណចាក់វ៉ាក់សាំងកូវីដ ១៩ ចំនួន ០១
៥.១៣-លិខិតឆ្លងដែនឥណ្ឌូនេស៊ី លេខ C0578170 ចំនួន ០១
៥.១៤-កាត VISA ABA ចំនួន ០១
-ចក្ខុតាងដែលដកហូតពីឈ្មោះ RUDY GUNAWAN រួមមាន ៖
៥.១៥-បណ្ណចាក់វ៉ាក់សាំងកូវីដ ១៩ ចំនួន ០១
៥.១៦-សៀវភៅការងារជនបរទេស ចំនួន ០១
៥.១៧-លិខិតឆ្លងដែនឥណ្ឌូនេស៊ី ចំនួន ០២
-ចក្ខុតាងដែលដកហូតពីឈ្មោះ KENT WIJAYA រួមមាន ៖
៥.១៨-កាតរបស់ក្រុមហ៊ុន វីអូអេចឡូជីស្ទីក & ត្រេនស្ព័តឯ.ក ចំនួន ០១
៥.១៩-កាតធនាគារ ចំនួន ១២
៥.២០-ប័ណ្ណចាក់វ៉ាក់សាំងកូវីដ ១៩ ចំនួន ០១
៥.២១-អត្តសញ្ញាណបណ្ណឥណ្ឌូនេស៊ី ចំនួន ០១
៥.២២-បណ្ណបើកបរខ្មែរ ចំនួន ០១
៥.២៣-សៀវភៅការងារជនបរទេស ចំនួន ០១
៥.២៤-បណ្ណសម្គាល់យានយន្ត ផ្លាកលេខ ភ្នំពេញ 2AG -9985 (ថតចម្លង)
៥.២៥-បណ្ណសម្គាល់យានយន្ត ផ្លាកលេខ ភ្នំពេញ 2BI -5538 (ថតចម្លង)
៥.២៦-កាបូបដៃបុរសម៉ាក TOUGH ពណ៌ខ្មៅ ចំនួន ០១
៥.២៧-កាបូបដៃម៉ាក LV ពណ៌ខ្មៅ ចំនួន ០១
៥.២៨-សៀវភៅធនាគារ ចំនួន ០៣ ក្បាល
៥.២៩-លិខិតបញ្ជាក់ទីលំនៅរបស់ឈ្មោះ KENT WIJAYA ចំនួន ០១ សន្លឹក
-ចក្ខុតាងដែលដកហូតពីឈ្មោះ RUDI SUPARNO រួមមាន ៖
៥.៣០-កាតធនាគារ ABA ចំនួន ០១
៥.៣១-កាតធនាគារ MAY BANK ចំនួន ០១
៥.៣២-កាតធនាគារ CIMB NIAGA ចំនួន ០១
៥.៣៣-សៀវភៅការងារជនបរទេស ចំនួន ០២
៥.៣៤-អត្តសញ្ញាណបណ្ណឥណ្ឌូនេស៊ី ចំនួន ០១
៥.៣៥-កាតផ្សេងៗ ចំនួន ០២

៥.៣៦-លិខិតឆ្លងដែនឥណ្ឌូនេស៊ី លេខ C1520754 ចំនួន ០១

**-វត្ថុតាងដែលឆែកឆេរបាននៅ** SKY TREE APARTMENT **រួមមាន ៖**

៥.៣៧-កិច្ចសន្យាជួលខុនដូរខ្មៅសាប ០១ ច្បាប់

៥.៣៨-ឯកសារ មួយចំនួន។

៦-/ ចេញដីកាបង្គាប់ឲ្យចាប់ខ្លួនជនជាប់ចោទឈ្មោះ ZHENG YINGFEI ភេទប្រុស ជនជាតិចិន និងជនជាប់ចោទឈ្មោះ PENG HUA ភេទប្រុស ជនជាតិចិន ដើម្បីយកមកអនុវត្តទោសតាមអំណាចសាលក្រមនេះ និងធ្វើការឃុំខ្លួនតាមបញ្ញត្តិមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**៧-/ អនុវត្តទោសបន្ថែមលើជនជាប់ចោទ ៖**

៧.១-ឈ្មោះ KENT WIJAYA ភេទប្រុស អាយុ៤៤ឆ្នាំ ជនជាតិឥណ្ឌូនេស៊ី

៧.២-ឈ្មោះ RUDI SUPARNO ភេទប្រុស អាយុ៤២ឆ្នាំ ជនជាតិឥណ្ឌូនេស៊ី

៧.៣-ឈ្មោះ HENDRA CAHYADI ភេទប្រុស អាយុ៣១ឆ្នាំ ជនជាតិឥណ្ឌូនេស៊ី

៧.៤-ឈ្មោះ RUDY GUNAWAN ភេទប្រុស អាយុ៣៣ឆ្នាំ ជនជាតិឥណ្ឌូនេស៊ី

៧.៥-ឈ្មោះ RODIH CANDIAWAN ភេទប្រុស អាយុ៣៦ឆ្នាំ ជនជាតិឥណ្ឌូនេស៊ី

ការហាមឃាត់ដល់ទណ្ឌិតបរទេសចំពោះការចូល និងស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា សម្រាប់រយៈពេល **៥ឆ្នាំ (ប្រាំឆ្នាំ)** ក្រោយអនុវត្តទោសចប់ តាមបញ្ញត្តិមាត្រា ២៥៧ ចំណុចទី៤ នៃក្រមព្រហ្មទណ្ឌ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២២ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២២

-ចំពោះមុខជនជាប់ចោទ ៖ ១.ឈ្មោះ KENT WIJAYA, ២.ឈ្មោះ RUDI SUPARNO, ៣.ឈ្មោះ HENDRA CAHYADI, ៤.ឈ្មោះ RUDY GUNAWAN, ៥.ឈ្មោះ RODIH CANDIAWAN និងចំពោះមុខមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ៖ ១.មេធាវី ចូវ ឥវ៉ន, ២.មេធាវី សុខណាតដារ៉ា បញ្ញា, ៣.មេធាវី ហង្ស ដារ៉ាធី, ៤.មេធាវី ថេង ចំរើន, ៥.មេធាវី លឹម អេងរតនៈ។

-កំបាំងមុខជនជាប់ចោទឈ្មោះ គង់ ស្មើ, ជនជាប់ចោទឈ្មោះ ZHENG YINGFEI និងជនជាប់ចោទឈ្មោះ PENG HUA។

-កំបាំងមុខជនរងគ្រោះឈ្មោះ ជីមី្ម (Mr.JIMMY), ជនរងគ្រោះឈ្មោះ ថូមី្ម ធី ជែមេឡាង (TOMMY T JEMERLANG)។

ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |
| **សុខ ចណ្ណារ៉ា** | **ឈុន ដាវី** | **ឆាម ច័ន្ទពិសិដ្ឋ** | **សុខ ប៊ុណ្ណារិទ្ធិ** |

---

**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃសុក្រ [illegible] ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២២

ក្រឡាបញ្ជី

**សុខ ចណ្ណារ៉ា**

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

**សុខ ប៊ុណ្ណារិទ្ធិ**

**ឧបសម្ព័ន្ធទី ៩**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តព្រះសីហនុ

សាលក្រមព្រហ្មទណ្ឌលេខ: ៨២ "ជ"
ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១៧
[redacted] សំណុំរឿងព្រហ្មទណ្ឌលេខ ១៥៣
ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៧

## តាង នាម ប្រ ជា រា ស្ត្រ ខ្មែ រ
## សាលាដំបូងខេត្តព្រះសីហនុ

បានបើកសវនាការជាសាធារណៈ នៅសាលសវនាការសាលាដំបូងខេត្តព្រះសីហនុ នៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១៧ វេលាម៉ោង ៩ និង ០០ នាទីព្រឹក និងប្រកាសសាលក្រមនៅថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១៧ វេលាម៉ោង ៩:០០ នាទី ព្រឹក ដែលមានសមាសភាពដូចតទៅ:

**ចៅក្រមជំនុំជម្រះ**

-លោក [redacted] ជាចៅក្រមសាលាដំបូងខេត្តព្រះសីហនុ

**តំណាងអយ្យការ**

-លោក [redacted] ជាព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តព្រះសីហនុ

**ក្រឡាបញ្ជីសវនាការ**

-ព្រមាក [redacted] ជាក្រឡាបញ្ជីសាលាដំបូងខេត្តព្រះសីហនុ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ: ១៥៣ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៧ ដែលមានជនជាប់ចោទ:

១-ឈ្មោះ [redacted] ឈាង ហៅ វ៉ាង ភេទប្រុស អាយុ ២៦ ឆ្នាំ ជនជាតិខ្មែរ មុខរបរ កម្មកររោងចក្រ កើតនៅសង្កាត់លេខ៤ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ មានទីលំនៅមុនពេលឃាត់ខ្លួន នៅភូមិ [redacted] ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ប្រពន្ធឈ្មោះ [redacted] មានកូន ០១ នាក់ ឪពុកឈ្មោះ [redacted] (ស) ឈ្មោះ ម្តាយឈ្មោះ [redacted]) ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន។

ឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ: ៥៧៥ ត.ព.ជ/១៧ ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ...

២-ឈ្មោះ [redacted] សុភ័ក្រ្ត ហៅ តូ ភេទប្រុស កើតឆ្នាំ ១៩៩៩ ជនជាតិខ្មែរ មុខរបរ ...
កើតនៅភូមិ៤ សង្កាត់លេខ៤ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ មានទីលំនៅមុនពេលឃាត់ខ្លួន នៅភូមិ

[redacted] ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ប្រពន្ធឈ្មោះ [redacted] មានកូន ០១ នាក់ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ "គ្មាន"។

ឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ: ៥៧៧ ត.ព.ជ/១៧ ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៧។

ជាប់ចោទពីបទ: អំពើលួច ប្រព្រឹត្តនៅក្រុម១ ភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

៣-ឈ្មោះ [redacted] ចំរើន ហៅ ដូច ភេទប្រុស អាយុ ២៥ ឆ្នាំ មុខរបរ ជាងម៉ូតូ ជនជាតិខ្មែរ កើតនៅភូមិអណ្តូងថ្ម ឃុំអណ្តូងថ្ម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ មានទីលំនៅមុនពេលឃាត់ខ្លួន នៅភូមិ [redacted] ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ប្រពន្ធឈ្មោះ ម៉ាត់ កល្យាណ មានកូន ០១ នាក់ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ "គ្មាន"។

ដោយមានលោក [redacted] វិទ្យា ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ចំរើន។

ឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ: ៥៧៩ ត.ព.ជ/១៧ ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៧។

៤-ឈ្មោះ [redacted] ខា ភេទប្រុស កើតឆ្នាំ ១៩៨៦ ជនជាតិខ្មែរ កើតនៅភូមិវាលមាស ឃុំវាលរេញ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ មានទីលំនៅបច្ចុប្បន្ន [redacted] ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ "គ្មាន"។ (គេចខ្លួន)

ឃុំខ្លួនតាមដីកាបង្គាប់ឲ្យចាប់ខ្លួនលេខ:៥៣ ត.ព/១៧ ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ ២០១៧។

ជាប់ចោទពីបទ: ទទួលផលចោរកម្ម ប្រព្រឹត្តនៅក្រុម១ ភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ។

តាមដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ: ១២៥៧ ត.ព/១៧ ចុះថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៧ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តព្រះសីហនុ។

**អង្គហេតុកើតមានឡើងដូចតទៅ:**

កាលពីថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៦ ម៉ោង ០៥:០០ នាទីទៀបភ្លឺ ស្ថិតនៅក្រុម០១ ភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ មានករណីអំពើលួចមួយបានកើតឡើង បង្កដោយឈ្មោះ [redacted] ឈាង ហៅ វ៉ាង និងឈ្មោះ [redacted] សុភ័ក្រ្ត ហៅ តូ បានធ្វើសកម្មភាពលួចម៉ូតូរបស់ជនរងគ្រោះ ឈ្មោះ [redacted] UNLU ភេទប្រុស ជនជាតិទួគី បានម៉ូតូម៉ាក អ៊ែប្លូត ពណ៌ខ្មៅចំនួន ០១ គ្រឿង។ ក្រោយពេលធ្វើសកម្មភាពលួចម៉ូតូរួចហើយ ជនជាប់ចោទទាំងពីរ ក៏បាននាំគ្នាយក ម៉ូតូទៅលក់ឱ្យឈ្មោះ [redacted] ភេទប្រុស និងឈ្មោះ [redacted] ចំរើន។

**នាពេលសវនាការ**

-ជនជាប់ចោទឈ្មោះ [redacted] ឈាង បានឆ្លើយថា៖ ខ្លួនធ្លាប់យកម៉ូតូទៅលក់ឱ្យឈ្មោះ [redacted]

បានម្តង កាលពីថ្ងៃខែមិនចាំ ហើយម៉ូតូនោះខ្លួនបានលួចគេមកដោយមិនចាំថ្ងៃខែលួចនោះទេ។ ខ្លួនធ្លាប់ទៅលួចម៉ូតូគេជាមួយឈ្មោះ ភ័ក្រ្ត បានចំនួន ០២ ទៅ ០៣ ដងមកហើយ។ ខ្លួនធ្លាប់យកម៉ូតូដែលលួចពីគេទៅលក់ឱ្យឈ្មោះ ខា បានចំនួន ០៥ ទៅ ០៦ ដងមកហើយ និងលក់ឱ្យឈ្មោះ [redacted] ចំរើន ០២ ទៅ ០៣ ដងមកហើយដែរ។ នៅពេលដែលខ្លួនលក់បានលុយហើយ ខ្លួនយកលុយទាំងអស់នោះទៅលេងល្បែង ជល់មាន់ លេងអាប៉ោងជាដើម។ នាពេលកន្លងមក គឺខ្លួនតែងតែលួចអាវេឆ្លាម និងអាសង់ដោយលួចសរុបបានចំនួន ១៥ ដងមកហើយ។

-ជនជាប់ចោទឈ្មោះ [redacted] សុភ័ក្រ្ត បានឆ្លើយថា៖ ខ្លួនក៏ធ្លាប់យកម៉ូតូដែលបានលួចពីគេទៅលក់ឱ្យឈ្មោះ ចំរើន បានម្តងដែរ ។ ខ្លួន និងឈ្មោះ [redacted] ចំរើន ធ្លាប់និយាយគ្នាថា បើខ្លួនលួចបានហើយ នោះខ្លួននឹងយកទៅលក់ឱ្យឈ្មោះ ចំរើន នេះ។ ខ្លួនពិតជាបានលួចម៉ូតូគេពិតមែន ដោយទៅជាមួយឈ្មោះ [redacted] ឈាង បានចំនួន ០២ ដង ហើយខ្លួនក៏យកម៉ូតូដែលលួចបាននេះទៅលក់ឱ្យឈ្មោះ [redacted] ចំរើន។ ឈ្មោះ [redacted] ចំរើន ពិតបានដឹងថាម៉ូតូដែលខ្លួន និងឈ្មោះ [redacted] ឈាង លក់ឱ្យនោះជាម៉ូតូដែលបានមកពីលួចគេពិតមែន ហើយប្រាក់ដែលខ្លួនបានមកពីការលក់ម៉ូតូនេះ គឺខ្លួនយកទៅទិញគ្រឿងញៀនជក់។

-ជនជាប់ចោទឈ្មោះ [redacted] ចំរើន បានឆ្លើយថា៖ ខ្លួនធ្លាប់ទិញម៉ូតូពីឈ្មោះ [redacted] ឈាង បានចំនួន ០២ ដង តែឈ្មោះ [redacted] ឈាង មិនបានប្រាប់ខ្លួនថាម៉ូតូនេះបានមកពីណានោះទេ ហើយខ្លួនក៏មិនដឹងថាម៉ូតូដែលឈ្មោះ [redacted] ឈាង យកមកលក់ឱ្យខ្លួននេះជាម៉ូតូលួចគេដែរ។ នៅរាល់ការទិញលក់ម៉ូតូជាមួយឈ្មោះ [redacted] ឈាង នេះ គឺពុំមានធ្វើលិខិតស្នាមអ្វីឡើយ ពោលគឺទិញដោយនិយាយគ្នាផ្ទាល់មាត់តែប៉ុណ្ណោះ ព្រោះខ្លួនមិនចេះធ្វើលិខិតស្នាមទិញលក់នោះទេ។

-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ៖ ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទឈ្មោះ [redacted] ឈាង ហៅ វ៉ាង និងឈ្មោះ [redacted] សុភ័ក្រ្ត បានឆ្លើយសារភាពថា ពួកខ្លួនពិតជាបានប្រព្រឹត្តសកម្មភាពលួចម៉ូតូរបស់គេពិតមែន។ ដោយឡែកជនជាប់ចោទឈ្មោះ [redacted] ចំរើន បានឆ្លើយបដិសេធថាខ្លួនមិនបានដឹងថាម៉ូតូដែលខ្លួនទិញនោះ គឺជាម៉ូតូដែលបានមកអំពើលួចនោះឡើយ។ ចម្លើយនេះមិនអាចឱ្យតុលាការជឿជាក់បាននោះទេ ព្រោះថាយោងតាមចម្លើយរបស់ឈ្មោះ [redacted] សុភ័ក្រ្ត បានឆ្លើយថា ឈ្មោះ [redacted] ចំរើន ពិតជាដឹងថាម៉ូតូនោះជាម៉ូតូដែលពួកខ្លួនលួចពីគេយកទៅលក់ឱ្យខ្លួន។ មួយវិញទៀតជនជាប់ចោទឈ្មោះ [redacted] ខា ក៏ត្រូវបានឈ្មោះ [redacted] ឈាង ហៅ វ៉ាង ធ្លាប់យកម៉ូតូទៅលក់ឱ្យដែរ ហើយបច្ចុប្បន្នជនជាប់ចោទឈ្មោះ [redacted] ខា បានរត់គេចខ្លួនបាត់ទៅហើយ។ ដូច្នេះតំណាងអយ្យការនៅតែប្តឹងសុំលោកចៅក្រមជំនុំជម្រះផ្តន្ទាទោសលើជនជាប់ចោទទាំងអស់។

-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ចំរើន ឈ្មោះ [redacted] ចំរើន គឺជាជាងម៉ូតូ ដែលមានលទ្ធភាពតិចតួចបំផុតក្នុងរកស៊ីចិញ្ចឹមគ្រួសារ...

ឯការទិញម៉ូតូនេះ  ក៏មានតម្លៃតិចតួចផងដែរ  ជាពិសេសកូនក្តីខ្លួនក៏មិនដឹងថាម៉ូតូនេះជាម៉ូតូដែលបានមកពីអំពើលួចនោះដែរ។  ហេតុដូច្នេះស្នើសុំលោកចៅក្រមជំនុំជម្រះឱ្យកូនក្តីខ្លួនរួចផុតពីបទចោទប្រកាន់។

-សំដីចុងក្រោយរបស់ជនជាប់ចោទទាំងពីររូបៈ ពួកខ្លួនស្នើសុំតុលាការមេត្តាបន្ធូរបន្ថយទោសដល់រូបខ្លួនផងចុះ។

**ក្រោយពីបាន:**

-ស្តាប់ចម្លើយជនជាប់ចោទ

-ស្តាប់អំណានផ្សេងៗ

-ពិនិត្យភស្តុតាងនានាក្នុងសំណុំរឿង

-ស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ សុខ ចំរើន

-ស្តាប់សំណូមពរចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាដំបូងខេត្តព្រះសីហនុ

## យល់ឃើញថា

-ជនជាប់ចោទឈ្មោះ [redacted] ឈាង និងឈ្មោះ [redacted] សុភ័ក្រ្ត បានឆ្លើយសារភាពដោយមានភាពស៊ីសង្វាក់គ្នាថា  ពួកខ្លួនពិតជាបានចូលរួមគ្នាប្រព្រឹត្ត  អំពើលួចម៉ូតូរបស់គេពិតមែន  ហើយក៏បានយកទៅលក់ឱ្យឈ្មោះ ខា និងឈ្មោះ [redacted] ចំរើន។ ដោយលក់ឱ្យឈ្មោះ ខា បានចំនួន ០៥ ទៅ ០៦ ដងមកហើយ និងលក់ឱ្យឈ្មោះ [redacted] ចំរើន បានតែ ០៣ ដងប៉ុណ្ណោះ។ ដោយឡែកជនជាប់ចោទឈ្មោះ [redacted] ចំរើន បានឆ្លើយបដិសេធថា ខ្លួនមិនដឹងថាម៉ូតូដែលខ្លួនទិញនេះជាម៉ូតូរបស់ចោរនោះឡើយ។  ចម្លើយនេះទោះបីជាជនជាប់ចោទបានឆ្លើយបដិសេធយ៉ាងណាក៏ដោយ  តែយោងតាមចម្លើយរបស់ឈ្មោះ [redacted] សុភ័ក្រ្ត បានឆ្លើយថា ខ្លួន និងឈ្មោះ [redacted] ចំរើន បាននិយាយគ្នាមុនថា បើខ្លួនលួចម៉ូតូបាន នោះនឹងយកទៅលក់ឱ្យឈ្មោះ [redacted] ចំរើន។ ជនជាប់ចោទឈ្មោះ [redacted] សុភ័ក្រ្ត បានឆ្លើយទៀតថា ឈ្មោះ [redacted] ចំរើន  ពិតជាបានដឹងថាម៉ូតូដែលគាត់ទិញនោះជាម៉ូតូដែលបានមកពីលួចគេយ៉ាងពិតប្រាកដ។

-មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់ដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] ឈាង ហៅ ក៉ង ភេទប្រុស (មានសាវតាជាតិដូចខាងលើ) និងឈ្មោះ [redacted] សុភ័ក្រ្ត ភេទប្រុស (មានសាវតាជាតិដូចខាងលើ) ពីបទ អំពើលួច ប្រព្រឹត្តនៅក្រុម១ ភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៧  បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

-មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់ដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] ចំរើន ភេទប្រុស (មានសាវតាជាតិដូចខាងលើ) និងឈ្មោះ [redacted] ខា ភេទប្រុស (មានសាវតាជាតិដូចខាងលើ) ពីបទ ទទួលផលចោរកម្ម ប្រព្រឹត្តនៅក្រុម១ ភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ។

-ជនជាប់ចោទឈ្មោះ [redacted] ឈាង ហៅ វ៉ាង ឈ្មោះ [redacted] សុភ័ក្រ្ត ឈ្មោះ [redacted] ខា និងឈ្មោះ [redacted] ចំរើន ជានីតិជនស្ថិតនៅក្នុងនីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ហើយបានប្រព្រឹត្តអំពើល្មើសដោយមានចេតនាយល់ដឹងគ្រប់គ្រាន់ចំពោះអំពើ និងព្យសនកម្មដែលកើតឡើងដោយសារការប្រព្រឹត្តអំពើរបស់ខ្លួន។ ប៉ុន្តែជនជាប់ចោទឈ្មោះ [redacted] ខា បានរត់គេចខ្លួន ដែលជាការគេចវេសពីការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួនដែលបានប្រព្រឹត្ត។

-ចំពោះវត្ថុដែលចាប់យក គឺមានកំណត់ហេតុចាប់យកដកហូតនៅដំណាក់កាលសមត្ថកិច្ច ប៉ុន្តែមកដល់តំណាងអយ្យការ និងចៅក្រមស៊ើបសួរ ពុំមានកំណត់ហេតុស្តីពីការទទួលវត្ថុតាងឡើយ។ ហេតុដូច្នេះតុលាការមិនពិចារណាសម្រេចឡើយ។

-សេចក្តីសន្និដ្ឋាន
របស់តំណាងអយ្យការខាងលើមានលក្ខណៈសមស្របដូចមានក្នុងសំអាងហេតុខាងលើ។

-សេចក្តីសន្និដ្ឋាន របស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ មិនមានលក្ខណៈសមស្របដូចក្នុងសំអាងហេតុ និងសំអាងច្បាប់ខាងលើ តុលាការមិនលើកយកមកពិចារណា។

-ជនជាប់ចោទឈ្មោះ [redacted] ឈាង ឈ្មោះ [redacted] សុភ័ក្រ្ត និងឈ្មោះ [redacted] ចំរើន បាននិយាយសំដីចុងក្រោយ សំណូមពរឱ្យតុលាការបន្ធូរបន្ថយទោសដល់ខ្លួនផង។

**ហេតុដូច្នេះ សាលាដំបូងខេត្តព្រះសីហនុ**

**វិនិច្ឆ័យ សេចក្តី**

**១- ផ្តន្ទាទោស:**

ក-ឈ្មោះ [redacted] ឈាង ហៅ វ៉ាង ភេទប្រុស អាយុ ២៦ ឆ្នាំ ជនជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ០១ (មួយ) ឆ្នាំ និង ០៦ (ប្រាំមួយ) ខែ។

ខ-ឈ្មោះ [redacted] សុភ័ក្រ្ត ហៅ តូ ភេទប្រុស កើតឆ្នាំ ១៩៩៩ ជនជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ០១ (មួយ) ឆ្នាំ និង ០៦ (ប្រាំមួយ) ខែ។

ពីបទ: អំពើលួច ប្រព្រឹត្តនៅក្រុម១ ភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

គ-ឈ្មោះ [redacted] ចំរើន ភេទប្រុស អាយុ ២៥ ឆ្នាំ ជនជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ០២ (ពីរ) ឆ្នាំ តែទោសនេះត្រូវអនុវត្តក្នុងពន្ធនាគារកំណត់រយៈពេល

០១ (មួយ) ឆ្នាំ ទោសដែលនៅសល់ត្រូវព្យួរការអនុវត្តធម្មតា។

ឃ-ឈ្មោះ [redacted] ឆា ភេទប្រុស កើតឆ្នាំ ១៩៨៦ ជនជាតិខ្មែរ (កេនសារពើជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ០២ (ពីរ) ឆ្នាំ។

ពីបទ ទទួលផលចោរកម្ម ប្រព្រឹត្តនៅក្រុម១ ភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ។

២-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ឈាង ហៅ វ៉ាង ឈ្មោះ [redacted] សុភ័ក្ត្រ ហៅ ពូ ឈ្មោះ [redacted] ចំរើន និងចំពោះមុខមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ចំរើន ដោយកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ឆា។

ទុកសិទ្ធិឲ្យប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

ក្រឡាបញ្ជី

ហត្ថលេខា និងត្រា [redacted]

ចៅក្រមជំនុំជម្រះ

ហត្ថលេខា និងត្រា [redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ខេត្តព្រះសីហនុ ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ ២០១៧

ក្រឡាបញ្ជី

[redacted]

បានឃើញ

ចៅក្រមជំនុំជម្រះ

[redacted]

**ឧបសម្ព័ន្ធទី ១០**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

**សាលក្រមព្រហ្មទណ្ឌ**
**លេខ: ៣២០៩ "ទ"**
**ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០**
**-សំណុំរឿងព្រហ្មទណ្ឌលេខខ: ៣៤២១**
ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨
**-សំណុំរឿងជំនុំជម្រះផ្ទាល់លេខ: ៣៩១៥**
ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៨

**ក្នុងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងរាជធានីភ្នំពេញ**

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង២ និង ៣០ នាទី នៅសាលសវនាការទី៤ ដោយមានសមាសភាព ៖

**ចៅក្រមជំនុំជម្រះ**

លោក **លិ សុខា** ជាចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

**តំណាងអយ្យការ**

លោក **សឿន មុនីរ័ត្ន** ជាព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

លោក **តិច ប៉ូ** ជាក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះផ្ទាល់លើសំណុំរឿងព្រហ្មទណ្ឌលេខ: ៣៤២១ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨ ដែលមានជនជាប់ចោទដូចខាងក្រោមនេះ៖

១.ឈ្មោះ **ចេង ច័ន្ទដារ៉ា** ភេទប្រុស អាយុ៥១ឆ្នាំ សញ្ជាតិខ្មែរ មុខរបរតន្ត្រីករ សាសនា ព្រះពុទ្ធ ទីកន្លែងកំណើតនៅភូមិអង្គតាសោម ឃុំអង្គតាសោម ស្រុកត្រាំកក់ ខេត្តតាកែវ មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ:១៧៥៤ ផ្លូវលេខ៦២ ក្រុមទី៤ ភូមិផ្សារតូច សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោះ **តាយ ចេង** "ស្លាប់" ម្តាយឈ្មោះ **សោ ក្រាញ់** "ស្លាប់" ប្រពន្ធឈ្មោះ **លុយ កែវសុខទៀង** មានកូន០៣នាក់ ទោសពីមុនគ្មាន ។ ( **ក្រៅឃុំ** )

-លោកមេធាវី **យុង ផានិត** អត្តលេខ០៨៧ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទមានការិយាល័យផ្ទះលេខ ២១១០B ផ្លូវជាតិលេខ៥ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

២.ឈ្មោះ **លុយ កែវសុខទៀង** ភេទស្រី អាយុ៣៩ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ មេផ្ទះ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅសង្កាត់លេខ១ ក្រុងភ្នំពេញ មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ:១៧៥៤ ផ្លូវលេខ៦២ ក្រុមទី៤ ភូមិផ្សារតូច សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោះ **លុយ សាវ៉ាន់**"រស់" ម្តាយឈ្មោះ **តូច សាវឿន**"រស់" ប្តីឈ្មោះ **ចេង ច័ន្ទដារ៉ា** ទោសពីមុនគ្មាន ។ ( **ក្រៅឃុំ** )

ជាប់ចោទពីបទ: **ប្តឹងបរិហាបង្កាច់កេរ្តិ៍** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងតាមមាត្រា ៣១១ និងឲ្យផ្តន្ទាទោសតាមមាត្រា ៣១២ នៃក្រមព្រហ្មទណ្ឌ ។

-ជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ **ផ្លុង សុខ្ជន** ភេទប្រុស អាយុ៣៧ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅផ្ទះលេខ:៧០០ ផ្លូវលេខ៥៨ ភូមិផ្សារតូច សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

-លោកមេធាវី **ហេង ឃាង ,ជួន ចាន់ធារិទ្ធ** និងលោកមេធាវី **ចេង ប៉េងហាប់** ជាមេធាវីការពារក្តី និងជាតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី ។

**<u>អង្គហេតុនៃរឿងមានដូចតទៅ៖</u>**

កាលពីថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៧ ឈ្មោះ **ចេង ច័ន្ទដារ៉ា** និងប្រពន្ធឈ្មោះ **លុយ កែវសុខទៀង** បានប្ដឹងពីឈ្មោះ **ផ្លុង សុខ្ខន** មកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ពីករណី បំភាន់មន្ត្រីសុរិយោដីក្នុងពេលបំពេញបេសកកម្ម និងបំភាន់អាជ្ញាធរយកដីរបស់ជនរងគ្រោះទៅចុះបញ្ជីសុរិយោដីធ្វើជាកម្មសិទ្ធរបស់ខ្លួន តែត្រូវបានតំណាងអយ្យការសម្រេចតម្កល់រឿងទុកឥតចាត់ការ តាមដីកាលេខ:០៣១ អ.យ.ឃ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៨។ បន្ទាប់មកឈ្មោះ ចេង ច័ន្ទដារ៉ា និងប្រពន្ធបានប្ដឹងឧទ្ធរណ៍និងដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការនេះ ហើយមហាអយ្យការអមសាលាឧទ្ធរណ៍ពិនិត្យលើសំណុំរឿងនេះហើយក៏បានចេញសេចក្ដីសម្រេចតម្កល់រឿងទុកឥតចាត់ការលេខ: ០៧៦ សត.ប្រក.០១៨ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៨ ដែលមានខ្លឹមសារតម្កល់តាមដីកាសម្រេចរបស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល។ យោងតាមដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ ឈ្មោះ ផ្លុង សុខ្ខន បានដាក់ពាក្យបណ្ដឹងចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ ប្ដឹងពីឈ្មោះឈ្មោះ **ចេង ច័ន្ទដារ៉ា** និងប្រពន្ធឈ្មោះ **លុយ កែវសុខទៀង** ពីបទ: បរិហាបង្កាច់កេរ្តិ៍ មកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ហើយត្រូវបានតំណាងអយ្យការសម្រេចបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់តាមដីកាលេខ: ០៩១ អ.យ.ស ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨ តែម្ដង។

-**បានឃើញ** ដីកាតម្កល់រឿងទុកឥតចាត់ការលេខ: ០៣១ អ.យ.ឃ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៨ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-**បានឃើញ** សេចក្ដីសម្រេចតម្កល់ដីកាតម្កល់រឿងទុកឥតចាត់ការលេខ: ០៧៦ សត.ប្រក.០១៨ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៨ របស់មហាអយ្យការអមសាលាឧទ្ធរណ៍។

-**បានឃើញ** ដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់លេខ:០៩១អ.យ.ស ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

## <u>នាពេលសវនាការ</u>

-ជនជាប់ចោទឈ្មោះ **ចេង ចាន់ដារ៉ា** បានឆ្លើយថា កាលពីថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៧ ខ្លួនពិតជាបានប្ដឹងឈ្មោះ **ផ្លុង សុខ្ខន** ភេទប្រុស រស់នៅផ្ទះលេខ:៧០០ ផ្លូវលេខ៥៨ ស្ថិតនៅភូមិផ្សារតូច សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវពិតមែន ក្នុងគោលបំណងទាមទារដីរបស់ខ្លួនមកវិញតែប៉ុណ្ណោះ មិនមានបំណងបរិហាបង្កាច់កេរ្តិ៍នោះទេ ហើយប្រពន្ធខ្លួនក៏មិនបានចូលរួមប្ដឹងជាមួយខ្លួននោះដែរ។ បន្ទាប់ពីខ្លួនបានដាក់ពាក្យបណ្ដឹងទៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញរួចមក ស្រាប់តែតំណាងអយ្យការបានសម្រេចតម្កល់សំណុំរឿងទុកឥតចាត់ការ តាមដីកាសម្រេចលេខ ០៣១ អ.យ.ឃ ចុះថ្ងៃទី ០៨ ខែមករា ឆ្នាំ២០១៨ ដោយសាររឿងនេះជារឿងពិត ខ្លួនមិនសុខចិត្តនិងដីកាសម្រេចនេះក៏បានប្ដឹងឧទ្ធរណ៍និងដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការនេះទៅសាលាឧទ្ធរណ៍ទៀត។ បន្ទាប់ពីមហាអយ្យការអមសាលឧទ្ធរណ៍បានពិនិត្យលើសំណុំរឿងបណ្ដឹងឧទ្ធរណ៍រួចហើយ ស្រាប់តែមហាអយ្យការអមសាលាឧទ្ធរណ៍បានសម្រេចតម្កល់សំណុំរឿងនេះទុកឥតចាត់ការទៀត តាមដីកាសម្រេចរបស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។ គោលដែលខ្លួនប្ដឹងនេះ គ្រាន់តែចង់បានដីរបស់ខ្លួនមកវិញតែប៉ុណ្ណោះ មិនមានចេតនាប្ដឹងបរិហាបង្កាច់កេរ្តិ៍ លើឈ្មោះ **ផ្លុង សុខ្ខន** នោះទេ។

-សាក្សីឈ្មោះ **អ៊ុក វណ្ណា** បានឆ្លើយថា ខ្លួនដឹងថាឈ្មោះ ចេង ច័ន្ទដារ៉ា បានប្ដឹងពីឈ្មោះ ផ្លុង សុខ្ខន ដោយសារតែឈ្មោះ ផ្លុង សុខ្ខន បានធ្វើផ្ទះនៅលើដីរបស់គាត់ដោយគាត់ចូលទៅមើលដីគាត់ឈ្មោះ ផ្លុង សុខ្ខន មិនឱ្យគាត់ចូលទៅមើលដីរបស់គាត់ឡើយ។ នៅពេលដែលតុលាការតម្កល់ពាក្យបណ្ដឹងរបស់ឈ្មោះ ចេង ច័ន្ទដារ៉ា នៅសាលាដំបូងរាជធានីភ្នំពេញ និងទាំងនៅសាលាឧទ្ធរណ៍ភ្នំពេញនោះខ្លួនមិនបានដឹងឡើយ។

-ឈ្មោះ **ផ្លុង វុទ្ធី** បានឆ្លើយថា ខ្លួនជាបងប្រុសបង្កើតរបស់ឈ្មោះ ផ្លុង សុខ្ខន ការដែលខ្លួនមកធ្វើជាសាក្សីនេះដោយសារតែឃើញមានភាពអយុត្តិធម៌ចំពោះឈ្មោះ ចេង ច័ន្ទដារ៉ា ដែលត្រូវបានឈ្មោះ ផ្លុង សុខ្ខន បានធ្វើការបំភាន់យកដីរបស់ឈ្មោះ ចេង ច័ន្ទដារ៉ា ធ្វើការសាងសង់ផ្ទះរួចធ្វើឯកសារជាកម្មសិទ្ធិរបស់ខ្លួនរហូតមកដល់សព្វថ្ងៃនេះ។ ចំពោះពាក្យបណ្តឹងរបស់ឈ្មោះ ចេង ច័ន្ទដារ៉ា ដែលបានប្តឹងទៅសាលាដំបូងរាជធានីភ្នំពេញ ហើយត្រូវបានតំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញធ្វើការតម្កល់ទុកឥតចាត់ការ និងនៅមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញធ្វើការតម្កល់ទុក យ៉ាងណានោះខ្លួនមិនបានដឹងរឿងឡើយ។

-សាក្សីឈ្មោះ **ឌិត សំអាង** បានឆ្លើយថា ខ្លួនត្រូវជាប់សាច់ញាតិជាមួយជនជាប់ចោទដែលខ្លួនមកធ្វើជាសាក្សីនេះដោយសារតែឃើញមានភាពអយុត្តិធម៌ចំពោះឈ្មោះ ចេង ច័ន្ទដារ៉ា ដែលត្រូវបានឈ្មោះ ផ្លុង សុខ្ខន បានធ្វើការបំភាន់យកដីរបស់ឈ្មោះ ចេង ច័ន្ទដារ៉ា ធ្វើការសាងសង់ផ្ទះរួចធ្វើឯកសារជាកម្មសិទ្ធិរបស់ខ្លួនគ្រប់គ្រងរហូតមកដល់សព្វថ្ងៃនេះ។ ចំពោះពាក្យបណ្តឹងរបស់ឈ្មោះ ចេង ច័ន្ទដារ៉ា ដែលបានប្តឹងទៅសាលាដំបូងរាជធានីភ្នំពេញ ហើយត្រូវបានតំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញធ្វើការតម្កល់ទុកឥតចាត់ការ និងនៅមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញធ្វើការតម្កល់ទុក យ៉ាងណានោះខ្លួនមិនបានដឹងរឿងឡើយ។

-តាមអំណានពាក្យបណ្តឹងចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ របស់ឈ្មោះ **ផ្លុង សុខ្ខន** ថា សុំប្តឹងឈ្មោះ **ចេង ច័ន្ទដារ៉ា** និងប្រពន្ធឈ្មោះ **លុយ កែវសុខទៀង** ពីបទ **បរិហាបង្កាច់កេរ្តិ៍** កាលពីថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៧។ យោងតាមដីកាតម្កល់រឿងទុកឥតចាត់ការលេខ: ០៣១ អ.យ.ឃ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៨ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ និងយោងសេចក្តីសម្រេចតម្កល់ដីកាតម្កល់រឿងទុកឥតចាត់ការលេខ:០៧៦ សត.ប្រក.០១៨ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៨ របស់មហាអយ្យការអមសាលាឧទ្ធរណ៍។ តបតាមកម្មវត្ថុខាងលើខ្លួនសូមជម្រាបជូនលោកព្រះរាជអាជ្ញាមេត្តាជ្រាបថា កាលពីថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៧ ឈ្មោះ **ចេង ច័ន្ទដារ៉ា** និងប្រពន្ធឈ្មោះ **លុយ កែវសុខទៀង** បានដាក់ពាក្យបណ្តឹងប្តឹងខ្លួនពីបទ បំភាន់មន្ត្រីសុរិយោដីក្នុងពេលបំពេញបេសកកម្ម និងបំភាន់អាជ្ញាធរយកដីរបស់ជនរងគ្រោះទៅចុះបញ្ជីសុរិយោដីធ្វើជាកម្មសិទ្ធរបស់ខ្លួន មកកាន់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។ ក្រោយពីអយ្យការធ្វើការស៊ើបអង្កេតកោះហៅគូភាគីដែលពាក់ព័ន្ធទាំងអស់មកសាកសួរ ឆ្លើយបំភ្លឺរួចមកឃើញថា ខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់របស់ឈ្មោះ **ចេង ច័ន្ទដារ៉ា** និងប្រពន្ធឈ្មោះ **លុយ កែវសុខទៀង** ឡើយ រួចតំណាងអយ្យការក៏បានចេញដីកាតម្កល់រឿងទុកឥតចាត់ការលេខ: ០៣១ អ.យ.ឃ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៨។ លុះក្រោយមកឈ្មោះ **ចេង ច័ន្ទដារ៉ា** និងប្រពន្ធឈ្មោះ **លុយ កែវសុខទៀង** បានប្តឹងឧទ្ធរណ៍និងដីការម្កល់រឿងទុកឥតចាត់ការលេខ: ០៣១ អ.យ.ឃ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៨ហើយក៏ត្រូវបានមហាអយ្យការអមសាលាឧទ្ធរណ៍ចេញសេចក្តីសម្រេចតម្កល់ដីកាតម្កល់រឿងទុកឥតចាត់ការលេខ: ០៧៦ សត.ប្រក.០១៨ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៨ ដែលមានខ្លឹមសារតម្កល់តាមដីកានេះទុកជាបានការដដែលទៀត។ ហេតុដូច្នេះទង្វើរបស់ឈ្មោះ **ចេង ច័ន្ទដារ៉ា** និងប្រពន្ធឈ្មោះ **លុយ កែវសុខទៀង** នេះមានចេតនាទុច្ចរិតធ្វើឲ្យប៉ះពាល់ដល់កិត្តិយស និងសេចក្តីថ្លៃថ្នូរ របស់ខ្លួនក្នុងសង្គមជាខ្លាំងក្នុងនាមខ្លួនជាប្រជាពលរដ្ឋស្លូតត្រង់ម្នាក់។ ក្នុងរឿងនេះខ្លួនស័ណ្ឋមពរ៖

១.ចោទប្រកាន់លើឈ្មោះ **ចេង ច័ន្ទដារ៉ា** និងប្រពន្ធឈ្មោះ **លុយ កែវសុខទៀង** ទៅតាមច្បាប់។

២.ទាមទារសំណងការខូចខាត ជម្ងឺចិត្តចំនួន ២០០០០(ពីរម៉ឺន)ដុល្លាអាមេរិក។

៣.សេវាមេធាវីចំនួន ៤០០០ (បួនពាន់) ដុល្លាអាមេរិក ។

-អំណានដីកាតម្កល់រឿងទុកឥតចាត់ការលេខ: ០៣១ អ.យ.ឃ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៨របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ថា សម្រេចតម្កល់សំណុំរឿងព្រហ្មទណ្ឌលេខ៤៩៩២ ចុះថ្ងៃទី ០៩ ខែមករា ឆ្នាំ២០១៨ ទុក

គតចាត់ការតទៅ ។

-អំណានសេចក្តីសម្រេចតម្កល់ដីកាតម្កល់រឿងទុកឥតចាត់ការលេខ:០៧៦សត.ប្រក.០១៨ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៨ របស់មហាអយ្យការអមសាលាឧទ្ធរណ៍ថា តម្កល់ដីកាតម្កល់រឿងទុកឥតចាត់ការលេខ០៣១ អ.យ.ឃ ចុះថ្ងៃទី ០៨ ខែមករា ឆ្នាំ២០១៨ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល។

លោក **ជួន ចាន់ធារិទ្ធ** ជាមេធាវីការពារសិទ្ធិនិងជាតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើសេចក្តីសន្និដ្ឋានថា ក្រោយពីបានសិក្សាសំណុំរឿងនិងបានស្តាប់ការសាកសួរដេញដោលលើជនជាប់ចោទ និងសាក្សីឃើញថា តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ ចេង ច័ន្ទដារ៉ា បានឆ្លើយសារភាពថា ខ្លួនពិតជាបានប្តឹងពីកូនក្តីរបស់ខ្លួនពីបទបំភាន់សុរិយោដីមកសាលាដំបូងរាជធានីភ្នំពេញមែន ហើយត្រូវបានតំណាងអយ្យការអមសាលាដំបូងរាជធានីធ្វើការតម្កល់រឿងទុកឥតចាត់ការ។ បន្ទាប់មកឈ្មោះ ចេង ច័ន្ទដារ៉ា បានបន្តប្តឹងទៅមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញដែលសំណុំរឿងនេះក៏ត្រូវបានមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញបានសម្រេចតម្កល់ដីកាតម្កល់រឿងទុកឥតចាត់ការលេខ:០៣១អ.យ.ឃ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៨ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល នេះបញ្ជាក់ឱ្យឃើញថា ការប្តឹងរបស់ឈ្មោះ ចេង ច័ន្ទដារ៉ា ទាំងពីរសាលាមកលើកូនក្តីរបស់ខ្លួនមិនមានភស្តុតាងអ្វីមកដាក់បន្ទុកលើកូនក្តីខ្លួនឡើយ។ ម្យ៉ាងតាមចម្លើយសាក្សីរបស់ជនជាប់ចោទ មិនបានដឹងពីសំណុំរឿងដែលជនជាប់ចោទប្តឹងពីកូនក្តីរបស់ខ្លួនឡើយ ហើយក៏មិនបានដឹងពីសំណុំរឿងរបស់ជនចាប់ចោទ ដែលត្រូវបានតំណាងអយ្យការធ្វើការតម្កល់ទុកឥតចាត់ការទាំងពីរសាលានោះឡើយ។ ដូច្នេះក្នុងនាមខ្លួនជាមេធាវីការពារ និងជាតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿងនេះខ្លួនប្តឹងទាមទារដូចក្នុងពាក្យបណ្តឹង ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ ពីជនជាប់ចោទដដែល។

*•សេចក្តីសន្និដ្ឋានថ្លែងសុំរបស់តំណាងអយ្យការ•*

តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ ,សាក្សី និងអំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងអំណានឯកសារផ្សេងៗមានក្នុងសំណុំរឿងឃើញថា ពិតជាមានអំពើ **បរិហាបង្កាច់កេរ៍** ប្រាកដមែន ដូច្នេះតំណាងអយ្យការសុំតម្កល់ការប្តឹងចោទ តាមដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់រលេខ: ០៩១ អ.យ.ស ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨ ទុកដដែល និងសុំឲ្យតុលាការពិចារណាសម្រេចតាមច្បាប់ ។

លោក **យុង ផានិត** ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា កូនក្តីខ្លួនបានដាក់ពាក្យប្តឹងឈ្មោះ ផ្លុង សុខ្ខន ដោយសារតែឈ្មោះនេះបានលួចធ្វើកម្មសិទ្ធិលើដីរបស់កូនក្តីខ្លួនរួចបានធ្វើផ្ទះនៅលើដីរបស់កូនក្តីខ្លួនដែលបានបុកត្រឹះរួចគ្រប់គ្រងរហូតមកដល់បច្ចុប្បន្ន ហើយកូនក្តីរបស់ខ្លួនឈ្មោះ ចេង ច័ន្ទដារ៉ា តែម្នាក់គត់ធ្វើការដាក់ពាក្យបណ្តឹងទៅលើឈ្មោះ ផ្លុង សុខ្ខន មកសាលាដំបូងរាជធានីភ្នំពេញ ពីបទ បំភាន់មន្ត្រីសុរិយោដីក្នុងពេលបំពេញបេសកម្មនិងបំភាន់អាជ្ញាធរយកដីរបស់កូនក្តីខ្លួនទៅចុះបញ្ជីធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួន ហើយតំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញមិនបានធ្វើការស្រាវជ្រាវរកតាមពាក្យបណ្តឹងរបស់ខ្លួនក្តីខ្លួននោះទេ ក៏បានតម្កល់សំណុំរឿងទុកឥតចាត់ការតែម្តង ទើបធ្វើកូនក្តីរបស់ខ្លួនមិនអស់ចិត្តក៏បានបន្តប្តឹងពីដីកាតម្កល់រឿងទុកឥតចាត់ការរបស់សាលាដំបូងរាជធានីភ្នំពេញទៅមហាអយ្យការអមសាលាឧទ្ធរណ៍ ដើម្បីជួយរកយុត្តិធម៌ឱ្យ តែត្រូវបានមហាអយ្យការអមសាលាឧទ្ធរណ៍ធ្វើការតម្កល់ដីកាតម្កល់រឿងទុកឥតចាត់ការលេខ:០៣១ អ.យ.ឃ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៨ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែលទៀត។ ចំណែកឯឈ្មោះ លុយ កែវសុខទៀង ដែលត្រូវជាប្រពន្ធរបស់ឈ្មោះ ចេង ច័ន្ទដារ៉ា នោះ គាត់នៅឯក្រៅប្រទេសមិនបានដឹងរឿងអ្វីទេ ហើយការដាក់ពាក្យបណ្តឹងនេះមានតែឈ្មោះ ចេង ច័ន្ទដារ៉ា ម្នាក់គត់មិនមានស្នាមមេដៃ ឬក៏ឈ្មោះ លុយ កែវសុខទៀង ក្នុងការចូលរួមប្តឹងក្នុងសំណុំរឿងនេះឡើយ។ បើយើងពិនិត្យលើសំណុំ/

រឿងនេះក៏ដូចជាពាក្យបណ្ដឹងរបស់ឈ្មោះ ចេង ច័ន្ទដារ៉ា ដែលប្ដឹងពីឈ្មោះ ផ្លុង សុខ្លួន សុទ្ធតែជាបងប្អូនគ្នា ដែលទាក់ទងជម្លោះកម្មសិទ្ធិដីធ្លី ដូច្នេះហើយ ខ្លួនសុំឱ្យតុលាការពិចារណាសម្រេចឱ្យកូនក្ដីរបស់ខ្លួនទាំងពីរនាក់គឺឈ្មោះ ចេង ច័ន្ទដារ៉ា និងប្រពន្ធឈ្មោះ លុយ កែវសុខទៀង បានរួចផុតពីបទចោទប្រកាន់ក្នុងរឿងនេះតាមផ្លូវច្បាប់។

*•សំដីចុងក្រោយរបស់ជនជាប់ចោទ•*

-ជនជាប់ចោទឈ្មោះ **ចេង ច័ន្ទដារ៉ា** បាននិយាយសម្ដីចុងក្រោយបង្ហសំថា ខ្លួនសុំឱ្យតុលាការលើកលែងចោទប្រកាន់។

-ក្រោយពីបានស្ដាប់អំណានចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្ដាប់ចម្លើយសាក្សី

-ក្រោយពីបានស្ដាប់អំណានពាក្យបណ្ដឹង ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨

-ក្រោយពីបានស្ដាប់អំណានឯកសារមានក្នុងសំណុំរឿង

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋាន របស់មេធាវីការពារសិទ្ធិនិងតំណាងឱ្យដើមបណ្ដឹងរដ្ឋប្បវេណី

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋាន របស់មេធាវីការពារសិទ្ធិជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារ ភស្តុតាងនានា ដែលមានក្នុងសំណុំរឿង

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## **សំអាងហេតុ**

១.កាលពីថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៧ ឈ្មោះ **ចេង ច័ន្ទដារ៉ា** បានប្ដឹងពីឈ្មោះ **ផ្លុង សុខ្លួន** ភេទប្រុស អាយុ៣៧ឆ្នាំ ជនជាតិខ្មែរ មកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ពីករណី បំភាន់មន្ត្រីសុរិយោដីក្នុងពេលបំពេញបេសកកម្ម និងបំភាន់អាជ្ញាធរយកដីរបស់ជនរងគ្រោះទៅចុះបញ្ជីសុរិយោដីធ្វើជាកម្មសិទ្ធរបស់ខ្លួន តែត្រូវបានតំណាងអយ្យការសម្រេចតម្កល់រឿងទុកឥតចាត់ការ តាមដីកាលេខ: ០៣១ អ.យ.ឃ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៨ បន្ទាប់មកឈ្មោះ **ចេង ច័ន្ទដារ៉ា** បានប្ដឹងដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការរបស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញទៅមហាអយ្យការអមសាលាឧទ្ធរណ៍ពិនិត្យលើសំណុំរឿងនេះក៏បានចេញសេចក្ដីសម្រេចតម្កល់រឿងទុកឥតចាត់ការលេខ: ០៧៦ សត.ប្រក.០១៨ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៨ ដែលមានខ្លឹមសារតម្កល់តាមដីកាសម្រេចរបស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល។ យោងតាមដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការរបស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញនិងមហាអយ្យការអមសាលាឧទ្ធរណ៍ ទើបឈ្មោះ **ផ្លុង សុខ្លួន** បានដាក់ពាក្យបណ្ដឹង ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ ប្ដឹងពីឈ្មោះ **ចេង ច័ន្ទដារ៉ា** និងប្រពន្ធឈ្មោះ **លុយ កែវសុខទៀង** ពីបទ: **បរិហាបង្កាច់កេរ្តិ៍** មកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ហើយត្រូវបានតំណាងអយ្យការសម្រេច តាមដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់លេខ: ០៩១ អ.យ.ស ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨ តែម្ដង។

២.ជនជាប់ចោទឈ្មោះ **ចេង ច័ន្ទដារ៉ា** និងឈ្មោះ **លុយ កែវសុខទៀង** ត្រូវបានតំណាងអយ្យការចោទប្រកាន់ពីបទ **បរិហាបង្កាច់កេរ្តិ៍** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៧ តាមបញ្ញត្តិមាត្រា ៣១១ និងមាត្រា ៣១២ នៃក្រមព្រហ្មទណ្ឌ តាមដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់លេខ: ០៩១ អ.យ.ស ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨។

៣.ជនជាប់ចោទឈ្មោះ **ចេង ច័ន្ទដារ៉ា** បានឆ្លើយសារភាពថា ខ្លួនពិតជាបានដាក់ពាក្យប្ដឹងឈ្មោះ **ផ្លុង សុខ្លួន** ពីករណី បំភាន់មន្ត្រីសុរិយោដីក្នុងពេលបំពេញបេសកកម្ម និងបំភាន់អាជ្ញាធរយកដីរបស់ជនរងគ្រោះទៅចុះបញ្ជីសុរិយោដីធ្វើ

ជាកម្មសិទ្ធិរបស់ខ្លួន មកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ តែត្រូវបានតំណាងអយ្យការសម្រេចតម្កល់រឿងទុកឥតចាត់ការ ហើយខ្លួនបានប្ដឹងពីដីកាសម្រេចរបស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញទៅសាលាឧទ្ធរណ៍ហើយត្រូវបានមហាអយ្យការអមសាលាឧទ្ធរណ៍សម្រេចតម្កល់រឿងទុកឥតចាត់ការតាមដីកាលេខ: ០៧៦ សត.ប្រក.០១៨ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៨ ដោយឡែកប្រពន្ធរបស់ខ្លួនមិនបានចូលរួមប្ដឹងជាមួយខ្លួនទេ ព្រោះថាខ្លួនប្ដឹងដើម្បីការពារផលប្រយោជន៍នីតិវិធីរបស់ខ្លួនតែប៉ុណ្ណោះ។ ចម្លើយនេះជាចម្លើយសារភាពស៊ីសង្វាក់ជាមួយចម្លើយរបស់ជនជាប់ចោទពីមុខនិងពាក្យបណ្ដឹងរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ព្រមទាំងភស្តុតាងដែលមានក្នុងសំណុំរឿង ដែលអាចឱ្យតុលាការជឿបាន។

៤.តាមចម្លើយរបស់សាក្សីទាំងអស់នេះបានបញ្ជាក់ថា ពួកគេគ្រាន់បានដឹងថា ឈ្មោះ ផ្លុង សុទ្ធន បានធ្វើការបំភាន់យកដីរបស់ឈ្មោះ ចេង ច័ន្ទដារ៉ា ធ្វើការសាងសង់ផ្ទះរួចធ្វើឯកសារជាកម្មសិទ្ធិរបស់ខ្លួនរហូតមកដល់សព្វថ្ងៃនេះ។ ចំពោះការប្ដឹងផ្ដល់គ្នាពួកខ្លួនមិនបានដឹងទេ។

៥.តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ **ចេង ច័ន្ទដារ៉ា** ក៏ដូចជាពាក្យបណ្ដឹងបានឱ្យឃើញថា កាលពីអំឡុងឆ្នាំ២០១៧ជនជាប់ចោទរូបនេះពិតជាបានប្ដឹងឈ្មោះ **ផ្លុង សុទ្ធន** ពីករណីបំភាន់មន្ត្រីសុរិយោដីក្នុងពេលបំពេញបេសកកម្ម និងបំភាន់អាជ្ញាធរយកដីរបស់ជនរងគ្រោះទៅចុះបញ្ជីសុរិយោដីធ្វើជាកម្មសិទ្ធិរបស់ខ្លួន មកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញហើយត្រូវបានតំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញបានតម្កល់ទុកឥតចាត់ការ ហើយបានជនជាប់ចោទរូបនេះបានប្ដឹងនឹងដីកាសម្រេចរបស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ទៅសាលាឧទ្ធរណ៍ត្រូវបានមហាអយ្យការអមសាលាឧទ្ធរណ៍សម្រេចតម្កល់ទុកឥតចាត់ការដដែលនេះសបញ្ជាក់ឱ្យឃើញថា សកម្មភាពរបស់ជនជាប់ចោទរូបនេះត្រូវបានច្បាប់កំណត់ថា ជាអំពើ **បរិហារបង្កាច់កេរ្តិ៍** ជាបទល្មើសព្រហ្មទណ្ឌដែលមានចែងតាមមាត្រា៣១១ និងឱ្យផ្ដន្ទាទោសតាមមាត្រា៣១២ នៃក្រមព្រហ្មទណ្ឌ។ ចំណែកឈ្មោះ **លុយ កែវសុខទៀង** នេះមិនបានប្ដឹងឈ្មោះ **ផ្លុង សុទ្ធន** ពីករណីបំភាន់មន្ត្រីសុរិយោដីក្នុងពេលបំពេញបេសកកម្ម និងបំភាន់អាជ្ញាធរយកដីរបស់ជនរងគ្រោះទៅចុះបញ្ជីសុរិយោដីធ្វើជាកម្មសិទ្ធិរបស់ខ្លួននោះទេ ដែលបញ្ជាក់ថា ឈ្មោះ **លុយ កែវសុខទៀង** មិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះឡើយ។

៦.សកម្មភាពទាក់ទងនឹងបទ: **បរិហារបង្កាច់កេរ្តិ៍** ត្រូវបានហាមឃាត់ដោយច្បាប់ ដូច្នេះជនជាប់ចោទឈ្មោះ **ចេង ច័ន្ទដារ៉ា** បានដឹងរួចហើយថា សកម្មភាពដែលខ្លួនបានប្រព្រឹត្តនោះគឺជាអំពើខុសច្បាប់ ប៉ុន្តែជនជាប់ចោទរូបនេះនៅតែប្រព្រឹត្តដដែលគឺបញ្ជាក់យ៉ាងច្បាស់ថា ជនជាប់ចោទរូបនេះពិតជាមានចេតនាទុច្ចរិតក្នុងការប្រព្រឹត្តនូវអំពើ **បរិហារបង្កាច់កេរ្តិ៍** ដែលច្បាប់បានបញ្ញត្តិថាជាបទល្មើសនិងត្រូវផ្ដន្ទាទោស។

៧.ជនជាប់ចោទឈ្មោះ **ចេង ច័ន្ទដារ៉ា** ជានីតិជន មានសតិគ្រប់គ្រាន់ មិនវិបល្លាសស្មារតី មានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវនូវអំពើរបស់ខ្លួនដែលបានប្រព្រឹត្តកន្លងមក។

៨.អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ **ចេង ច័ន្ទដារ៉ា** បានធ្វើឱ្យប៉ះពាល់ដល់របៀបរៀបរយសណ្ដាប់សាធារណៈ និងប៉ះពាល់ដល់កេរ្តិ៍ឈ្មោះ សេចក្ដីថ្លៃថ្នូរ របស់ជនរងគ្រោះ ។

៩.មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ **ចេង ច័ន្ទដារ៉ា** ភេទប្រុស អាយុ៥១ឆ្នាំ សញ្ជាតិខ្មែរ មានសារតារជាតិខាងលើ ពីបទ: **បរិហារបង្កាច់កេរ្តិ៍** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងតាមមាត្រា ៣១១ និងឱ្យផ្ដន្ទាទោសតាមមាត្រា ៣១២ នៃក្រមព្រហ្មទណ្ឌ ។

១០.គ្មានភស្តុតាងគ្រប់គ្រាន់ដាក់បន្ទុកលើឈ្មោះ **លុយ កែវសុខទៀង** ភេទស្រី អាយុ៣៨ឆ្នាំ សញ្ជាតិខ្មែរ មានសារតារជាតិខាងលើ ពីបទ **បរិហារបង្កាច់កេរ្តិ៍** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងតាមមាត្រា ៣១១ និងឱ្យផ្ដន្ទាទោសតាមមាត្រា ៣១២ នៃក្រមព្រហ្មទណ្ឌ។ ដូច្នេះតុលាការគប្បីសម្រេចឱ្យឈ្មោះ **លុយ**

**កែវសុខទៀង** រួចផុតពីបទចោទប្រកាន់។

១១.ដើមបណ្តឹងរដ្ឋប្បវេណីបានប្តឹងទាមទារសំណងការខូចខាត ជម្ងឺចិត្តជាទឹកប្រាក់ចំនួន ២០០០០(ពីរម៉ឺនដុល្លារអាមេរិក និងថ្លៃសេវាមេធាវីចំនួន ៥០០០ (ប្រាំពាន់ដុល្លារអាមេរិក)នោះ តុលាការគប្បីពិចារណាតាមការជាក់ស្តែង ។

**ហេតុដូច្នេះសម្រេច**

១.ឱ្យឈ្មោះ **លុយ កែវសុខទៀង** ភេទស្រី អាយុ៣៩ឆ្នាំ សញ្ជាតិខ្មែរ មានសាវតារជាតិខាងលើ **រួចផុតបទចោទប្រកាន់** ពីបទ **ឧបិហារបន្ថាប់កេរ្តិ៍** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងតាមមាត្រា ៣១១ និងឱ្យផ្តន្ទាទោសតាមមាត្រា ៣១២ នៃក្រមព្រហ្មទណ្ឌ។

២.ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ **ចេង ច័ន្ទដារ៉ា** ភេទប្រុស អាយុ៥១ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានសាវតារជាតិខាងលើ ដាក់ពន្ធនាគារកំណត់រយៈពេល **៦ ( ប្រាំមួយ )ខែ** តែទោសនេះត្រូវព្យួរទាំងស្រុង ពីបទ **ឧបិហារបន្ថាប់កេរ្តិ៍**ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងតាមមាត្រា **៣១១** និងឱ្យផ្តន្ទាទោសតាមមាត្រា **៣១២** នៃក្រមព្រហ្មទណ្ឌ។

៣.ឱ្យឈ្មោះ **ចេង ច័ន្ទដារ៉ា** សងសំណងជម្ងឺចិត្តនិងថ្លៃសេវាមេធាវីជាទឹកប្រាក់ចំនួន **១.០០០.០០០(មួយលាន)រៀល** ទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ **ផ្លុង សុគ្គន** ។ ច្រានចោលការទាមទារលើសពីនេះ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទឈ្មោះ **ចេង ច័ន្ទដារ៉ា** ,កំបាំងមុខជនជាប់ចោទឈ្មោះ **លុយ កែវសុខទៀង** និងដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈនៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០ ។ ទុកសិទ្ធិប្តឹងឱ្យប្តឹងទាស់ ឬ ប្តឹងឧទ្ធរណ៍តាមច្បាប់កំណត់។

**ក្រឡាបញ្ជីសវនាការ**
ហត្ថលេខា និងត្រា៖ **តិច ប៊ុ**

**ចៅក្រមជំនុំជម្រះ**
ហត្ថលេខា និងត្រា៖ **លិ សុខា**

---

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"
ថ្ងៃ ពុធ ១០ រោច ខែ អាសាឍ ឆ្នាំ ជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ ,ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០

**បានឃើញ**
**ចៅក្រមជំនុំជម្រះ**
លិ_សុខា

**ក្រឡាបញ្ជីសវនាការ**
តិច_ប៊ុ

# ឧបសម្ព័ន្ធទី ១១

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមព្រហ្មទណ្ឌ**

-លេខ ៥០៩ "ព"ក្រ៧

ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២២

-សំណុំរឿងព្រហ្មទណ្ឌលេខ៤៦១១

ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២១

-សំណុំរឿងស៊ើបសួរលេខ៣៥០៩

ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២១

-សំណុំរឿងជំនុំជម្រះលេខ២៣៦

ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២២

**តាងនាមប្រជារាស្ត្រខ្មែរ**

**សាលាដំបូងរាជធានីភ្នំពេញ**

បានបើកសវនាការអសាធារណៈ នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ វេលាម៉ោង ០២ និង៣០ នាទីរសៀល នៅសាលសវនាការទី៩ ដោយមានសមាសភាព៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

-លោកចៅក្រម ជាប្រធានក្រុមប្រឹក្សា

-លោកអនុប្រធាន ជាចៅក្រមប្រឹក្សា

-លោកស្រីចៅក្រម ជាចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

-លោក ជាព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

-លោក ជាក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៤៦១១ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២១ ដែលមានជនជាប់ចោទ៖ ឈ្មោះ មៀន ស្រៀន ភេទប្រុស កើតឆ្នាំ២០០៤ ជនជាតិខ្មែរ មុខរបរជាងពិដាន នៅលីវ ឪពុកឈ្មោះ មុន មៀន "រស់" ម្ដាយឈ្មោះ យ៉ុន យ៉េន "រស់" ជាអនីតិជន ទោសពីមុន "គ្មាន"។ (ក្នុងឃុំ)

ទីកន្លែងកំណើត: ភូមិស្រីសន្ធរ ឃុំបារាយណ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។

អាសយដ្ឋានបច្ចុប្បន្ន: ស្នាក់នៅបន្ទប់ជួល ភូមិសេអំពិល សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

ឃាត់ខ្លួននៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១។

ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៧៧០៦ "ឃ" ដ.ឃ.ង ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២១។ (ម២)

ដោយមានលោក រស់ ឧត្តម ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

ដោយមានលោក ព្រីង ស៊ីណា ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

ជាប់ចោទពីបទ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចផ្លូវលំ ភូមិជម្ពូវ័ន សង្កាត់ចោមចៅ៣ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**អង្គហេតុនៃរឿងមានដូចតទៅ**

កាលពីថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១ វេលាម៉ោង១៤ និង៥៥នាទី ការិយាល័យអន្តរាគមន៍(ក៨) នៃមន្ទីរប្រឆាំងបទល្មើសគ្រឿងញៀន បានចុះបង្ក្រាបជាក់ស្តែងករណីរក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន នៅចំណុចផ្លូវលំ ភូមិជម្ពូវ័ន សង្កាត់ចោមចៅ៣ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ឃាត់ខ្លួនជនជាប់ចោទឈ្មោះ មៀន ស្រៀន ភេទប្រុស កើតឆ្នាំ២០០៤ ដកហូតបានម្សៅក្រាមពណ៌សថ្លាសង្ស័យជា សារធាតុញៀនប្រភេទមេតំហ្វេតាមីនចំនួន០២កញ្ចប់ ដែលមានទម្ងន់ ០,៤០ក្រាម ហើយបាននាំខ្លួនមកកាន់មន្ទីរប្រឆាំងបទល្មើសគ្រឿងញៀន ដើម្បីធ្វើការសាកសួរ។ ក្រោយពីធ្វើការសាកសួរទទួលបានលទ្ធផលថាថ្នាំញៀនទាំងនោះ គឺជនជាប់ចោទបានទិញពីអ្នកលក់មិនស្គាល់ឈ្មោះ នៅម្តុំសាលា

ជម្ពូវ័ន បំណងយកមកទុកប្រើប្រាស់។ ក្រោយពីធ្វើការសាកសួររួចសមត្ថកិច្ចបានធ្វើការឃាត់ខ្លួនជនជាប់ចោទខាងលើ និងដកហូតវត្ថុតាង រួចកសាងសំណុំរឿងបញ្ជូនមកអយ្យការសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមនីតិវិធី។

-បានឃើញ របាយការណ៍លេខ ៦៧៤ រ.ប.ក ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២១ របស់មន្ទីរប្រឆាំងបទល្មើសគ្រឿងញៀន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៤៦៧៧ អ.យ.ទ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១។

-បានឃើញ ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះលេខ ៣៧ "ថ" ស.ដ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២២។

## នាពេលសវនាការ

ជនជាប់ចោទឈ្មោះ មៀន ស្រៀន បានឆ្លើយថា នៅថ្ងៃកើតហេតុ ខ្លួនបានហៅផាស់អែបជិះទៅទិញគ្រឿងញៀននៅម្តុំជម្ពូវ័ន ដោយខ្លួនបានទិញពីមនុស្សប្រុសមិនស្គាល់ឈ្មោះ ចំនួនពីរកញ្ចប់តូច ដោយក្នុងមួយកញ្ចប់ តម្លៃ២០.០០០ (ពីរម៉ឺន)រៀល។ ក្រោយមកត្រូវសមត្ថកិច្ចចុះមកឃាត់ខ្លួនតែម្តង។ ខ្លួនបានទិញថ្នាំញៀនក្នុងគោលបំណងយកមកប្រើប្រាស់ផ្ទាល់ខ្លួនប៉ុណ្ណោះ។ សមត្ថកិច្ចដកហូតថ្នាំញៀនពីខ្លួនបានចំនួន០២កញ្ចប់។

ក្រឡាបញ្ជីអានកំណត់ហេតុទទួលវត្ថុចាប់យក (១) លេខ ២០០៤ រ.វ.ត ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ រួមមាន៖[1]

-ស្រោមសំបុត្របិទជិតពណ៌លឿងទុំចំនួន០១ សរសេរថាក្រាមពណ៌សថ្លាទម្ងន់ ០,៤០ (សូន្យក្បៀសសែសិប) ក្រាម ដោយមានស្នាមផ្តិតម្រាមដៃជនជាប់ចោទឈ្មោះ មៀន ស្រៀន និងចុះហត្ថលេខារបស់មន្ត្រីនគរបាលយុត្តិធម៌។

ក្រឡាបញ្ជីអានលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ ៣៣៩៧៦ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២១ របស់មន្ទីរពិសោធន៍ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ឃើញថា៖[2] សំណាកជាគ្រឿងញៀនប្រភេទក្រាមម្សៅថ្លា ឈ្មោះ មេតំហ្វេតាមីន របស់ឈ្មោះ មៀន ស្រៀន ដែលមានកម្រិតភាពសុទ្ធ៧៥.៦៩%នៃទម្ងន់សរុប វាស្ថិតនៅក្នុងតារាងទី២ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀន ដូចមានចែងលម្អិតក្នុងតារាងឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា។

## សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋាន តាមចម្លើយសារភាពរបស់ជនជាប់ចោទ និងភស្តុតាងដែលសមត្ថកិច្ចបានដកហូត ឃើញថា ជនជាប់ចោទពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ប្រាកដមែន ហេតុនេះ តំណាងអយ្យការនៅតែរក្សាបទចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ ៤៦៧៧ អ.យ.ទ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ ទុកជាបានការដដែល និងសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

## សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

លោកមេធាវី រស់ ឧត្តម ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ បានធ្វើសេចក្តីសន្និដ្ឋានថា កូនក្តីរបស់ខ្លួនជាអនីតិជន ប្រកបរបរស្របច្បាប់ និងពុំធ្លាប់មានទោសពីមុនមកទេ ដោយសារកម្រិតវប្បធម៌ទាប រៀនបានត្រឹមថ្នាក់ទី២ គាត់ងាយនឹងទទួលរងគ្រោះក្នុងការប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនជាទីបំផុត។ ក្រោយពីបានពិភាក្សាដេញដាលក្នុងពេលសវនាការ និងឯកសារភស្តុតាងក្នុងសំណុំរឿងឃើញថា កូនក្តីរបស់ខ្លួន គឺបានប្រព្រឹត្តតែ បទប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដូចមានចែងក្នុងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន តែប៉ុណ្ណោះ ហើយគាត់ពុំបានប្រព្រឹត្ត បទរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន ដូចមានចែងក្នុងមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន នោះឡើយ។ ដូច្នេះក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ សូមស្នើសុំក្រុមប្រឹក្សាជំនុំជម្រះ មេត្តាឱ្យកូនក្តីខ្លួនរួចផុតពីបទចោទ រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន។ ម្យ៉ាងវិញទៀត រហូតមកដល់ពេលនេះ កូនក្តីខ្លួនត្រូវបាន

(1). [illegible]

(2). [illegible]

ខ្ញុំនៅបណ្ដោះអាសន្នអស់រយៈពេលលើសពី៦ខែហើយ ដូច្នេះខ្ញុំសូមស្នើក្រុមប្រឹក្សាជំនុំជម្រះដោះលែងកូនក្តីខ្ញុំឱ្យបានត្រឡប់ទៅផ្ទះវិញ។

## សំដីចុងក្រោយរបស់ជនជាប់ចោទ

ជនជាប់ចោទឈ្មោះ មៀន ស្រៀន បានសំណូមពរសុំតុលាការ ជួយបន្ធូរបន្ថយទោសដល់ខ្លួនផង។

-ក្រោយពីបានស្ដាប់ចម្លើយសារភាពរបស់ជនជាប់ចោទ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារភស្ដុតាងនានា។

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

## សាលាដំបូងរាជធានីភ្នំពេញ

## យល់ឃើញថា[3]

ក. តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៣៧ "ថ" ដ.ជ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ បានសម្រេចបញ្ជូនទៅជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ៤៦១១ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២១ ដែលមានជនជាប់ចោទឈ្មោះ មៀន ស្រៀន ភេទប្រុស កើតឆ្នាំ២០០៤ ពីបទរក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចផ្លូវលំ ភូមិជម្ពូវ័ន សង្កាត់ចោមចៅ៣ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ និងមាត្រា៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។[4]

ខ. អង្គហេតុកើតឡើងនៅចំណុចផ្លូវលំ ភូមិជម្ពូវ័ន សង្កាត់ចោមចៅ៣ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ហេតុនេះជាសមត្ថកិច្ចរបស់តុលាការព្រហ្មទណ្ឌនៃសាលាដំបូងរាជធានីភ្នំពេញ។[5]

គ. អង្គហេតុកើតឡើងកាលពីថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១ បើគិតរហូតមកដល់ពេលនេះ មិនទាន់ផុតអាជ្ញាយុកាលនៃបទល្មើសទេ។[6]

ឃ. តាមរបាយការណ៍សំយោគលេខ ៦៧៤ រ.ប.ក ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២១ របស់មន្ទីរប្រឆាំងបទល្មើសគ្រឿងញៀន នៃក្រសួងមហាផ្ទៃ បានធ្វើការសន្និដ្ឋានថា ជនជាប់ចោទឈ្មោះ មៀន ស្រៀន ពិតជាបាន ជួញដូរដោយខុសច្បាប់នូវសារធាតុញៀនប្រាកដមែន។[7]

ង. តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ មៀន ស្រៀន បានឆ្លើយសារភាពថា ខ្លួនពិតជាបានទិញថ្នាំញៀនពីមនុស្សប្រុសមិនស្គាល់ឈ្មោះ ចំនួនពីរកញ្ចប់តូច ដោយក្នុងមួយកញ្ចប់ តម្លៃ២០.០០០ (ពីរម៉ឺន)រៀល។ ក្រោយមកសមត្ថកិច្ចចុះមកឃាត់ខ្លួនតែម្ដង។ ខ្លួនបានទិញថ្នាំញៀនក្នុងគោលបំណងយកមកប្រើប្រាស់ផ្ទាល់ខ្លួនប៉ុណ្ណោះ សមត្ថកិច្ចដកហូតថ្នាំញៀនពីខ្លួនបានចំនួន០២កញ្ចប់។

ច. សកម្មភាពរបស់ជនជាប់ចោទឈ្មោះ មៀន ស្រៀន ដែលបានទិញថ្នាំញៀនពីជនមិនស្គាល់ឈ្មោះ យកមកទុកក្នុងគោលបំណងយកមកប្រើប្រាស់ បង្ហាញពីចេតនាទុច្ចរិតក្នុងការរក្សាទុកដោយខុសច្បាប់នូវគ្រឿងញៀន។

ឆ. តាមកំណត់ហេតុទទួលវត្ថុចាប់យក (១) លេខ ២០០៤ វ.វ.ត ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ រួមមាន៖[8]

---

(3). មាត្រា[illegible] មាត្រា[illegible] និងមាត្រា[illegible] នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

(4). មាត្រា[illegible] នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

(5). មាត្រា[illegible] នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

(6). មាត្រា១០ និង១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

(7)(ចំណារលេខ-៧) របាយការណ៍សំយោគរបស់មន្ទីរប្រឆាំងបទល្មើសគ្រឿងញៀន នៃក្រសួងមហាផ្ទៃ។

(8). ចំណារលេខ ៨ កំណត់ហេតុទទួលវត្ថុចាប់យករបស់សាលាដំបូងរាជធានីភ្នំពេញ។

-ស្រោមសំបុត្របិទជិតពណ៌លឿងទុំចំនួន០១ មានសរសេរថា ក្រាមពណ៌សថ្លាទម្ងន់ ០,៤០ (សូន្យក្បៀសសែសិប) ក្រាម បើផ្អែកតាមលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ ៣៣៩៧៦ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២១ របស់មន្ទីរពិសោធន៍ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បញ្ជាក់ឱ្យឃើញថា ជាគ្រឿងញៀនប្រភេទមេតំហ្វេតាមីន ស្ថិតនៅក្នុងតារាងទី២ មាត្រា៥ នៃតារាងឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន មានកម្រិតភាពសុទ្ធចំនួន ៧៥.៦៩% (ចិតសិបប្រាំក្បៀសហុកសិបប្រាំបួនភាគរយ) នៃទម្ងន់សរុប ហេតុនេះមានបរិមាណសារធាតុញៀនសុទ្ធមានចំនួន $\frac{0,៤0g \times ៧៥.៦៩}{១00} = 0,៣0g$ (សូន្យក្បៀសសាមសិបមួយ)ក្រាម។

ជ. តាមចម្លើយសារភាពរបស់ជនជាប់ចោទខាងលើ តាំងពីនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ រហូតដល់ដំណាក់កាលជំនុំជម្រះ និងរបាយការណ៍របស់សមត្ថកិច្ច ព្រមទាំងភស្តុតាងផ្សេងៗទៀតដែលដកហូតបានដោយមន្ត្រីនគរបាលយុត្តិធម៌ មានភាពស៊ីសង្វាក់គ្នាបង្ហាញឱ្យឃើញថាជនជាប់ចោទឈ្មោះ មៀន ស្រៀន ពិតជាបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់ប្រាកដមែន។

ឈ. អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ មៀន ស្រៀន ដែលបានទិញគ្រឿងញៀនពីជនមិនស្គាល់ឈ្មោះ យកមកទុក ហើយត្រូវបានសមត្ថកិច្ចធ្វើការឃាត់ខ្លួន និងឆែកឆេររកឃើញថ្នាំញៀនប្រភេទមេតំហ្វេតាមីនដែលមានបរិមាណសារធាតុញៀនសុទ្ធចំនួន 0,៣0g (សូន្យក្បៀសសាមសិប)ក្រាម ក្រោយពីធ្វើការឃាត់ខ្លួនសមត្ថកិច្ចបានធ្វើតេស្តទឹកនោមស្វែងរកសារធាតុញៀន លើជនជាប់ចោទឈ្មោះ មៀន ស្រៀន លទ្ធផលវិជ្ជមាន បើផ្អែកតាមធាតុនីត្យានុកូលស្របទៅនឹងបទ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ជាបទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌ១ និងកថាខណ្ឌ៤ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-មាត្រា៤០ កថាខណ្ឌ១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ការកាន់កាប់ ការលាក់ទុក សន្និធិ និងសកម្មភាពប្រហាក់ប្រហែលផ្សេងទៀតដោយខុសច្បាប់នូវសារធាតុញៀន គឺជាអំពើរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន។

-មាត្រា៤០ កថាខណ្ឌ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន បានចែងថា បទរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន ដែលស្ថិតនៅក្នុងតារាងទី១ និងតារាងទី២ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២(ពីរ)ឆ្នាំ ទៅ៥(ប្រាំ)ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ៤.000.000(បួនលាន)រៀល ទៅ១0.000.000 (ដប់លាន)រៀល។

-មាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ជនណាប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនដែលស្ថិតនៅក្នុងតារាងទី១ និងតារាងទី២ តាមគ្រប់រូបភាព និងធ្លាប់ត្រូវបានទទួលរងនូវវិធានការព្យាបាលដោយបង្ខំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ទៅ៦(ប្រាំមួយ)ខែ និងអាចត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី១00.000 (មួយសែន)រៀល ទៅ១.000.000(មួយលាន)រៀល។

ញ. ជនជាប់ចោទឈ្មោះ មៀន ស្រៀន ភេទប្រុស កើតឆ្នាំ២00៤ ជាអនីតិជន មានស្មារតីល្អ មានការយល់ដឹងខុសត្រូវច្បាស់លាស់ ហើយក៏ពុំមានសញ្ញាណណាមួយបញ្ជាក់ថា ជននេះមានវិបល្លាសស្មារតីអ្វីដែរ។

ដ. អំពើដែលជនជាប់ចោទ បានប្រព្រឹត្តធ្វើឱ្យប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយសង្គម ជាពិសេសធ្វើឱ្យប៉ះពាល់ដល់សុខភាពបុគ្គល ជាអំពើផ្ទុយច្បាប់ តម្រូវអោយផ្តន្ទាទោស។

ឋ. កំណត់ហេតុទទួលវត្ថុចាប់យក (១) លេខ ២00៤ រ.វ.ត ចុះថ្ងៃទី៣0 ខែតុលា ឆ្នាំ២0២១ រួមមាន ស្រោមសំបុត្របិទជិតពណ៌លឿងទុំចំនួន០១ សរសេរថាក្រាមពណ៌សថ្លាទម្ងន់0,៤0(សូន្យក្បៀសសែសិប)ក្រាម មានបរិមាណសារធាតុញៀនសុទ្ធទម្ងន់ 0,៣0g (សូន្យក្បៀសសាមសិប)ក្រាម ជាវត្ថុតាងនៃការប្រព្រឹត្តបទល្មើស គប្បីតុលាការសម្រេច រឹបអូសបំផ្លាញចោល ផ្អែកតាមមាត្រា៩៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ឌ. តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋាន នៅតែរក្សាបទចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ ៤៦៧៧ អ.យ.ទ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ ទុកជាបានការដដែល និងសុំឱ្យតុលាការផ្ដន្ទាទោសជនជាប់ចោទតាមច្បាប់ ការស្នើសុំនេះតុលាការនឹងលើកយកមកពិចារណា។

ឍ. លោក រស់ ឧត្តម ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្ដីសន្និដ្ឋាន ដោយសូមស្នើសុំក្រុមប្រឹក្សាជំនុំជម្រះមេត្តាឱ្យកូនក្តីរបស់ខ្លួនរួចផុតពីបទចោទ រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន និងស្នើសុំក្រុមប្រឹក្សាជំនុំជម្រះដោះលែងកូនក្តីរបស់ខ្លួន ការស្នើសុំនេះតុលាការនឹងលើកយកធ្វើការពិចារណា។

ណ. ជនជាប់ចោទឈ្មោះ មៀន ស្រៀន បានសំណូមពរឱ្យតុលាការមេត្តាជួយបន្ធូរបន្ថយទោសដល់ខ្លួនផង ការស្នើសុំនេះតុលាការនឹងលើកយកមកធ្វើការពិចារណា។

មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ មៀន ស្រៀន ភេទប្រុស កើតឆ្នាំ២០០៤ ពីបទ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចផ្លូវលំ ភូមិជម្ពូវ័ន សង្កាត់ចោមចៅ៣ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌ១ និងកថាខណ្ឌ៤ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

## ហេតុដូច្នេះ សម្រេច

១.ផ្ដន្ទាទោសជនជាប់ចោទឈ្មោះ មៀន ស្រៀន ភេទប្រុស កើតឆ្នាំ២០០៤ (មានអត្តសញ្ញាណដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេលចំនួន ២ (ពីរ)ឆ្នាំ តែត្រូវអនុវត្តទោសក្នុងពន្ធនាគាររយៈពេលចំនួន ១០ (ដប់)ខែ ទោសសល់ពីនេះត្រូវព្យួរសាកល្បងរយៈពេល ២ (ពីរ)ឆ្នាំ។

ពីបទ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចផ្លូវលំ ភូមិជម្ពូវ័ន សង្កាត់ចោមចៅ៣ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌ១ និងកថាខណ្ឌ៤ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។[9]

២.ក្នុងរយៈពេល២(ពីរ)ឆ្នាំ នៃការព្យួរទោសសាកល្បងនេះ ទណ្ឌិតឈ្មោះ មៀន ស្រៀន ត្រូវគោរពនូវកាតព្វកិច្ចមួយចំនួនដូចតទៅ:[10]

ក.ទណ្ឌិតត្រូវចូលបង្ហាញខ្លួនតាមការកោះហៅរបស់ព្រះរាជអាជ្ញា ឬ គ្រប់បុគ្គលដែលព្រះរាជអាជ្ញាបានផ្ដល់អំណាចឱ្យ។

ខ.ទណ្ឌិតមិនត្រូវសេពគប់រាល់បុគ្គលដែលពាក់ព័ន្ធនឹងគ្រឿងញៀននោះទេ។

គ.ទណ្ឌិតមិនត្រូវសេពគប់កន្លែងលក់គ្រឿងស្រវឹង។

ឃ.ទណ្ឌិតត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា អំពីការផ្លាស់ប្ដូរអាសយដ្ឋានរស់នៅរបស់ខ្លួន។

៣.វត្ថុចាប់យកមាននៅក្នុងកំណត់ហេតុលេខ (១) លេខ ២០០៤ រ.វ.ត ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២១ រួមមានក្រាមពណ៌សថ្លាទម្ងន់ ០,៤០ (សូន្យក្បៀសសែសិប)ក្រាម មានបរិមាណសារធាតុញៀនសុទ្ធទម្ងន់ ០,៣០៤ (សូន្យក្បៀសសាមសិប)ក្រាម ត្រូវរឹបអូសបំផ្លាញចោល។[11]

សាលក្រមនេះជំនុំជម្រះជាអសាធារណៈនៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ វេលាម៉ោង០២ និង៣០ នាទីរសៀល ចំពោះមុខជនជាប់ចោទឈ្មោះ មៀន ស្រៀន និងប្រកាសជាអសាធារណៈនៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២២ វេលាម៉ោង ៩ព្រឹក។[12]

(9) មាត្រា៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។
(10) មាត្រា១១៦ នៃក្រមព្រហ្មទណ្ឌ។
(11) មាត្រា៩៨ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។
(12) មាត្រា៣៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ទុកសិទ្ធិប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។[13]

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |
| លោក យស វាសនា | លោក រស់ ពិសិដ្ឋ | លោកស្រី សៀង ចរិយា | លោក ម៉ៅ ស៊ីណា |

**បានឃើញ**

ថ្ងៃពុធ ១៥កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២២

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

ម៉ៅ ស៊ីណា

**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃពុធ ១៥កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

យស វាសនា

(13) [illegible]

**ឧបសម្ព័ន្ធទី ១២**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តតាកែវ**

-សំណុំរឿងព្រហ្មទណ្ឌលេខ: ៦០២
ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១
-សាលក្រមព្រហ្មទណ្ឌលេខ: ៤៥ "ជ"
ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២

**សាលក្រម**

**តាងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្តតាកែវ**

បានបើកសវនាការជាសាធារណៈនៅសាលាដំបូងខេត្តតាកែវ នាថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២២ វេលាម៉ោង ៨ និង ០០នាទីព្រឹក ដោយមានសមាសភាពចូលរួមដូចតទៅ:

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

លោក **ហុង សុខហ៊ាង** ចៅក្រម នៃសាលាដំបូងខេត្តតាកែវ

**ចៅក្រមប្រឹក្សា**

លោក **រិន តិរុណា** ចៅក្រម នៃសាលាដំបូងខេត្តតាកែវ

លោក **គុជ តារ៉ា** ចៅក្រម នៃសាលាដំបូងខេត្តតាកែវ

**តំណាងអយ្យការ**

លោក **ស្រ៊ុន គឹមស្រស់** ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តតាកែវ

**ក្រឡាបញ្ជីសវនាការ**

លោក **ស៊ឹម សុផល** ក្រឡាបញ្ជីសាលាដំបូងខេត្តតាកែវ

**ដើម្បីជំនុំជម្រះ**

លើសំណុំរឿងព្រហ្មទណ្ឌលេខ: ៦០២ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១ ដែលមានជនជាប់ចោទ:

១-ឈ្មោះ ផុន សុភាព ហៅ វេង ភេទប្រុស អាយុ១៧ឆ្នាំ (កើតថ្ងៃទី១៦ ខែមេសា ឆ្នាំ២០០៤) ជនជាតិខ្មែរ មុខរបរកម្មករសំណង់ មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិពន្លៃ ឃុំជំរះពេន ស្រុកសំរោង ខេត្តតាកែវ ឪពុកឈ្មោះ ផុន សុជាត (រស់) ម្តាយឈ្មោះ ប៊ុក គឹមសេង (រស់) មានប្រពន្ធឈ្មោះ សាង រក្សា (រស់) មានកូន១នាក់ ជាអនីតិជន កម្រិតវប្បធម៌រៀនថ្នាក់ទី៥ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ: គ្មាន។ (ឃុំខ្លួនថ្ងៃទី១៥-១០-២០២១)

២-ឈ្មោះ ឈួន ហួត ភេទប្រុស អាយុ២១ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិពន្លៃ ឃុំជំរះពេន ស្រុកសំរោង ខេត្តតាកែវ ឪពុកឈ្មោះ ឈួន ហាង

(រស់) ម្តាយឈ្មោះ ហ៊ុល យឹម (ស្លាប់) នៅលីវ ជានីតិជន កម្រិតវប្បធម៌រៀនថ្នាក់ទី០២ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការៈ គ្មាន។ (ឃុំខ្លួនថ្ងៃទី១៥-១០-២០២១)

ជាប់ចោទពីបទៈ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិពន្លី ឃុំជំរះពេន ស្រុកសំរោង ខេត្តតាកែវ កាលពីថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២១ បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៣-ឈ្មោះ ផុន ពុទ្ធា ហៅ ផុន ម៉ូង ភេទប្រុស កើតថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩២ ជនជាតិខ្មែរ មុខរបរកសិករ មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិពន្លី ឃុំជំរះពេន ស្រុកសំរោង ខេត្តតាកែវ ឪពុកឈ្មោះ ថេង ធឿន (រស់) ម្តាយឈ្មោះ ម៉ៅ ញឹង (រស់) មានប្រពន្ធឈ្មោះ មុត សុខលាប (រស់) មានកូន ០១នាក់ ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការៈ គ្មាន។ (គេចខ្លួន)

៤-ឈ្មោះ មិន ធូ ហៅ មិន ខូ ភេទប្រុស កើតថ្ងៃទី០៨ ខែមករា ឆ្នាំ១៩៨៩ ជនជាតិខ្មែរ មុខរបរកសិករ មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិពន្លី ឃុំជំរះពេន ស្រុកសំរោង ខេត្តតាកែវ ឪពុកឈ្មោះ មាស ធី (រស់) ម្តាយឈ្មោះ ង៉ែត ប៊ុន (រស់) មានប្រពន្ធឈ្មោះ ណយ វាសនា (រស់) មានកូន ០២ នាក់ ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការៈ គ្មាន។ (គេចខ្លួន)

ជាប់ចោទពីបទៈ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិពន្លី ឃុំជំរះពេន ស្រុកសំរោង ខេត្តតាកែវ កាលពីថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២១ បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ដោយមានលោក ម៉ែន វុធ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ ផុន សុភាព ហៅ វ៉េង។

-បានឃើញ របាយការណ៍សរុបលេខៈ ១២៨/២០២១ ល.ប.ផ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១ របស់ស្នងការដ្ឋាននគរបាលខេត្តតាកែវ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខៈ ៥៧៩ ជ.ស.ព ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងខេត្តតាកែវ។

-បានឃើញ ដីកាដំណោះស្រាយលេខៈ ១៩/២០២១ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តតាកែវ។

-បានឃើញ ដីកាចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះបន្តលេខៈ ៩១៤ ដចត/២២ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២២ របស់ប្រធានសាលាដំបូងខេត្តតាកែវ។

-បានឃើញឯកសារផ្សេងៗក្នុងសំណុំរឿងព្រហ្មទណ្ឌខាងលើ។

**អង្គហេតុដែលខ្លឹមមកតុលាការមានដូចតទៅ:**

កាលពីថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២១ វេលាម៉ោង ១០ និង ៣០នាទី កម្លាំងសមត្ថកិច្ចនៃអធិការដ្ឋាននគរបាលស្រុកសំរោង បានចុះបង្ក្រាបករណីរក្សាទុក ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនមួយកន្លែងដែលស្ថិតនៅភូមិពន្លី ឃុំជំរះពេន ស្រុកសំរោង ខេត្តតាកែវ ធ្វើការឃាត់ខ្លួនជនត្រូវ

ចោទចំនួន ០២នាក់ មានឈ្មោះ ផុន សុភាព ភេទប្រុស អាយុ១៨ឆ្នាំ និងឈ្មោះ ឈួន ហួត ភេទប្រុស អាយុ២១ឆ្នាំ ព្រមទាំងដកហូតបានគ្រឿងញៀនប្រភេទមេតំហ្វេតាមីន (ម៉ាទឹកកក) ចំនួន ០១កញ្ចប់តូច ទម្ងន់ ០,២០ក្រាម ក្រោយពីធ្វើការសាកសួររួចមកឃើញថាជនត្រូវចោទបានឆ្លើយថាគ្រឿងញៀនដែល ពួកគេបានទិញយកមកប្រើប្រាស់ គឺទិញពីឈ្មោះ ផុន ពុទ្ធា ហៅ ម៉ុង ភេទប្រុស អាយុ២៩ឆ្នាំ និងឈ្មោះ មិន ធូ ហៅ ឌូ ភេទប្រុស អាយុ៣២ឆ្នាំ។

## នាពេលសវនាការ

-ចម្លើយរបស់ជនជាប់ចោទឈ្មោះ ផុន សុភាព ហៅ វ៉េង បានឆ្លើយថា: ខ្ញុំបាទពិជាបានប្រព្រឹត្ត អំពើទិញគ្រឿងញៀនយកមកប្រើប្រាស់ពិតមែន។ ដោយនៅថ្ងៃកើតហេតុខ្ញុំបាទបានយកលុយចំនួន ១៥,០០០៛ ទៅទិញថ្នាំញៀនពីឈ្មោះ ផុន ពុទ្ធា ហៅ ផុន ម៉ុង និងឈ្មោះ មិន ធូ ហៅ មិន ឌូ ដើម្បីយក មកប្រើប្រាស់ជាមួយនឹងឈ្មោះ ឈួន ហួត ដោយនៅពេលទិញនោះ គឺខ្ញុំបាទបានចំណាយប្រាក់អស់ ចំនួន ១៥,០០០៛ និងបានថ្នាំញៀនចំនួន ០១កញ្ចប់ ពេលខ្ញុំបាទបានទិញថ្នាំញៀនរួចហើយមិនទាន់ បានប្រើប្រាស់ផង ក៏ត្រូវបានសមត្ថកិច្ចឃាត់ខ្លួនខ្ញុំបាទ និងឈ្មោះ ឈួន ហួត តែម្តង។ ខ្ញុំបាទធ្លាប់ប្រើ ប្រាស់គ្រឿងញៀនអស់រយៈពេល ០៦ខែមកហើយ ប៉ុន្តែមិនដែលធ្លាប់ជួញដូរនោះទេ។ ចំពោះលុយ ចំនួន ១៥,០០០៛ ដែលយកទៅទិញថ្នាំញៀននោះ គឺឈ្មោះ ឈួន ហួត ជាអ្នកឱ្យលុយមកខ្ញុំបាទដើម្បី ទៅទិញថ្នាំញៀន។ ចំពោះថ្នាំញៀននោះ គឺពេលខ្ញុំបាទទិញរួចហើយបានយកមកទុកនៅក្នុងហោប៉ៅ ខោដើម្បីជក់។

-ចម្លើយរបស់ជនជាប់ចោទឈ្មោះ ឈួន ហួត បានឆ្លើយថា: ខ្ញុំបាទពិតជាបានប្រព្រឹត្តអំពើខាង លើដូចការចោទប្រកាន់ពិតមែន។ ដោយនៅថ្ងៃកើតហេតុថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២១ ខ្ញុំបាទបានឱ្យ លុយទៅឈ្មោះ ផុន សុភាព ចំនួន ១៥,០០០៛ ដើម្បីឱ្យគេយកប្រាក់នោះទៅទិញថ្នាំញៀនយកមកប្រើ ប្រាស់ជាមួយគ្នា។ ហើយនៅពេលនោះឈ្មោះ ផុន សុភាព បានលុយពីខ្ញុំបាទហើយគេបានជិះម៉ូតូទៅ ទិញថ្នាំញៀនទៅ ចំណែកឯរូបខ្ញុំបាទ គឺបានដើរទៅរើសខ្សងតែម្តងទៅ។ ពេលខ្ញុំបាទដើររើសខ្សងបាន ប្រហែលជា ១៥នាទី ក៏មានសន្តិសុខភូមិឈ្មោះ ខន បានជិះម៉ូតូមកហៅខ្ញុំបាទដើម្បីសួរនាំ រួចហើយ បានឃាត់ខ្លួនរូបខ្ញុំបាទតែម្តង។ កន្លងមកខ្ញុំបាទធ្លាប់ទិញថ្នាំញៀនពីឈ្មោះ ឌូ ដោយបានទិញម្តងៗតម្លៃ ១ម៉ឺនរៀល និង ១៥,០០០៛ ដើម្បីយកមកប្រើប្រាស់តែប៉ុណ្ណោះ។ ខ្ញុំបាទចេះប្រើប្រាស់គ្រឿងញៀនអស់ រយៈពេល ០២ឆ្នាំមកហើយ ហើយក៏បានឈប់ប្រើប្រាស់វិញហើយដែរ ទើបតែមួយរយៈក្រោយនេះខ្ញុំ បាទមានវិបត្តិក្នុងគ្រួសារទើបប្រើប្រាស់វិញ។ ខ្ញុំបាទមិនដែលជួញដូរ ឬចែកចាយនូវថ្នាំញៀននោះទេ ដោយខ្ញុំបាទគ្រាន់តែបានប្រើប្រាស់តែប៉ុណ្ណោះ។ ពេលសមត្ថកិច្ចឃាត់ខ្លួនខ្ញុំបាទពុំបានដកហូតអ្វីនោះ ទេ។

-លោកវរសេនីយ៍ទោ គឹម សាញ់ ជាមន្ត្រីនគរបាលយុត្តិធម៌នៃអធិការដ្ឋាននគរបាលស្រុកសំរោង ខេត្តតាកែវ បានឆ្លើយបំភ្លឺថា: ចំពោះរឿងហេតុនេះ គឺខាងប៉ុស្តិ៍រដ្ឋបាលបានឃាត់ខ្លួនជនជាប់ចោទទាំង ពីរនាក់នេះ និងបានកសាងបញ្ជូនមកការិយាល័យជំនាញរបស់យើងខ្ញុំតែម្តង។ ចំពោះជនជាប់ចោទ

ទាំងពីរនាក់នេះ គឺពុំមាន និងពុំមែនជាមុខសញ្ញាគ្រឿងញៀនសកម្មនៅក្នុងមូលដ្ឋាននោះទេ។ ចំពោះ
រឿងហេតុផ្សេងទៀតខ្ញុំបាទពុំដឹងនោះទេ។

-លោកវរសេនីយ៍ទោ ផាត់ សារ៉ុម ជាមន្ត្រីនគរបាលយុត្តិធម៌នៃអធិការដ្ឋាននគរបាលស្រុកសំរោង ខេត្តតាកែវ បានឆ្លើយបំភ្លឺថា: ចំពោះរឿងហេតុខាងលើនេះ គឺដូចដែលលោកអធិការរងឈ្មោះ គឹម សាញ់ បានលើកឡើងពិតមែន។ ដោយនៅថ្ងៃកើតហេតុ គឺខាងមន្ត្រីប៉ុស្តិ៍រដ្ឋបាលបានឃាត់ខ្លួនជនជាប់ចោទ ទាំងពីរនាក់នេះមកអធិការនគរបាលស្រុកសំរោង ដើម្បីកសាងសំណុំរឿងបញ្ជូនមកតុលាការដើម្បីចាត់ការតាមនីតិវិធី។

-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា: ក្រោយពីបានស្តាប់ចម្លើយសារភាពរបស់ជនជាប់ចោទ ព្រមទាំងបានពិនិត្យលើឯកសារគតិយុត្តិនានារបស់មន្ត្រីនគរបាលយុត្តិធម៌ឃើញថា: នៅថ្ងៃកើតហេតុពិតជាមានជនជាប់ចោទឈ្មោះ ឈួន ហួត ពិតជាបានឱ្យប្រាក់ទៅជនជាប់ចោទឈ្មោះ ផុន សុភាព ចំនួន ១៥,០០០៛ ដើម្បីទៅទិញថ្នាំញៀនចំនួន ០១កញ្ចប់ទម្ងន់ ០,២០ក្រាម យកមកប្រើប្រាស់រួមគ្នាពិតមែន ដោយថ្នាំញៀននោះគេបានទិញពីឈ្មោះ ថុន ពុទ្ធា ហៅ ថុន ម៉ូង និងឈ្មោះ មិន ធូ ហៅ មិនឌូ។ ហេតុនេះ តំណាងអយ្យការនៅតែតម្កល់ការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរទុកជាបានការដដែលនិងសុំឱ្យតុលាការផ្តន្ទាទោសជននេះតាមច្បាប់។

-លោក ម៉ែន វុធ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ ផុន សុភាព ហៅ វ៉េង បានធ្វើសេចក្តីសន្និដ្ឋានថា: ក្រោយពីបានស្តាប់ការដេញដោលនាពេលសវនាការនេះឃើញថា: កូនក្តីរបស់ខ្ញុំបាទបានសារភាពហើយថានៅថ្ងៃកើតហេតុនោះ គឺគាត់បានជិះម៉ូតូទៅទិញថ្នាំញៀនក្នុងគោលបំណងដើម្បីយកមកប្រើប្រាស់ពិតមែន ដោយកូនក្តីរបស់ខ្ញុំបាទរួមជាមួយនឹងឈ្មោះ ឈួន ហួត គឺពួកគេពុំមានចេតនាយកថ្នាំញៀននោះទៅធ្វើការជួញដូរបន្តទៀតនោះទេ។ ហើយមូលហេតុដោយសារកត្តាស្ថានភាពជីវភាពគ្រួសាររបស់កូនក្តីខ្ញុំបាទឈ្មោះ ផុន សុភាព មានឪពុកម្តាយ ប្រពន្ធ និងកូនមានអាយុពីរខែត្រូវរកស៊ីចិញ្ចឹម ព្រមទាំងឈ្មោះ ឈួន ហួត គឺមានឪពុកដែលមានជំងឺត្រូវនៅផ្ទះត្រូវចិញ្ចឹម និងមើលថែរ ហើយមួយវិញទៀតឃើញថាសាក្សីដែលជាមន្ត្រីនគរបាលយុត្តិធម៌បានមកឆ្លើយបំភ្លឺនេះ គឺមានភាពស្រពិចស្រពិលមិនច្បាស់លាស់ក្នុងការដាក់បន្ទុកមកលើកូនក្តីរបស់ខ្ញុំបាទនោះដែរ។ ហេតុដូច្នេះខ្ញុំបាទសូមស្នើសុំដល់តុលាការមេត្តាពិចារណា និងលើកលែងទោស ឬបន្ធូរបន្ថយទោសដល់កូនក្តីខ្ញុំបាទផង។

-សម្តីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ ផុន សុភាព ហៅ វ៉េង ថា: ខ្ញុំបាទសំណូមពរសុំឱ្យតុលាការមេត្តាបន្ធូរបន្ថយទោសដល់រូបខ្ញុំផង ព្រោះខ្ញុំបានដឹងពីកំហុសហើយ និងសូមសន្យាថាពេលចេញពីពន្ធនាគារខ្ញុំនឹងមិនប្រព្រឹត្តអំពើបែបនេះទៀតទេ មួយវិញទៀតសព្វថ្ងៃនេះខ្ញុំបាទមានឪពុកម្តាយ និងមានប្រពន្ធ ព្រមទាំងកូនតូចដែលមានអាយុទើបតែពីរខែត្រូវចិញ្ចឹមផងដែរ។

-សម្តីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ ឈួន ហួត ថា: ខ្ញុំបាទសំណូមពរសុំឱ្យតុលាការមេត្តាបន្ធូរបន្ថយទោសដល់រូបខ្ញុំផង ព្រោះខ្ញុំបានដឹងពីកំហុសហើយ និងសូមសន្យាថាពេលចេញពីពន្ធនាគារ

ឈប់ពាក់ព័ន្ធនឹងគ្រឿងញៀននេះទៀតហើយ មួយវិញទៀតសព្វថ្ងៃនេះខ្ញុំបាទមានឪពុកដែលមានជំងឺស សែប្រសាទម្នាក់ត្រូវចិញ្ចឹម និងមើលថែរផងដែរ។

-ក្រោយពីបាន ស្តាប់ចម្លើយ-អំណានចម្លើយរបស់ជនជាប់ចោទ។

-ក្រោយពីបាន ស្តាប់ចម្លើយបំភ្លឺរបស់សាក្សីដែលជាមន្ត្រីនគរបាលយុត្តិធម៌។

-ក្រោយពីបាន ពិនិត្យឯកសារ និងភស្តុតាងពាក់ព័ន្ធក្នុងសំណុំរឿង។

-ក្រោយពីបាន ស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ។

-ក្រោយពីបាន ស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

-ក្រោយពីបាន ស្តាប់សំណូមពរចុងក្រោយរបស់ជនជាប់ចោទ។

-ក្រោយពីបាន ពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

## សំអាងហេតុ

១-ក្រោយពីធ្វើការស៊ើបសួរតាមនីតិវិធីចប់សព្វគ្រប់ហើយ ចៅក្រមស៊ើបសួរបានចេញដីកាដំណោះស្រាយលេខៈ ១៩/២០២១ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២២ ដោយបានបញ្ជូនជនត្រូវចោទឈ្មោះ ផុន សុភាព និងឈ្មោះ ឈួន ហួត មកជំនុំជម្រះពីបទៈ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងជនជាប់ចោទឈ្មោះ ផុន ពុទ្ធា ហៅ ម៉ូង និងឈ្មោះ មិន ធូ ហៅ ខូ មកជំនុំជម្រះពីបទៈ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ ផុន សុភាព ហៅ វ៉េង និងឈ្មោះ ឈួន ហួត ព្រមទាំងតាមរបាយការណ៍របស់អធិការដ្ឋាននគរបាលស្រុកសំរោង នៃស្នងការដ្ឋាននគរបាលខេត្តតាកែវ បញ្ជាក់ឱ្យឃើញថាៈ កាលពីថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២១ ស្ថិតនៅចំណុចភូមិពន្លឺ ឃុំជំរះពេន ស្រុកសំរោង ខេត្តតាកែវ មានជនជាប់ចោទឈ្មោះ ឈួន ហួត បានឱ្យប្រាក់ទៅជនជាប់ចោទឈ្មោះ ផុន សុភាព ហៅ វ៉េង ចំនួន ១៥,០០០រៀល ដើម្បីទៅទិញថ្នាំញៀនពីឈ្មោះ ផុន ពុទ្ធា ហៅ ផុន ម៉ូង និងឈ្មោះ មិន ធូ ហៅ មិន ខូ បានថ្នាំញៀនចំនួន ០១កញ្ចប់តូចទម្ងន់ ០,២០ (សូន្យក្បៀសម្ភៃ) ក្រាម យកមកទុកនៅផ្ទះរបស់ឈ្មោះ ផុន សុភាព ហៅ វ៉េង ដើម្បីប្រើប្រាស់រួមគ្នាជាមួយនឹងឈ្មោះ ឈួន ហួត ក្រោយមកសមត្ថកិច្ចប៉ុស្តិ៍នគរបាលឃុំជំរះពេន បានចុះទៅដល់ផ្ទះរបស់ជនជាប់ចោទឈ្មោះ ផុន សុភាព ហៅ វ៉េង ដោយបានឆែកឆេររកឃើញថ្នាំញៀចំនួន ០១កញ្ចប់តូចនៅផ្ទះរបស់គេ និងបានបន្តឃាត់ខ្លួនជនជាប់ចោទឈ្មោះ ឈួន ហួត ដែលជាអ្នកប្រើប្រាស់គ្រឿងញៀនជាមួយគ្នា រួចហើយសមត្ថកិច្ចបានកសាងសំណុំរឿងបញ្ជូនមកតុលាការដើម្បីចាត់ការតាមនីតិវិធីច្បាប់។

៣-ផ្អែកតាមកំណត់ហេតុធ្វើតេស្តស្វែងរកសារធាតុញៀនរបស់អធិការដ្ឋាននគរបាលស្រុកសំរោង នៃស្នងការដ្ឋាននគរបាលខេត្តតាកែវចុះថ្ងៃ១៤ ខែតុលា ឆ្នាំ២០២១ ឃើញថាៈ ជនជាប់ចោទឈ្មោះ ផុន

សុភាព ហៅ វ៉េង និងឈ្មោះ ឈួន ហួត ពិតជាមានផ្ទុកនូវសារធាតុញៀននៅក្នុងខ្លួនរបស់ពួកគេពិតមែន។

៤-ផ្អែកតាមកំណត់ហេតុធ្វើតេស្តជំហ៊ានដំបូងចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២១ របស់ការិយាល័យគ្រឿងញៀននៃស្នងការដ្ឋាននគរបាលខេត្តតាកែវ បញ្ជាក់ឱ្យឃើញថា: ម្សៅក្រាមសថ្លាសង្ស័យជាសារធាតុញៀនចំនួន ០១កញ្ចប់តូចដែលមានទម្ងន់ ០,២០ (សូន្យក្បៀសម្ភៃ) ក្រាម ដែលសមត្ថកិច្ចដកហូតបានពីជនជាប់ចោទឈ្មោះ ផុន សុភាព ហៅ វ៉េង និងឈ្មោះ ឈួន ហួត ជាថ្នាំញៀនប្រភេទមេតំហ្វេតាមីន (ICE) ចេញជាពណ៌លឿងទុំជាសារធាតុនៃគ្រឿងញៀនប្រាកដមែន។

៥-យល់ឃើញថា: អំពើរបស់ជនជាប់ចោទឈ្មោះ ផុន សុភាព ហៅ វ៉េង និងឈ្មោះ ឈួន ហួត ដែលបាននាំគ្នាទិញថ្នាំញៀនពីឈ្មោះ ផុន ពុទ្ធា ហៅ ផុន ម៉ុង និងឈ្មោះ មិន ធូ ហៅ មិន ឌូ ដើម្បីយកមកទុកសម្រាប់ប្រើប្រាស់ និងបានប្រើប្រាស់គ្រឿងញៀនរួមគ្នា ដោយចេតនាទុច្ចរិត គឺជាអំពើដែលធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ និងសន្តិសុខសង្គម ជាពិសេសធ្វើឱ្យប៉ះពាល់ដល់សុខភាពខ្លួនឯងផងដែរ ហើយអំពើនោះទៀតសោតត្រូវបានច្បាប់ហាមឃាត់ និងកំណត់ថាជាបទៈ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៦-យល់ឃើញថា: អំពើរបស់ជនជាប់ចោទឈ្មោះ ផុន ពុទ្ធា ហៅ ផុន ម៉ុង និងឈ្មោះ មិន ធូ ហៅ មិន ឌូ ដែលបាននាំគ្នាធ្វើសកម្មភាពចែកចាយថ្នាំញៀនឱ្យទៅឈ្មោះ ផុន សុភាព និងឈ្មោះ ឈួន ហួត ដើម្បីយកទៅប្រើប្រាស់បន្ត ដោយចេតនាទុច្ចរិត គឺជាអំពើដែលធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ និងសន្តិសុខសង្គម ជាពិសេសធ្វើឱ្យប៉ះពាល់ដល់សុខភាពសរបស់អ្នកដទៃទៀតផង ហើយអំពើនោះទៀតសោតត្រូវបានច្បាប់ហាមឃាត់ និងកំណត់ថាជាបទៈ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៧-យល់ឃើញថា: ជនជាប់ចោទឈ្មោះ ផុន សុភាព ហៅ វ៉េង ភេទប្រុស អាយុ១៧ឆ្នាំ (កើតថ្ងៃទី១៦ ខែមេសា ឆ្នាំ២០០៤) គឺជាអនីតិជន ប៉ុន្តែមានស្មារតីយល់ដឹងអាចទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត។

៨-យល់ឃើញថា: ជនជាប់ចោទឈ្មោះ ឈួន ហួត ភេទប្រុស អាយុ២១ឆ្នាំ, ឈ្មោះ ផុន ពុទ្ធា ហៅ ផុន ម៉ុង ភេទប្រុស កើតថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩២ និងឈ្មោះ មិន ធូ ហៅ មិន ឌូ ភេទប្រុស កើតថ្ងៃទី០៨ ខែមករា ឆ្នាំ១៩៨៩ គឺជានីតិជនដែលមានស្មារតីយល់ដឹង និងមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសព្រហ្មទណ្ឌដែលកើតចេញពីអំពើដែលខ្លួនបានប្រព្រឹត្ត។

៩-យល់ឃើញថា: មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ ផុន សុភាព ហៅ វ៉េង ភេទប្រុស អាយុ១៧ឆ្នាំ (កើតថ្ងៃទី១៦ ខែមេសា ឆ្នាំ២០០៤) និងឈ្មោះ ឈួន ហួត ភេទប្រុស អាយុ២១ឆ្នាំ ពីបទៈ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិពន្លឺ ឃុំជំរះពេន ស្រុកសំរោង ខេត្តតាកែវ

កាលពីថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២១ បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១០-យល់ឃើញថា: មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ ផុន ពុទ្ធា ហៅ ផុន ម៉ូង ភេទប្រុស កើតថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩២ និងឈ្មោះ មិន ធូ ហៅ មិន ខូ ភេទប្រុសកើតថ្ងៃទី០៨ ខែមករា ឆ្នាំ១៩៨៩ ពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិពន្លឺ ឃុំជំរះពេន ស្រុកសំរោង ខេត្តតាកែវ កាលពីថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២១ បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១១-យល់ឃើញថា: ចំពោះថ្នាំញៀនដែលសមត្ថកិច្ចដកហូតពីជនជាប់ចោទឈ្មោះ ផុន សុភាព ហៅ វ៉េង និងឈ្មោះ ឈួន ហួត បានចូលលុយគ្នាទិញបានចំនួន ០១កញ្ចប់ មានទម្ងន់ ០,២០ (សូន្យក្បៀសម្ភៃ) ក្រាម នាំឱ្យបទល្មើសដែលត្រូវផ្តន្ទាទោស គឺជាបទ: រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៤ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១២-យល់ឃើញថា: ចំពោះថ្នាំញៀនដែលជនជាប់ចោទឈ្មោះ ផុន ពុទ្ធា ហៅ ផុន ម៉ូង និងឈ្មោះ មិន ធូ ហៅ មិន ខូ បានលក់ឱ្យទៅឈ្មោះ ផុន សុភាព ហៅ វ៉េង និងឈ្មោះ ឈួន ហួត មានចំនួន ០១ កញ្ចប់ មានទម្ងន់ ០,២០ (សូន្យក្បៀសម្ភៃ) ក្រាម នាំឱ្យបទល្មើសដែលត្រូវផ្តន្ទាទោស គឺជាបទ: រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១៣-តាមការប្តឹងសុំរបស់តំណាងអយ្យការឱ្យផ្តន្ទាទោសជនជាប់ចោទឈ្មោះ ផុន សុភាព ហៅ វ៉េង និងឈ្មោះ ឈួន ហួត ពីបទ: រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន, ឈ្មោះ ផុន ពុទ្ធា ហៅ ផុន ម៉ូង និងឈ្មោះ មិន ធូ ហៅ មិន ខូ ពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន។ តុលាការយល់ឃើញថា: ការប្តឹងសុំនេះមានមូលដ្ឋានតាមផ្លូវច្បាប់គ្រប់គ្រាន់ គប្បីសម្រេចតាមការប្តឹងសុំ។

១៤-សេចក្តីសន្និដ្ឋានសុំរបស់លោក ម៉ែន វុធ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ ផុន សុភាព ហៅ វ៉េង ដោយស្នើសុំដល់តុលាការមេត្តាពិចារណា និងលើកលែងទោស ឬបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនឈ្មោះ ផុន សុភាព ហៅ វ៉េង និងឈ្មោះ ឈួន ហួត។ ហេតុនេះគប្បីតុលាការទទួលយកមកពិចារណា។

១៥-យល់ឃើញថា: នាពេលសវនាការជំនុំជម្រះជនជាប់ចោទឈ្មោះ ឈួន ហួត មានការភ្ញាក់រលឹក និងបានសារភាពទទួលស្គាល់នូវកំហុសរបស់ខ្លួនដែលបានប្រព្រឹត្ត និងសន្យាថាឈប់ប្រព្រឹត្តអំពើដែលខុសច្បាប់ទៀតហើយដែរ មួយវិញទៀតឃើញថាថ្នាំញៀនដែលបានដកហូតពីជនជាប់ចោទនេះមានបរិមាណត្រឹមតែ ០,២០ (សូន្យក្បៀសម្ភៃ) ក្រាម តែប៉ុណ្ណោះ។ ហេតុនេះគប្បីតុលាការសម្រេចផ្តន្ទាទោសលើជននេះក្នុងកម្រិតអប្បបរមានៃទោសដាក់ពន្ធនាគារចំនួន ០២ (ពីរ) ឆ្នាំនិងប្រកាសមួយផ្នែកឱ្យអនុវត្តទោសក្នុងពន្ធនាគារចំនួន ០១ (មួយ) ឆ្នាំ ទោសដែលនៅសល់ត្រូវអនុវត្តការព្យួរទោសសាកល្បង

តាមបញ្ញត្តិមាត្រា ១១៧ នៃក្រមព្រហ្មទណ្ឌ និងអាចឱ្យជនជាប់ចោទស្ថិតនៅក្រោមវិធានការត្រួតពិនិត្យ និងគោរពនូវការតព្វកិច្ចដោយឡែកស្របតាមបញ្ញត្តិមាត្រា ១១៨, ១១៩ និងមាត្រា ១២០ នៃក្រមព្រហ្មទណ្ឌ។

១៦-យល់ឃើញថា: នាពេលសវនាការជំនុំជម្រះជនជាប់ចោទឈ្មោះ ផុន សុភាព ហៅ វ៉េង មានការភ្ញាក់រលឹក និងបានសារភាពទទួលស្គាល់នូវកំហុសរបស់ខ្លួនដែលបានប្រព្រឹត្ត និងសន្យាថាឈប់ប្រព្រឹត្តអំពើដែលខុសច្បាប់ទៀតហើយដែរ មួយវិញទៀតឃើញថាថ្នាំញៀនដែលបានដកហូតពីជនជាប់ចោទនេះមានបរិមាណត្រឹមតែ ០,២០ (សូន្យក្បៀសម្ភៃ) ក្រាម តែប៉ុណ្ណោះ មួយវិញទៀតបើគិតមកដល់ថ្ងៃកើតហេតុថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២១ ជនជាប់ចោទឈ្មោះ ផុន សុភាព ហៅ វ៉េង ភេទប្រុស អាយុ ១៧ឆ្នាំ (កើតថ្ងៃទី១៦ ខែមេសា ឆ្នាំ២០០៤) គឺនៅជាអនីតិជននៅឡើយ។ ហេតុដូច្នេះគប្បីតុលាការសម្រេចផ្តន្ទាទោសលើជននេះក្នុងកម្រិតអប្បបរមានៃទោសដាក់ពន្ធនាគារចំនួន ០១ (មួយ) ឆ្នាំ ស្របតាមបញ្ញត្តិមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ។

១៧-ផ្អែកតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ ឈួន ហួត និងឈ្មោះ ផុន សុភាព ហៅ វ៉េង បានឆ្លើយថានៅថ្ងៃកើតហេតុ គឺពួកខ្លួនបានទិញថ្នាំញៀនពីឈ្មោះ ថុន ពុទ្ធា ហៅ ថុន ម៉ុង និងឈ្មោះ មិន ធូ ហៅ មិន ឌូ បានចំនួន ០១កញ្ចប់តូចទម្ងន់ ០,២០ (សូន្យក្បៀសម្ភៃ) ក្រាម។ ក្នុងករណីនេះតុលាការយល់ឃើញថា: ចំពោះថ្នាំញៀនដែលជនជាប់ចោទទាំងពីរនាក់ខាងលើបានលក់ឱ្យទៅឈ្មោះ ឈួន ហួត និងឈ្មោះ ផុន សុភាព ហៅ វ៉េង មានបរិមាណត្រឹមតែ០,២០ (សូន្យក្បៀសម្ភៃ) ក្រាមតែប៉ុណ្ណោះ។ ហេតុដូច្នេះ គប្បីតុលាការសម្រេចផ្តន្ទាទោសលើជនជាប់ចោទទាំងពីរនាក់នេះក្នុងកម្រិតអប្បបរមានៃទោសដាក់ពន្ធនាគារចំនួន ០២ (ពីរ) ឆ្នាំ។

១៨-យល់ឃើញថា: ចៅក្រមស៊ើបសួរបានចេញដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ: ៣០៧/២០២១ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២១ លើជនជាប់ចោទឈ្មោះ ថុន ពុទ្ធា ហៅ ថុន ម៉ុង ភេទប្រុស កើតថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩២ និងដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ: ៣០៨/២០២១ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២១ លើជនជាប់ចោទឈ្មោះ មិន ធូ ហៅ មិន ឌូ ភេទប្រុស កើតថ្ងៃទី០៨ ខែមករា ឆ្នាំ១៩៨៩ ហើយជនជាប់ចោទទាំងពីរនាក់នេះត្រូវបានតុលាការសម្រេចផ្តន្ទាទោសតាមអំណាចសាលក្រមខាងលើនេះហើយ។ ហេតុដូច្នេះ គប្បីតុលាការសម្រេចចេញដីកាបញ្ឈប់អានុភាពដីកាបង្គាប់ឱ្យចាប់ខ្លួនរបស់ចៅក្រមស៊ើបសួរ។

១៩-យល់ឃើញថា: ជនជាប់ចោទឈ្មោះ ថុន ពុទ្ធា ហៅ ថុន ម៉ុង និងឈ្មោះ មិន ធូ ហៅ មិន ឌូ ត្រូវបានតុលាការរកឃើញថាមានពិរុទ្ធភាពពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ហើយត្រូវបានតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធគារលើសពី ១ (មួយ) ឆ្នាំដោយគ្មានការព្យួរ។ មួយវិញទៀតដើម្បីធានាឱ្យជនជាប់ចោទខាងលើអនុវត្តទោសតាមអំណាចសាលក្រមនេះ ក៏ដូចជាដើម្បីរក្សាសណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ និងសន្តិសុខសង្គមឱ្យបានល្អ។ គប្បីតុលាការចេញដីកាបង្គាប់ឱ្យចាប់ខ្លួនលើជនជាប់ចោទខាងលើនេះតាមបញ្ញត្តិមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២០-យល់ឃើញថា: វត្ថុតាងមានម្សៅក្រាមប្រភេទមេតំហ្វេតាមីន (ICE) ចំនួន ០១កញ្ចប់តូច ទម្ងន់ ០,២០ (សូន្យក្បៀសម្ភៃ) ក្រាម ជាវត្ថុតាងដែលជាប់ពាក់ព័ន្ធនឹងបទល្មើសខាងលើ គប្បីតុលាការសម្រេចរឹបអូសតាមបញ្ញត្តិមាត្រា ៩៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**ហេតុដូច្នេះសម្រេច**

១-ផ្តន្ទាទោសលើជនជាប់ចោទ:

១.១-ឈ្មោះ ផុន សុភាព ហៅ វេង ភេទប្រុស អាយុ១៧ឆ្នាំ (កើតថ្ងៃទី១៦ ខែមេសា ឆ្នាំ២០០៤) (អត្តសញ្ញាណខាងលើ) ដាក់ពន្ធនាគារកំណត់ចំនួន ០១ (មួយ) ឆ្នាំ ពីបទ: រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិពន្លឺ ឃុំជំរះពេន ស្រុកសំរោង ខេត្តតាកែវ កាលពីថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២១ បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៤ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១.២-ឈ្មោះ ឈួន ហួត ភេទប្រុស អាយុ២១ឆ្នាំ (អត្តសញ្ញាណខាងលើ) ដាក់ពន្ធនាគារកំណត់ចំនួន ០២ (ពីរ) ឆ្នាំ តែទោសនេះត្រូវអនុវត្តទោសក្នុងពន្ធនាគារចំនួន ០១ (មួយ) ឆ្នាំ ទោសដែលនៅសល់ត្រូវអនុវត្តការព្យួរទោសសាកល្បងក្នុងរយៈពេល ០២ (ពីរ) ឆ្នាំ ដោយជនជាប់ចោទត្រូវគោរពនូវវិធានការត្រួតពិនិត្យ និងកាតព្វកិច្ចដោយឡែកមួយចំនួនដូចខាងក្រោម:

**ក-វិធានការត្រួតពិនិត្យ:**

-ត្រូវគោរពតាមដីកាកោះរបស់ព្រះរាជអាជ្ញា ឬរបស់បុគ្គលដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឲ្យ

-ត្រូវមកទទួលនូវការមកពិនិត្យមើលរបស់បុគ្គលដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឲ្យ

-ត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញាអំពីការផ្លាស់ប្តូរអាសដ្ឋានរបស់ខ្លួន

-ត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញាអំពីការផ្លាស់ប្តូរមុខរបររបស់ខ្លួន

-ត្រូវតែមានការអនុញ្ញាតពីព្រះរាជអាជ្ញាមុនពេលធ្វើដំណើរទៅបរទេស។

**ខ-កាតព្វកិច្ចដោយឡែក:**

-មិនត្រូវសេពគប់បនល្បែងណាមួយ

-មិនត្រូវកាន់កាប់ ឬយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ

-មិនត្រូវសេពគប់ ប្រើប្រាស់ និងពាក់ព័ន្ធគ្រឿងញៀនគ្រប់ប្រភេទ។

ពីបទ: រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិពន្លឺ ឃុំជំរះពេន ស្រុកសំរោង ខេត្តតាកែវ កាលពីថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២១ បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៤ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១.៣-ឈ្មោះ ថុន ពុទ្ធា ហៅ ថុន ម៉ុង ភេទប្រុស កើតថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩២ (អត្តសញ្ញាណខាងលើ) ឈ្មោះ មិន ធូ ហៅ មិន ខូ ភេទប្រុសកើតថ្ងៃទី០៨ ខែមករា ឆ្នាំ១៩៨៩ (អត្ត

សញ្ញាណខាងលើ) ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់ចំនួន ០២ (ពីរ) ឆ្នាំ ពីបទៈ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិពន្លឺ ឃុំជំរះពេន ស្រុកសំរោង ខេត្តតាកែវ កាលពីថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២១ បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២-បញ្ឈប់អានុភាពនៃដីកាបង្គាប់ឱ្យចាប់ខ្លួន[redacted]សួរលេខៈ ៣០៧/២០២១ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២១ លើជនជាប់ចោទឈ្មោះ ថុន ពុទ្ធា ហៅ ថុន ម៉ូង ភេទប្រុស កើតថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩២ និងដីកាបង្គាប់ឱ្យចាប់ខ្លួនលេខៈ ៣០៨/២០២១ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២១ លើជនជាប់ចោទឈ្មោះ មិន ធូ ហៅ មិន ឌូ ភេទប្រុស កើត[redacted]ាំ១៩៨៩។

៣-ចេញដីកាបង្គាប់ឱ្យចាប់ខ្លួនលើជនជាប់ចោទឈ្មោះ [redacted]ថុន ម៉ូង ភេទប្រុស កើតថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩២ (អត្តសញ្ញាណខាងលើ) និងឈ្មោះ មិន ធូ ហៅ មិន ឌូ ភេទប្រុស កើតថ្ងៃទី០៨ ខែមករា ឆ្នាំ១៩៨៩ (អត្តសញ្ញាណខាងលើ) តាមបញ្ញត្តិមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៤-វត្ថុតាងរួមមានៈ ម្សៅក្រាមប្រភេទមេតំហ្វេតាមីន (ICE) ចំនួន ០១កញ្ចប់តូច ទម្ងន់ ០,២០ (សូន្យក្បៀសម្ភៃ) ក្រាម សម្រេចរឹបអូស។

-សាលក្រមនេះជំនុំជម្រះជាសាធារណៈនាថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២២ និងប្រកាសជាសាធារណៈនៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២ នៅសាលាដំបូងខេត្តតាកែវ ចំពោះមុខជនជាប់ចោទឈ្មោះ ផុន សុភាព និងឈ្មោះ ឈួន ហួត និងកំបាំងមុខជនជាប់ចោទឈ្មោះ ថុន ពុទ្ធា ហៅ ថុន ម៉ូង និងឈ្មោះ មិន ធូ ហៅ មិន ឌូ។

-ទុកសិទ្ធិឱ្យប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |
| ស៊ឹម សុផល | គុជ តារ៉ា | រិន តិរុណា | ហុង សុខហ៊ាង |

(បានថតចម្លងត្រឹមត្រូវតាមលិខិតដើម)

ថ្ងៃចន្ទ ៦រោច ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

តាកែវ, ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២

**ក្រឡាបញ្ជីសវនាការ**

**ស៊ឹម សុផល**

បានឃើញ

តាកែវ, ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

**ហុង សុខហ៊ាង**